

នគរទ្រង់ត្រូវបានដណ្ដើមយក តែទ្រង់នឹងយកមកវិញ

# មហាក្សត្រ ដ៏មានសិរីល្អ

ដំណើររឿង និងខ្លឹមសារសំខាន់ៗ
នៅក្នុងព្រះគម្ពីរ
សង្ខេបជា៧០ភាគ


និពន្ធដោយៈ
ប៉ុល ដាន ប្រាមសិន
P. D. BRAMSEN

គូររូបដោយៈ
អាមីនដា សាន ម៉ាទីន
ARMINDA SAN MARTÍN


ចូរទស្សនាភាពយន្ត
មហាក្សត្រ ដ៏មាន សិរីល្អ
ជាច្រើនភាសា
www.ikingofglory.com

មនុស្សគ្រប់វ័យចូលចិត្តរឿងស្នេហា និងការជួយរំដោះដែលមានចុងបញ្ចប់ដ៏ល្អ ហើយសាច់រឿងនិយាយអំពីការល្អឈ្នះលើការអាក្រក់។ កំណត់ត្រារបស់ពួកហោរាពីបុរាណតំណាលនូវរឿងដើម អំពីសេចក្ដីស្រឡាញ់ និងការសង្គ្រោះគឺការល្អយកឈ្នះលើការអាក្រក់ ក្នុងរបៀបដ៏អស្ចារ្យបំផុតដែលនឹកស្មានមិនដល់។

ដកស្រង់ចេញពីបទគម្ពីររបស់ពួកហោរា

# មហាក្សត្រដ៏មានសិរីល្អ

រឿងពីបុរាណនេះ មានតួអង្គដ៏អស្ចារ្យ និងសាច់រឿងដ៏គួរឲ្យចាប់អារម្មណ៍ គឺនិយាយអំពីព្រះមហាក្សត្រមួយអង្គ និងផែនការដ៏អាចកំចាំងរបស់ទ្រង់ដើម្បីសង្គ្រោះរាស្ត្រដែលបានបះបោរឲ្យរួចពីនគរនៃសេចក្ដីងងឹត ហើយជួយពួកគេឲ្យមានលក្ខណ:ស័ក្តិសមនឹងរស់នៅជាមួយទ្រង់ក្នុងនគរនៃពន្លឺដោយសុភមង្គលជារៀងរហូត។

ប៉ុន្តែ តើរឿងនេះពិតជាបានកើតឡើងមែនឬ? ឬក៏វាគ្រាន់តែជារឿងប្រឌិតប៉ុណ្ណោះ? ការតំណាលរឿងក្នុងលក្ខណ:ជាបទបង្ហាញនេះ នឹងនាំមិត្តអ្នកអានឲ្យរកឃើញចម្លើយយ៉ាងច្បាស់លាស់។

ចូរពិសោធន៍រឿងនេះមើល ហើយជួបព្រះមហាក្សត្រចុះ! បន្ទាប់មក ចូរសម្រេចចិត្តចុះ។



## ចំណុចពិសេស

- ដំណើររឿង និងសារតាមរយ:ពួកហោរាក្នុង៧០ភាគ
- រូបគំនូរដ៏ស្រស់ស្អាតក្នុង៧០ទំព័រ
- ពាក្យសាមញ្ញៗងាយស្រួលយល់
- សេចក្ដីពិតដ៏ជ្រាលជ្រៅ
- សេចក្ដីបន្ថែមពិសេស
- សំណួររំឭក
- ការណែនាំអំពីភាពយន្ត
- សម្រាប់មនុស្សគ្រប់វ័យ និងគ្រប់ជាតិសាសន៍

ISBN 978-9924-9062-5-4
9 789924 906254 >

www.ikingofglory.com

នគរទ្រង់ត្រូវបានដណ្ដើមយក
តែទ្រង់នឹងយកមកវិញ

# មហាក្សត្រ ដ៏មានសិរីល្អ



ដកស្រង់ចេញពី៖
ព្រះគម្ពីរបរិសុទ្ធ

និពន្ធដោយ៖
ប៉ុល ដាន ប្រាមសិន (P.D. Bramsen)

គូររូបដោយ៖
អាមីនដា សាន ម៉ាទីន (Arminda San Martín)

EMMAUS CAMBODIA
ROCK INTERNATIONAL
MILLSTONE

# មហាក្សត្រដ៏មានសិរីល្អ

និពន្ធដោយ៖ ប៉ុល ដាន ប្រាមសិន **(By P.D. Bramsen)**
គូររូបដោយ៖ អាមីនដា សាន ម៉ាទីន **(Illustrated by Arminda San Martín)**

រក្សាសិទ្ធិ © ២០១១, ២០១៥, ២០១៨, ២០២០, ២០២៣, **២០២៥** ដោយអង្គការ ROCK International។ រក្សាសិទ្ធិគ្រប់បែបយ៉ាង។
ការបោះពុម្ពជាភាសាខ្មែរ © ២០២៥ ដោយអង្គការអេម៉ោស កម្ពុជា ដោយមានការអនុញ្ញាតពីអង្គការ ROCK International។

KING of GLORY Copyright © 2011, 2015, 2018, 2020, 2023, **2025** ROCK International. All rights reserved.
Khmer edition © 2025 Translated & published by Emmaus Cambodia with permission from ROCK International.
Khmer Edition ISBN 978-9924-9062-5-4

អត្ថបទព្រះគម្ពីរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ឆ្នាំ១៩៥៤, ១៩៦២ ហើយខគម្ពីរមួយចំនួនតូចបានដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធកែសម្រួល ២០១៦ (គកស១៦) និងព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន ២០០៥ (គខប)។ © រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល ដកស្រង់ដោយមានការអនុញ្ញាត។ យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរតាមព្រះគម្ពីរខាងលើ ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូល យើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

Unless otherwise marked, Scripture quotations used in this book are taken from Khmer Old Version (KHOV) © 1954, 1962. A few verses are taken from Revised Khmer Old Version © 2016 and Khmer Standard Version Bible © 2005. Used by Permission of United Bible Societies. All rights reserved.

**អំពីអ្នកនិពន្ធ៖** លោកគ្រូ ប៉ុល ដាន ប្រាមសិន (PAUL DAN BRAMSEN) បានកើតនៅរដ្ឋកាលីហ្វ័រញ៉ា។ គាត់ និងភរិយាគាត់បានចិញ្ចឹមកូនបីនាក់ នៅប្រទេសសេណេហ្គាល់នៃអាហ្វ្រិកខាងលិច នៅខាងចុងវាលខ្សាច់សាហារ៉ា ដែលមានប្រជាជនភាគច្រើនកាន់តាមសាសនាឥស្លាម។ លោកគ្រូ ប្រាមសិន បាននិពន្ធ ហើយបង្កើតធនធាន ដែលរៀបរាប់រឿង និងបកស្រាយសាររបស់ពួកហោរានៅក្នុងព្រះគម្ពីរតាមលំដាប់លំដោយ សម្រាប់អស់អ្នកអាន និងអ្នកស្តាប់នៅជុំវិញពិភពលោក។ ស្នាដៃរបស់លោក រួមមាន៖ *THE WAY OF RIGHTEOUSNESS* (ជាស៊េរីផ្សព្វផ្សាយតាមវិទ្យុ ដែលមាន១០០ភាគ សរសេរជាភាសាវ៉ូឡូហ្វនៃប្រទេសសេណេហ្គាល់ ដែលឥឡូវនេះត្រូវបានបកប្រែជាច្រើនភាសាបន្ថែមទៀត) សៀវភៅ *ONE GOD ONE MESSAGE* និងភាពយន្ត *មហាក្សត្រដ៏មានសិរីល្អ*។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖ WWW.ROCKINTL.ORG/RESOURCES

**អំពីវិចិត្រករ៖** អ្នកស្រី អាមីនដា សាន ម៉ាទីន (Arminda San Martin) ដែលមកពីប្រទេសអាហ្សង់ទីនបានសរសេរថា៖ “តាំងពីពេលដែលខ្ញុំអាចចងចាំបាន ខ្ញុំចូលចិត្តគូររូបជានិច្ច។ ជំនាញដែលព្រះជាម្ចាស់បានប្រទានឲ្យខ្ញុំទាំងអស់ ត្រូវបានប្រើប្រាស់នៅក្នុងការគូររូបភាពសម្រាប់សៀវភៅ មហាក្សត្រដ៏មានសិរីល្អ នេះ។ សម្រាប់ខ្ញុំ គម្រោងនេះ គឺដូចជាសុបិនដែលក្លាយជាការពិត ហើយក៏ជាឱកាសដែលមានតែម្តងគត់ នៅក្នុងមួយជីវិតរបស់ខ្ញុំផងដែរ។ ខ្ញុំអរព្រះគុណដល់ព្រះអម្ចាស់សម្រាប់ឱកាសនេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកគ្រូ ប៉ុល ប្រាមសិន ដែលមិនត្រឹមតែជាអ្នកនិពន្ធដឹកនាំដោយព្រះវិញ្ញាណប៉ុណ្ណោះទេ តែក៏ជាអ្នកកែសម្រួលដ៏ឆ្នើមម្នាក់ផងដែរ។ ខ្ញុំសូមអរព្រះគុណដល់ព្រះជាម្ចាស់ចំពោះចំណេះដឹងរបស់លោក និងការណែនាំដ៏ឥតឈប់ឈររបស់លោក ដើម្បីសម្រេចលទ្ធផលចុងក្រោយនេះ“។ បច្ចុប្បន្ន អ្នកស្រី អាមីនដា ធ្វើការជាវិចិត្រករក្នុងវិស័យបោះពុម្ពយ៉ាងសកម្ម។

បោះពុម្ពនៅសាធារណរដ្ឋកូរ៉េ





# សម្រាប់សិរីល្អរបស់ព្រះមហាក្សត្រ
# និងសម្រាប់កុមារទាំងឡាយនៃគ្រប់ជាតិសាសន៍
# ឲ្យបានទទួលព្រះពរ





*"ស្លូត? តើអ្នកណាបាននិយាយថាស្លូត?*
*ពិតណាស់ ទ្រង់មិនស្លូតទេ ប៉ុន្តែទ្រង់គឺល្អ។*
*ខ្ញុំប្រាប់អ្នករាល់គ្នាឲ្យដឹងថា ទ្រង់គឺជាព្រះមហាក្សត្រ។"*

— ដកស្រង់ចេញពីរឿង *The Lion, the Witch, and the Wardrobe*
ដែលនិពន្ធដោយលោក C.S. Lewis











# មាតិកា


**បុព្វកថារបស់អ្នកនិពន្ធ** ........ ៨

**សេចក្តីផ្តើម** ........ ១១

១ • ព្រះមហាក្សត្រ និងនគររបស់ទ្រង់

២ • ព្រះមហាក្សត្រ និងពួកហោរារបស់ទ្រង់

៣ • ព្រះមហាក្សត្រ និងសកលលោករបស់ទ្រង់

**ផ្នែកទី១ – ព្រះមហាក្សត្រមានបន្ទូលទុកជាមុនអំពីផែនការរបស់ទ្រង់** ........ ១៩

| | |
|---|---|
| ៤ • ថ្ងៃទីមួយ | លោកុប្បត្តិ ១ |
| ៥ • ពិភពលោកដ៏ល្អឥតខ្ចោះ | លោកុប្បត្តិ ១-២ |
| ៦ • មនុស្សដំបូងបង្អស់ | លោកុប្បត្តិ ១-២ |
| ៧ • ទីជម្រកដ៏ល្អឥតខ្ចោះ | លោកុប្បត្តិ ២ |
| ៨ • អំណាចរបស់អំពើបាប និងសេចក្តីស្លាប់ | លោកុប្បត្តិ ២ |
| ៩ • មនុស្សស្រីដំបូងបង្អស់ | លោកុប្បត្តិ ២ |
| ១០ • នគរនៃពន្លឺ | វិវរណៈ ៤-៥ |
| ១១ • នគរនៃសេចក្តីងងឹត | អេសាយ ១៤ និងអេសេគាល ២៨ |
| ១២ • សត្វពស់ | លោកុប្បត្តិ ៣ |
| ១៣ • ជម្រើស | លោកុប្បត្តិ ៣ |
| ១៤ • អំពើបាប និងសេចក្តីអាម៉ាស់ | លោកុប្បត្តិ ៣ |
| ១៥ • សេចក្តីស្លាប់ខាងវិញ្ញាណ | លោកុប្បត្តិ ៣ |
| ១៦ • បណ្តាសា | លោកុប្បត្តិ ៣ |
| ១៧ • សេចក្តីសន្យា | លោកុប្បត្តិ ៣ |
| ១៨ • យញ្ញបូជាដំបូងបង្អស់ | លោកុប្បត្តិ ៣ |
| ១៩ • ការបណ្តេញចេញ | លោកុប្បត្តិ ៣ |
| ២០ • កូនដំបូងបង្អស់ | លោកុប្បត្តិ ៤ |
| ២១ • ការថ្វាយបង្គំរបស់មនុស្សមានបាប | លោកុប្បត្តិ ៤ |
| ២២ • ច្បាប់នៃតង្វាយលោះបាប | លោកុប្បត្តិ ៤ |
| ២៣ • ការទទួលយក និងការបដិសេធ | លោកុប្បត្តិ ៤ |
| ២៤ • ឃាតកម្មដំបូងបង្អស់ | លោកុប្បត្តិ ៤-៥ |

២៥ • ការអត់ធ្មត់ និងការជំនុំជម្រះ លោកុប្បត្តិ ៦-៧
២៦ • ការចាប់ផ្ដើមសាជាថ្មី លោកុប្បត្តិ ៨-៩
២៧ • ប៉មនៃសេចក្ដីអំនួត លោកុប្បត្តិ ១១
២៨ • ព្រះជាម្ចាស់ត្រាស់ហៅលោក អ័ប្រាហាំ លោកុប្បត្តិ ១២
២៩ • ការបំពេញសេចក្ដីសន្យា លោកុប្បត្តិ ១៥
៣០ • សេចក្ដីល្បងលដ៏ពិបាកបំផុត លោកុប្បត្តិ ២២
៣១ • កូនប្រុសដែលត្រូវស្លាប់ លោកុប្បត្តិ ២២
៣២ • រូបភាព និងទំនាយ លោកុប្បត្តិ ២២
៣៣ • ព្រះជាម្ចាស់ដ៏ស្មោះត្រង់ និងបរិសុទ្ធ និក្ខមនំ ១៩-២០
៣៤ • ក្រឹត្យវិន័យទាំង១០ប្រការ និក្ខមនំ ២០
៣៥ • រូបភាពបន្ថែមទៀត និក្ខមនំ ២០ និង២៤
៣៦ • ទំនាយបន្ថែមទៀត ទំនុកដំកើង និងកណ្ឌគម្ពីរពួកហោរា

**ផ្នែកទី ២ – ព្រះមហាក្សត្របំពេញផែនការរបស់ទ្រង់ ........................................ ៨៧**

៣៧ • រឿងរបស់ព្រះមហាក្សត្របន្ត ម៉ាថាយ ១
៣៨ • រឿងរ៉ាវរបស់នាង ម៉ារា លូកា ១
៣៩ • រឿងរ៉ាវរបស់លោក យ៉ូសែប ម៉ាថាយ ១
៤០ • ការយាងមកដល់ លូកា ២
៤១ • រឿងរ៉ាវរបស់ពួកអ្នកគង្វាល លូកា ២
៤២ • រឿងរ៉ាវរបស់ពួកហោរាពីទិសខាងកើត ម៉ាថាយ ២
៤៣ • បុត្រដ៏ល្អឥតខ្ចោះ លូកា ២
៤៤ • កូនចៀមនៃព្រះ យ៉ូហាន ១
៤៥ • ព្រះរាជបុត្រាដ៏ល្អឥតខ្ចោះ ម៉ាថាយ ៣
៤៦ • មនុស្សទីពីរ ម៉ាថាយ ៤
៤៧ • ព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ លូកា ៤
៤៨ • អំណាចលើពួកអារក្ស និងជំងឺ លូកា ៤
៤៩ • អំណាចលើខ្យល់ និងសមុទ្រ ម៉ាកុស ៤
៥០ • អំណាចលើអំពើបាប ម៉ាកុស ២
៥១ • អំណាចលើសេចក្ដីស្លាប់ លូកា ៧ និងយ៉ូហាន ១១
៥២ • អ្នកផ្គត់ផ្គង់ យ៉ូហាន ៦
៥៣ • គ្រូបង្រៀន ម៉ាថាយ ៥-៧

៥៤ • ឫទ្ធានុភាពរបស់ព្រះមហាក្សត្រ ម៉ាថាយ ១៧
៥៥ • បេសកកម្មរបស់ព្រះមហាក្សត្រ ម៉ាថាយ ១៦, ២០
៥៦ • ព្រះមហាក្សត្រយាងចូលក្រុងយេរូសាឡិម ម៉ាកុស ១១
៥៧ • ព្រះមហាក្សត្រត្រូវបានចោទសួរ លូកា ២០
៥៨ • ព្រះមហាក្សត្រត្រូវបានចាប់ខ្លួន ម៉ាកុស ១៤
៥៩ • ព្រះមហាក្សត្រត្រូវបានកាត់ទោស យ៉ូហាន ១៨
៦០ • ព្រះមហាក្សត្រត្រូវបានបំពាក់ភួងបន្លា ម៉ាថាយ ២៧
៦១ • ព្រះមហាក្សត្រត្រូវបានឆ្កាង លូកា ២៣
៦២ • ព្រះសង្គ្រោះដ៏ជាព្រះមហាក្សត្រ លូកា ២៣
៦៣ • យញ្ញបូជាចុងក្រោយបង្អស់ ម៉ាថាយ ២៧
៦៤ • ព្រះមហាក្សត្រត្រូវបានបញ្ចុះក្នុងផ្នូរ ម៉ាថាយ ២៧
៦៥ • ផ្នូរនៅទទេ ម៉ាថាយ ២៨
៦៦ • សាររបស់ពួកហោរា លូកា ២៤
៦៧ • រូបកាយដែលបានផ្លាស់ប្រែ យ៉ូហាន ២០
៦៨ • ការយាងចាកចេញ កិច្ចការ ១
៦៩ • ការអបអរសាទរជ័យជម្នះ ទំនុកដំកើង ២៤ និងវិវរណៈ ៥
៧០ • ព្រះមហាក្សត្រនឹងយាងមកវិញ វិវរណៈ ១៩-២២

សេចក្តីបញ្ចប់ ........ ១៥៧
• រស់នៅដោយសុភមង្គលជារៀងរហូត ឬយ៉ាងណា?
• ដំណឹងអាក្រក់
• ដំណឹងល្អ
• ការឆ្លើយតបរបស់អ្នកចំពោះព្រះមហាក្សត្រ

សេចក្តីបន្ថែមពិសេស ........ ១៦៧
• សំណួររំឭកសម្រាប់ភាគនីមួយៗ
• កំណត់យោង
• ធនធានផ្សេងៗទៀត
• ចំណងជើងវគ្គនីមួយៗនៃភាពយន្ត

# បុព្វកថារបស់អ្នកនិពន្ធ

*អាលីសចាប់ផ្តើមធុញទ្រាន់នឹងការអង្គុយនៅក្បែរបងស្រីរបស់នាងនៅឯមាត់ទន្លេ ដោយអត់មានអ្វីធ្វើ។ នាងបានលួចមើលសៀវភៅដែលបងស្រីរបស់នាងកំពុងតែអានម្តងជាពីរដង ប៉ុន្តែសៀវភៅនោះគ្មានរូបភាព ឬការសន្ទនាសោះ ដូច្នេះអាលីសគិតក្នុងចិត្តថា "តើសៀវភៅបែបនេះមានប្រយោជន៍អី បើគ្មានរូបភាព ឬការសន្ទនាដូច្នោះ?"។*

— ពាក្យចាប់ផ្តើមដំបូងនៃសៀវភៅ *ដំណើរផ្សងព្រេងរបស់អាលីសនៅទឹកដីដ៏អស្ចារ្យ* និពន្ធដោយលោក លេវីស ខារ៉ូល នៅឆ្នាំ១៨៦៥

សៀវភៅដែលអ្នករៀបនឹងអាននេះ គឺពោរពេញទៅដោយរូបភាព និងការសន្ទនា ប៉ុន្តែវាមិនដូចទៅនឹងរឿងប្រឌិតដ៏ល្បីល្បាញដូចជា *ដំណើរផ្សងព្រេងរបស់អាលីសនៅទឹកដីដ៏អស្ចារ្យ*[១] នោះទេ ពីព្រោះរូបភាព និងការសន្ទនានៅក្នុងរឿង *មហាក្សត្រដ៏មានសិរីល្អ* នេះ គឺដកស្រង់ចេញពីរឿងដែលបានកើតឡើងពិតមែន។[២]

ខ្ញុំមានការស្ទាក់ស្ទើរខ្លះៗដែរក្នុងការសម្រេចចិត្តផលិតសៀវភៅមួយអមដោយរូបភាព ស្តីអំពីរឿងដ៏អស្ចារ្យបំផុតដែលមិនធ្លាប់មាន។

នៅច្រើនឆ្នាំមុន ពេលដែលខ្ញុំកំពុងរស់នៅតំបន់អាហ្វ្រិកខាងលិច ខ្ញុំបានចុះឈ្មោះចូលរៀនវគ្គសិក្សាទាក់ទងនឹងការផលិតកម្មវិធីវិទ្យុ។ នៅថ្ងៃដំបូងនៃវគ្គសិក្សានោះ សាស្ត្រាចារ្យបានសួរថា “តើអ្វីទៅជាគុណសម្បត្តិចម្បងមួយរបស់វិទ្យុ ដែលពិសេសលើសជាងទូរទស្សន៍?”។ ចម្លើយរបស់គាត់បានធ្វើឲ្យអ្នកសិក្សាភ្ញាក់ផ្អើល។

“វាផ្តល់រូបភាពល្អប្រសើរជាង។”

ពិតមែនហើយ។

សូម្បីតែភាពយន្តដែលចំណាយថវិកាយ៉ាងច្រើនមហិមា ក៏មិនស្មើនឹងសមត្ថភាពរបស់គំនិតមនុស្ស ដែលអាចយកពាក្យពេចន៍មកស្រមៃជារូបភាពដ៏រស់រវើកបានឡើយ។ នៅក្នុងបទគម្ពីរដែលសរសេរដោយពួកហោរាពីបុរាណ ពាក្យរបស់ពួកគេផ្តល់រាប់រយរូបភាព ដែលគ្មានខ្សែភាពយន្តណាអាចបង្ហាញយ៉ាងច្បាស់ ហើយក៏គ្មានវិចិត្រករណាអាចគូរយ៉ាងល្អគ្រប់គ្រាន់បានឡើយ។

ដូច្នេះ ខ្ញុំសូមទទួលស្គាល់ថា គ្មានស្នាដៃសិល្បៈណាមួយដែលអាចពិពណ៌នាយ៉ាងល្អឥតខ្ចោះអំពីរឿងដ៏ល្អបំផុតនេះ ដែលមិនធ្លាប់មាននោះទេ តែខ្ញុំពិតជាមានអំណរក្នុងការព្យាយាមសាកល្បង។









អ្នកស្រី អាមីនដា សាន ម៉ាទីន (Arminda San Martín) គឺជាវិចិត្រករជនជាតិអាហ្សង់ទីន ដែលមានអំណោយទាន ហើយមានចិត្តសប្បុរស។ អ្នកស្រីបានយករឿងព្រះគម្ពីរមកបង្កើតជារូបភាពយ៉ាងអស្ចារ្យ ហើយត្រឹមត្រូវផងដែរ។ អ្នកស្រីបានប្រើកម្មវិធីកុំព្យូទ័រ ដើម្បីគូរពីគំនូរព្រាងរហូតដល់គំនូរចុងក្រោយ ក្នុងរយៈពេលត្រឹមតែ១៤ខែប៉ុណ្ណោះ។ ខ្ញុំសង្ឃឹមថា លោកអ្នកនឹងពេញចិត្តចំពោះស្នាដៃរបស់អ្នកស្រីដូចខ្ញុំដែរ។

ឥឡូវ សូមលោកអ្នកគិតពិចារណាអំពីចំណុចនេះសិន។

នៅពេលដែលយើងអានសៀវភៅរឿងណាមួយ តើយើងគួរចាប់ផ្តើមពីកន្លែងណាទៅ? នៅពាក់កណ្តាលនៃសៀវភៅមែនឬ? ទេ! យើងចាប់ផ្តើមពីដំបូងទៅ ទើបយើងអាចយល់អំពីរឿងនោះបាន។ ដូចគ្នានេះដែរ ដើម្បីយល់អំពីព្រះគម្ពីរ នោះយើងត្រូវតែចាប់ផ្តើមពីដំបូងទៅ ហើយតាមដានសាច់រឿងរហូតដល់ការបញ្ចប់ដ៏សមហេតុផល និងជាទីគាប់ចិត្តផងដែរ។

កំណត់ត្រារបស់ពួកហោរាមានរឿងខ្លីៗរាប់រយរឿង ដែលទាំងអស់ផ្គុំគ្នាបង្កើតជារឿងតែមួយ។ ក្នុងការសរសេរសៀវភៅ *មហាក្សត្រដ៏មានសិរីល្អ* ខ្ញុំមានអារម្មណ៍ដូចជាអ្នកលក់ផ្កា ដែលបានទទួលការងារឲ្យចូលទៅក្នុងសួនដ៏ធំល្វឹងល្វើយ ដើម្បីជ្រើសរើសផ្កាតែ៣០ទៅ៤០ទង យកមករៀបជាបាច់ផ្កាមួយ ដែលបង្ហាញពីសិរីល្អនៃសួនទាំងមូល។ សម្រាប់សៀវភៅនេះ ខ្ញុំព្យាយាមជ្រើសរើសយករឿងសំខាន់ៗ៣០ទៅ៤០រឿងចេញពីព្រះគម្ពីរ ដើម្បីរៀបចំជារឿងមួយដ៏គួរឲ្យចាប់អារម្មណ៍ ដែលចែកចេញជា៧០ភាគ ក្នុងគោលបំណងចង់បង្ហាញពីសិរីល្អរបស់ព្រះមហាក្សត្រដ៏នៅអស់កល្បជានិច្ច ដែលបានបើកសម្តែងពីអង្គទ្រង់តាមរយៈប្រវត្តិសាស្ត្រនៃមនុស្សជាតិ។

សេចក្តីអធិស្ឋានរបស់ខ្ញុំទៅកាន់ព្រះជាម្ចាស់គឺថា ការបង្ហាញ និងការតំណាលរឿងពិតមួយនេះនឹងជួយដល់អ្នកអានគ្រប់វ័យឲ្យមានអំណរចំពោះពាក្យរបស់ពួកហោរា ហើយមានចិត្តស្រឡាញ់ព្រះជាម្ចាស់ ដែលរឿងទាំងអស់នេះចង្អុលបង្ហាញ ព្រមទាំងចូលមកក្នុងនគរដ៏រីករាយរបស់ទ្រង់ដែលនៅស្ថិតស្ថេរជាដរាបដោយគ្មានទីបញ្ចប់។

ដើម្បីបង្ហាញជូនរូបភាពដ៏ច្បាស់លាស់
***ប៉ុល ដាន ប្រាមសិន***

# សេចក្ដីផ្ដើម

**ចិត្តរបស់ខ្ញុំពេញហៀរដោយពាក្យពេជន៍ដ៏ល្អ**
**ខ្ញុំលើកកំណាព្យរបស់ខ្ញុំថ្វាយព្រះមហាក្សត្រ**
**អណ្ដាតខ្ញុំប្រៀបដូចជាប៉ាកការបស់កវីនិពន្ធ ដែលត្រៀមជាស្រេច។**

**សូមយាងទៅដោយឥទ្ធិឫទ្ធិរបស់ព្រះអង្គ ទាំងមានជ័យជម្នះ**
**ដើម្បីការពារសេចក្ដីពិត ភាពស្លូតបូត និងសេចក្ដីសុចរិត**
**សូមព្រះហស្តស្ដាំរបស់ព្រះអង្គបង្រៀនព្រះអង្គពីការដែលគួរកោតខ្លាច!**

— ដកស្រង់ចេញពីបទគម្ពីររបស់ពួកហោរា
(ទំនុកដំកើង ៤៥:១,៤ គកស១៦)



## ភាគទី១

# ព្រះមហាក្សត្រ និងនគររបស់ទ្រង់

អស់រយៈពេលដ៏យូរលង់មកហើយ មុនពិភពលោកបានចាប់ផ្តើមឡើង មានព្រះមហាក្សត្រមួយព្រះអង្គ ជាមហាក្សត្រដ៏មានសិរីល្អ។

ព្រះមហាក្សត្រនេះ ខ្ពង់ខ្ពស់លើសអស់ទាំងមនុស្ស និងរបស់សព្វសារពើ ដែលយើងស្មានមិនដល់។ ក្នុងភាពអស់កល្បគ្មានដែនកំណត់ ទ្រង់ជាព្រះមហាក្សត្រតែមួយអង្គ ហើយនគរទ្រង់ គឺជានគរតែមួយគត់ ដែលពេញដោយប្រាជ្ញា សេចក្តីស្រឡាញ់ អំណរ និងភាពសុខសាន្តដ៏ល្អឥតខ្ចោះ។ នគរនេះមិនត្រូវការព្រះអាទិត្យ ឬដួងតារាទេ ដ្បិតអង្គទ្រង់ផ្ទាល់ គឺជាពន្លឺសម្រាប់នគរនេះឯង។

នគរនេះគ្មានដែនកំណត់ចំពោះទំហំក៏ពិតមែន តែមានដែនកំណត់ចំពោះរាស្ត្រវិញ។ ខ្លះនិយាយថា ព្រះមហាក្សត្រនេះគ្មានរាស្ត្រទាល់តែសោះ។

ពិតមែនឬ?

អាថ៌កំបាំងពីដើមនៃព្រះមហាក្សត្រនេះ គឺទ្រង់មិនដែលគង់នៅឯកានោះទេ សូម្បីតែពេលទ្រង់គង់នៅតែអង្គឯងក៏ដោយ។

ប៉ុន្តែ ទ្រង់ចង់មានទំនាក់ទំនងជាមួយនឹងភាវៈដែលមានប្រាជ្ញាដទៃទៀត។

ដូច្នេះ ព្រះមហាក្សត្រដ៏សប្បុរស ហើយមានប្រាជ្ញានេះ បានបង្កើតស្ថានសួគ៌ និងភាវៈជាវិញ្ញាណដ៏ចិញ្ចាចចិញ្ចែង ដ៏ឈ្លាសវៃរាប់លាននាក់ហៅថា ទេវតា។ ទ្រង់បានស្គាល់ឈ្មោះទេវតាទាំងអស់នោះ ហើយទ្រង់ក៏ចង់ឲ្យពួកគេស្គាល់ទ្រង់ដែរ។ ជីវិតរស់នៅជាមួយទ្រង់ គឺជាការផ្សងព្រេងឥតឈប់ឈរ។

ប៉ុន្តែ ទ្រង់ចង់បានអ្វីដែលលើសពីពួកទេវតាទៅទៀត។ ដូច្នេះ ទ្រង់បានបង្កើតអាណាចក្រមួយដែលមានពេលវេលា លំហ និងរូបធាតុ គឺសកលលោកដ៏ធំអស្ចារ្យ ដែលមានភពមួយភ្លឺចិញ្ចាចចិញ្ចែង សម្រាប់ធ្វើជាជម្រកនៃភាវៈរស់ដ៏អស្ចារ្យហៅថា មនុស្ស។

ខុសពីពួកទេវតា មនុស្សលោកបានកើតចេញពីមនុស្សតែពីរនាក់ប៉ុណ្ណោះ គឺប្រុសម្នាក់ស្រីម្នាក់។ ដូចទៅនឹងពួកទេវតា ព្រះមហាក្សត្រនេះក៏ចង់មានទំនាក់ទំនងជាមួយនឹងមនុស្សផងដែរ។

ក្រោយមក ក៏មានហេតុការណ៍មួយបានកើតឡើង ជាហេតុមួយដ៏អាក្រក់។ ការបះបោរបានកើតឡើងក្នុងនគរនេះ ដំបូងនៅស្ថានសួគ៌ បន្ទាប់មកនៅផែនដី។

ទេវតាដែលបះបោរមួយបានក្តាប់យកនគរផែនដី ដោយចាប់មនុស្សធ្វើជាចំណាប់ខ្មាំងរបស់វា។ ប៉ុន្តែ ព្រះមហាក្សត្រមិនបានភ្ញាក់ផ្អើលនឹងការនេះសោះ។

នៅក្នុងទីជម្រៅនៃព្រះហឫទ័យទ្រង់ មានផែនការសង្គ្រោះមួយដ៏ធំអស្ចារ្យ ដ៏អាថ៌កំបាំងដ៏មានតម្លៃ ដ៏ទូលំទូលាយ ដែលទ្រង់នឹងត្រូវចំណាយពេលរាប់ពាន់ឆ្នាំ ដើម្បីសម្រេចផែនការនេះ។

តើមានការអ្វីដែលពិបាកពេកចំពោះព្រះមហាក្សត្រដ៏នៅអស់កល្បដែរឬ?

ទ្រង់គង់នៅលើសពីអស់ទាំងពេលវេលា។





# ភាគទី២
# ព្រះមហាក្សត្រ និងពួកហោរារបស់ទ្រង់

ដើម្បីស្គាល់ព្រះមហាក្សត្រ និងផែនការរបស់ទ្រង់ អ្នកត្រូវស្គាល់សៀវភៅរបស់ទ្រង់ជាមុនសិន។

ក្នុងពេលជាង១៥សតវត្សរ៍ ព្រះមហាក្សត្របានជ្រើសរើសមនុស្សខ្ទង់៤០នាក់ ដើម្បីកត់ត្រារឿង និងសាររបស់ទ្រង់។ ពួកគេទាំងនោះត្រូវបានហៅថាជាហោរា។ ព្រះមហាក្សត្របានប្រទានព្រះបន្ទូលដល់ពួកហោរា ហើយពួកគេក៏បានកត់ត្រានៅលើក្រាំង ដើម្បីចម្លង ចែកចាយ និងរក្សាទុកសម្រាប់ជំនាន់ក្រោយៗ។ ទោះបីជាពួកហោរាភាគច្រើនមិនបានស្គាល់គ្នាក៏ដោយ កំណត់ត្រារបស់ពួកគេតំណាលពីរឿង និងសារតែមួយ។

កំណត់ត្រារបស់ពួកហោរាគឺហៅថា ព្រះគម្ពីរបរិសុទ្ធ។ បើគ្មានព្រះគម្ពីរទេ នោះយើងមិនអាចដឹងថា តើយើងមកពីណា ហេតុអ្វីបានជាយើងនៅទីនេះ ហើយតើយើងត្រូវទៅណា។ ដើម្បីដឹងចម្លើយដ៏ត្រឹមត្រូវ យើងត្រូវការសៀវភៅរបស់ព្រះមហាក្សត្រនេះ។

ខ្ទង់៣៥០០ឆ្នាំមុន ទ្រង់បានបណ្ដាលឲ្យហោរាឈ្មោះ ម៉ូសេ កត់ត្រាថា៖

> មនុស្សមិនមែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋនៃព្រះយេហូវ៉ាមក។ (ចោទិយកថា ៨:៣)

បច្ចុប្បន្ន ព្រះបន្ទូលរបស់ទ្រង់ត្រូវបានចងក្រងជាសៀវភៅមួយហៅថា *ព្រះគម្ពីរបរិសុទ្ធ*។ បរិសុទ្ធមានន័យថា *វិសុទ្ធ* ឬ *ញែកចេញពីគ្រប់ទាំងអស់*។ ព្រះគម្ពីរមានន័យថា *សៀវភៅ* ឬ *បណ្ដុំសៀវភៅជាច្រើន*។ ព្រះគម្ពីរគឺជាសៀវភៅលក់ដាច់ជាងគេ ហើយត្រូវបានបកប្រែច្រើនជាងគេ។ ច្បាប់ដើមនៃព្រះគម្ពីររាប់ពាន់ច្បាប់ ដែលជាក្រាំងធ្វើពីដើមរុក្ខជាតិ និងស្បែកសត្វ គឺត្រូវបានរក្សាទុកយ៉ាងល្អលើសអស់ទាំងឯកសារពីបុរាណ។[៣]

ព្រះគម្ពីរមាន២ផ្នែកសំខាន់ៗ៖

ផ្នែកទី១ គឺជាព្រះគម្ពីរសញ្ញាចាស់ (កណ្ឌគម្ពីរក្រឹត្យវិន័យ ទំនុកដំកើង។ល។)
ដែលព្រះមហាក្សត្រមានបន្ទូលទុកជាមុនអំពីផែនការរបស់ទ្រង់។

ផ្នែកទី២ គឺជាព្រះគម្ពីរសញ្ញាថ្មី (កណ្ឌគម្ពីរដំណឹងល្អ កិច្ចការ។ល។)
ដែលព្រះមហាក្សត្របំពេញផែនការរបស់ទ្រង់។

សញ្ញាមានន័យថា *សម្ព័ន្ធមេត្រី កិច្ចសន្យា* ឬ *កិច្ចព្រមព្រៀង*។ ព្រះគម្ពីរសញ្ញាចាស់ប្រាប់ទុកជាមុនអំពីផែនការរបស់ព្រះជាម្ចាស់។ ព្រះគម្ពីរសញ្ញាថ្មីកត់ត្រាអំពីការបំពេញផែនការរបស់ទ្រង់។ មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចកត់ត្រាពីប្រវត្តិសាស្ត្រទុកជាមុន។

ភាពខុសគ្នារវាងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី គឺអាចប្រៀបដូចជាភាពខុសគ្នារវាងការទទួលសំបុត្រ និងរូបថតពីព្រះមហាក្សត្រដ៏អស្ចារ្យ និងការជួបព្រះមហាក្សត្រនោះដោយផ្ទាល់។

ព្រះគម្ពីរត្រូវបានចែកចាយដំបូងនៅក្នុងតំបន់មជ្ឈិមបូព៌ា ទ្វីបអាហ្វ្រិក ទ្វីបអាស៊ី និងទ្វីបអឺរ៉ុប ក្រោយមកបានចូលដល់ទ្វីបអាមេរិក និងបន្តទៅទៀត។ ពួកហោរាបានមកពីតំបន់មជ្ឈិមបូព៌ា ប៉ុន្តែរឿង និងសារដែលពួកគេបានកត់ត្រានោះ គឺសម្រាប់គ្រប់ជាតិសាសន៍ គ្រប់គ្រួសារ គ្រប់បុគ្គល...

និងសម្រាប់អ្នក។





## ភាគទី៣
# ព្រះមហាក្សត្រ និងសកលលោករបស់ទ្រង់

បើយើងអាចធ្វើដំណើរថយក្រោយ ទាំងឆ្លងកាត់ពេលវេលា និងលំហ
ថយហើយ
ថយទៀត
កាន់តែថយទៅទៀត
មុនមានមនុស្ស ភព និងតារា នោះយើងអាចឃើញពីអំណាច និងសិរីល្អ ដែលមានបង្កប់នៅក្នុងខគម្ពីរដំបូងបង្អស់៖

កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃនឹងផែនដី។ (លោកុប្បត្តិ ១:១)

បច្ចុប្បន្ន មនុស្សជាច្រើនគិតថា លោកីយ៍ និងរបស់សព្វសារពើមិនបានកើតឡើងដោយសារព្រះអាទិករដ៏មានប្រាជ្ញានោះទេ។ ប៉ុន្តែ ទ្រឹស្តីរបស់ពួកគេមិនអាចពន្យល់ច្បាស់អំពីការរចនាដ៏ស្មុគស្មាញ និងលំដាប់លំដោយដ៏ទៀងទាត់នៃសកលលោកបានឡើយ។

ក្នុងសៀវភៅរបស់ទ្រង់ ព្រះមហាក្សត្របានចែងថា៖

ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញ
ការដែលព្រះហស្តទ្រង់ធ្វើ។ (ទំនុកដំកើង ១៩:១)

ចូរមើលដៃរបស់អ្នក រួចសាកកម្រើកមេដៃទាំង២ ហើយព្យាយាមកាន់សៀវភៅ អំបោស ឬញញួរ ដោយមិនប្រើមេដៃ។ ចូរសង្កេតក្រចកដៃ សន្លាក់ និងស្បែករបស់អ្នក ហើយគិតអំពីសកម្មភាពសំខាន់ៗទាំងប៉ុន្មាន ដែលអ្នកធ្វើតាមរយៈដៃ។ តើមានសិប្បករណាដែលអាចបង្កើតឧបករណ៍បែបនេះបាន?

តើត្រូវមានប្រាជ្ញា និងអំណាចប៉ុណ្ណា ដើម្បីបង្កើតកាឡាក់ស៊ីរាប់ពាន់លានបាន? ឬបង្កើតកោសិកាមួយដែលមានរាប់លានផ្នែកដ៏ស្មុគស្មាញបាន? ឬភ្ជាប់ប្រវាក់កោសិកាដ៏សែនល្អិតជាមួយនឹងទិន្នន័យហ្សែន ដើម្បីបង្កើតរូបអ្នកបាន?

ខ្ទង់៣០០០ឆ្នាំមុន ស្តេច ដាវីឌ ជាហោរាបានសរសេរថា៖

ទ្រង់...បានផ្សំគ្រឿងនៃទូលបង្គំនៅក្នុងផ្ទៃម្តាយ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់
ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ។ (ទំនុកដំកើង ១៣៩:១៣-១៤)

តើអ្នកចង់ជួបព្រះជាម្ចាស់ដែលបានបង្កើតអ្នកដែរឬទេ? តើអ្នកចង់រស់នៅជាមួយព្រះអាទិករ និងម្ចាស់នៃកាឡាក់ស៊ីជាដរាបដែរឬទេ? អ្នកពិតជាអាច។ ទ្រង់បានបើកសម្តែងពីអង្គទ្រង់ ហើយក៏ចង់ឲ្យអ្នក គ្រួសារអ្នក និងសហគមន៍អ្នកស្គាល់ទ្រង់ផងដែរ។ ទ្រង់ហៅអ្នកឲ្យស្គាល់ផែនការសេចក្តីស្រឡាញ់ និងឫទ្ធានុភាពរបស់ទ្រង់ ហើយចុះចូលនឹងទ្រង់ និងរស់សម្រាប់សិរីល្អរបស់ទ្រង់។ ប៉ុន្តែ ទ្រង់នឹងមិនបង្ខំអ្នកឲ្យក្លាយជារាស្ត្ររបស់ទ្រង់ទេ។

ទ្រង់មិនមែនជាស្តេចធម្មតាទេ ប៉ុន្តែទ្រង់ជាព្រះមហាក្សត្រដ៏ឧត្តម គឺ*មហាក្សត្រដ៏មានសិរីល្អ*។

នេះជារឿងរបស់ទ្រង់។



# ផ្នែកទី១

## ព្រះមហាក្សត្រ
## មានបន្ទូលទុកជាមុន
## អំពីផែនការរបស់ទ្រង់

— ព្រះគម្ពីរសញ្ញាចាស់ —



# ភាគទី៤
# ថ្ងៃទីមួយ

សៀវភៅរបស់ព្រះជាម្ចាស់ចាប់ផ្ដើមយ៉ាងស័ក្ដិសមជាព្រះមហាក្សត្រ។ ទ្រង់ប្រាប់យើងអំពីអ្វីដែលទ្រង់ចង់ឲ្យយើងដឹងតែប៉ុណ្ណោះ។

> កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃនឹងផែនដី។ (លោកុប្បត្តិ ១:១)

អ្វីៗដែលយើងអាចមើលឃើញ ហើយប៉ះបានមានការចាប់ផ្ដើម ប៉ុន្តែព្រះអាទិករដែលជាម្ចាស់នៃសកលលោក ទ្រង់គ្មានទីចាប់ផ្ដើម និងទីបញ្ចប់ទេ។ ទ្រង់ជាវិញ្ញាណដ៏នៅអស់កល្ប ដែលមើលមិនឃើញ ហើយអាចគង់នៅគ្រប់ទីកន្លែងក្នុងពេលតែមួយ។ ទ្រង់ទតឃើញ ហើយជ្រាបអ្វីៗទាំងអស់។

តើអ្នកស្គាល់ព្រះនាមរបស់ទ្រង់ដែរឬទេ? ព្រះជាម្ចាស់មានព្រះនាមជាច្រើន ប៉ុន្តែព្រះនាមរបស់ទ្រង់ដែលល្បីបំផុតនោះ គឺព្រះយេហូវ៉ា។ ក្នុងភាសាដើមនៃសៀវភៅរបស់ព្រះជាម្ចាស់ ព្រះនាមរបស់ទ្រង់គឺ *យ៉ាវេ (Yahweh)* មានន័យថា *ព្រះដ៏គង់នៅ* ឬ *ព្រះដ៏ជាព្រះ*។

រឿងនៃការបង្កើតបន្តដោយការរៀបរាប់របស់ព្រះមហាក្សត្រអំពីផែនដីក្នុងភាពដើម។

> ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតនៅគ្របលើជំរៅទឹក
> ហើយព្រះវិញ្ញាណនៃព្រះក៏រេរានៅពីលើទឹក។ (លោកុប្បត្តិ ១:២)

ឥឡូវ ដល់ពេលត្រូវរៀបចំផែនដីសម្រាប់មនុស្សហើយ។

> នោះព្រះទ្រង់មានបន្ទូលថា “ចូរឲ្យមានពន្លឺឡើង” ដូច្នេះពន្លឺក៏មានឡើង។
>
> ព្រះទ្រង់ឃើញពន្លឺនោះក៏យល់ថាជាល្អហើយ រួចទ្រង់ញែកពន្លឺពីងងឹតចេញ។ ទ្រង់ហៅពន្លឺថាជា“ថ្ងៃ” ហើយហៅងងឹតថាជា“យប់” នោះក៏មានល្ងាចមានព្រឹកឡើង ជាថ្ងៃទី១។ (លោកុប្បត្តិ ១:៣-៥)

តើព្រះជាម្ចាស់បានធ្វើអ្វីនៅថ្ងៃទីមួយនៃការបង្កើត? ទ្រង់បានបង្គាប់ពន្លឺឲ្យបំភ្លឺភាពងងឹត។ ក្រោយមក ព្រះអាទិត្យនឹងបំភ្លឺផែនដី តែមិនមែនក្នុងថ្ងៃទីមួយទេ។ ព្រះជាម្ចាស់ចង់ឲ្យយើងដឹងថា ទ្រង់ជាប្រភពនៃពន្លឺ។

> ព្រះទ្រង់ជាពន្លឺភ្លឺ គ្មានសេចក្ដីងងឹតណា នៅក្នុងទ្រង់សោះ។ (១យ៉ូហាន ១:៥)

ព្រះជាម្ចាស់ គឺបរិសុទ្ធដូចជាពន្លឺ ហើយទ្រង់មិនអាចទៅជាសៅហ្មងបានទេ។
ទោះបីជាពន្លឺចាំងមកលើវត្ថុកខ្វក់ក៏ដោយ វានៅតែបរិសុទ្ធដដែល។
ព្រះជាម្ចាស់ គឺល្អឥតខ្ចោះ។ ព្រះជាម្ចាស់ គឺបរិសុទ្ធ។

តើអ្នកកត់សម្គាល់ទេថា នរណាបាននៅជាមួយព្រះជាម្ចាស់ត្រង់កន្លែងដែលទ្រង់បង្កើតនោះ? ព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់បានគង់នៅទីនោះ ទាំងរេរានៅពីលើទឹក។ ព្រះបន្ទូលរបស់ទ្រង់ក៏បានគង់នៅទីនោះដែរ ទាំងមានបន្ទូល។

> កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។ ទ្រង់គង់នៅជាមួយនឹងព្រះ តាំងអំពីដើមមក។ គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់...។ (យ៉ូហាន ១:១-៣)

ព្រះវិញ្ញាណបរិសុទ្ធនៃព្រះ និងព្រះបន្ទូលតែងតែគង់នៅជាមួយនឹងព្រះជាម្ចាស់ដ៏ពិតតែមួយ ដូច្នេះទើបអាចនិយាយបានថា៖

*ទ្រង់មិនដែលគង់នៅឯកានោះទេ សូម្បីតែពេលទ្រង់គង់នៅតែអង្គឯងក៏ដោយ។*





## ភាគទី៥
# ពិភពលោកដ៏ល្អឥតខ្ចោះ

ក្នុង៦ថ្ងៃបន្តបន្ទាប់គ្នា ព្រះមហាក្សត្របានបង្កើតពិភពលោកដ៏ស្អាតអស្ចារ្យ។ ព្រះជាម្ចាស់គ្រាន់តែមានបន្ទូលទៅ នោះអ្វីៗដ៏អស្ចារ្យដែលរចនាឡើងយ៉ាងល្អឥតខ្ចោះបានលេចមក។

នៅថ្ងៃទី១ ព្រះជាម្ចាស់មានបន្ទូលថា “ចូរឲ្យមានពន្លឺឡើង!” នោះពន្លឺក៏មានឡើង។

នៅថ្ងៃទី២ ព្រះជាម្ចាស់បានបង្កើតលំហផែនដី ដែលមានផ្ទៃមេឃដ៏មើលឃើញ និងមានខ្យល់សម្រាប់ដកដង្ហើមដ៏មើលមិនឃើញ។ ព្រះជាម្ចាស់បានរចនាផ្ទៃមេឃ ដោយការលាយផ្សំឧស្ម័នទ្រទ្រង់ជីវិតយ៉ាងល្អឥតខ្ចោះ មានដូចជាអុកស៊ីសែន និងអាសូតជាដើម។

នៅថ្ងៃទី៣ ព្រះជាម្ចាស់មានបន្ទូលថា “ចូរឲ្យមានទីគោកដុះលេចឡើង!” នោះក៏មានដូច្នោះ។ រួចព្រះជាម្ចាស់មានបន្ទូលថា “ចូរឲ្យដីដុះតិណជាតិឡើង!” ភ្លាមនោះ ស្មៅ រុក្ខជាតិ ផ្កា និងផ្លែឈើ ដែលមានគ្រាប់ក៏ដុះឡើងតាមពូជនីមួយៗ។

នៅថ្ងៃទី៤ ព្រះជាម្ចាស់បានបង្គាប់ព្រះអាទិត្យ និងព្រះច័ន្ទ ឲ្យបំភ្លឺ និងសម្គាល់ឆ្នាំ ខែ និងថ្ងៃ ហើយទ្រង់ក៏បានបង្កើតផ្កាយផងដែរ។

នៅថ្ងៃទី៥ ព្រះជាម្ចាស់មានបន្ទូលថា “ចូរឲ្យមានមច្ឆាជាតិរវើកនៅក្នុងទឹកជាបរិបូរ និងបក្សីជាតិហើរលើដីនៅនាអាកាស!” នោះក៏មានដូច្នោះ។

នៅថ្ងៃទី៦ ព្រះជាម្ចាស់មានបន្ទូលថា “ចូរឲ្យចតុប្បាទជាតិកើតមកនៅដីគោកតាមពូជ គឺជាសត្វស្រុក សត្វលូនវារ និងសត្វព្រៃនៅផែនដី!”។ ព្រះជាម្ចាស់បង្កើតគ្រប់សត្វមានជីវិតឲ្យមានសមត្ថភាពអាចបង្កើតកូនតាមពូជ និងថែរក្សាកូនផងដែរ។

ព្រះទ្រង់ឃើញថាល្អ។ (លោកុប្បត្តិ ១:២៥)

ផែនដីពោរពេញដោយសន្តិភាព។ ពីដំបូងឡើយ សត្វទាំងអស់មានលក្ខណៈស្លូតបូត គឺពួកវាមិនបានសម្លាប់ ឬក៏ស៊ីគ្នាឡើយ។ ពួកវាបានស៊ីរុក្ខជាតិជាអាហារ។

ផែនដីក៏ពោរពេញដោយសណ្តាប់ធ្នាប់។ ដូចនាឡិកាដែរ ព្រះអាទិត្យស្ថិតក្នុងចម្ងាយដ៏ត្រឹមត្រូវពីផែនដី រីឯព្រះច័ន្ទប្តូរពីមួយចំណិតតូចទៅពេញវង់ ហើយផែនដីប្រើការវិលចុះឡើងនៃខ្យល់ ទឹក និងសំណល់។ បើគ្រប់គ្រងបានល្អ នគរផែនដីនឹងមិនខ្វះអ្វីឡើយ។ វាអាចជាជម្រកដ៏ល្អឥតខ្ចោះសម្រាប់មនុស្សជាតិ។

ថ្ងៃនីមួយៗនៃការបង្កើតបង្ហាញឲ្យយើងដឹងអំពីលក្ខណៈរបស់ព្រះជាម្ចាស់[4]៖

ថ្ងៃទី១ ព្រះជាម្ចាស់ទ្រង់*បរិសុទ្ធ*។ ទ្រង់ល្អឥតខ្ចោះ និងវិសុទ្ធដូចពន្លឺ។
ថ្ងៃទី២ ព្រះជាម្ចាស់ទ្រង់*មានគ្រប់អំណាចព្រះចេស្តា*។ ទ្រង់បានបង្កើត ហើយរក្សាបរិយាកាស។
ថ្ងៃទី៣ ព្រះជាម្ចាស់ទ្រង់*ល្អ*។ ទ្រង់បានបង្កើតរុក្ខជាតិ និងអាហារគ្រប់សព្វសម្រាប់យើង។
ថ្ងៃទី៤ ព្រះជាម្ចាស់ទ្រង់*ស្មោះត្រង់*។ ព្រះអាទិត្យ និងព្រះច័ន្ទស្ថិតក្នុងគន្លងរបស់វា។
ថ្ងៃទី៥ ព្រះជាម្ចាស់ទ្រង់ជា*ជីវិត*។ ទ្រង់ដាក់ត្រីក្នុងសមុទ្រ និងបក្សីនៅលើមេឃ។
ថ្ងៃទី៦ ព្រះជាម្ចាស់ទ្រង់ជា*សេចក្តីស្រឡាញ់*។ ក្រោយពីព្រះជាម្ចាស់បានបង្កើតសត្វចតុប្បាទរួចហើយ នោះក៏ដល់ពេលត្រូវបង្កើតភាវៈរស់ ដែលទ្រង់នឹងចាក់សេចក្តីស្រឡាញ់របស់ទ្រង់មក។

នេះជាពេលដើម្បីបង្កើតភាវៈដ៏ពិសេស ដែលអាចឆ្លុះបញ្ចាំងពីភាពបរិសុទ្ធ ព្រះចេស្តា សេចក្តីសប្បុរស សេចក្តីស្មោះត្រង់ ជីវិត និងសេចក្តីស្រឡាញ់របស់ទ្រង់។





## ភាគទី៦
# មនុស្សដំបូងបង្អស់

ក្នុងថ្ងៃទី៦នៃការបង្កើត ព្រះមហាក្សត្រមានបន្ទូលនៅក្នុងអង្គទ្រង់ (គឺព្រះជាម្ចាស់ ព្រះវិញ្ញាណបរិសុទ្ធ និងព្រះបន្ទូល) ថា៖

> “ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង ឲ្យមានភាពដូចយើង[៥] ហើយឲ្យមានអំណាច... លើផែនដីទាំងមូល ព្រមទាំងសត្វ...។”
>
> ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី។ (លោកុប្បត្តិ ១:២៦-២៧)

ពេលព្រះគម្ពីរចែងថា ព្រះជាម្ចាស់បង្កើតមនុស្សឲ្យចំនឹងរូបអង្គទ្រង់ នេះមិនមែនមានន័យថា ព្រះជាម្ចាស់មានភាពដូចយើងនោះទេ។ នេះមានន័យថា យើងត្រូវឆ្លុះបញ្ចាំងពីលក្ខណៈរបស់ទ្រង់វិញ។ ដូចរូបស្តេចត្រូវបានឆ្លាក់នឹងលុយកាក់ជាយ៉ាងណា នោះរូបអង្គទ្រង់ក៏ត្រូវបានឆ្លាក់នឹងមនុស្សយ៉ាងនេះដែរ។ មនុស្សប្រុសស្រីដំបូងបង្អស់ត្រូវបានបង្កើតឡើងឲ្យចេះគិត ចេះស្រឡាញ់ និងចេះនិយាយដូចព្រះអាទិកររបស់ខ្លួន ដើម្បីឲ្យពួកគេអាចមានទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយនឹងទ្រង់។ ព្រះជាម្ចាស់មិនបានបង្កើតមនុស្សមកឲ្យធ្វើជាទាសកររបស់ទ្រង់ទេ ប៉ុន្តែឲ្យធ្វើជាមិត្តសម្លាញ់របស់ទ្រង់វិញ។

ក្នុងការបង្កើតមនុស្សឲ្យមានភាពដូចទ្រង់ ព្រះជាម្ចាស់បានប្រទានអំណាចដល់ពួកគេ។ មនុស្សត្រូវថែរក្សា និងគ្រប់គ្រងផែនដីសម្រាប់ព្រះជាម្ចាស់ ហើយស្វែងរកអាថ៌កំបាំង និងប្រើប្រាស់ធនធាននៃផែនដីឲ្យបានល្អ។ សមត្ថភាពបែបនេះធ្វើឲ្យមនុស្សមានលក្ខណៈខុសដាច់ពីពពួកសត្វ។

ចំពោះសត្វ ព្រះជាម្ចាស់បានប្រទានឲ្យមាន២ផ្នែក គឺរូបកាយ និងព្រលឹង។
ចំពោះមនុស្សវិញ ព្រះជាម្ចាស់បានប្រទានឲ្យមាន៣ផ្នែក គឺរូបកាយ ព្រលឹង និងវិញ្ញាណ។

> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដី[៦]មកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង។ (លោកុប្បត្តិ ២:៧)

រូបកាយប្រៀបដូចជាផ្ទះឬតង់ ដែលព្រះជាម្ចាស់បានផ្លុំបញ្ចូលព្រលឹង និងវិញ្ញាណនៃមនុស្ស។

ព្រលឹង គឺជាបញ្ញា អារម្មណ៍ និងឆន្ទៈនៃមនុស្ស ដែលធ្វើឲ្យមនុស្សអាចគិតពិចារណា មានអារម្មណ៍ និងជ្រើសរើសអ្វីមួយ។

វិញ្ញាណភ្ជាប់មនុស្សទៅនឹងព្រះជាម្ចាស់។ រូបកាយជួយឲ្យមនុស្សទាក់ទងជាមួយនឹងលោកីយ៍ដែលមើលឃើញ រីឯវិញ្ញាណជួយឲ្យមនុស្សទាក់ទងជាមួយនឹងព្រះជាម្ចាស់ដែលមើលមិនឃើញ។ ព្រះយេហូវ៉ាចង់ឲ្យមនុស្សស្គាល់ទ្រង់។

មនុស្សនឹងក្លាយជាសម្បត្តិដ៏ពិសេសរបស់ព្រះជាម្ចាស់។ ដោយសារព្រះជាម្ចាស់បានបង្កើតមនុស្សមក ទ្រង់ជាព្រះអាទិករផង ហើយក៏ជាម្ចាស់របស់ពួកគេផងដែរ។

ព្រះយេហូវ៉ាដ៏ជាព្រះបានដាក់ឈ្មោះឲ្យមនុស្សប្រុសដំបូងបង្អស់ថា អ័ដាម គឺមានន័យថា *ពីដី* ឬ *មនុស្ស*។ ក្រោយមក ព្រះជាម្ចាស់នឹងបង្កើតមនុស្សស្រីដំបូងបង្អស់ ប៉ុន្តែមានកិច្ចការខ្លះដែលត្រូវរៀបចំជាមុនសិន។

លោក អ័ដាម ត្រូវការជម្រក និងការងារ។





## ភាគទី៧
# ទីជម្រកដ៏ល្អឥតខ្ចោះ

ក្រោយពីព្រះជាម្ចាស់បានបង្កើតរូបកាយមនុស្សដំបូងបង្អស់ពីធូលីដី[៦] ហើយផ្លុំបញ្ចូលខ្យល់ដង្ហើមជីវិតរួចមក នោះទ្រង់ក៏ធ្វើសួនមួយនៅអេដែនក្នុងតំបន់មជ្ឈិមបូព៌ា។

មានទន្លេមួយថ្លាដូចកញ្ចក់បានហូរកាត់សួននោះ។

> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ក៏ធ្វើឲ្យដីដុះគ្រប់អស់ទាំងដើមឈើ ដែលគួរពិចពិលរមើលមើល ហើយសំរាប់ជាអាហារផង ក៏ដាំដើមជីវិត នឹងដើមសំរាប់ដឹងខុសត្រូវ នៅកណ្តាលសួនច្បារនោះដែរ។
>
> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកអ័ដាមទៅដាក់នៅក្នុងសួនច្បារអេដែន ឲ្យគាត់ធ្វើការ ហើយថែរក្សា។ (លោកុប្បត្តិ ២:៩, ១៥)

ព្រះយេហូវ៉ាមិនបានសួរលោក អ័ដាម ថា តើគាត់ចង់រស់នៅក្នុងសួនអេដែនដែរឬអត់នោះទេ។ ព្រះជាម្ចាស់ គឺជាព្រះអាទិករ និងជាម្ចាស់របស់មនុស្ស។ ទ្រង់បានជ្រាបថា អ្វីជាការល្អបំផុតសម្រាប់មនុស្ស។

សួនអេដែនដែលជាទីជម្រករបស់លោក អ័ដាម គឺពោរពេញទៅដោយសេចក្តីអំណរជានិរន្តរ៍ មានអ្វីៗជាច្រើនដែលមើលឃើញ ស្តាប់ឮ ដឹងក្លិន ប៉ះពាល់ និងភ្លក់ ដូចជាទឹកហូរចាំងចែង សម្លេងបក្សីយំ ផ្កាដ៏ក្រអូប សត្វមានរោម ផ្លែឈើមានទឹកច្រើន បន្លែដ៏ស្រួយ ព្រៃដ៏ស្តុកថ្មគ្រប់ពណ៌ សត្វល្អិតគួរឲ្យចាប់អារម្មណ៍ និងអ្វីៗដ៏អស្ចារ្យរាប់លានមុខ រង់ចាំតែមនុស្សស្វែងរកឲ្យឃើញ។

ប៉ុន្តែ ព្រះជាម្ចាស់បង្កើតមនុស្សមកក្នុងគោលបំណងលើសពីការរុករក និងការបរិភោគទៅទៀត។ ព្រះជាម្ចាស់បង្កើតលោក អ័ដាម ឲ្យធ្វើជាមេនៃមនុស្សជាតិ។ ព្រះជាម្ចាស់ចង់ឲ្យលោក អ័ដាម និងគ្រួសារគាត់សោយរាជ្យនឹងទ្រង់ជាដរាប ប៉ុន្តែមានតែមនុស្សស្មោះត្រង់នឹងកិច្ចការតូចប៉ុណ្ណោះ ដែលអាចទទួលកិច្ចការធំបាន។

ដូច្នេះ ព្រះជាម្ចាស់បានឲ្យលោក អ័ដាម ថែរក្សាសួនជាការងារដំបូង។

សួននេះជាកន្លែងដ៏ល្អឥតខ្ចោះ គ្មានបន្លា ឬអញ្ចាញ ឬក៏សត្វល្អិតចង្រៃ។ ជាតុអាកាសក៏ល្អ ហើយដីមានជីវជាតិ ទោះបើមិនដែលភ្លៀងក៏ដោយ តែមានចំហាយពីដីមកស្រោចស្រពលើផែនដី។

ព្រះជាម្ចាស់ក៏បានប្រទានការងារមួយទៀតដល់លោក អ័ដាម គឺការដាក់ឈ្មោះឲ្យគ្រប់សត្វ។

ព្រះយេហូវ៉ាបាននាំគ្រប់សត្វមកឯលោក អ័ដាម ដើម្បីឲ្យដឹងថា គាត់នឹងហៅឈ្មោះអ្វី។ ចូរស្រមៃមើល សត្វមួយគូរមានសក់វែងជាប់នឹងក និងជើងដ៏រឹងមាំ ដែលអាចបោលយ៉ាងលឿន។ លោក អ័ដាម បានសង្កេតទាំងអង្អែលខ្នង ហើយក៏ហៅឈ្មោះថា សត្វសេះ។ ពេលព្រះអាទិករហៅ នោះបក្សីធំមួយមានចំពុះកោង និងស្លាបវែងបានហើរមក នោះលោក អ័ដាម ហៅវាថា “សត្វឥន្ទ្រី!”។ បន្ទាប់មក មានសត្វមួយពណ៌ទឹកក្រូចលាយឆ្នូតខ្មៅដើរកាត់ពីមុខគាត់។ តើអ្នកគិតថា លោក អ័ដាម បានហៅឈ្មោះអ្វី?

> អ័ដាមដាក់ឈ្មោះឲ្យដល់គ្រប់ទាំងសត្វស្រុក សត្វព្រៃ នឹងសត្វហើរលើអាកាសទាំងប៉ុន្មានជាស្រេច។ (លោកុប្បត្តិ ២:២០)

សួនអេដែន គឺជាកន្លែងដ៏ល្អឥតខ្ចោះសម្រាប់ឲ្យមនុស្សស្គាល់ព្រះអាទិកររបស់ខ្លួន។

ឥឡូវនេះ ដល់ពេលត្រូវល្បងលលោក អ័ដាម ហើយ។





## ភាគទី៨
# អំណាចរបស់អំពើបាប និងសេចក្ដីស្លាប់

តាំងពីដើមដំបូង ព្រះជាម្ចាស់ និងមនុស្សជាមិត្តសម្លាញ់នឹងគ្នា តែមិត្តភាពនេះត្រូវល្បងល ជាមុនសិន។ ព្រះមហាក្សត្រនៃសកលលោកនឹងមិនឲ្យនគររបស់ទ្រង់ពេញដោយរាស្ត្រ ដែលត្រូវបង្ខំឲ្យចុះចូលនឹងទ្រង់នោះទេ។

ព្រះជាម្ចាស់ស្រឡាញ់លោក អ័ដាម ហើយក៏មានផែនការដ៏អស្ចារ្យសម្រាប់គាត់ និងគ្រួសាររបស់គាត់ផងដែរ។ ពីព្រោះព្រះជាម្ចាស់ចង់បានមនុស្ស មិនមែនជាតុក្កតាទេ ទើបទ្រង់បានប្រទានបញ្ញត្តិមួយឲ្យលោក អ័ដាម គោរពតាម។

> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បង្គាប់ទៅអ័ដាមថា "ឯងនឹងស៊ីផ្លែឈើទាំងអស់ក្នុងសួនច្បារនេះបានតាមចិត្ត។ តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឲ្យឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន"។ (លោកុប្បត្តិ ២:១៦-១៧)

នេះមិនមែនជាការបង្គាប់ដ៏ពិបាកនឹងធ្វើតាមនោះទេ។ លោក អ័ដាម អាចបរិភោគផ្លែឈើទាំងអស់ក្នុងសួនបាន *លើកលែងតែមួយប៉ុណ្ណោះ*។ ដោយធ្វើតាមបញ្ញត្តិដ៏សាមញ្ញនេះ លោក អ័ដាម អាចបង្ហាញថា គាត់ទុកចិត្តព្រះអាទិករ ដែលជ្រាបពីអ្វីដែលល្អបំផុតសម្រាប់គាត់។

តើព្រះជាម្ចាស់មានបន្ទូលថានឹងមានអ្វីកើតឡើង ប្រសិនបើគាត់រំលងបញ្ញត្តិនេះ?

តើព្រះជាម្ចាស់មានបន្ទូលប្រាប់លោក អ័ដាម ថា បើគាត់បរិភោគផ្លែឈើដែលទ្រង់ហាមនោះគាត់ត្រូវធ្វើបុណ្យ អុជធូប តមអាហារ ដាក់ទាន ទៅវត្ត និងព្យាយាមធ្វើល្អ ដើម្បីសងនឹងការអាក្រក់ដែរឬទេ? តើព្រះជាម្ចាស់បានមានបន្ទូលយ៉ាងដូច្នេះឬ?

ទេ! ព្រះជាម្ចាស់មិនបានមានបន្ទូលយ៉ាងដូច្នេះទេ!

ព្រះជាម្ចាស់មានបន្ទូលប្រាប់លោក អ័ដាម ថា "នៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវ*ស្លាប់*ជាមិនខាន"។

ការមិនស្ដាប់បង្គាប់តាមច្បាប់របស់ព្រះជាម្ចាស់ គឺហៅថា *អំពើបាប*។
ទោសនៃការរំលងបញ្ញត្តិរបស់ព្រះជាម្ចាស់ គឺជា *សេចក្ដីស្លាប់*។
ក្នុងសៀវភៅរបស់ទ្រង់ ព្រះមហាក្សត្រហៅការនេះថា
"អំណាចរបស់អំពើបាប និងសេចក្ដីស្លាប់" (រ៉ូម ៨:២)។

ច្បាប់របស់ព្រះមហាក្សត្រចែងថា អំពើបាបត្រូវជំនុំជម្រះដោយសេចក្ដីស្លាប់។

សេចក្ដីស្លាប់មានន័យថា *ការដាច់ចេញ*។ ប្រសិនបើលោក អ័ដាម មិនស្ដាប់បង្គាប់តាមបញ្ញត្តិតែមួយរបស់ព្រះជាម្ចាស់ទេ នោះគាត់នឹងក្លាយដូចជាមែកឈើបាក់ ដែលចាប់ផ្ដើមក្រៀមស្វិត ហើយងាប់ ខណៈដែលវាដាច់ចេញពីប្រភពនៃជីវិត។

ប្រសិនបើលោក អ័ដាម សម្រេចធ្វើតាមចិត្តខ្លួន ហើយមិនធ្វើតាមព្រះមហាក្សត្រនៃសកលលោក នោះគឺជាការបះបោរ ហើយនោះគឺជា *អំពើបាប*។

អំពើបាបនឹងផ្ដាច់មិត្តភាពរវាងមនុស្ស និងព្រះជាម្ចាស់។
អំពើបាបនឹងធ្វើឲ្យមនុស្សកាន់តែចាស់ទៅៗ ហើយស្លាប់។
អំពើបាបនឹងផ្ដាច់វិញ្ញាណ ព្រលឹង និងរូបកាយរបស់មនុស្សចេញពីព្រះជាម្ចាស់ជាដរាប។

អំពើបាប គឺបំផ្លាញជីវិត។





## ភាគទី៩
# មនុស្សស្រីដំបូងបង្អស់

ក្រោយពីព្រះជាម្ចាស់បានផ្ដល់ការងារ និងបញ្ញត្តិមួយដល់មនុស្សប្រុសដំបូងបង្អស់ នោះក៏ដល់ពេលត្រូវបង្កើតមនុស្សស្រីដំបូងបង្អស់ហើយ។

> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលថា “ដែលមនុស្សនេះនៅតែម្នាក់ឯង នោះមិនស្រួលទេ អញនឹងធ្វើឲ្យមានម្នាក់ជាជំនួយសម្រាប់ជួយវា”។
>
> នោះព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ធ្វើឲ្យអ័ដាមដេកលក់ស៊ប់ទៅ រួចទ្រង់យកឆ្អឹងជំនីរគាត់១ ហើយភ្ជិតសាច់ទៅវិញ។ រីឯឆ្អឹងដែលព្រះយេហូវ៉ាដ៏ជាព្រះបានយកពីអ័ដាមមក នោះទ្រង់ជបឲ្យកើតឡើងជាមនុស្សស្រី ក៏នាំទៅអ័ដាម។
>
> អ័ដាមក៏ថា “នេះហើយជាឆ្អឹងពីឆ្អឹងអញ ជាសាច់ពីសាច់អញ នឹងត្រូវហៅថា «ស្ត្រី» ពីព្រោះបានយកចេញពីបុរសមក”។ (លោកុប្បត្តិ ២:១៨, ២១-២៣)

តើអ្នកដឹងទេ នរណាបានធ្វើការវះកាត់មុនគេ ហើយរៀបចំអាពាហ៍ពិពាហ៍មុនគេ? មែនហើយ គឺជាព្រះជាម្ចាស់!

ស្ត្រីមានន័យថា *ចេញពីបុរស* ហើយក្រោយមក លោក អ័ដាម ហៅប្រពន្ធរបស់គាត់ថា អេវ៉ា គឺមានន័យថា *ម្ដាយនៃមនុស្សទាំងអស់*។ ព្រះជាម្ចាស់បានប្រទានឲ្យពួកគេមានតួនាទីខុសគ្នា ប៉ុន្តែទ្រង់បានបង្កើតមនុស្សប្រុសស្រីឲ្យមានតម្លៃស្មើគ្នា។ ដូចទៅនឹងលោក អ័ដាម ផងដែរ ព្រះជាម្ចាស់បានបង្កើតនាង អេវ៉ា ឲ្យចំនឹងរូបអង្គទ្រង់។ នាងក៏ត្រូវបានបង្កើតមកឲ្យស្គាល់ព្រះអាទិករដ៏ជាម្ចាស់របស់ខ្លួន ឆ្លុះបញ្ចាំងពីលក្ខណសម្បត្តិរបស់ទ្រង់ ហើយមានអំណរក្នុងទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយនឹងទ្រង់ជាដរាប។

> ព្រះទ្រង់ទតគ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ ក៏ឃើញថា ទាំងអស់ជាការល្អប្រពៃ នោះក៏មានល្ងាច មានព្រឹកឡើង ជាថ្ងៃទី៦។
>
> លុះដល់ថ្ងៃទី៧ ការដែលព្រះទ្រង់ធ្វើ នោះបានហើយជាស្រេច ទ្រង់ក៏ឈប់ផ្អាកសំរាកនៅថ្ងៃទី៧នោះ ពីគ្រប់ទាំងការដែលទ្រង់ធ្វើ។ (លោកុប្បត្តិ ១:៣១; ២:២)

ហេតុអ្វីបានជាព្រះជាម្ចាស់សម្រាកនៅថ្ងៃទី៧? ពីព្រោះកិច្ចការរបស់ទ្រង់បានហើយជាស្រេច។ ដោយបង្កើតលោកីយ៍ក្នុង៦ថ្ងៃ ហើយសម្រាកនៅថ្ងៃទី៧ ទ្រង់ក៏បានបង្កើតឲ្យ១អាទិត្យមាន ៧ថ្ងៃ មានទាំងថ្ងៃធ្វើការ និងថ្ងៃឈប់សម្រាកវិលជុំ ដែលជាការអនុវត្តទូទាំងសកលលោក។

ព្រះយេហូវ៉ាដ៏ជាព្រះបានថែរក្សាលោក អ័ដាម និងនាង អេវ៉ា ដូចជាឪពុកដ៏មានប្រាជ្ញា និងសេចក្ដីស្រឡាញ់។ រាល់ល្ងាច ទ្រង់បានយាងមកឯសួន ដើម្បីប្រកបជាមួយនឹងពួកគេ។ ពួកគេមានអំណរ និងភាពសុខសាន្តក្នុងវត្តមានរបស់ទ្រង់។

> អ័ដាមនឹងប្រពន្ធគាត់ក៏នៅជាអាក្រាតទទេ ឥតមានសេចក្ដីអៀនខ្មាសឡើយ។ (លោកុប្បត្តិ ២:២៥)

ចូរស្រមៃមើលពីផែនដីដ៏ល្អឥតខ្ចោះ ដែលមានប្ដីប្រពន្ធដ៏គ្រប់លក្ខណ៍ រស់នៅក្នុងភាពស្និទ្ធស្នាលជាមួយនឹងព្រះអាទិករដ៏ល្អឥតខ្ចោះ។ នេះជាស្ថានភាពនៅគ្រាដើមដំបូង។

ប៉ុន្តែ តើមានរឿងអ្វីបានកើតឡើង?





# ភាគទី១០
# នគរនៃពន្លឺ

មុននឹងយើងរកឃើញថា មានរឿងអាក្រក់អ្វីបានកើតឡើងនៅលើផែនដី យើងត្រូវយល់នូវចំណុចខ្លះៗអំពីស្ថានសួគ៌ជាមុនសិន។

ពិភពដ៏ពិសេសដាច់គេនេះក៏អាចហៅថា ស្ថានបរមសុខ ដែលជាកន្លែងពោរពេញដោយពន្លឺដ៏បរិសុទ្ធ ពណ៌ដ៏ស្រស់ស្អាត តន្ត្រីដ៏ពិរោះ សន្ទនាដ៏រីករាយ និងអាថ៌កំបាំងដ៏លាតត្រដាង។ ការតូចតាចបំផុតនៅឯស្ថានសួគ៌ក៏អស្ចារ្យលើសជាងអស់ទាំងការសប្បាយនៅលើផែនដីផងដែរ។ ស្ថានសួគ៌ គឺជាកន្លែងដ៏វិសេស ដែលរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។

ស្ថានសួគ៌ គឺជាដំណាក់នៃព្រះមហាក្សត្រ។

ចំណុចដ៏គួរឲ្យចាប់អារម្មណ៍បំផុតនៃកន្លែងដ៏សុខសាន្តនេះ គឺព្រះមហាក្សត្រទ្រង់ផ្ទាល់។ គ្រប់ផ្នែកនៃទីក្រុងស្ថានសួគ៌បានរចនាឡើង ដើម្បីបង្ហាញពីឫទ្ធានុភាពរបស់ទ្រង់។

> ទីក្រុងក៏ធ្វើពីមាសសុទ្ធ ដូចជាកែវថ្លាល្អ។ (វិវរណៈ ២១:១៨)

ការរៀបរាប់ដ៏លម្អិតអំពីស្ថានសួគ៌ មានកត់ត្រានៅក្នុងកណ្ឌគម្ពីរចុងក្រោយ គឺ *ព្រះគម្ពីរវិវរណៈ*។ ព្រះជាម្ចាស់បានសម្តែងឲ្យហោរា យ៉ូហាន ឃើញពីស្ថានសួគ៌ រួចបង្គាប់គាត់ឲ្យសរសេរអ្វីដែលគាត់បានឃើញ។

> ហើយឃើញមានបល្ល័ង្ក១ ដាក់នៅលើស្ថានសួគ៌ ក៏មាន១អង្គគង់នៅលើបល្ល័ង្កនោះ។ ...ក៏មានឥន្ទធនូនៅព័ទ្ធជុំវិញបល្ល័ង្ក ដែលមើលទៅដូចជាត្បូងមរកត។ ...មានផ្លេកបន្ទោរ សៀងសំឡេង នឹងផ្គរលាន់ចេញពីបល្ល័ង្ក១នោះមក...។ ឯនៅខាងមុខបល្ល័ង្កនោះ មានសមុទ្រកែវ ដូចជាកែវចរណៃ...។
>
> នោះខ្ញុំឃើញ ហើយក៏ឮសំឡេងទេវតាជាច្រើននៅជុំវិញបល្ល័ង្ក...ឯចំនួននៃទេវតានោះ មានទាំងម៉ឺនទាំងសែន ហើយទាំងពាន់រាប់ជាពាន់។ ...ក៏ចេះតែពោលពាក្យឥតឈប់ឈរ ទាំងយប់ទាំងថ្ងៃថា "បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ គឺព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្តាបំផុត ដែលទ្រង់គង់នៅតាំងតែពីដើម ក៏នៅឥឡូវនេះ ហើយត្រូវយាងមកទៀត"។
> (វិវរណៈ ៤:២-៣, ៥-៦; ៥:១១; ៤:៨)

ពាក្យថា ទេវតា គឺមានន័យថា *អ្នកនាំសារ* ឬ *អ្នកបម្រើ* ហើយពួកទេវតា គឺជាវិញ្ញាណ។ ដូចទៅនឹងព្រះអាទិករដែរ មនុស្សមើលពួកទេវតាមិនឃើញទេ លើកលែងតែពេលពួកគេមានបេសកកម្មដែលតម្រូវឲ្យឃើញប៉ុណ្ណោះ។

ព្រះមហាក្សត្រនៃស្ថានសួគ៌បានបង្កើតពួកទេវតា មុនពេលទ្រង់បានបង្កើតមនុស្សមក។ នៅក្នុងសៀវភៅរបស់ទ្រង់ ទ្រង់មានបន្ទូលប្រាប់យើងថា "ពពួកទេវតាបន្លឺសំឡេងយ៉ាងសប្បាយ" (យ៉ូប ៣៨:៧ គខប) ខណៈដែលពួកគេបានឃើញទ្រង់បង្កើតលោកីយ៍។

ព្រះជាម្ចាស់បានប្រទានឲ្យពួកទេវតាមានសមត្ថភាពស្គាល់ ស្តាប់បង្គាប់ សរសើរតម្កើង និងបម្រើទ្រង់ជាដរាប។ ពួកទេវតាមិនមែនជាទាសកររបស់ព្រះជាម្ចាស់ទេ។ ដូចទៅនឹងមនុស្សដែរ ព្រះជាម្ចាស់មិនបង្ខំពួកគេឲ្យចុះចូលនឹងទ្រង់ឡើយ។ ទ្រង់ចង់បានអ្នកបម្រើដែលបម្រើទ្រង់ដោយរីករាយ ហើយស្ម័គ្រពីចិត្ត។

ព្រះគម្ពីរប្រាប់យើងអំពីទេវតាមានឋានៈខ្ពស់មួយរូប ដែលព្រះជាម្ចាស់បានប្រទានប្រាជ្ញា រូបឆោម និងអំណាចដ៏អស្ចារ្យ។

បើអ្នកដឹងរឿងរ៉ាវពីទេវតានេះ នោះអ្នកនឹងដឹងថា សេចក្តីអាក្រក់បានកើតមកពីណា។





## ភាគទី១១
# នគរនៃសេចក្ដីងងឹត

លូស៊ីហ្វើរធ្លាប់ធ្វើជាមេទេវតាឋានៈដ៏ខ្ពស់មួយរបស់ព្រះជាម្ចាស់។ លូស៊ីហ្វើរមានន័យថា *ផ្កាយព្រឹក*។ បទគម្ពីររបស់ពួកហោរារៀបរាប់ថា លូស៊ីហ្វើរជា "អ្នកបំពេញខ្នាត ដោយមានប្រាជ្ញាពោរពេញ ហើយលំអគ្រប់លក្ខណ៍" (អេសេគាល ២៨:១២)។[៧]

លូស៊ីហ្វើរបានចាប់ផ្ដើមសម្លឹងមើលខ្លួនឯងជាជាងព្រះអាទិករ ដែលជាព្រះមហាក្សត្រដ៏ឧត្តម។ នេះជាលើកទីមួយ ដែលភាវៈទ្រង់បង្កើតមក មានអំនួតលើខ្លួនឯង! ដោយឈ្លក់វង្វេងនឹងរូបឆោម និងបញ្ញារបស់ខ្លួន ទាំងបំភ្លេចព្រះជាម្ចាស់ដែលបង្កើតខ្លួនមក នោះលូស៊ីហ្វើរគិតក្នុងចិត្តថា៖

> "អញនឹងដំកើងបល្ល័ង្កអញ ឲ្យខ្ពស់ជាងអស់ទាំងផ្កាយរបស់ព្រះ...។
> អញនឹងឡើងទៅផុតទីខ្ពស់នៃពពក
> អញនឹងលើកខ្លួនឲ្យបានដូចជាព្រះដ៏ខ្ពស់បំផុត។" (អេសាយ ១៤:១៣-១៤)

លូស៊ីហ្វើរចង់ធ្វើជាស្ដេច។ វាចង់សម្រេចតាម*បំណងរបស់វា* ជាជាងតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

អំពើបាបក៏បានចូលមកក្នុងសកលលោក។

លូស៊ីហ្វើរបានបបួល១ភាគ៣នៃពួកទេវតា ឲ្យចូលរួមជាមួយវាក្នុងការបះបោរ ប៉ុន្តែព្រះជាម្ចាស់ដែលមិនអនុញ្ញាតឲ្យមានអំពើបាបនៅចំពោះទ្រង់ បានបោះទម្លាក់ពួកវាឲ្យចុះពីស្ថានសួគ៌ដែលជាដំណាក់របស់ទ្រង់។

ឈ្មោះរបស់លូស៊ីហ្វើរបានដូរទៅជា សាតាំង មានន័យថា *អ្នកចោទប្រកាន់*។ វាក៏ត្រូវបានហៅថា អារក្ស មានន័យថា *អ្នកបោកបញ្ឆោត*។ រីឯពួកបរិវារវាត្រូវបានហៅថា ពួកអារក្ស។

នៅទីងងឹតដ៏អាថ៌កំបាំង ព្រះជាម្ចាស់បានរៀបចំគុកសម្រាប់សាតាំង និងពួកបរិវារវា។ កន្លែងនោះហៅថា ស្ថាននរក ឬបឹងភ្លើង។ វាជាកន្លែងដែលត្រូវដាច់ចេញពីព្រះជាម្ចាស់អស់កល្បជានិច្ច ហើយក៏ជាកន្លែងដែលពួកប្រឆាំងមិនអាចបង្កបញ្ហាបានទៀត។ នៅថ្ងៃមួយ សាតាំង និងពួកបរិវារវានឹងត្រូវឃុំក្នុងគុកនោះជាដរាប ប៉ុន្តែពួកវាមិនទាន់បានចូលទៅទីនោះនៅឡើយទេ។

ដូច្នេះ តើសាតាំង និងពួកបរិវារវាបានទៅកន្លែងណាវិញ ក្រោយពីព្រះជាម្ចាស់បានបោះទម្លាក់ពួកវាចុះមក?

ពួកវាបានប្ដូរទៅនៅក្នុងលំហនៃផែនដី។ នៅទីនោះ សាតាំងបានរៀបចំពួកបរិវារវាតាមឋានៈខុសៗគ្នា។ *បើវាគ្រប់គ្រងនៅស្ថានសួគ៌មិនបាន វានឹងគ្រប់គ្រងនៅលើផែនដីវិញ!* ហេតុនេះហើយបានជាព្រះគម្ពីរហៅសាតាំងថា "មេគ្រប់គ្រងរាជ្យលើអាកាស ជាវិញ្ញាណ ដែលសព្វថ្ងៃនេះ កំពុងត្រួតត្រាអស់អ្នកដែលមិនស្ដាប់បង្គាប់" (អេភេសូរ ២:២ គកស១៦)។

យើងមិនអាចមើលឃើញសាតាំង និងពួកបរិវារវាបានទេ ប៉ុន្តែពួកវាពិតជាមានមែន។ ទោះបីជាយើងមិនដឹងថា ពួកវាមានរូបរាងយ៉ាងណាក៏ដោយ ប៉ុន្តែយើងដឹងពីបំណងអាក្រក់របស់ពួកវា។ ពួកវានឹងប្រើគ្រប់ល្បិច ដើម្បីទាញមនុស្សឲ្យធ្លាក់ទៅក្នុងនគរនៃសេចក្ដីងងឹត និងសេចក្ដីហិនវិនាសរបស់ពួកវា។ ពួកវានឹងធ្វើគ្រប់បែបយ៉ាងដើម្បីបំផ្លាញអ្នក។

> អារក្សសាតាំងក៏ក្លែងខ្លួនធ្វើជាទេវតានៃពន្លឺដែរ។ (២កូរិនថូស ១១:១៤)

> អារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន។ (១ពេត្រុស ៥:៨)

ឥឡូវនេះ សូមត្រឡប់ទៅកាន់រឿងឪពុកម្ដាយដំបូងរបស់យើងវិញ។





# ភាគទី១២
# សត្វពស់

ជីវិតរបស់លោក អ័ដាម និងនាង អេវ៉ា ពេញទៅដោយគោលបំណង និងបទពិសោធន៍ថ្មីៗ។

ពីមួយថ្ងៃទៅមួយថ្ងៃ ជីវិតរបស់ពួកគេពេញទៅដោយភាពអស្ចារ្យ ខណៈដែលពួកគេរុករកក្នុងសួនដ៏ធំល្វឹងល្វើយ ទាំងថែរក្សាសត្វ និងរុក្ខជាតិ ហើយភ្លក់ផលផ្លែនៅទីនោះ។

អ្វីដែលអស្ចារ្យជាងនេះទៅទៀត គឺរាល់ល្ងាច ព្រះអាទិករដ៏ជាម្ចាស់របស់ពួកគេបានផ្តល់កិត្តិយស ដោយការយាងមកជួបដោយផ្ទាល់។ ពួកគេពេញចិត្តនឹងការប្រកបជាមួយទ្រង់ខ្លាំងណាស់! លោក អ័ដាម និងប្រពន្ធគាត់មានអំណរក្នុងសួន ដែលជាទីលំនៅរបស់ពួកគេ។

ប៉ុន្តែ សាតាំងវិញមិនសប្បាយចិត្តសោះ។ វាបានស្អប់ព្រះជាម្ចាស់ ហើយក៏ស្អប់មនុស្សទាំងពីរនាក់នេះ ដែលឆ្លុះបញ្ចាំងពីរូបអង្គទ្រង់!

ដូច្នេះ អារក្សដែលបានបរាជ័យក្នុងការដណ្តើមយកនគរស្ថានសួគ៌ ក៏មានឧបាយកលនឹងដណ្តើមយកនគរផែនដីវិញម្តង៖ *គឺមានតែធ្វើឲ្យលោក អ័ដាម ដែលជាមេនៃមនុស្សជាតិជ្រើសរើសយកការរំលងច្បាប់របស់ព្រះជាម្ចាស់។ ប៉ុន្តែ វានឹងមិនល្បួងលោក អ័ដាម ដោយផ្ទាល់ទេ...*

នៅថ្ងៃមួយ នាង អេវ៉ា បានឮសម្លេងមួយ។

វាមិនមែនជាសម្លេងរបស់លោក អ័ដាម ហើយក៏មិនមែនជាសម្លេងរបស់ព្រះជាម្ចាស់ដែរ។

វាជាសម្លេងរបស់សត្វពស់!

ចំពោះនាង អេវ៉ា ការជួបសត្វលូនវារដែលចេះនិយាយនោះ គឺគ្រាន់តែជាបទពិសោធន៍ថ្មីមួយទៀតប៉ុណ្ណោះ។ នាងមិនបានដឹងទេថា ខ្មាំងសត្រូវរបស់ព្រះជាម្ចាស់កំពុងប្រើសត្វពស់នេះ។ នាងក៏មិនបានដឹងថា វាចង់ប្រើនាង ដើម្បីល្បួងលោក អ័ដាម ឲ្យរំលងច្បាប់របស់ព្រះជាម្ចាស់ដែរ។

សត្វពស់បានរង់ចាំឱកាសយ៉ាងយូរ ហើយភ្នែកវាបានតាមសម្លឹងមើលនាងរហូត។ លុះមានឱកាសល្អ វាក៏ខ្សឹបទៅនាងថា៖

> “តើព្រះមានបន្ទូលហាមមិនឲ្យអ្នកបរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ?” (លោកុប្បត្តិ ៣:១)

សាតាំងចង់ឲ្យនាង អេវ៉ា សង្ស័យព្រះបន្ទូលរបស់ព្រះជាម្ចាស់។ វាក៏ចង់ឲ្យនាងគិតថា ព្រះជាម្ចាស់កំពុងតែលាក់អ្វីដែលល្អពីនាង និងប្តីនាង។

> ស្ត្រីឆ្លើយតបថា “យើងបរិភោគអស់ទាំងផ្លែឈើនៅក្នុងសួនច្បារបាន។ តែត្រង់ដើមឈើ១ដែលនៅកណ្តាលសួនច្បារនោះ ព្រះទ្រង់មានបន្ទូលថា «កុំឲ្យបរិភោគផ្លែនោះឡើយ ថែមទាំងកុំឲ្យពាល់ប៉ះផង ក្រែងលោស្លាប់»”។
>
> រួចពស់ក៏និយាយទៅស្ត្រីថា “អ្នកមិនស្លាប់ជាពិតមែនទេ។ ដ្បិតព្រះទ្រង់ជ្រាបថា នៅថ្ងៃណាដែលអ្នកបរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹងបានដូចជាព្រះដែរ ព្រមទាំងដឹងការខុសត្រូវផង”។ (លោកុប្បត្តិ ៣:២-៥)

តើនាង អេវ៉ា នឹងធ្វើយ៉ាងដូចម្តេច?





# ភាគទី១៣
# ជម្រើស

ព្រះជាម្ចាស់បានប្រទានសេរីភាពដល់លោក អ័ដាម និងនាង អេវ៉ា ឲ្យជ្រើសរើសធ្វើតាមព្រះហឫទ័យទ្រង់ ឬតាមចិត្តពួកគេ។

ព្រះយេហូវ៉ាបានជ្រាបថា អ្វីជាការល្អបំផុតសម្រាប់ទាំងពីរនាក់ជាស្នាព្រះហស្តដ៏វិសេស ដែលទ្រង់បានបង្កើតឲ្យចំនឹងរូបអង្គទ្រង់។ ព្រះជាម្ចាស់ចង់ឲ្យលោក អ័ដាម និងនាង អេវ៉ា ទុកចិត្តលើទ្រង់ ទោះបើពួកគេមិនយល់ពីហេតុផលនៃបញ្ញត្តិរបស់ទ្រង់ក៏ដោយ។

មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលជ្រាបពីលទ្ធផលដ៏ស្វែងខ្លាចនៃសេចក្តីអាក្រក់ ដូច្នេះហើយបានជាទ្រង់មានបន្ទូលទៅលោក អ័ដាម ថា៖

> “ត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឲ្យឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន។” (លោកុប្បត្តិ ២:១៦-១៧)

ប៉ុន្តែ ពេលនោះ សត្វពស់ប្រាប់ទៅនាង អេវ៉ា ថា៖

> “អ្នកមិនស្លាប់ជាពិតមែនទេ។” (លោកុប្បត្តិ ៣:៤)

តើនាងគួរជឿទុកចិត្តលើអ្នកណា? ព្រះអាទិករ ឬសត្វដែលទ្រង់បានបង្កើតមក?

នេះជាអ្វីដែលបានកើតឡើង៖

> កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក
> ហើយជាដើមដែលល្អមគួរនឹងចង់បាន ដើម្បីឲ្យបានប្រាជ្ញា
> នោះនាងក៏យកផ្លែមកបរិភោគ ព្រមទាំងចែកឲ្យដល់ប្តីដែរ
> គាត់ក៏បរិភោគតាម។ (លោកុប្បត្តិ ៣:៦)

នាង អេវ៉ា បានបរិភោគ! លោក អ័ដាម ក៏បានបរិភោគដែរ!

នាង អេវ៉ា បានបរិភោគផ្លែឈើដែលព្រះជាម្ចាស់ហាម ព្រោះនាងបានចាញ់ល្បិចរបស់សាតាំង។ លោក អ័ដាម ក៏បានបរិភោគដែរ ពីព្រោះគាត់បានតាំងចិត្តជ្រើសរើសទៅតាមផ្លូវរបស់ខ្លួនជាជាងផ្លូវរបស់ព្រះជាម្ចាស់។

មនុស្សជាតិមិនបានចុះចូលនឹងព្រះអាទិករដ៏បរិសុទ្ធ និងពេញដោយសេចក្តីស្រឡាញ់នោះទេ តែបែរជាចុះចូលនឹងខ្មាំងសត្រូវវិញ។

ឪពុកម្តាយដំបូងបង្អស់របស់យើងបានធ្វើបាប។





# ភាគទី១៤
# អំពើបាប និងសេចក្តីអាម៉ាស់

លោក អ័ដាម ត្រូវបានតាំងឡើងជាមេនៃមនុស្សជាតិ។ គាត់នេះហើយ ដែលព្រះជាម្ចាស់បានប្រទានសេចក្តីបង្គាប់មិនឲ្យបរិភោគផ្លែនៃដើមដឹងខុសត្រូវ។ ក្រោយពីលោក អ័ដាម បានខាំផ្លែឈើដែលព្រះជាម្ចាស់ហាមនោះហើយ ទើបគាត់ និងប្រពន្ធគាត់ចាប់ផ្តើមជួបលទ្ធផលដ៏គួរឲ្យស្វែងខ្លាចនៃជម្រើសរបស់ពួកគេ។

> ពេលនោះ ស្រាប់តែភ្នែករបស់អ្នកទាំងពីរបានភ្លឺឡើង ហើយគេដឹងថា គេនៅខ្លួនទទេ ហើយគេក៏យកស្លឹកល្វាមកខ្ទាស់ ធ្វើជាប៉ឹងបិទបាំងកាយ។ (លោកុប្បត្តិ ៣:៧ គកស១៦)

ភាពអាម៉ាស់ និងកំហុសដ៏គួរឲ្យឈឺចាប់បានចូលពេញក្នុងព្រលឹងរបស់ពួកគេ។ ពួកគេបានដឹងថា ខ្លួនកខ្វក់ទាំងខាងក្នុង និងខាងក្រៅ។

អំពើបាបបាននាំឲ្យមានសេចក្តីអាម៉ាស់។

មុនពេលលោក អ័ដាម និងនាង អេវ៉ា រំលងច្បាប់របស់ព្រះជាម្ចាស់ នោះពួកគេបានផ្តោតលើព្រះជាម្ចាស់ ហើយ “ឥតមានសេចក្តីអៀនខ្មាសឡើយ” (លោកុប្បត្តិ ២:២៥)។ ពួកគេបានទទួលកិត្តិយសឲ្យនៅជាមួយព្រះអាទិកររបស់ខ្លួន  ឆ្លុះបញ្ចាំងពីរូបអង្គទ្រង់ និងធ្វើជាមិត្តសម្លាញ់របស់ទ្រង់។

ប៉ុន្តែ នៅពេលដែលពួកគេបានបរិភោគផ្លែនៃដើមដឹងខុសត្រូវហើយ នោះពួកគេចាប់ផ្តើមផ្តោតលើខ្លួនឯង ហើយមានសេចក្តីអៀនខ្មាសវិញ។

សេចក្តីអាម៉ាស់បានចូលមកជំនួសកិត្តិយស។

ពួកគេព្យាយាមបិទបាំងភាពអាម៉ាស់ដោយស្លឹកល្វា ប៉ុន្តែទោះបីជាពួកគេខិតខំប្រឹងប្រែងដោយខ្លួនឯងយ៉ាងណាក៏ដោយ ក៏មិនអាចដោះស្រាយបញ្ហារបស់ពួកគេបានឡើយ។ ពួកគេគ្មានសង្ឃឹមនឹងលុបបំបាត់អំពើបាប ដែលបានចូលពេញក្នុងព្រលឹងរបស់ពួកគេទេ។ ពួកគេក៏គ្មានសង្ឃឹមនឹងស្តារកិត្តិយស ដែលពួកគេបានបាត់បង់នោះដែរ។

នោះក៏ដល់ពេលរសៀលហើយ។

បន្តិចទៀត ព្រះអាទិករដ៏បរិសុទ្ធ និងពេញដោយសេចក្តីស្រឡាញ់នឹងយាងមកជួប។ ពួកគេមានចិត្តភ័យញាប់ញ័រ ពេលនឹកដល់ការជួបជាមួយទ្រង់។

តើទ្រង់នឹងមានបន្ទូលទៅពួកគេយ៉ាងដូចម្តេច?

តើពួកគេនឹងទូលទៅទ្រង់យ៉ាងដូចម្តេច?





# ភាគទី១៥
# សេចក្ដីស្លាប់ខាងឯវិញ្ញាណ

មុនពេលពួកគេមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ នោះលោក អ័ដាម និងនាង អេវ៉ា មានអំណរនឹងជួបជាមួយព្រះអាទិករដ៏ជាមិត្តសម្លាញ់របស់ពួកគេ រាល់ពេលដែលទ្រង់យាងមក។

ឥឡូវនេះ ពួកគេមានចិត្តភ័យខ្លាចវិញ។

> រួចមកបានឮសំឡេងព្រះយេហូវ៉ាដ៏ជាព្រះ ដែលទ្រង់យាងក្នុងសួនច្បារនៅពេលថ្ងៃល្ងើយ នោះអ័ដាម នឹងប្រពន្ធគាត់ ក៏ពួននឹងព្រះយេហូវ៉ាដ៏ជាព្រះនៅកណ្ដាលដើមឈើក្នុងសួនច្បារ។ (លោកុប្បត្តិ ៣:៨)

ដូចដែលកូនមិនបានស្ដាប់បង្គាប់ព្យាយាមពួនពីឪពុកម្ដាយជាយ៉ាងណា នោះលោក អ័ដាម និងនាង អេវ៉ា ក៏ព្យាយាមពួនពីព្រះអាទិកររបស់ពួកគេយ៉ាងនោះដែរ។

> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ហៅរកអ័ដាមដោយបន្ទូលថា “ឯងនៅឯណា?”។
>
> គាត់ទូលឆ្លើយថា “ទូលបង្គំបានឮសំឡេងទ្រង់នៅក្នុងសួនច្បារ ក៏រត់ទៅពួន ដោយនឹកភ័យខ្លាច ពីព្រោះនៅខ្លួនទទេ”។
>
> នោះព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលសួរថា “តើអ្នកណាប្រាប់ឲ្យឯងដឹងថាឯងនៅខ្លួនទទេដូច្នេះ? តើឯងបានស៊ីផ្លែឈើដែលអញហាមមិនឲ្យស៊ីឬអី?”។
>
> អ័ដាមទូលទ្រង់ថា “ស្ត្រីដែលទ្រង់បានប្រទានឲ្យនៅជាមួយនឹងទូលបង្គំ វាឲ្យផ្លែឈើនោះមកទូលបង្គំ ទូលបង្គំក៏ទទួលទានទៅ”។
>
> រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលសួរទៅស្ត្រីថា “ឯងបានធ្វើអ្វីដូច្នេះ?”
>
> នាងទូលឆ្លើយថា “ពស់វាមកល្បួងបញ្ឆោតខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់បានទទួលទាន”។ (លោកុប្បត្តិ ៣:៩-១៣)

ហេតុអ្វីបានជាលោក អ័ដាម និងនាង អេវ៉ា ចង់ពួនពីព្រះជាម្ចាស់? ពីព្រោះពួកគេបានធ្វើបាប។ ហេតុអ្វីបានជាពួកគេទម្លាក់កំហុសដាក់គ្នាទៅវិញទៅមក? ពីព្រោះពួកគេអៀនខ្មាស។

លោក អ័ដាម និងនាង អេវ៉ា លែងបានបង្ហាញរូបអង្គទ្រង់ដ៏បរិសុទ្ធទៀតហើយ។ ជំនួសឲ្យការឆ្លុះបញ្ចាំងពីភាពបរិសុទ្ធ និងសេចក្ដីស្រឡាញ់របស់ព្រះអាទិករ ឥឡូវនេះ ពួកគេបានឆ្លុះបញ្ចាំងពីការបះបោរ និងអំនួតរបស់អារក្សវិញ។

ប្ដីប្រពន្ធដំបូងបង្អស់នេះបានក្លាយដូចជាមែកឈើ ដែលដាច់ចេញពីដើមដ៏រស់។ អំពើបាបរបស់ពួកគេបានផ្ដាច់ទំនាក់ទំនងជាមួយនឹងព្រះមហាក្សត្រនៃសកលលោក។

ខាងឯវិញ្ញាណ ពួកគេបានស្លាប់បាត់ហើយ។ អំពើបាបរបស់ពួកគេបានផ្ដាច់ពួកគេចេញពីព្រះជាម្ចាស់ដ៏ជាប្រភពនៃជីវិតអស់កល្បជានិច្ច។

ខាងឯរូបកាយ ពួកគេនៅមានជីវិត ប៉ុន្តែពួកគេចាប់ផ្ដើមចាស់ទៅៗហើយ។ អំណាចរបស់សេចក្ដីស្លាប់បានចូលវាយលុកក្នុងរូបកាយរបស់ពួកគេ។

តើអ្វីជាមូលហេតុដែលបណ្ដាលឲ្យមានសេចក្ដីស្លាប់ និងសេចក្ដីវិនាសទាំងនេះ?

គឺអំពើបាប។





# ភាគទី១៦
# បណ្តាសា

នៅគ្រាដើមដំបូងនៃប្រវត្តិសាស្ត្រមនុស្សជាតិ ព្រះជាម្ចាស់ និងមនុស្សបាននៅជាមួយគ្នា ហើយក៏ពោរពេញដោយសន្តិភាព និងអំណរ។ ប៉ុន្តែ មនុស្សបានរំលងច្បាប់របស់ព្រះជាម្ចាស់។

នៅថ្ងៃដដែល ដែលលោក អ័ដាម និងនាង អេវ៉ា បានធ្វើបាប នោះព្រះជាម្ចាស់បានប្រកាសអំពីលទ្ធផលដ៏ធ្ងន់ធ្ងរនៃអំពើបាបរបស់ពួកគេ។

ទ្រង់មានបន្ទូលទៅស្ត្រីថា៖

> “ឯងនឹងបង្កើតកូនដោយឈឺចាប់ ចិត្តឯងនឹងប្រាថ្នាខាងឯងប្តី
> ហើយប្តីនឹងត្រូវត្រួតត្រាលើឯង។” (លោកុប្បត្តិ ៣:១៦)

មុនពេលអំពើបាបបានចូលមក នាង អេវ៉ា ត្រេកអរនឹងសេចក្តីស្រឡាញ់ និងការថ្នាក់ថ្នមរបស់ប្តីដែលចេះលះបង់ ប៉ុន្តែនៅពេលនេះ និស្ស័យបាបរបស់ពួកគេនឹងនាំឲ្យមានជម្លោះ និងការឈឺចាប់នៅក្នុងជីវិតអាពាហ៍ពិពាហ៍។

បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលទៅលោក អ័ដាម ថា៖

> “ដីត្រូវបណ្តាសាដោយព្រោះឯង ឯងត្រូវរកស៊ីពីដីដោយនឿយហត់អស់១ជីវិត។ ដីនឹងដុះជាបន្លា ហើយនឹងអញ្ចាញឲ្យឯង...។ ឯងនឹងបានអាហារស៊ីដោយការបែកញើស ដរាបដល់ឯងត្រឡប់ទៅជាដីវិញ ពីព្រោះអញបានយកឯងពីដីមក ដ្បិតឯងជាធូលីដី ក៏ត្រូវត្រឡប់ទៅជាធូលីដីវិញ។” (លោកុប្បត្តិ ៣:១៧-១៩)

ដោយព្រោះអំពើបាបរបស់ពួកគេ លោក អ័ដាម និងនាង អេវ៉ា បានបាត់បង់អំណាចគ្រប់គ្រងលើផែនដីហើយ។ ឥឡូវនេះ លោកីយ៍របស់ពួកគេនឹងមានបន្លា ការឈឺចាប់ ទុក្ខសោក ជំងឺ និងសេចក្តីស្លាប់។

អ្នកខ្លះធ្លាប់មានការវេទនាបែបនេះជាច្រើន បានជាពួកគេគិតថា វាជារឿងធម្មតា។ ប៉ុន្តែ តើការរចនាដំបូងរបស់ព្រះជាម្ចាស់ បានតម្រូវឲ្យកុលាបដ៏ក្រអូបមានបន្លាមុតដែរឬទេ? ឬតម្រូវឲ្យការបង្កើតកូនដ៏អស្ចារ្យមានការឈឺចាប់ខ្លាំងឬ? ឬក៏តម្រូវឲ្យមនុស្សដែលបង្កើតមកដូចរូបអង្គទ្រង់ ទៅជាចាស់ ហើយស្លាប់ដែរឬទេ? ទេ! ព្រះជាម្ចាស់គ្មានបំណងឲ្យរបស់ដែលទ្រង់បង្កើតមកប្រឆាំងនឹងខ្លួនឯងនោះទេ។ ដោយព្រោះអំពើបាបរបស់មនុស្ស ផែនដីត្រូវស្ថិតនៅក្រោមបណ្តាសារបស់ព្រះជាម្ចាស់។

មនុស្សបានធ្វើបាប ដូច្នេះមនុស្សត្រូវតែស្លាប់។
អំណាចរបស់អំពើបាប និងសេចក្តីស្លាប់តម្រូវយ៉ាងដូច្នេះឯង។

សេចក្តីស្លាប់ គឺជាការដាច់ចេញ។ អំពើបាបនាំឲ្យមានការដាច់ចេញដ៏អាក្រក់៣យ៉ាង៖

១. សេចក្តីស្លាប់ខាងឯវិញ្ញាណ៖ វិញ្ញាណរបស់មនុស្សត្រូវដាច់ចេញពីព្រះជាម្ចាស់។
២. សេចក្តីស្លាប់ខាងឯរូបកាយ៖ ព្រលឹង និងវិញ្ញាណរបស់មនុស្សត្រូវដាច់ចេញពីរូបកាយ និងមនុស្សជាទីស្រឡាញ់។
៣. សេចក្តីស្លាប់ដ៏អស់កល្បជានិច្ច៖ ព្រលឹង វិញ្ញាណ និងរូបកាយរបស់មនុស្សត្រូវដាច់ចេញពីព្រះជាម្ចាស់ជាដរាបនៅក្នុងបឹងភ្លើង។[៨]

មនុស្សគ្មានផ្លូវណាដើម្បីសង្គ្រោះខ្លួនឯង ឲ្យរួចពីបណ្តាសានៃអំពើបាបបានឡើយ។

តើមនុស្សមានសង្ឃឹមដែរឬទេ?





# ភាគទី១៧
# សេចក្ដីសន្យា

សាតាំងបានលួចសម្បត្តិដ៏ពិសេសរបស់ព្រះមហាក្សត្រហើយ ប៉ុន្តែទ្រង់មានផែនការដ៏អាថ៌កំបាំងដើម្បីទិញមកវិញ។ ដោយសារថ្លៃលោះដែលព្រះមហាក្សត្របានរៀបចំនឹងបង់នោះ មានតម្លៃហួសប្រមាណ ទើបមនុស្ស ឬពួកអារក្សមិនអាចយល់ពីផែនការរបស់ទ្រង់រហូតដល់ការនោះបានសម្រេច។

នៅថ្ងៃដែលសាតាំងបានដណ្ដើមយកមនុស្សជាតិ ព្រះជាម្ចាស់មានបន្ទូលទៅសត្វពស់ថា៖

> “ដោយព្រោះឯងធ្វើដូច្នេះ នោះនៅក្នុងអស់ទាំងពួកសត្វស្រុក សត្វព្រៃ ឯងជាសត្វត្រូវបណ្ដាសាហើយ គឺឯងត្រូវលូនតែនឹងពោះ ហើយត្រូវស៊ីធូលីដីអស់១ជីវិត។”
> (លោកុប្បត្តិ ៣:១៤)

ពេលព្រះជាម្ចាស់បង្កើតសត្វពស់មក គឺវាមានជើង។ ដោយសារសាតាំងបានប្រើសត្វពស់ដើម្បីល្បួងមនុស្សជាតិឲ្យធ្លាក់ក្នុងអំពើបាប នោះព្រះជាម្ចាស់បានដាក់បណ្ដាសាវាឲ្យលូនលើដី។ (តើអ្នកបានដឹងទេថា ពស់ថ្លាន់មានស្នាមសម្គាល់ជើងនៅក្រោមពោះរបស់វា?) ដោយការដាក់បណ្ដាសាសត្វពស់ឲ្យទៅជាសត្វទាបបំផុត ព្រះជាម្ចាស់បានបង្ហាញដល់មនុស្សជាតិឲ្យដឹងថា ដល់ពេលកំណត់របស់ទ្រង់ នោះទ្រង់នឹងកម្ទេច “ពស់ពីបុរាណដែលឈ្មោះហៅថា អារក្ស ហើយសាតាំងផង ដែលបាននាំលោកីយទាំងមូលឲ្យវង្វេងចេញ” (វិវរណៈ១២:៩)។

រួចមក ព្រះជាម្ចាស់មានបន្ទូលទៅសាតាំង ដែលបានប្រើសត្វពស់ថា៖

> “អញនឹងធ្វើឲ្យឯង ហើយនឹងស្ត្រី គឺទាំងពូជឯង នឹងពូជនាងមានសេចក្ដីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ។” (លោកុប្បត្តិ ៣:១៥)

នេះជាទំនាយដំបូងបង្អស់ក្នុងចំណោមទំនាយជាច្រើន ដែលព្រះជាម្ចាស់នឹងបើកសម្ដែងបន្តិចម្ដងៗ ឲ្យយើងដឹងអំពីផែនការដ៏អាថ៌កំបាំងរបស់ទ្រង់  ដើម្បីសង្គ្រោះមនុស្សពីសាតាំង ពីអំពើបាប និងពីសេចក្ដីស្លាប់។ ប៉ុន្តែ ដើម្បីលាក់បាំងផែនការនោះពីសាតាំង និងពួកបរិវារវា ព្រះមហាក្សត្របានដាក់ទំនាយនេះនៅក្នុងរូបភាពដ៏សម្ងាត់។

ព្រះជាម្ចាស់បានសន្យានឹងចាត់ព្រះសង្គ្រោះ ដែលជា*ពូជស្ត្រី* ឲ្យយាងមកលើផែនដី។ ព្រះសង្គ្រោះនេះនឹងមានម្ដាយជាមនុស្ស តែគ្មានឪពុកជាមនុស្សទេ។ គេនឹងស្គាល់ទ្រង់ជាព្រះមេស្ស៊ី ដែលមានន័យថា *អ្នកដែលព្រះជាម្ចាស់បានរើសតាំង*។ សាតាំងនឹងចឹកកែងជើងព្រះមេស្ស៊ី ប៉ុន្តែព្រះមេស្ស៊ីនឹងកិនក្បាលសាតាំងវិញ។

តើទាំងអស់នេះមានន័យយ៉ាងដូចម្ដេច? នាពេលខាងមុខ ព្រះមហាក្សត្រនឹងបើកសម្ដែងឲ្យឃើញយ៉ាងច្បាស់ ប៉ុន្តែសម្រាប់ពេលនេះ ព្រះជាម្ចាស់បានប្រទានពន្លឺនៃក្ដីសង្ឃឹមដល់លោកអ័ដាម និងនាង អេវ៉ា។

រាប់ពាន់ឆ្នាំក្រោយមក ហោរាម្នាក់របស់ព្រះមហាក្សត្របានសរសេរថា៖

> បណ្ដាជនដែលដើរក្នុងសេចក្ដីងងឹត គេបានឃើញពន្លឺយ៉ាងធំ...។ នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយនឹងឲ្យព្រះនាមថា អេម៉ាញូអែល (ដែលប្រែថា ព្រះអង្គទ្រង់គង់ជាមួយនឹងយើងខ្ញុំ)។ (អេសាយ ៩:២, ៧:១៤)

ព្រះមហាក្សត្រនឹងលោះ៩សម្បត្តិដ៏ពិសេសរបស់ទ្រង់មកវិញ។
ប៉ុន្តែ តើទ្រង់នឹងលោះដោយបង់ថ្លៃប៉ុន្មាន?





## ភាគទី១៨
# យញ្ញបូជាដំបូងបង្អស់

តើអ្នកចាំអ្វីដែលលោក អ័ដាម និងនាង អេវ៉ា បានធ្វើ ក្រោយពេលពួកគេបរិភោគផ្លែឈើដែលព្រះជាម្ចាស់ហាមដែរឬទេ? ពួកគេបានយកស្លឹកល្វាមកធ្វើជារបស់បិទបាំង។

តើរបស់បិទបាំងនេះបានធ្វើឲ្យពួកគេមានអារម្មណ៍សុខស្រួល ក្នុងវត្តមានរបស់ព្រះអាទិករដ៏ជាចៅក្រមដែរឬទេ? ទេ! ពួកគេមានអារម្មណ៍ថាមានកំហុស ហើយអៀនខ្មាស។ ពួកគេគ្មានផ្លូវណាដើម្បីផ្សះផ្សាជាមួយព្រះជាម្ចាស់បានឡើយ។

ដូច្នេះ ព្រះជាម្ចាស់បានធ្វើអ្វីមួយសម្រាប់ពួកគេ។

> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ក៏ធ្វើអាវពីស្បែក ឲ្យអ័ដាម នឹងប្រពន្ធគាត់ពាក់បិទបាំងកាយ។ (លោកុប្បត្តិ ៣:២១)

តើនរណាបានយកសត្វមកធ្វើជាយញ្ញបូជាមុនគេបង្អស់? គឺព្រះជាម្ចាស់!

ព្រះយេហូវ៉ាបានសម្លាប់សត្វ រួចធ្វើអាវពីស្បែកសត្វនោះ ហើយយកមកបំពាក់ឲ្យលោក អ័ដាម និងនាង អេវ៉ា។ ដោយធ្វើបែបនេះ ព្រះជាម្ចាស់បានបង្រៀនមេរៀនសំខាន់ៗដល់ពួកគេ អំពីសេចក្ដីយុត្តិធម៌ សេចក្ដីមេត្តាករុណា និងព្រះគុណរបស់ទ្រង់។

ចូរគិតពិចារណាអំពីពាក្យដ៏សំខាន់ទាំង៣នេះ៖

> *សេចក្ដីយុត្តិធម៌*៖ ចូរមើលសត្វដែលបានងាប់។ ហេតុអ្វីបានជាព្រះជាម្ចាស់សម្លាប់សត្វទាំងនោះ? គឺដើម្បីបង្ហាញលោក អ័ដាម និងនាង អេវ៉ា ថា ច្បាប់នៃអំពើបាប និងសេចក្ដីស្លាប់ត្រូវអនុវត្តតាម។ អំពើបាបរបស់ពួកគេត្រូវជំនុំជម្រះដោយសេចក្ដីស្លាប់។ នេះហើយជាសេចក្ដីយុត្តិធម៌។
>
> *សេចក្ដីមេត្តាករុណា*៖ ចូរមើលលោក អ័ដាម និងនាង អេវ៉ា។ តើព្រះជាម្ចាស់បានសម្លាប់ពួកគេដែរឬទេ? ទេ! ព្រះជាម្ចាស់បានប្រទានសត្វឲ្យងាប់ជំនួសពួកគេវិញ។ នេះជារបៀបដែលព្រះជាម្ចាស់ជំនុំជម្រះអំពើបាបរបស់ពួកគេ ដោយមិនជំនុំជម្រះពួកគេផ្ទាល់។ នេះហើយជាសេចក្ដីមេត្តាករុណា។
>
> *ព្រះគុណ*៖ ចូរមើលសម្លៀកបំពាក់ដ៏ល្អរបស់លោក អ័ដាម និងនាង អេវ៉ា។ តើអ្នករំលងច្បាប់ទាំងពីរនាក់នេះ សមនឹងទទួលអំណោយនេះដែរឬទេ? ទេ! ប៉ុន្តែ ព្រះជាម្ចាស់បានបង្ហាញសេចក្ដីសប្បុរស ដោយបំពាក់ពួកគេនឹងស្បែករបស់សត្វដែលត្រូវបានសម្លាប់។ នេះហើយជាព្រះគុណ។

តាមរយៈអ្វីដែលព្រះយេហូវ៉ាបានធ្វើសម្រាប់ពួកគេ នោះលោក អ័ដាម និងនាង អេវ៉ា មានអំណរជាមួយនឹងព្រះជាម្ចាស់សាជាថ្មី!

ឈាមសត្វបានបិទបាំង *អំពើបាប* របស់ពួកគេ។ លោក អ័ដាម និងនាង អេវ៉ា សមនឹងស្លាប់នៅថ្ងៃនោះ ប៉ុន្តែសត្វដែលគ្មានទោសបានងាប់ជំនួសពួកគេវិញ។

អាវធ្វើពីស្បែកសត្វបានបិទបាំង *ភាពអាម៉ាស់* របស់ពួកគេ។ លោក អ័ដាម និងនាង អេវ៉ា ក៏មានភាពសុខសាន្ត នៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ម្ដងទៀត។

រាប់ពាន់ឆ្នាំក្រោយមក ហោរាម្នាក់របស់ព្រះជាម្ចាស់បានសរសេរថា៖

> ព្រលឹងខ្ញុំនឹងរីករាយចំពោះព្រះនៃខ្ញុំ ពីព្រោះទ្រង់បានប្រដាប់ខ្លួនខ្ញុំដោយសំលៀកបំពាក់នៃសេចក្ដីសង្គ្រោះ ទ្រង់បានគ្រលុំខ្ញុំដោយអាវជាសេចក្ដីសុចរិត។ (អេសាយ ៦១:១០)

មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចធ្វើឲ្យមនុស្សមានបាបបានសុចរិតវិញ។





# ភាគទី១៩
# ការបណ្ដេញចេញ

ពេលព្រះជាម្ចាស់បណ្ដេញពួកទេវតាដែលបះបោរឲ្យចេញពីស្ថានសួគ៌ នោះទ្រង់ក៏បានប្រកាសសេចក្ដីវិនាសដល់ពួកវា។ ពួកវិញ្ញាណដែលធ្លាប់រស់នៅក្នុងភាពរុងរឿងនៃស្ថានសួគ៌ មិនអាចដោះសារចំពោះអំពើបាបរបស់ពួកវាបានឡើយ។ ប៉ុន្តែ ចំពោះមនុស្សមានបាប នោះព្រះយេហូវ៉ាមានផែនការនឹងយកពួកគេមកវិញ ប្រសិនបើពួកគេទុកចិត្តលើទ្រង់។

ទោះជាយ៉ាងណាក៏ដោយ អំពើបាបនៅតែមានផលវិបាក។ ដូចដែលព្រះជាម្ចាស់បានបណ្ដេញ លូស៊ីហ្វើរ និងពួកបរិវារវាពីស្ថានសួគ៌ជាយ៉ាងណា នោះព្រះជាម្ចាស់ក៏បានបណ្ដេញលោក អ័ដាម និងនាង អេវ៉ា ឲ្យចេញពីសួនអេដែនជាស្ថានសួគ៌លោកីយ៍យ៉ាងនោះដែរ។

> ទ្រង់បណ្ដេញមនុស្សចេញ ហើយដាក់ចេរូប៊ីននៅខាងកើតសួនច្បារអេដែន នឹងដាវ ដែលជាអណ្ដាតភ្លើងរេបែរទៅគ្រប់ទិស ដើម្បីនឹងរក្សាផ្លូវទៅឯដើមជីវិត។ (លោកុប្បត្តិ ៣:២៤)

ដើមជីវិត គឺជាដើមដ៏ពិសេសមួយទៀតនៅកណ្ដាលសួន។ មានតែមនុស្សគ្រប់លក្ខណ៍ប៉ុណ្ណោះ ដែលអាចបរិភោគផ្លែពីដើមនោះបាន។ លោក អ័ដាម និងនាង អេវ៉ា លែងគ្រប់លក្ខណ៍ទៀតហើយ។ ពួកគេបានធ្វើបាប ដូច្នេះត្រូវចាស់ ហើយស្លាប់។

ព្រះអាទិករដ៏ធំអស្ចារ្យរបស់យើង គឺបរិសុទ្ធ។ នេះមានន័យថា ទ្រង់វិសុទ្ធ ស្អាតស្អំ ល្អឥតខ្ចោះ និងសុចរិត។ ដោយព្រោះនិស្ស័យដ៏បរិសុទ្ធ និងច្បាប់ដ៏បរិសុទ្ធរបស់ទ្រង់ នោះព្រះជាម្ចាស់ត្រូវជំនុំជម្រះអំពើបាបដោយសេចក្ដីស្លាប់ គឺជាការដាច់ចេញពីព្រះជាម្ចាស់ដ៏ជាប្រភពនៃជីវិត។

មនុស្សខ្លះគិតថា បើព្រះជាម្ចាស់ទ្រង់ “ធំអស្ចារ្យ” នោះទ្រង់មិនចាំបាច់អនុវត្តតាមច្បាប់ដែលទ្រង់បានបង្កើតនោះទេ។ ចូរស្រមៃមើលពីតុលាការ ដែលមានចៅក្រមមិនអនុវត្តតាមច្បាប់នៃប្រទេសខ្លួន។ តើអ្នកយល់ថា ចៅក្រមនោះ*ល្អ* ដែរឬទេ? ចូរស្រមៃមើលពីការប្រកួតបាល់ទាត់ ដែលមានអាជ្ញាកណ្ដាលមិនអនុវត្តតាមច្បាប់កីឡាបាល់ទាត់។ តើអ្នកចាត់ទុកគាត់ជាអាជ្ញាកណ្ដាល*ល្អ* ឬ*មិនល្អ*?

សាតាំងចង់ឲ្យនាង អេវ៉ា ជឿថា ព្រះអាទិកររបស់នាងនឹងមិនអនុវត្តតាមច្បាប់របស់ទ្រង់ទេ ហើយក៏មិនជំនុំជម្រះអ្នករំលងច្បាប់ដោយសេចក្ដីស្លាប់ដែរ។ ប៉ុន្តែ ព្រះមហាក្សត្រដែលជាចៅក្រមដ៏សុចរិតនៃសកលលោក តែងតែធ្វើតាមព្រះបន្ទូលរបស់ទ្រង់ជានិច្ច។

ព្រះជាម្ចាស់ គឺធំអស្ចារ្យ ដូច្នេះអ្នកអាចទុកចិត្តលើទ្រង់បាន។

> សេចក្ដីសុចរិត នឹងសេចក្ដីយុត្តិធម៌ជាជើងថ្កល់នៃបល្ល័ង្កទ្រង់ សេចក្ដីសប្បុរស នឹងសេចក្ដីពិតត្រង់ ដើរនាំមុខទ្រង់។ (ទំនុកដំកើង ៨៩:១៤)

ចូរសាកឆ្លើយសំណួរមួយនេះមើល៖ *តើមានអ្វីដែលសាតាំង និងមនុស្សអាចធ្វើបាន ដែលព្រះជាម្ចាស់មិនអាចធ្វើបាននោះ?*

នេះជាចម្លើយរបស់ទ្រង់ផ្ទាល់៖

> “អញនឹងមិនក្បត់សេចក្ដីសញ្ញារបស់អញ ឬបំផ្លាស់បំប្រែសេចក្ដីដែលបានចេញពីបបូរមាត់អញឡើយ។ ...ដោយនូវសេចក្ដីបរិសុទ្ធរបស់អញ...អញមិនព្រមពោលកុហក...ឡើយ។”
> (ទំនុកដំកើង ៨៩:៣៤-៣៥)

ព្រះមហាក្សត្រនៃសកលលោក មិនអាចផ្លាស់ប្ដូរព្រះបន្ទូលរបស់ទ្រង់បានឡើយ។





# ភាគទី២០
# កូនដំបូងបង្អស់



នៅខាងក្រៅសួន លោកីយ៍នៅតែជាកន្លែងដ៏ស្រស់ស្អាតដដែល ប៉ុន្តែវាក៏មានបញ្ហា ដូចជាបន្លាអញ្ចាញ សត្វល្អិតចង្រៃ ដំបៅ និងជំងឺជាដើម។ សត្វដ៏ច្រើនក្លាយជាកាចសាហាវ ហើយអាហារក៏ពិបាករក។ លោក អ័ដាម និងនាង អេវ៉ា ត្រូវធ្វើការយ៉ាងនឿយហត់ ដើម្បីចម្អែតក្រពះខ្លួន។

ប៉ុន្តែ ពួកគេក៏មានពេលសប្បាយរីករាយដែរ។

> អ័ដាមក៏ស្គាល់អេវ៉ាជាប្រពន្ធ ហើយនាងមានទំងន់បង្កើតបានកាអ៊ីន រួចនាងនិយាយថា "អញបានកូនប្រុស១ ដោយព្រះយេហូវ៉ាទ្រង់ប្រោសប្រទាន"។ (លោកុប្បត្តិ ៤:១)

នាង អេវ៉ា បានហៅកូនដែលកើតមកដំបូងបង្អស់នៅក្នុងលោកីយ៍នេះថា កាអ៊ីន ដែលមានន័យថា *ទទួលបាន*។ នេះជាសម្បត្តិដ៏មានតម្លៃមកពីព្រះជាម្ចាស់! នាងប្រហែលជាបានគិតថា កូននេះជាព្រះសង្គ្រោះដែលត្រូវបានសន្យា ប៉ុន្តែមិនយូរប៉ុន្មាន នាងក៏បានដឹងថា កូនដ៏គួរឲ្យស្រឡាញ់នេះមានចិត្តមានះ និងអាត្មានិយម ដូចឪពុកម្តាយរបស់វាដែរ!

ក្រោយមក ពេលកូនទី២បានកើតមក នាង អេវ៉ា ក៏ដាក់ឈ្មោះឲ្យកូននេះថា អេបិល ដែលមានន័យថា *អសារឥតការ*។ ប្រាកដណាស់ លោក អ័ដាម និងនាង អេវ៉ា មិនអាចបង្កើត *ពូជស្ត្រី* គ្មានបាប ដែលអាចសង្គ្រោះមនុស្សឲ្យរួចពីអំពើបាបបានឡើយ។

ជំនួសឲ្យការឆ្លុះបញ្ចាំងពីរូបអង្គនៃព្រះដ៏បរិសុទ្ធ ពូជរបស់លោក អ័ដាម និងនាង អេវ៉ា បានឆ្លុះបញ្ចាំងពីនិស្ស័យបាបរបស់ពួកគេវិញ។

> អ័ដាម...បង្កើតបានកូនជាប្រុសជាស្រីតទៅ...តាមរូបភាពគាត់ ហើយមើលទៅដូចជាគាត់។ (លោកុប្បត្តិ ៥:៤, ៣)

សូមមើលទៅរូបភាព។ តើអ្នកឃើញកាអ៊ីនដណ្តើមយកផ្លែឪឡឹកពីប្អូនវាដែរឬទេ? កាអ៊ីនកំពុងធ្វើដូចឪពុកម្តាយវា ដែលបានយកផ្លែមិនមែនជារបស់ខ្លួន។ ដូចជាជំងឺឆ្លង អំពើបាបរបស់លោក អ័ដាម និងនាង អេវ៉ា បានឆ្លងទៅកូនរបស់ពួកគេហើយ។

> បាបបានចូលមកក្នុងលោកីយ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្តីស្លាប់ចូលមកដែរ...នោះសេចក្តីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នា...ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ។ (រ៉ូម ៥:១២)

សុភាសិតអាហ្វ្រិកពោលថា៖ *កណ្តុរអាចបង្កើតបានតែពូជកាយដី*។ សុភាសិតអារ៉ាប់ក៏ពោលបែបនេះដែរថា៖ *កូនទាកើតមកចេះហែលទឹក*។

នៅពេលដែលឪពុកម្តាយដំបូងបង្អស់របស់យើងបានធ្វើបាប នោះពួកគេបានក្លាយដូចជាមែកឈើដែលបាក់ពីដើម។ ដូចដែលមែកតូចៗ និងស្លឹកជាប់នឹងមែកនោះត្រូវរងឥទ្ធិពលជាយ៉ាងណា នោះពូជរបស់លោក អ័ដាម ទាំងអស់ក៏ត្រូវរងឥទ្ធិពល ដោយអំពើបាបរបស់លោក អ័ដាម យ៉ាងនោះដែរ។

ក្រោយពីលោក អ័ដាម បានស្លាប់ជាច្រើនឆ្នាំមក ស្តេច ដាវីឌ ជាហោរាបានសរសេរថា៖

> ទូលបង្គំកើតមកក្នុងអំពើទុច្ចរិត ហើយទូលបង្គំមានបាបតាំងពីនៅក្នុងផ្ទៃម្តាយ។ (ទំនុកដំកើង ៥១:៥ គកស១៦)

យើងប្រហែលជាមិនចង់ឮពីការនេះទេ ប៉ុន្តែយើងដឹងថា វាជាការពិត។





## ភាគទី២១
# ការថ្វាយបង្គំរបស់មនុស្សមានបាប

លោក អ័ដាម និងនាង អេវ៉ា មានកូនប្រុសស្រីជាច្រើន ប៉ុន្តែព្រះគម្ពីរផ្តោតទៅលើកូនប្រុសពីរនាក់ដំបូងរបស់ពួកគេ។

អេបិលជាអ្នកគង្វាលហ្វូងសត្វ តែកាអ៊ីនជាអ្នកធ្វើស្រែចំការវិញ។ (លោកុប្បត្តិ ៤:២)

ទាំងពីរនាក់ គឺកាអ៊ីន និងអេបិលជាអ្នកឧស្សាហ៍នឹងការងារ។
ទាំងពីរនាក់បានស្គាល់ព្រះអាទិករ។
ទាំងពីរនាក់ចង់ឲ្យព្រះជាម្ចាស់ទទួលពួកគេ និងការថ្វាយបង្គំរបស់ពួកគេ។
ទាំងពីរនាក់ក៏មានបញ្ហាដូចគ្នា គឺ *អំពើបាប*។

ពួកគេមិនត្រឹមតែបានកើតមកជាមនុស្សមានបាបនោះទេ ប៉ុន្តែពួកគេក៏បានរស់នៅដូចជាមនុស្សមានបាបដែរ។ ជារៀងរាល់ថ្ងៃ ពួកគេបានគិត និយាយ ហើយប្រព្រឹត្តផ្ទុយពីលក្ខណៈរបស់ព្រះជាម្ចាស់ ដែលពេញទៅដោយភាពបរិសុទ្ធ និងសេចក្តីស្រឡាញ់។ ក្នុងសៀវភៅរបស់ទ្រង់ ព្រះមហាក្សត្រនៃសកលលោកហៅការនេះថា អំពើបាប។

គ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ។ (រ៉ូម ៣:២៣)

តើមានផ្លូវណាដែលព្រះជាម្ចាស់អាចអត់ទោសកាអ៊ីន និងអេបិល ហើយរាប់ពួកគេជាសុចរិតនៅចំពោះទ្រង់ដែរឬទេ? មាន! ប៉ុន្តែ វានឹងទាមទារតម្លៃដ៏ខ្ពស់បំផុត។

បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឲ្យបានរួចពីបាបឡើយ។ (ហេព្រើរ ៩:២២)

ច្បាប់នៃសកលលោកដែលមិនអាចរំលងបាន គឺច្បាប់នៃអំពើបាប និងសេចក្តីស្លាប់ត្រូវតែអនុវត្តតាម។ អំពើបាបត្រូវជំនុំជម្រះដោយសេចក្តីស្លាប់។ ដូច្នេះ ការអត់ទោសរបស់ព្រះមហាក្សត្រតម្រូវឲ្យសងលោះដោយសេចក្តីស្លាប់។ មនុស្សមានបាបសមនឹងស្លាប់
ប៉ុន្តែព្រះជាម្ចាស់នឹងទទួលយកឈាមនៃសត្វមួយចំនួន ដូចជាកូនចៀម។

កូនចៀមនោះមិនអាចមានជំងឺ របួសស្នាម ឬសៅហ្មងបានឡើយ។ វាត្រូវមានសុខភាពល្អ ហើយស្អាត គឺវាត្រូវតែជាកូនចៀមដ៏ល្អឥតខ្ចោះ។

កូនចៀមនោះត្រូវបានសម្លាប់ ហើយដុត។ វាត្រូវងាប់ជំនួសមនុស្សមានបាបដែលជាប់ទោស។
កូនចៀមនោះត្រូវមកជំនួសមនុស្សមានបាប។

នៅថ្ងៃមួយ បងប្អូនទាំងពីរនាក់បានយកតង្វាយមកថ្វាយដល់ព្រះជាម្ចាស់
ប៉ុន្តែមានតែម្នាក់ប៉ុណ្ណោះ ដែលបានយកតង្វាយដ៏ត្រឹមត្រូវមក។

កន្លងក្រោយមក កាអ៊ីនបានយកផលដែលកើតពីដី មកថ្វាយជាដង្វាយដល់ព្រះយេហូវ៉ា។

ហើយអេបិល...យកកូនជាដំបូង១ពីហ្វូងសត្វមកថ្វាយ ព្រមទាំងខ្លាញ់វាផង...។
(លោកុប្បត្តិ ៤:៣-៤)

តើអ្នកគិតថា ព្រះជាម្ចាស់បានទទួលតង្វាយមួយណា?





## ភាគទី២២
# ច្បាប់នៃតង្វាយលោះបាប

ចូរមើលបងប្អូនទាំងពីរនាក់នេះ និងតង្វាយដែលពួកគេបម្រុងនឹងថ្វាយដល់ព្រះជាម្ចាស់។ ចូរមើលអាសនារបស់ពួកគេ។

អាសនា គឺជាកន្លែងរៀបចំឡើងឲ្យខ្ពស់ ដែលជាធម្មតាធ្វើពីថ្ម ឬដី។ វាជាកន្លែងនៃសេចក្ដីស្លាប់។ អាសនា គឺជាទីថ្វាយតង្វាយ ដែលស្ថិតនៅរវាងស្ថានសួគ៌ និងផែនដី គឺរវាងព្រះជាម្ចាស់ និងមនុស្ស។ គ្រប់តង្វាយនៅលើអាសនាត្រូវដុតនឹងភ្លើង។

ព្រះជាម្ចាស់ប្រកាន់ខ្ជាប់សេចក្ដីយុត្តិធម៌ជានិច្ច ប៉ុន្តែទ្រង់ក៏ចង់បង្ហាញសេចក្ដីមេត្តាករុណាដែរ។ តើទ្រង់អាចធ្វើការទាំងពីរនេះយ៉ាងដូចម្ដេច? តើទ្រង់អាចជំនុំជម្រះអំពើបាប ដោយមិនដាក់ទោសមនុស្សមានបាបយ៉ាងដូចម្ដេច?

លុះពេលជាយូរក្រោយមក តាំងពីជំនាន់របស់កាអ៊ីន និងអេបិល នោះព្រះជាម្ចាស់មានបន្ទូលប្រាប់ហោរា ម៉ូសេ ថា៖

> ជីវិតនៃរូបសាច់ នោះនៅក្នុងឈាម ហើយអញបានឲ្យឈាមដល់ឯងរាល់គ្នា សំរាប់នឹងថ្វាយនៅលើអាសនា ដើម្បីឲ្យបានធួននឹងជីវិតឯង ដ្បិតគឺជាឈាមនោះឯងដែលធួននឹងព្រលឹងបាន។ (លេវីវិន័យ ១៧:១១)
>
> គេត្រូវដាក់ដៃលើក្បាលនៃសត្វនោះ ហើយទ្រង់នឹងទទួលដង្វាយនោះស្នងគេ ដើម្បីឲ្យបានធួននឹងខ្លួនគេ។ (លេវីវិន័យ១:៤)

តើពាក្យថា *ធួន* មានន័យយ៉ាងដូចម្ដេច? គឺមានន័យថា ការបង់ថ្លៃលោះដែលតម្រូវឲ្យបង់ដើម្បីបិទបាំង លាងសម្អាត និងអត់ទោសអំពើបាប។ នៅសម័យព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់មានបន្ទូលថា ទ្រង់នឹងទទួលយកឈាមនៃសត្វចៀម ពពែ គោ និងព្រាបដែលល្អ ជាការបង់ថ្លៃលោះសម្រាប់អំពើបាបរបស់មនុស្ស។ ឈាមនៃសត្វទាំងនោះនឹងផ្ដល់ការធួនដែលជាការបិទបាំងអំពើបាប គឺរហូតដល់ថ្ងៃដែលព្រះជាម្ចាស់ប្រទានយញ្ញបូជាដ៏ល្អឥតខ្ចោះ ដើម្បីបង់ថ្លៃលោះដ៏ពេញលេញ ដែលអំណាចនៃអំពើបាប និងសេចក្ដីស្លាប់ពិតជាបានទាមទារ។

ឥឡូវ ចូរមើលកាអ៊ីន និងតង្វាយដែលគាត់បម្រុងនឹងថ្វាយដល់ព្រះជាម្ចាស់។ ទាំងនេះពិតជាផ្លែឈើ និងបន្លែដ៏ល្អក្រៃលែង! គាត់ពិតជាបានខិតខំធ្វើការ ដើម្បីបានតង្វាយនេះ! ប៉ុន្តែវាមិនអាចបិទបាំងអំពើបាបរបស់គាត់បានទេ ពីព្រោះវាជាតង្វាយគ្មានឈាម គឺមិនមែនជាការបង់ថ្លៃលោះដោយសេចក្ដីស្លាប់។

ចូរមើលអេបិល និងតង្វាយរបស់គាត់។ គួរឲ្យអាណិតមែន! កូនចៀមនេះត្រូវបានចងទុកដើម្បីសម្លាប់។ តើអ្នកឃើញអេបិលដាក់ដៃលើក្បាលកូនចៀមនោះដែរឬទេ? អេបិលបានជឿលើផែនការរបស់ព្រះជាម្ចាស់ ដូច្នេះព្រះជាម្ចាស់បានយកអំពើបាបរបស់អេបិលទាំងអស់មកដាក់លើកូនចៀមនោះ។ អេបិលកំពុងអរព្រះគុណដល់ព្រះយេហូវ៉ាថា ទោះបីជាគាត់សមនឹងទទួលទោសជាសេចក្ដីស្លាប់ក៏ដោយ ទ្រង់នឹងទទួលយកឈាមនៃកូនចៀម ជាការបិទបាំងអំពើបាបរបស់គាត់។

ច្បាប់របស់ព្រះជាម្ចាស់តម្រូវឲ្យមនុស្សមានបាបទាំងអស់ ទទួលការជំនុំជម្រះដោយសេចក្ដីស្លាប់ ប៉ុន្តែព្រះជាម្ចាស់ដ៏យុត្តិធម៌ និងមេត្តាករុណា នឹងទទួលយកកូនចៀមជាតង្វាយជំនួសមនុស្សវិញ។ ព្រះជាម្ចាស់ហៅការនេះថា ច្បាប់នៃតង្វាយ "លោះបាប"(លេវីវិន័យ ៦:២៥)។

ច្បាប់នៃតង្វាយលោះបាបនេះ បានធ្វើឲ្យអេបិលរួចផុតពីអំណាចនៃអំពើបាប និងសេចក្ដីស្លាប់។ ចុះចំណែកឯកាអ៊ីនវិញ?





## ភាគទី២៣
# ការទទួលយក និងការបដិសេធ

តើអ្នកឃើញអាសនារបស់កាអ៊ីនដែរឬទេ? តើមានអ្វីនៅលើអាសនានោះ? គឺផលផ្លែដំស្ងួតស្រពោន។ ឥឡូវ ចូរមើលអាសនារបស់អេបិលវិញ។ តើមានអ្វីនៅលើអាសនានោះ? គឺឈាម និងផេះ។

តើព្រះជាម្ចាស់យល់ឃើញយ៉ាងដូចម្តេចចំពោះបងប្អូនទាំងពីរនាក់ និងការថ្វាយបង្គំរបស់ពួកគេ?

> ព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យចំពោះអេបិល នឹងដង្វាយរបស់គាត់
> តែមិនសព្វព្រះហឫទ័យចំពោះដង្វាយរបស់កាអ៊ីនទេ។ (លោកុប្បត្តិ ៤:៤-៥)

យើងមិនដឹងថា ព្រះជាម្ចាស់បានបង្ហាញការសព្វព្រះហឫទ័យចំពោះតង្វាយរបស់អេបិល ហើយបង្ហាញការបដិសេធចំពោះតង្វាយរបស់កាអ៊ីន[១០]យ៉ាងដូចម្តេចនោះទេ។ ព្រះគម្ពីរគ្រាន់តែចែងថា៖

> ដោយសារសេចក្តីជំនឿ នោះអេបិលបានថ្វាយយញ្ញបូជាដល់ព្រះ ដែលប្រសើរជាងដង្វាយរបស់កាអ៊ីន ហើយមានសេចក្តីបន្ទាល់ពីគាត់ ដោយព្រោះយញ្ញបូជានោះថា គាត់សុចរិត ទាំងមានព្រះធ្វើបន្ទាល់ពីដង្វាយគាត់ផង។ (ហេព្រើរ ១១:៤)

ដោយសារគាត់បានទុកចិត្តលើព្រះជាម្ចាស់ និងផែនការរបស់ទ្រង់ នោះអេបិលត្រូវបានអត់ទោស ហើយរាប់ជាសុចរិត។ នេះហើយជាអំណោយរបស់ព្រះជាម្ចាស់ចំពោះអេបិល។

ព្រះជាម្ចាស់បានផ្ទុកអំពើបាបរបស់គាត់ទៅលើកូនចៀម។ កូនចៀមបានងាប់ជំនួសអេបិល។ ឈាមនៃកូនចៀមត្រូវបានបង្ហូរ ហើយខ្លួនវាត្រូវបានដុតក្លាយជាផេះ។ សេចក្តីក្រោធដ៏សុចរិតនៃព្រះជាម្ចាស់ចំពោះអំពើបាប បានធ្លាក់មកលើកូនចៀមជំនួសអេបិល។ ហេតុអ្វីបានជាព្រះជាម្ចាស់សព្វព្រះហឫទ័យចំពោះកូនចៀមដែលអេបិលបានថ្វាយនោះ? ពីព្រោះវាចង្អុលបង្ហាញពីព្រះសង្គ្រោះដែលត្រូវយាងមកនៅថ្ងៃមួយ ដើម្បីសងថ្លៃលោះបាបរបស់លោកីយ៍។

ដោយសារសេចក្តីជំនឿលើផែនការរបស់ព្រះជាម្ចាស់ ឥឡូវ អេបិលមានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះជាម្ចាស់វិញ។ ក្រោយមក នៅពេលដែលអេបិលស្លាប់ទៅ នោះគាត់មិនដាច់ចេញពីព្រះជាម្ចាស់ជាដរាបទេ តែនឹងបានទៅនៅជាមួយព្រះជាម្ចាស់ដ៏ជាមិត្តសម្លាញ់របស់គាត់វិញ។ ច្បាប់នៃតង្វាយលោះបាបបានឈ្នះលើអំណាចនៃអំពើបាប និងសេចក្តីស្លាប់ហើយ។

កាអ៊ីនបានចូលទៅចំពោះព្រះជាម្ចាស់ដោយការអធិស្ឋាន ប៉ុន្តែគាត់មិនបានធ្វើតាមច្បាប់របស់ព្រះជាម្ចាស់ ដែលចែងថា អំពើបាបត្រូវជំនុំជម្រះដោយសេចក្តីស្លាប់នោះទេ។ កាអ៊ីនជាអ្នកកាន់តាមសាសនា ប៉ុន្តែគាត់គ្មានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះជាម្ចាស់ទេ។ អំណាចនៃអំពើបាប និងសេចក្តីស្លាប់នៅតែគ្របដណ្តប់លើគាត់ ដូចជាពពកខ្មៅ។ បើគាត់មិនទុកចិត្តលើព្រះជាម្ចាស់ និងផែនការរបស់ទ្រង់ទេ នោះគាត់មិនអាចស្គាល់ព្រះជាម្ចាស់ជាមិត្តសម្លាញ់របស់គាត់សោះឡើយ។ គាត់ត្រូវប្រឈមមុខនឹងព្រះជាម្ចាស់ជាចៅក្រមវិញ។

មនុស្សខ្លះព្យាយាមគាំទ្រកាអ៊ីន ដោយនិយាយថា “កាអ៊ីនជាកសិករ ដូច្នេះគាត់បានថ្វាយអ្វីដែលគាត់មាន”។ ប៉ុន្តែ ព្រះជាម្ចាស់មិនចង់បានអ្វីដែលគាត់មាននោះទេ។ កាអ៊ីនអាចដោះដូរផលផ្លែរបស់ខ្លួនជាមួយនឹងកូនចៀមរបស់អេបិល ឬក៏អាចទៅដាក់ដៃគាត់នៅលើកូនចៀមរបស់អេបិល ហើយថ្វាយបង្គំនៅមុខអាសនាតែមួយ។

តើកាអ៊ីននឹងធ្វើយ៉ាងដូចម្តេច?

តើគាត់នឹងប្រែចិត្ត ហើយមកឯព្រះជាម្ចាស់ ដោយនាំយកតង្វាយដ៏ត្រឹមត្រូវដែរឬទេ?





# ភាគទី២៤
# ឃាតកម្មដំបូងបង្អស់

ព្រះយេហូវ៉ាបានបដិសេធចំពោះតង្វាយរបស់កាអ៊ីន ប៉ុន្តែទ្រង់នៅតែស្រឡាញ់គាត់ ហើយក៏បានដាស់តឿនគាត់ឲ្យប្រែចិត្ត។

តើការប្រែចិត្តមានន័យយ៉ាងដូចម្តេច?

ឧបមាថា អ្នកចង់ធ្វើដំណើរទៅទីក្រុងណាមួយ។ ក្រោយពេលឡើងរថភ្លើងរួច អ្នកក៏ដឹងខ្លួនថាបានជិះរថភ្លើងខុស។ តើអ្នកត្រូវធ្វើយ៉ាងដូចម្តេច? អ្នកត្រូវទទួលស្គាល់កំហុស ហើយចុះពីរថភ្លើងនោះ រួចឡើងជិះរថភ្លើងដែលត្រឹមត្រូវវិញ។ នេះហើយដែលមានន័យថា ប្រែចិត្ត។

ការប្រែចិត្តមានន័យថា *ការផ្លាស់ប្តូរចិត្តគំនិតរបស់ខ្លួន គឺបែរចេញពីអ្វីដែលខុសឆ្គង ហើយចុះចូលនឹងអ្វីដែលត្រឹមត្រូវវិញ*។ ការប្រែចិត្តចំពោះព្រះជាម្ចាស់មិនមែនមានន័យថា ខ្ញុំត្រូវដាក់ទោសខ្លួនឯង ដោយសារអំពើបាបរបស់ខ្ញុំនោះទេ ប៉ុន្តែមានន័យថា ខ្ញុំត្រូវមើលឃើញអំពើបាបរបស់ខ្ញុំដូចដែលព្រះជាម្ចាស់ទតឃើញយ៉ាងនោះដែរ។

ព្រះជាម្ចាស់ចង់ឲ្យកាអ៊ីនប្រែចិត្ត គឺឈប់ទុកចិត្តលើផ្លូវរបស់ខ្លួន ហើយមកទុកចិត្ត និងដើរតាមផ្លូវរបស់ទ្រង់វិញ។

> នោះកាអ៊ីនក៏ក្តៅក្រហាយ ហើយឡើងទឹកមុខក្រញូវ។
>
> ព្រះយេហូវ៉ាទ្រង់មានបន្ទូលសួរកាអ៊ីនថា "ឯងខឹងធ្វើអី? ហេតុអ្វីបានជាឯងធ្វើទឹកមុខក្រញូវដូច្នេះ? បើឯងធ្វើល្អ តើមិនបានទឹកមុខរីករាយវិញទេឬអី? បើឯងធ្វើមិនល្អ នោះមានដង្វាយលោះបាបដេកនៅមាត់ទ្វារស្រាប់ហើយ ចិត្តវានឹងបណ្តោយតាមឯង ហើយឯងមានអំណាចលើវាដែរ។ (លោកុប្បត្តិ ៤:៥-៧)

កាអ៊ីនមិនចង់ប្រែចិត្តទេ ដោយសារគាត់មានអំនួតខ្លាំងពេក។ *គាត់ត្រូវអាម៉ាស់ដោយសារប្អូន! គាត់នឹងបំបាត់ភាពអាម៉ាស់នេះ ហើយស្តារកិត្តិយសឡើងវិញតាមផ្លូវរបស់គាត់!*

> កាអ៊ីនក៏ដំណាលប្រាប់ដល់អេបិលជាប្អូន រួចមានកាល១ថ្ងៃកំពុងដែលគេនៅឯវាល នោះស្រាប់តែកាអ៊ីនក្រោកឡើងសំឡាប់អេបិលជាប្អូនទៅ។
>
> ព្រះយេហូវ៉ាក៏មានបន្ទូលសួរកាអ៊ីនថា "អេបិលប្អូនឯងនៅឯណា?"។
>
> គាត់ទូលឆ្លើយថា "ទូលបង្គំមិនដឹងទេ តើទូលបង្គំជាអ្នកថែរក្សាប្អូនឬអី?"។
>
> នោះទ្រង់មានបន្ទូលសួរថា "ឯងបានធ្វើអ្វីដូច្នេះ? ពីព្រោះឮសូរសំរែកនៃឈាមរបស់ប្អូនឯងពីដីឡើងទៅដល់អញ"។ (លោកុប្បត្តិ ៤:៨-១០)

ព្រលឹងវិញ្ញាណរបស់អេបិលបានទៅឯព្រះជាម្ចាស់ ប៉ុន្តែរូបកាយរបស់គាត់នឹងត្រឡប់ជាធូលីដីវិញរហូតដល់ថ្ងៃមួយ ដែលព្រះជាម្ចាស់ធ្វើឲ្យធូលីដីនោះក្លាយជារូបកាយដ៏រុងរឿង ដែលស័ក្តិសមនឹងភាពអស់កល្បជានិច្ច។

ចំពោះកាអ៊ីនវិញ ព្រះជាម្ចាស់បានផ្តល់ឱកាសឲ្យប្រែចិត្តម្តងទៀត ប៉ុន្តែគាត់បានបដិសេធ។

> នោះកាអ៊ីនក៏ចេញពីចំពោះព្រះយេហូវ៉ា។ (លោកុប្បត្តិ ៤:១៦)

ដោយចិត្តបះបោរ និងអំនួត កាអ៊ីនបានទៅសាងសង់ទីក្រុងមួយនៅភាគខាងកើត។ គាត់ និងប្រពន្ធគាត់មានកូនជាច្រើន។ កូនចៅជំនាន់ក្រោយៗរបស់ពួកគេ បានក្លាយទៅជាអ្នកបង្កើតឧបករណ៍ដែក និងឧបករណ៍ភ្លេងមុនគេបង្អស់។

ពូជរបស់កាអ៊ីនមានភាពឈ្លាសវៃណាស់ ប៉ុន្តែពួកគេមិនបានស្គាល់ព្រះយេហូវ៉ាឡើយ។





# ភាគទី២៥
# ការអត់ធ្មត់ និងការជំនុំជម្រះ

ដប់ជំនាន់បានកន្លងផុតទៅ ក្រោយពីលោក អ័ដាម បានធ្វើបាបដំបូង នោះព្រះជាម្ចាស់បានកត់ត្រាពីស្ថានភាពដ៏កំសត់របស់មនុស្សលោកយ៉ាងដូច្នេះ៖

> ការអាក្រក់របស់មនុស្សបានចំរើនជាច្រើនឡើងនៅផែនដី ហើយអស់ទាំងគំនិតក្នុងចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ច។ (លោកុប្បត្តិ ៦:៥)

ប៉ុន្តែ មានគ្រួសារមួយនៅលើផែនដី ដែលនៅតែទុកចិត្តលើព្រះជាម្ចាស់។

> ណូអេបានប្រកបដោយព្រះគុណនៅចំពោះព្រះយេហូវ៉ា...។
>
> ព្រះទ្រង់មានបន្ទូលទៅណូអេថា “អស់ទាំងសាច់ត្រូវផុតពីមុខអញហើយ ដ្បិតផែនដីបានពេញជាសេចក្តីកាចសហ័សដោយសារគេ មើល អញនឹងបំផ្លាញគេទៅជាមួយនឹងផែនដីផង។  ចូរឯងយកឈើម៉ៃសាក់ធ្វើជាទូកធំសំរាប់ឯង ត្រូវឲ្យធ្វើបន្ទប់នៅក្នុងទូកនោះ ហើយពរជ័រទាំងខាងក្នុងខាងក្រៅ។ ត្រូវឲ្យឯងធ្វើយ៉ាងដូច្នេះ...”។ (លោកុប្បត្តិ ៦:៨, ១៣-១៥)

ទូកធំបីជាន់នេះ មានប្រវែងវែងជាងទីលានបាល់ទាត់មួយ ហើយពាក់កណ្តាលទៀត ក៏មានបន្ទប់គ្រប់គ្រាន់ ដើម្បីដាក់សត្វមួយគូរៗគ្រប់ប្រភេទ និងសត្វ៧គូរៗនៃគ្រប់ទាំងសត្វ ដែលអាចធ្វើជាតង្វាយលោះបាប។ ទូកធំនេះមានប្រកខ្យល់ចេញចូល និងទ្វារធំមួយ។

អស់រយៈពេលមួយសតវត្សរ៍ លោក ណូអេ បានធ្វើទូកនេះជាមួយប្រពន្ធរបស់គាត់ កូនប្រុសទាំងបីនាក់ និងប្រពន្ធរបស់ពួកគេ។ ខណៈដែលគាត់ធ្វើទូកនេះ លោក ណូអេ បានព្រមានពិភពលោកអំពីការជំនុំជម្រះរបស់ព្រះជាម្ចាស់ ដែលជិតនឹងមកដល់ ប៉ុន្តែមនុស្សបានសើចចំអកឲ្យគាត់វិញ។

ទីបំផុត ទូកធំនោះបានហើយជាស្រេច។ គ្រួសាររបស់លោក ណូអេ បានរៀបចំស្បៀងអាហារទុកក្នុងទូកធំនោះ។ ព្រះជាម្ចាស់ក៏បាននាំសត្វជើងបួន សត្វលូនវារ សត្វល្អិត និងសត្វស្លាបគ្រប់ប្រភេទមក។ នេះជារូបភាពដ៏អស្ចារ្យ ដែលសត្វទាំងនោះបានចូលទៅនៅក្នុងទូកធំ ដែលមានបែងចែកជារាប់ពាន់កន្លែង!

លោក ណូអេ និងគ្រួសារក៏បានចូលទៅទីនោះដែរ។ តើមានអ្នកណាទៀតបានចូលទៅក្នុងទីសុវត្ថិភាពនោះដែរឬទេ? គ្មានទេ ដូច្នេះព្រះជាម្ចាស់ក៏បានបិទទ្វារទូកធំនោះ។ ពពកខ្មៅដ៏ខ្ទួលខ្មាញ់បានគ្របដណ្តប់ពាសពេញលើផែនដី ផ្លេកបន្ទោរក៏ចាំងចែង ហើយសម្លេងផ្គរលាន់ឮយ៉ាងរំពង។

> ថ្ងៃនោះឯងគ្រប់អស់ទាំងរន្ធទឹកនៅទីជំរៅធំក៏ធ្លាយ ហើយទ្វារទំនប់នៅលើមេឃក៏ត្រូវបើកចេញ។ មានភ្លៀងធ្លាក់មកលើផែនដី៤០ថ្ងៃ៤០យប់។ (លោកុប្បត្តិ ៧:១១-១២)

នេះជាគ្រោះធម្មជាតិដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្រ។ មនុស្សទាំងអស់បានវិនាស លើកលែងតែ៨នាក់ដែលបានជ្រកកោននៅក្នុងទូកធំនោះប៉ុណ្ណោះ។ លោកីយ៍ដែលមានអំនួតនិងគ្មានជំនឿបានដឹងការពិតយឺតពេលហើយ។

ភស្តុតាងភូមិសាស្ត្រ និងហ្វូស៊ីលបញ្ជាក់បង្ហាញពីភាពពិតនៃកំណត់ត្រាព្រះគម្ពីរនេះ។ ហ្វូស៊ីលសមុទ្រត្រូវបានរកឃើញតាមវាលខ្សាច់ និងជួរភ្នំធំៗនៃពិភពលោក ដូចជាវាលខ្សាច់សាហារ៉ា និងភ្នំហិមាល័យ។

ដោយសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះជាម្ចាស់អត់ធ្មត់ ប៉ុន្តែដោយសេចក្តីយុត្តិធម៌របស់ទ្រង់ ទ្រង់ត្រូវជំនុំជម្រះអំពើបាប។





# ភាគទី២៦
# ការចាប់ផ្ដើមសាជាថ្មី

តើមានអ្វីកើតឡើងចំពោះលោក ណូអេ គ្រួសារគាត់ និងសត្វនៅក្នុងទូកធំនោះ? ពួកគេត្រូវបានសង្គ្រោះពីការជំនុំជម្រះរបស់ព្រះជាម្ចាស់។

> ព្រះទ្រង់ក៏នឹកចាំពីណូអេ នឹងអស់ទាំងសត្វព្រៃ សត្វស្រុកទាំងប៉ុន្មាន ដែលនៅក្នុងទូកជាមួយនឹងគាត់ រួចទ្រង់ធ្វើឲ្យខ្យល់បក់មកលើផែនដី ហើយទឹកក៏ស្រកទៅ។ (លោកុប្បត្តិ ៨:១)

ទូកធំនោះបានអណ្ដែតចុះតាមទឹក  ហើយទីបំផុត វាបានកឿងលើភ្នំអារ៉ារ៉ាត ដែលមានកំពូលធំៗពីរ នៅភាគខាងកើតនៃប្រទេសតួកគី។

លោក ណូអេ បានលែងព្រាបចំនួន៣ដង ដើម្បីឲ្យដឹងថា តើវាអាចរកដីគោកឃើញដែរឬទេ។ លើកទី១ ព្រាបនោះត្រឡប់មកវិញដោយទទេ។ លើកទី២ ព្រាបនោះត្រឡប់មកវិញដោយពាំស្លឹកអូលីវ។ លើកទី៣ ព្រាបនោះមិនបានត្រឡប់មកវិញទេ ពីព្រោះវារកឃើញទីជម្រកហើយ! លោក ណូអេ បានដឹងថា ដល់ពេលត្រូវចេញពីទូកធំនោះ។ តាំងពីទឹកជំនន់បានកើតឡើងមួយឆ្នាំបានកន្លងផុតទៅហើយ។

តើអ្នកដឹងទេថា លោក ណូអេ បានធ្វើអ្វីមុនគេ ក្រោយពីគ្រួសារគាត់ និងសត្វទាំងអស់បានចេញពីទូកធំនោះមក?

> ណូអេបានស្អាងអាសនា១ថ្វាយព្រះយេហូវ៉ា ក៏យកសត្វជើង៤ពីសត្វដ៏ស្អាតគ្រប់មុខ ហើយពីសត្វស្លាបស្អាតគ្រប់មុខ មកថ្វាយជាដង្វាយដុតលើអាសនានោះ។ ព្រះយេហូវ៉ាទ្រង់ធុំក្លិនឈ្ងុយ...។ (លោកុប្បត្តិ ៨:២០-២១)

សេចក្ដីយុត្តិធម៌ និងសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់មិនបានផ្លាស់ប្ដូរឡើយ។ អំពើបាបនៅតែទាមទារការបង់ថ្លៃលោះដោយសេចក្ដីស្លាប់។ ហេតុនោះហើយបានជាលោក ណូអេ បង្ហូរឈាមសត្វដែលគ្មានទោស ហើយដុតពួកវានៅលើអាសនា ដែលស្ថិតនៅរវាងស្ថានសួគ៌ និងផែនដី គឺរវាងព្រះជាម្ចាស់ និងមនុស្ស។ ការថ្វាយតង្វាយបែបនេះ ចង្អុលបង្ហាញពីព្រះមែស្ស៊ីដ៏គ្មានបាប ដែលត្រូវយាងមកផែនដីនៅថ្ងៃមួយ ដើម្បីប្រទានថ្លៃលោះដ៏ពិតសម្រាប់អំពើបាប។

បន្ទាប់មក ព្រះជាម្ចាស់បានបង្គាប់លោក ណូអេ និងគ្រួសាររបស់គាត់ថា៖

> “ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យបាននៅពេញពាសលើផែនដីចុះ។” (លោកុប្បត្តិ ៩:១)

ព្រះយេហូវ៉ាដ៏ជាព្រះក៏បានសន្យាចំពោះផែនដីថា៖

> “អញដាក់ធ្នូរបស់អញនៅនាពពក នោះហើយជាទីសំគាល់នៃសេចក្ដីសញ្ញា ដែលអញតាំងនឹងផែនដី។ ...នោះនឹងគ្មានទឹកជន់ឡើងលិចផែនដី ដើម្បីបំផ្លាញគ្រប់ទាំងសាច់ទៀតឡើយ។” (លោកុប្បត្តិ ៩:១៣, ១៥)

ព្រះជាម្ចាស់បានបើកបង្ហាញឲ្យឃើញឥន្ទធនូដ៏អស្ចារ្យមួយខ្ពស់ដល់មេឃ ដែលជានិមិត្តរូបនៃសេចក្ដីសញ្ញារបស់ទ្រង់។ ព្រះជាម្ចាស់បានសន្យាថា ទ្រង់នឹងមិនចាត់ឲ្យមានទឹកជំនន់លិចផែនដីទៀតឡើយ។

ឥន្ទធនូជួយរំឭកដល់យើងថា ទោះជាការដាក់ទោស ឬជាការការពារក្ដី ព្រះជាម្ចាស់តែងតែគោរពតាមសេចក្ដីសន្យារបស់ទ្រង់ជានិច្ច...

គឺគ្រប់ពេលវេលា។





# ភាគទី២៧
# ប៉មនៃសេចក្តីអំនួត

ទោះបើមនុស្សលោកបានទទួលព្រះពរដោយការចាប់ផ្តើមសាជាថ្មីក៏ដោយ ប៉ុន្មានជំនាន់ក្រោយមក មនុស្សភាគច្រើនក៏បានបែរចេញពីព្រះយេហូវ៉ាទៅតាមផ្លូវគេរៀងៗខ្លួន។ ឧទាហរណ៍ ព្រះជាម្ចាស់បានបង្គាប់មនុស្សឲ្យខ្ចាត់ខ្ចាយ ហើយ “ឲ្យបាននៅពេញពាសលើផែនដី” (លោកុប្បត្តិ ១:២៨; ៩:១)។ ប៉ុន្តែ តើមនុស្សបានធ្វើយ៉ាងដូចម្តេច?

ព្រះគម្ពីរប្រាប់យើងថា៖

> រីឯនៅផែនដីទាំងមូល នោះមានភាសាមានសំដីតែ១ទេ។
>
> ហើយកំពុងដែលគេដើរដំណើរនៅស្រុកខាងកើត នោះក៏ប្រទះឃើញវាល១នៅស្រុកស៊ីណើរ (ប្រទេសអ៊ីរ៉ាក់នាពេលបច្ចុប្បន្ន) ហើយគេនាំគ្នាតាំងទីលំនៅនៅទីនោះ។ គេនិយាយគ្នាទៅវិញទៅមកថា “ចូរយើងធ្វើឥដ្ឋដុតឲ្យឆ្អិនទៅ”។
>
> នោះគេមានឥដ្ឋទុកជាថ្ម នឹងជ័រដីទុកជាបាយអ។
>
> រួចនិយាយគ្នាថា “ចូរយើងសង់ទីក្រុង១សម្រាប់យើង នឹងប៉ម១ដែលខ្ពស់ដល់ផ្ទៃមេឃ ដើម្បីឲ្យយើងបានកេរ្តិ៍ឈ្មោះ ក្រែងយើងរាល់គ្នាត្រូវខ្ចាត់ខ្ចាយទៅគ្រប់លើផែនដីទៅ”។ (លោកុប្បត្តិ ១១:១-៤)

ពួកអ្នកសាងសង់ទីក្រុងនេះ ចង់ឲ្យមនុស្សសរសើរពួកគេ ជាជាងសរសើរព្រះនាមរបស់ព្រះយេហូវ៉ាដ៏ធំអស្ចារ្យ។ ពួកគេពេញដោយចិត្តអំនួត និងការបះបោរ ដូចសាតាំងដែរ។

ដោយមានបំណងចង់សាងសង់“ប៉ម១ដែលខ្ពស់ដល់ផ្ទៃមេឃ” ពួកគេមានលក្ខណៈដូចទៅនឹងអ្នកកាន់តាមសាសនានៅសព្វថ្ងៃនេះ ដែលសង្ឃឹមនឹងទៅស្ថានសួគ៌ ដោយការខំប្រឹងប្រែងរបស់ខ្លួន។ ដូចទៅនឹងកាអ៊ីនដែរ ពួកគេបានកាន់តាមសាសនា ប៉ុន្តែធ្វើព្រងើយចំពោះផ្លូវនៃការអត់ទោស និងសេចក្តីសុចរិតរបស់ព្រះជាម្ចាស់វិញ។ ពួកគេមិនបានទុកចិត្តលើព្រះជាម្ចាស់ និងផែនការរបស់ទ្រង់ទេ។

ដូច្នេះ ព្រះយេហូវ៉ាដ៏ជាព្រះមានបន្ទូលថា៖

> “ចូរយើងចុះទៅបំភាន់ភាសាគេ ដើម្បីកុំឲ្យគេស្តាប់គ្នាបានទៀត។”
>
> ដូច្នេះព្រះយេហូវ៉ាទ្រង់កំចាត់កំចាយគេ ពីទីនោះទៅគ្រប់លើផែនដីវិញ ហើយគេក៏លែងសង់ទីក្រុងនោះទៅ។ ដោយហេតុនោះ បានជាគេហៅឈ្មោះក្រុងនោះថា បាបិល ពីព្រោះនៅទីនោះ ព្រះយេហូវ៉ាទ្រង់បានបំភាន់ភាសាលោកីយទាំងអស់ ហើយកំចាត់កំចាយគេពីទីនោះទៅគ្រប់លើផែនដី។ (លោកុប្បត្តិ ១១:៧-៩)

ដោយប្រទានឲ្យក្រុមគ្រួសារ ឬពូជអំបូរនីមួយៗមានភាសាផ្សេងគ្នា ព្រះយេហូវ៉ាបានបញ្ឈប់គម្រោងសាងសង់របស់ពួកគេ។ មនុស្សទាំងនេះគ្មានជម្រើសអ្វីក្រៅពីចាកចេញពីក្រុងបាបិល ហើយទៅនៅពាសពេញលើផែនដី ដូចព្រះជាម្ចាស់បានបង្គាប់។

ពួកគេមិនបានបង្ហើយប៉មរបស់ពួកគេទេ។ ប៉ុន្តែ ផែនការរបស់ព្រះជាម្ចាស់វិញ គឺកំពុងសម្រេចទៅតាមពេលកំណត់។





## ភាគទី២៨
# ព្រះជាម្ចាស់ត្រាស់ហៅលោក អ័ប្រាហាំ

ដប់ជំនាន់បានកន្លងផុតទៅ តាំងពីសម័យកាលនៃហោរា ណូអេ។ សាតាំងហាក់ដូចជាបានកាន់កាប់ប្រជាជាតិទាំងឡាយ។

មនុស្សបានជឿលើសាសនារបស់ពួកគេរៀងៗខ្លួន ជាជាងជឿលើព្រះយេហូវ៉ា។ ប្រជាជាតិខ្លះបានថ្វាយបង្គំព្រះអាទិត្យ ជាជាងថ្វាយបង្គំព្រះដែលបានបង្កើតវាមក។ ខ្លះទៀតបានថ្វាយបង្គំព្រះច័ន្ទវិញ។

ខ្ទង់ឆ្នាំ១៩២៥ មុនគ.ស. នៅទឹកដីភាគឦសាននៃតំបន់អារ៉ាប់ មានបុរសចំណាស់ម្នាក់ឈ្មោះអាប់រ៉ាម។ ក្រោយមក ព្រះជាម្ចាស់បានប្តូរឈ្មោះគាត់ទៅជា អ័ប្រាហាំ ដែលមានន័យថា *ឪពុកនៃសាសន៍ជាច្រើន*។

លោក អ័ប្រាហាំ មានអាយុ៧៥ឆ្នាំ។ រីឯនាង សារ៉ា ជាប្រពន្ធរបស់គាត់មានអាយុ៦៥ឆ្នាំ តែនាងគ្មានកូនសោះ។ ឪពុកម្តាយ និងអ្នកជិតខាងរបស់ពួកគេជាអ្នកថ្វាយបង្គំរូបព្រះជាជាងព្រះអាទិករ។

នៅថ្ងៃមួយ ព្រះយេហូវ៉ាមានបន្ទូលទៅលោក អ័ប្រាហាំ ថា៖

> "ចូរឯងចេញពីស្រុក ពីញាតិសន្តាន នឹងពីផ្ទះឪពុកឯង ទៅនៅឯស្រុកដែលអញនឹងបង្ហាញឯងចុះ។
>
> អញនឹងបង្កើតនគរ១យ៉ាងធំពីឯង អញនឹងឲ្យពរដល់ឯង ទាំងលើកឈ្មោះឯងជាធំផង ឯងនឹងបានធ្វើជាទីបញ្ចេញពរដល់មនុស្សទាំងឡាយ។ អញនឹងឲ្យពរដល់អស់អ្នកណាដែលឲ្យពរដល់ឯង ហើយនឹងដាក់បណ្តាសាដល់អស់អ្នកណាដែលផ្តាសាឯង គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរដោយសារឯង។" (លោកុប្បត្តិ ១២:១-៣)

ព្រះយេហូវ៉ាចង់តាំងសេចក្តីសញ្ញាជាមួយនឹងលោក អ័ប្រាហាំ។ បើគាត់ចាកចេញពីគ្រួសាររបស់ឪពុកគាត់ ហើយទៅកាន់ទឹកដីដែលគាត់មិនស្គាល់ នោះទ្រង់នឹងធ្វើការដ៏អស្ចារ្យ២យ៉ាងចំពោះគាត់៖

១. ព្រះជាម្ចាស់នឹងធ្វើឲ្យលោក អ័ប្រាហាំ ក្លាយជាឪពុកនៃសាសន៍មួយដ៏ធំ។
២. តាមរយៈសាសន៍ថ្មីនេះ ព្រះជាម្ចាស់នឹងប្រទានពរដល់មនុស្សគ្រប់ជាតិសាសន៍។

បើលោក អ័ប្រាហាំ ទុកចិត្ត ហើយធ្វើតាមព្រះយេហូវ៉ា នោះគាត់នឹងបានក្លាយជាឪពុកនៃសាសន៍មួយ ហើយតាមរយៈសាសន៍នេះ ទ្រង់នឹងប្រទានហោរា ព្រះគម្ពីរ និងព្រះសង្គ្រោះមក។

តើលោក អ័ប្រាហាំ បានធ្វើយ៉ាងដូចម្តេច?

> ដោយសារសេចក្តីជំនឿ កាលព្រះបានហៅលោកអ័ប្រាហាំ នោះលោកក៏បានស្តាប់បង្គាប់ លោកចេញទៅឯកន្លែងដែលត្រូវទទួលជាមរដក គឺចេញទៅឥតមានដឹងជាទៅឯណាទេ។ (ហេព្រើរ ១១:៨)

ការចាកចេញពីសាច់ញាតិ និងការបែរចេញពីសាសនារបស់គ្រួសារ នោះពិតជាពិបាកសម្រាប់លោក អ័ប្រាហាំ និងប្រពន្ធរបស់គាត់។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេសុខចិត្តស៊ូទ្រាំនឹងការរិះគន់របស់ញាតិសន្តាន ដើម្បីដើរតាមព្រះជាម្ចាស់ដ៏ពិតតែមួយ។

ការទុកចិត្ត និងការស្តាប់បង្គាប់ព្រះជាម្ចាស់ នោះមិនងាយស្រួលទេ ប៉ុន្តែវាជាការល្អបំផុត។





# ភាគទី២៩
# ការបំពេញសេចក្តីសន្យា

លោក អ័ប្រាហាំ និងប្រពន្ធរបស់គាត់ចាស់ហើយ ក៏គ្មានកូនដែរ។ ប៉ុន្តែ ព្រះយេហូវ៉ាបានសន្យានឹងធ្វើឲ្យលោក អ័ប្រាហាំ ក្លាយជាឪពុកនៃសាសន៍មួយដ៏ធំ។

តើគាត់បានឆ្លើយតបយ៉ាងដូចម្តេច ចំពោះសេចក្តីសន្យារបស់ព្រះជាម្ចាស់ ដែលហាក់ដូចជាមិនអាចកើតឡើងបាននោះ?

> អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្តីនោះ បានរាប់ជាសេចក្តីសុចរិតដល់លោក ព្រះក៏ហៅលោកជាសំឡាញ់របស់ទ្រង់ដែរ។ (យ៉ាកុប ២:២៣; លោកុប្បត្តិ ១៥:៦)

លោក អ័ប្រាហាំ ក៏ជាមនុស្សមានបាប ដូចអស់ទាំងពូជរបស់លោក អ័ដាម ដែរ ប៉ុន្តែគាត់បានថ្វាយតង្វាយលោះបាបដល់ព្រះជាម្ចាស់ ដូចអេបិល និងលោក ណូអេ។ ដោយសារគាត់បានជឿដល់ព្រះយេហូវ៉ា និងសេចក្តីសន្យារបស់ទ្រង់ នោះព្រះជាម្ចាស់បានរាប់គាត់ជាសុចរិតក្នុងបញ្ជីនៃស្ថានសួគ៌ ហើយបានប្រទានជីវិតអស់កល្បជានិច្ចជាអំណោយដល់គាត់។ នាង សារ៉ា ក៏បានទុកចិត្តលើព្រះយេហូវ៉ា ហើយព្រះជាម្ចាស់បានរាប់នាងជាសុចរិតដែរ។

ប៉ុន្តែ ការរង់ចាំ គឺពិបាកណាស់។

ក្រោយពីពួកគេបានរស់នៅក្នុងទឹកដីប៉ាឡេស្ទីនអស់រយៈពេល១០ឆ្នាំ ទាំងសង្ឃឹម និងអធិស្ឋានឲ្យនាង សារ៉ា មានទម្ងន់ នោះពួកគេក៏បានសម្រេចចិត្ត “ជួយ” ព្រះជាម្ចាស់ ដើម្បីបំពេញសេចក្តីសន្យារបស់ទ្រង់ ដែលថានឹងប្រទានកូនប្រុសមួយ។ តាមប្រពៃណីនៅស្រុកនោះ នាង សារ៉ា បានឲ្យអ្នកបម្រើសាសន៍អេស៊ីព្ទម្នាក់ឈ្មោះ ហាការ ទៅលោក អ័ប្រាហាំ។ គាត់បានរួមដំណេកជាមួយ រួចនាងក៏មានទម្ងន់ បង្កើតបានកូនប្រុសមួយ ដែលឈ្មោះថា អ៊ីសម៉ាអែល។

ខ្ទង់១៣ឆ្នាំក្រោយមក ពេលលោក អ័ប្រាហាំ មានអាយុ៩៩ឆ្នាំ ហើយនាង សារ៉ា មានអាយុ៨៩ឆ្នាំ នោះព្រះដ៏មានគ្រប់ព្រះចេស្តាបានលេចមកឯពួកគេម្តងទៀត។ ទ្រង់មានបន្ទូលថា ពួកគេនឹងមានកូនប្រុសមួយ ហើយត្រូវហៅឈ្មោះថា អ៊ីសាក។ ព្រះយេហូវ៉ាក៏មានបន្ទូលថា៖

> ឯអ៊ីសម៉ាអែល...អញបានឲ្យពរដល់វា...។ តែឯសេចក្តីសញ្ញារបស់អញ នោះនឹងបានតាំងនឹងអ៊ីសាកវិញ ដែលសារ៉ានឹងបង្កើតឲ្យដល់ឯងនៅកំណត់ឆ្នាំក្រោយនេះ។
> (លោកុប្បត្តិ ១៧:២០-២១)

មួយឆ្នាំក្រោយមក នាង សារ៉ា បង្កើតបានអ៊ីសាក ជាកូនប្រុសតាមសេចក្តីសន្យា។

សូមមើលរូបភាព។ តើអ្នកឃើញលោក អ័ប្រាហាំ និងនាង សារ៉ា កំពុងសម្លឹងមើលទៅមេឃនៅពេលយប់ដែរឬទេ? ពួកគេកំពុងអរព្រះគុណដល់ព្រះជាម្ចាស់ សម្រាប់សេចក្តីស្មោះត្រង់របស់ទ្រង់។ ក្រោយមក នាង ហាការ និងអ៊ីសម៉ាអែលត្រូវបានឲ្យចេញទៅ ប៉ុន្តែព្រះជាម្ចាស់ក៏ល្អចំពោះពួកគេដែរ។

> ព្រះទ្រង់ក៏គង់ជាមួយនឹងកូនជំទង់នោះ វាកាន់តែធំឡើង ហើយនៅតែក្នុងទីរហោស្ថានក៏បានត្រឡប់ជាអ្នកប្រមាញ់ធ្នូ។ វាអាស្រ័យនៅក្នុងទីរហោស្ថានប៉ារ៉ាន ហើយម្តាយក៏នាំយកស្ត្រីម្នាក់ពីស្រុកអេស៊ីព្ទមកឲ្យធ្វើជាប្រពន្ធ។ (លោកុប្បត្តិ ២១:២០-២១)

អ៊ីសម៉ាអែលបានក្លាយជាឪពុកនៃសាសន៍អារ៉ាប់ដ៏មានអំណាច ដែលព្រះជាម្ចាស់បានប្រទានពរជាច្រើន។

ចំណែកឯអ៊ីសាកវិញ គាត់នៅផ្ទះមើលថែហ្វូងសត្វរបស់ឪពុកខ្លួន។ ពេលខ្លះ អ៊ីសាកបានជួយឪពុកជ្រើសរើសកូនចៀមដ៏ល្អ ដើម្បីសម្លាប់ ហើយដុតលើអាសនាធ្វើជាតង្វាយលោះបាប។ ប៉ុន្តែ អ៊ីសាក និងឪពុករបស់គាត់ នឹកស្មានមិនដល់អំពីតង្វាយ ដែលព្រះជាម្ចាស់នឹងទាមទារនោះទេ។





## ភាគទី៣០
# សេចក្ដីល្បងលដ៏ពិបាកបំផុត

ព្រះជាម្ចាស់មានបំណងប្រើលោក អ័ប្រាហាំ និងកូនរបស់គាត់ ជាគំរូដែលបង្ហាញដល់លោកីយ៍ឲ្យឃើញពីទំនាយ និងរូបភាពនៃផែនការរបស់ទ្រង់ ដើម្បីជួយសង្គ្រោះមនុស្សមានបាបពីអំពើបាប និងសេចក្ដីស្លាប់។ ព្រះជាម្ចាស់ក៏មានបំណងល្បងលសេចក្ដីជំនឿរបស់លោក អ័ប្រាហាំ ដោយបង្គាប់ឲ្យធ្វើអ្វីមួយ ដែលគួរឲ្យតក់ស្លុត និងពិបាកយល់រហូតដល់ការល្បងលនោះបានសម្រេច។

ពេលនោះ លោក អ័ប្រាហាំ បានទុកចិត្តលើព្រះយេហូវ៉ាទាំងស្រុង។ លោក អ័ប្រាហាំ បានស្គាល់ព្រះជាម្ចាស់ ហើយក៏បានដឹងថា ព្រះទ្រង់ល្អ និងយុត្តិធម៌។ ប៉ុន្តែ តើលោក អ័ប្រាហាំ អាចទុកចិត្ត ហើយស្ដាប់បង្គាប់ទ្រង់បានដែរឬទេ ទោះបីជាអ្វីដែលព្រះជាម្ចាស់បានបង្គាប់ឲ្យគាត់ធ្វើនោះហាក់ដូចជាខុសក៏ដោយ?

នេះជាដំណើររឿង ដែលដកស្រង់ចេញពីព្រះគម្ពីរ៖

> ក្រោយការទាំងនោះមក ព្រះទ្រង់ល្បងអ័ប្រាហាំ ដោយមានបន្ទូលហៅគាត់ថា “អ័ប្រាហាំអើយ”។
>
> គាត់ក៏ទូលឆ្លើយថា “ព្រះករុណាវិសេសព្រះអម្ចាស់”។
>
> រួចទ្រង់មានបន្ទូលថា “ចូរយកអ៊ីសាកកូនឯងដែលជាកូនសំឡាញ់តែ១នោះទៅឥឡូវនាំគ្នាទៅឯស្រុកម៉ូរីយ៉ា[១១] រួចថ្វាយវាជាដង្វាយដុត នៅលើភ្នំ១ក្នុងស្រុកដែលអញនឹងបង្ហាញប្រាប់ឯងនោះ”។
>
> អ័ប្រាហាំក៏ក្រោកឡើងពីព្រលឹម ចាត់ចែងចងកែបលាខ្លួន ហើយពុះឧសសំរាប់ដង្វាយដុត រួចនាំយកបាវ២នាក់ នឹងអ៊ីសាកជាកូនទៅជាមួយ ក៏ដើរដំរង់ទៅឯកន្លែងដែលព្រះមានបន្ទូលប្រាប់នោះ។
>
> លុះដើរបាន៣ថ្ងៃហើយ នោះគាត់ងើបភ្នែកឡើង មើលទៅ ឃើញកន្លែងនោះពីចំងាយ រួចប្រាប់ទៅបាវថា “ចូរឯងនៅទីនេះសិនមើលលាផង អញនឹងទៅឯណោះថ្វាយបង្គំជាមួយនឹងកូនអញ រួចសឹមមកឯឯងវិញ”។
>
> នោះគាត់ចាប់យកឧសដែលសំរាប់ដង្វាយដុតដាក់ឲ្យអ៊ីសាកជាកូនលី ហើយគាត់យកភ្លើងនឹងកាំបិតកាន់នៅដៃ បណ្តើរគ្នាទៅ។
>
> អ៊ីសាកនិយាយនឹងឪពុកថា “លោកឪពុកអើយ”។
>
> គាត់ក៏ឆ្លើយថា “អីកូន”។
>
> រួចវានិយាយថា “នេះមានភ្លើងនិងឧសហើយ តែកូនចៀមសំរាប់ដង្វាយដុតតើនៅឯណា?”។
>
> អ័ប្រាហាំឆ្លើយថា “កូនអើយ កូនចៀមដែលសំរាប់ជាដង្វាយដុត នោះព្រះទ្រង់នឹងផ្គត់ផ្គង់ឲ្យ”។
>
> ដូច្នេះក៏នាំគ្នាទៅទៀត។ (លោកុប្បត្តិ ២២:១-៨)





## ភាគទី៣១
# កូនប្រុសដែលត្រូវស្លាប់

តើអ្នកបានឮអ្វីដែលលោក អ័ប្រាហាំ ប្រាប់ទៅអ្នកបម្រើរបស់គាត់ មុនពេលគាត់ឡើងទៅលើភ្នំ ដើម្បីថ្វាយយញ្ញបូជាដែរឬទេ?

“អញនឹងទៅឯណោះថ្វាយបង្គំជាមួយនឹងកូនអញ រួចសឹមមកឯឯងវិញ។”

តើកូនប្រុសរបស់លោក អ័ប្រាហាំ អាច*ត្រឡប់មកវិញ* ដូចម្តេចបាន ប្រសិនបើវាត្រូវសម្លាប់ ហើយដុតនោះ? ព្រះគម្ពីរចែងថា៖

លោកបានរាប់ថា ព្រះទ្រង់អាចនឹងប្រោសកូន ឲ្យរស់ពីស្លាប់ឡើងវិញបាន។ (ហេព្រើរ ១១:១៩)

ព្រះជាម្ចាស់បានសន្យាហើយថា ទ្រង់នឹងតាំងអ៊ីសាកជាឪពុកនៃសាសន៍មួយថ្មី (ហើយ តាមរយៈសាសន៍នេះ ព្រះសង្គ្រោះដែលត្រូវបានសន្យានឹងយាងមក)។ ព្រះជាម្ចាស់មិនអាច កុហកបានឡើយ។ ចំពោះលោក អ័ប្រាហាំ នោះគ្រប់គ្រាន់នឹងជឿទុកចិត្តហើយ។

ចុះអ៊ីសាកវិញ តើវាកំពុងគិតពីរឿងអ្វី? វាបានដឹងថា ខ្លួនជាមនុស្សមានបាប ហើយសមនឹង ស្លាប់ដោយសារអំពើបាបរបស់ខ្លួន។ វាក៏ដឹងថា ព្រះជាម្ចាស់នឹងទទួលយកតង្វាយយញ្ញបូជា ជំនួសវាវិញ។ *ប៉ុន្តែ នៅថ្ងៃនោះ ពួកគេកំពុងធ្វើដំណើរទៅកាន់កន្លែងថ្វាយយញ្ញបូជា ដោយគ្មាន ចៀមឈ្មោល ឬកូនចៀមទេតើ? មិនយល់សោះ!* នោះអ៊ីសាកក៏និយាយទៅឪពុកថា៖

“នេះមានភ្លើងនឹងឧសហើយ តែកូនចៀមសំរាប់ដង្វាយដុតតើនៅឯណា?”។

អ័ប្រាហាំឆ្លើយថា “កូនអើយ កូនចៀមដែលសំរាប់ជាដង្វាយដុត នោះព្រះទ្រង់នឹងផ្គត់ផ្គង់ឲ្យ”។

ឥឡូវ ចូរបន្តជាមួយរឿងនេះ។

លុះដល់កន្លែងដែលព្រះបានមានបន្ទូលប្រាប់គាត់ហើយ នោះអ័ប្រាហាំក៏ស្អាងអាសនា១ នៅទីនោះ រួចដំរៀបឧស ហើយចងអ៊ីសាកជាកូនដាក់លើឧសនៅលើអាសនា។

គាត់លូកដៃទៅចាប់យកកាំបិតមកប្រុងនឹងសំឡាប់កូន តែទេវតានៃព្រះយេហូវ៉ាមានបន្ទូលពីលើមេឃហៅគាត់ថា “អ័ប្រាហាំៗអើយ”។

នោះគាត់ទូលឆ្លើយថា “ព្រះករុណាវិសេសព្រះអម្ចាស់”។

រួចទ្រង់មានបន្ទូលថា “...កុំឲ្យធ្វើអ្វីដល់វាឲ្យសោះ ដ្បិតឥឡូវនេះអញដឹងថា ឯងកោតខ្លាច ដល់ព្រះហើយ ដោយព្រោះមិនបានសំចៃទុកនូវកូនឯងតែ១នេះនឹងអញសោះ”។ (លោកុប្បត្តិ ២២:៩-១២)

លោក អ័ប្រាហាំ និងកូនរបស់គាត់មានអំណរជាខ្លាំង! ចុះយញ្ញបូជាដែលត្រូវថ្វាយនោះវិញ?

នោះអ័ប្រាហាំគាត់ងើបភ្នែកឡើង ឃើញចៀមឈ្មោល១ជាប់ស្នែងនៅព្រៃខាងក្រោយខ្លួន។ (លោកុប្បត្តិ ២២:១៣)

កូនប្រុសរបស់លោក អ័ប្រាហាំ ត្រូវបានរួចផុតពីសេចក្តីស្លាប់ដែលជាទោសនៃអំពើបាប។ ព្រះជាម្ចាស់បានផ្គត់ផ្គង់តង្វាយយញ្ញបូជាឲ្យមកជំនួសហើយ!





## ភាគទី៣២
# រូបភាព និងទំនាយ

តើព្រះជាម្ចាស់បានសង្គ្រោះកូនប្រុសរបស់លោក អ័ប្រាហាំ ដែលត្រូវស្លាប់នោះយ៉ាងដូចម្ដេច? ទ្រង់បានផ្គត់ផ្គង់សត្វដ៏ល្អឥតខ្ចោះ ដែលគ្មានទោសឲ្យងាប់ជំនួស។

> នោះអ័ប្រាហាំគាត់ងើបភ្នែកឡើង ឃើញចៀមឈ្មោល១ជាប់ស្នែងនៅព្រៃខាងក្រោយខ្លួន រួចក៏ទៅយកចៀមឈ្មោលនោះ មកថ្វាយជាដង្វាយដុត ជំនួសកូនខ្លួនវិញ។
> (លោកុប្បត្តិ ២២:១៣)

ទាំងអស់នេះបង្ហាញពីរូបភាពនៃផែនការរបស់ព្រះជាម្ចាស់ ដើម្បីចាត់ព្រះសង្គ្រោះដ៏បរិសុទ្ធឲ្យយាងមកផែនដី ហើយបំពេញការទាមទារនៃអំណាចរបស់អំពើបាប និងសេចក្ដីស្លាប់ ព្រមទាំងសង្គ្រោះមនុស្សមានបាបគ្រប់ជាតិសាសន៍នៅលើផែនដី។

> លោកអ័ប្រាហាំដាក់ឈ្មោះកន្លែងនោះថា *«ព្រះយេហូវ៉ានឹងផ្គត់ផ្គង់»* ដូចមានគេនិយាយហេតុមកដល់ថ្ងៃនេះថា «នៅលើភ្នំរបស់ព្រះយេហូវ៉ា ព្រះអង្គនឹងផ្គត់ផ្គង់ឲ្យ»។
> (លោកុប្បត្តិ ២២:១៤ គកស១៦)

ហេតុអ្វីបានជាលោក អ័ប្រាហាំ ហៅភ្នំនោះថា *ព្រះយេហូវ៉ា**នឹង**ផ្គត់ផ្គង់* តែមិនហៅថា *ព្រះយេហូវ៉า**បាន**ផ្គត់ផ្គង់*?

តើព្រះជាម្ចាស់មិនទើបតែបានផ្គត់ផ្គត់សត្វជាថ្លៃលោះហើយទេឬអី?

ដោយការហៅភ្នំនោះថា *ព្រះយេហូវ៉ានឹងផ្គត់ផ្គង់* នោះហោរា អ័ប្រាហាំ បានប្រាប់ទុកជាមុនអំពីអ្វីនឹងត្រូវកើតឡើងនៅថ្ងៃមួយ គឺនៅលើភ្នំនោះឯង ព្រះជាម្ចាស់ទ្រង់ផ្ទាល់នឹងផ្គត់ផ្គង់យញ្ញបូជាមានឈាមដ៏ថ្លៃវិសេស ដែលទ្រង់នឹងទទួលយកជាការបង់ថ្លៃលោះដ៏ពេញលេញសម្រាប់អំពើបាបរបស់លោកីយ៍ ដូច្នេះអ្នកណាដែលជឿលើព្រះអង្គដ៏ជាយញ្ញបូជានោះមិនត្រូវវិនាសឡើយ គឺបានជីវិតអស់កល្បជានិច្ចវិញ។

ខ្ទង់១៩០០ឆ្នាំក្រោយពីហោរា អ័ប្រាហាំ បានថ្វាយចៀមឈ្មោលជាយញ្ញបូជានៅលើអាសនានោះព្រះសង្គ្រោះដែលត្រូវបានសន្យា បានមានបន្ទូលរំឭកអំពីហេតុការណ៍នេះថា៖

> “លោកអ័ប្រាហាំ ជាឰយុកោអ្នករាល់គ្នា លោកបានត្រេកអរដោយឃើញគ្រាខ្ញុំ លោកក៏បានឃើញមែន ហើយមានសេចក្ដីរីករាយ។” (យ៉ូហាន ៨:៥៦)

ខណៈដែលផ្សែងចេញពីចៀមឈ្មោលបានហុយឡើងទៅលើមេឃ នោះព្រះជាម្ចាស់បានបង្ហាញឲ្យលោក អ័ប្រាហាំ ឃើញពីតង្វាយដុត ដែលត្រូវថ្វាយនៅលើជួរភ្នំដដែលនោះក្នុងពេលអនាគត។ ភ្លាមនោះ ចម្លើយរបស់គាត់ចំពោះសំណួរកូនដែលសួរថា “តើកូនចៀមនៅឯណា?” គឺមានអត្ថន័យកាន់តែជ្រាលជ្រៅបន្ថែមទៀត។

> “កូនអើយ *កូនចៀម* ដែលសំរាប់ជាដង្វាយដុត នោះព្រះទ្រង់នឹងផ្គត់ផ្គង់ឲ្យ។”
> (លោកុប្បត្តិ ២២:៨)

សម្រាប់លោក អ័ប្រាហាំ និងកូនប្រុសគាត់ ព្រះជាម្ចាស់មិនទាន់បានផ្គត់ផ្គង់កូនចៀមនោះនៅឡើយទេ ប៉ុន្តែទ្រង់បានផ្គត់ផ្គង់ចៀមឈ្មោលវិញ។

តើ*កូនចៀម* នោះនៅឯណា?

ដល់ពេលកំណត់ ព្រះជាម្ចាស់ទ្រង់ផ្ទាល់នឹងប្រទានចម្លើយនោះ។





# ភាគទី៣៣
# ព្រះជាម្ចាស់ដ៏ស្មោះត្រង់ និងបរិសុទ្ធ

តើអ្នកនឹកចាំពីសេចក្ដីសន្យាធំៗទាំងពីរដែលព្រះយេហូវ៉ាបានសន្យាចំពោះលោក អ័ប្រាហាំ ដែរឬទេ? នៅក្នុងសេចក្ដីសន្យាទីមួយ ព្រះជាម្ចាស់មានបន្ទូលថា៖

“អញនឹងបង្កើតនគរ១យ៉ាងធំពីឯង។” (លោកុប្បត្តិ ១២:២)

ព្រះជាម្ចាស់បានសម្រេចតាមព្រះបន្ទូលរបស់ទ្រង់មែន។ លោក អ័ប្រាហាំ បង្កើតអ៊ីសាក អ៊ីសាកបង្កើតយ៉ាកុប ហើយយ៉ាកុបបង្កើតកូនប្រុស១២នាក់ រួចក្រោយមក កូនចៅរបស់ពួកគេ បានក្លាយជាពូជអំបូរទាំង១២នៃសាសន៍អ៊ីស្រាអែល។ ព្រះជាម្ចាស់ក៏មានបន្ទូលសន្យាថា៖

“គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរដោយសារឯង។” (លោកុប្បត្តិ ១២:៣)

ព្រះជាម្ចាស់នឹងសម្រេចតាមសេចក្ដីសន្យានេះដែរ។ តាមរយៈសាសន៍ដ៏ពិសេស (ក៏រឹងចចេស) នេះ ព្រះជាម្ចាស់ចង់បង្ហាញមនុស្សទាំងអស់នៅលើផែនដីអំពីលក្ខណៈរបស់ទ្រង់ និងអំពីរបៀប ដែលមនុស្សមានបាបអាចចូលមកចំពោះទ្រង់។ រាល់ពេលដែលព្រះជាម្ចាស់ការពារសាសន៍ នេះ ទ្រង់ក៏បានការពារផែនការរបស់ទ្រង់ ដើម្បីប្រទានពរដល់អ្នក និងខ្ញុំ ពីព្រោះតាមរយៈ សាសន៍នេះ ពួកហោរា ព្រះគម្ពីរបរិសុទ្ធ និងព្រះសង្គ្រោះដែលត្រូវបានសន្យានឹងមក។

ផែនការដ៏អាថ៌កំបាំងរបស់ព្រះជាម្ចាស់បានបន្តទៅមុខ។

ខ្ទង់១៥០០ឆ្នាំ មុនគ.ស. ព្រះជាម្ចាស់បានត្រាស់ហៅលោក ម៉ូសេ ជាពូជលោក អ័ប្រាហាំ ឲ្យធ្វើជាហោរារបស់ទ្រង់។ លោក ម៉ូសេ បានសរសេរព្រះគម្ពីរ៥កណ្ឌដំបូង។ ព្រះជាម្ចាស់ក៏ បានប្រើលោក ម៉ូសេ ឲ្យដឹកនាំពូជរបស់លោក អ័ប្រាហាំ ទាំង៣លាននាក់ឲ្យមានសេរីភាព ក្រោយពីពួកគេបានបម្រើជាទាសករ អស់រយៈពេល៤សតវត្សរ៍។ ព្រះជាម្ចាស់ទ្រង់ផ្ទាល់ បាននាំផ្លូវពួកគេឆ្លងកាត់វាលខ្សាច់ដ៏លំបាក ដោយបង្គោលពពកដើម្បីផ្ដល់ម្លប់នៅពេលថ្ងៃ និងបង្គោលភ្លើងដើម្បីបំភ្លឺនៅពេលយប់។ ដោយព្រះហស្តដ៏ខ្លាំងពូកែ ទ្រង់បានបើកផ្លូវនៅ កណ្ដាលសមុទ្រក្រហមឲ្យពួកគេរត់គេចខ្លួន ហើយប្រទានអាហារពីលើមេឃ និងទឹកចេញពីថ្ម រួចនាំពួកគេទៅឯភ្នំស៊ីណាយ។

នៅត្រង់ជើងភ្នំនោះ ព្រះជាម្ចាស់មានបន្ទូលទៅពួកគេថា៖

“ឯងរាល់គ្នានឹងបានធ្វើជានគរដល់អញ...ហើយជាសាសន៍បរិសុទ្ធឲ្យអញដែរ!” (និក្ខមនំ ១៩:៦)

ព្រះជាម្ចាស់ចង់ឲ្យសាសន៍នេះបរិសុទ្ធ គឺញែកចេញសម្រាប់ទ្រង់ ហើយឲ្យមានលក្ខណៈខុសពី សាសន៍ដទៃទៀតនៅជុំវិញ ប៉ុន្តែពួកគេមិនបានដឹងថា ភាពបរិសុទ្ធមានន័យយ៉ាងដូចម្ដេចទេ។ ពួកគេមិនបានរាប់ខ្លួនថាជាមនុស្សមានបាប ដែលគ្មានសង្ឃឹមនោះទេ។ ពួកគេបានគិតថា ខ្លួន អាចធ្វើអ្វីគ្រប់យ៉ាង ដើម្បីផ្គាប់ព្រះហឫទ័យរបស់ទ្រង់។ ដើម្បីបង្រៀនមេរៀនអំពីសេចក្ដីក្រោធ របស់ទ្រង់ចំពោះអំពើបាប នោះព្រះយេហូវ៉ាបានយាងចុះមក ទាំងមានភ្លើងឆេះ និងសម្លេងត្រែ ឮរំពងដល់ទៅកក្រើកដី។

> ឯភ្នំស៊ីណាយក៏ហុយផ្សែងឡើងពេញទាំងអស់ ដ្បិតព្រះយេហូវ៉ាទ្រង់យាងចុះមកលើភ្នំគង់ ក្នុងភ្លើង ផ្សែងនោះហុយឡើងដូចជាផ្សែងនៃគុកភ្លើង តួភ្នំទាំងមូលក៏កក្រើករំពើកយ៉ាង ខ្លាំង។ កាលឮសូរស្នែងកាន់តែឮខ្លាំងឡើង នោះម៉ូសេក៏ទូល ហើយព្រះទ្រង់មានបន្ទូល ឆ្លើយតបមកលោក។ (និក្ខមនំ ១៩:១៨-១៩)

ព្រះជាម្ចាស់បានប្រទានបញ្ញត្តិមួយដល់លោក អ័ដាម។

ឥឡូវ ទ្រង់នឹងប្រទានបញ្ញត្តិ១០ដល់សាសន៍ថ្មីនេះ។





# ភាគទី៣៤
# ក្រឹត្យវិន័យទាំង១០ប្រការ

មនុស្សភាគច្រើននៃសាសន៍នេះបានគិតថា ខ្លួនល្អគ្រប់គ្រាន់ដើម្បីធ្វើជារាស្ត្ររបស់ព្រះជាម្ចាស់។ ដូច្នេះ ព្រះយេហូវ៉ាបានប្រទានក្រឹត្យវិន័យទាំង១០ប្រការដល់ពួកគេ ជាដំបូងដោយសម្លេងដូចផ្គរលាន់ពីភ្នំស៊ីណាយ បន្ទាប់មកដោយចារឹកលើបន្ទះថ្ម២ផ្ទាំង។

ចូរអានក្រឹត្យវិន័យទាំង១០ប្រការ (នៅទំព័រខាងស្តាំ បានសង្ខេបពីព្រះគម្ពីរនិក្ខមនំ ២០)។

ព្រះជាម្ចាស់មានបន្ទូលប្រាប់លោក ម៉ូសេ ថា ពួកគេត្រូវតែគោរពតាមបញ្ញត្តិទាំង១០នេះឲ្យបានល្អឥតខ្ចោះ។

> "ត្រូវបណ្តាសាហើយ អ្នកណាដែលមិនយកចិត្តទុកដាក់នឹងអស់ទាំងពាក្យក្នុងក្រិត្យវិន័យនេះ។" (ចោទិយកថា ២៧:២៦)

តើអ្នកគិតថា ពួកគេមានអារម្មណ៍យ៉ាងណា ក្រោយពីបានឮបញ្ញត្តិទាំង១០នេះ? តើអ្នកគិតថា ពួកគេនៅតែរាប់ខ្លួនជាមនុស្សល្អគ្រប់គ្រាន់ដែរឬទេ? ចុះអ្នកវិញ? តើអ្នកគិតថា ខ្លួនអ្នកជាមនុស្សល្អគ្រប់គ្រាន់ ដើម្បីរស់នៅក្នុងនគររបស់ព្រះជាម្ចាស់ដ៏ល្អឥតខ្ចោះដែរឬទេ?

សូមអាន*បញ្ញត្តិទី១* ម្តងទៀត។ តើអ្នកតែងតែទុកព្រះជាម្ចាស់ជាទីមួយដែរឬទេ? បើអត់ទេ នោះអ្នកមិនបានគោរពតាមច្បាប់នេះ។ សូមអាន*បញ្ញត្តិទី៥*។ បើអ្នកធ្លាប់មិនស្តាប់បង្គាប់ឪពុកម្តាយ នោះអ្នកមានទោសចំពោះព្រះជាម្ចាស់ហើយ។ សូមអាន*បញ្ញត្តិទី៨*។ បើអ្នកធ្លាប់យករបស់គេ ឬក៏ធ្លាប់លួចមើលពេលប្រឡង នោះអ្នកបានរំលងច្បាប់នេះហើយ។ តើអ្នកធ្លាប់កុហកដែរឬទេ? នោះអ្នកមិនបានគោរពតាម*បញ្ញត្តិទី៩*ទេ។ *បញ្ញត្តិចុងក្រោយ* ប្រាប់យើងថា សូម្បីតែការចង់បានរបស់អ្នកដទៃក៏ខុសដែរ។ ព្រះជាម្ចាស់ទតឃើញអំពើបាបនៅក្នុងចិត្តរបស់យើង។

តើអំពើបាបចំនួនប៉ុន្មានបានបំផ្លាញទំនាក់ទំនងរបស់លោក អ័ដាម និងនាង អេវ៉ា ជាមួយនឹងព្រះជាម្ចាស់? *គឺតែមួយប៉ុណ្ណោះ*។ ខ្នាតដ៏សុក្រឹតរបស់ព្រះជាម្ចាស់ នោះមិនបានប្រែប្រួលទេ។

> ដ្បិតអ្នកណាដែលកាន់ក្រិត្យវិន័យទាំងមូល តែភ្លាត់ជំពប់នឹងបទណាមួយ នោះក៏ត្រូវរាប់ជាមានទោសចំពោះក្រិត្យវិន័យទាំងមូលនោះហើយ។ (យ៉ាកុប ២:១០)

ព្រះជាម្ចាស់ គឺបរិសុទ្ធ ទ្រង់មិនអាចមើលរំលងអំពើបាបបានឡើយ។ តើអ្នកចង់នៅក្នុងបន្ទប់មានជ្រូកងាប់ ដែលកំពុងស្អុយដែរឬទេ? អំពើបាបរបស់យើងនៅចំពោះព្រះជាម្ចាស់ គឺយ៉ាងដូច្នេះឯង។ ដូចដែលការបាញ់ទឹកអប់លើជ្រូកស្អុយនោះ មិនអាចសម្អាតបន្ទប់បានជាយ៉ាងណា នោះការខិតខំប្រឹងប្រែងតាមសាសនា ក៏មិនអាចសម្អាតចិត្តរបស់យើងបានយ៉ាងនោះដែរ។

ដូចជាកញ្ចក់បង្ហាញមុខខ្ញុំដែលប្រឡាក់ជាយ៉ាងណា នោះច្បាប់របស់ព្រះជាម្ចាស់ក៏បង្ហាញពីអំពើបាបក្នុងចិត្តខ្ញុំយ៉ាងនោះដែរ។ ដូចដែលកញ្ចក់មិនអាចសម្អាតមុខខ្ញុំជាយ៉ាងណា នោះក្រឹត្យវិន័យទាំង១០ប្រការ ក៏មិនអាចសម្អាតចិត្តខ្ញុំយ៉ាងនោះដែរ។

> គ្មានមនុស្សណាបានរាប់ជាសុចរិត នៅចំពោះទ្រង់ ដោយអាងការប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ ដ្បិតក្រិត្យវិន័យគ្រាន់តែសំដែងឲ្យស្គាល់អំពើបាបប៉ុណ្ណោះ។ (រ៉ូម ៣:២០)

ទោះបើយើងគិតថា ខ្លួនយើងល្អប៉ុណ្ណាក៏ដោយ នោះយើងនៅតែមិនល្អគ្រប់គ្រាន់ ដើម្បីរស់នៅជាមួយព្រះជាម្ចាស់នៅឯស្ថានសួគ៌ឡើយ។

យើងត្រូវការព្រះសង្គ្រោះ។

១. កុំឲ្យមានព្រះឯណា
ទៀតនៅចំពោះ
អញឲ្យសោះ។

២. កុំឲ្យឆ្លាក់ធ្វើរូបណា
សម្រាប់ឯងឲ្យសោះ
...ដ្បិតអញ
ដែលជាយេហូវ៉ា
ជាព្រះនៃឯង។

៣. កុំឲ្យចេញព្រះនាម
របស់ព្រះយេហូវ៉ា
ជាព្រះនៃឯង
ជាអសារឥតការ
ឡើយ។

៤. ចូរឲ្យនឹកចាំពី
ថ្ងៃឈប់សម្រាក
ដើម្បីញែកថ្ងៃនោះ
ចេញជាបរិសុទ្ធ។

៥. ចូរឲ្យគោរព
ប្រតិបត្តិដល់
ឪពុកម្តាយ។

៦. កុំឲ្យសម្លាប់
មនុស្សឲ្យសោះ។

៧. កុំឲ្យផិតគ្នា
ឲ្យសោះ។

៨. កុំឲ្យលួចប្លន់
ឲ្យសោះ។

៩. កុំឲ្យធ្វើជា
ទីបន្ទាល់ក្លែង
ទាស់នឹង
អ្នកជិតខាងខ្លួន
ឲ្យសោះ។

១០. កុំឲ្យលោភចង់
បានប្រពន្ធគេ
...ឬរបស់អ្វីផង
អ្នកជិតខាងខ្លួន
ឲ្យសោះ។



# ភាគទី៣៥
# រូបភាពបន្ថែមទៀត

ក្រឹត្យវិន័យទាំង១០ប្រការបានផ្តល់ខ្នាតដ៏ច្បាស់លាស់ដល់សាសន៍ថ្មីនេះ ឲ្យដឹងអ្វីដែលខុស និងអ្វីដែលត្រូវ។ នោះជាការល្អប្រសើរពិតមែន ប៉ុន្តែច្បាប់របស់ព្រះជាម្ចាស់ក៏បាននាំដំណឹងអាក្រក់មកជាមួយដែរ។ ច្បាប់ទាំងនោះបានបង្ហាញមនុស្សឲ្យដឹងថា ពួកគេកំពុងស្ថិតនៅក្នុងបញ្ហាដ៏ធំ។ ដោយព្រោះអំពើបាបរបស់ពួកគេ នោះពួកគេត្រូវតែស្លាប់ ហើយត្រូវដាច់ចេញពីព្រះជាម្ចាស់។

រីឯដំណឹងល្អវិញ គឺថា ព្រះយេហូវ៉ានៅតែទទួលយកឈាមនៃកូនចៀម គោឈ្មោល ពពែ និងព្រាប ដើម្បីបិទបាំងអំពើបាបរបស់ពួកគេ។ ដូច្នេះ នៅថ្ងៃដែលព្រះជាម្ចាស់បានប្រកាសក្រឹត្យវិន័យទាំង១០ប្រការនោះ ទ្រង់បានមានបន្ទូលប្រាប់លោក ម៉ូសេ ថា៖

> “ត្រូវឲ្យឯងយកដីស្អាងអាសនា...ហើយត្រូវថ្វាយដង្វាយដុត...នៅលើអាសនានោះ។”
> (និក្ខមនំ ២០:២៤)

តើអ្នកឃើញលោក ម៉ូសេ ដាក់ដៃលើក្បាលកូនចៀមដែរឬទេ? តើអ្នកឃើញពួកមនុស្សកំពុងលូកដៃទៅឯកូនចៀមនោះដែរឬទេ? ដោយសារពួកគេបានជឿដល់ព្រះជាម្ចាស់ និងផ្លូវនៃការអត់ទោសរបស់ទ្រង់ នោះអំពើបាបរបស់ពួកគេត្រូវបានផ្ទុកនៅលើកូនចៀមដែលគ្មានទោសវិញ។ បន្ទាប់មក កូនចៀមនោះត្រូវបានសម្លាប់នៅលើអាសនា។ ឈាមដែលត្រូវបានបង្ហូរនឹងបិទបាំងអំពើបាបរបស់ពួកមនុស្ស។ បន្ទាប់មកទៀត ខ្លួនរបស់វានឹងត្រូវដុតក្លាយជាផេះ។ ផេះនេះនឹងបង្ហាញមនុស្សពីអ្វីដែលព្រះជាម្ចាស់បានធ្វើចំពោះអំពើបាបរបស់ពួកគេ។ អំពើបាបរបស់ពួកគេត្រូវបានអត់ទោសហើយ!

ប៉ុន្តែ របៀបនៃការថ្វាយតង្វាយជាឈាមសត្វសម្រាប់ការអត់ទោសបាបនេះ គឺគ្រាន់តែជារូបភាពតំណាងឲ្យអ្វីដែលព្រះជាម្ចាស់ពិតជាបានទាមទារ។

> ដ្បិតឯក្រិត្យវិន័យ...ពុំអាចនឹងធ្វើឲ្យពួកអ្នក ដែលចូលមកថ្វាយយញ្ញបូជាដដែលៗរាល់តែឆ្នាំជានិច្ច បានគ្រប់លក្ខណ៍ឡើយ។ ដ្បិតបើបាន តើគេមិនបានលែងថ្វាយទេឬអីពីព្រោះបញ្ញាចិត្តនៃពួកអ្នកដែលថ្វាយបង្គំ នោះមិនបានដឹងថាមានបាបទៀតទេ ដោយព្រោះបានញែកសំអាតម្តងហើយ។
>
> តែយញ្ញបូជាទាំងនោះនាំឲ្យរំឭកឃើញ ពីអំពើបាបរបស់គេរាល់តែឆ្នាំវិញ។ ដ្បិតឈាមគោឈ្មោល នឹងពពែឈ្មោល នោះពុំអាចនឹងដោះបាបបានឡើយ។
> (ហេព្រើរ ១០:១-៤)

សត្វមិនត្រូវបានបង្កើតមកឲ្យចំនឹងរូបអង្គទ្រង់ទេ។

តម្លៃនៃកូនចៀមមិនស្មើនឹងតម្លៃនៃមនុស្សឡើយ។ ដូចដែលអ្នកមិនអាចយកឡានជ័រទៅដោះដូរជាមួយនឹងឡានពិតប្រាកដជាយ៉ាងណា នោះឈាមនៃកូនចៀមក៏មិនអាចបង់ថ្លៃដ៏ខ្ពស់ ដែលអំណាចរបស់អំពើបាប និងសេចក្តីស្លាប់ទាមទារយ៉ាងនោះដែរ។

មនុស្សត្រូវការយញ្ញបូជាដ៏ប្រសើរជាង។

ការថ្វាយសត្វជាយញ្ញបូជាមិនអាចដោះបាបរបស់លោកីយ៍ក៏ពិតមែន ប៉ុន្តែវាបានបង្ហាញមនុស្សមានបាបឲ្យឃើញពីរូបភាពនៃព្រះមួយអង្គដែលអាចដោះបាបបាន។





# ភាគទី៣៦
# ទំនាយបន្ថែមទៀត

ពេលវេលាដែលព្រះសង្គ្រោះត្រូវយាងមកកាន់តែខិតជិតមកដល់ នោះព្រះយេហូវ៉ាបានបង្គាប់ពួកហោរាឲ្យកត់ត្រាទំនាយ[១២]ជាច្រើនបន្ថែមទៀត អំពីព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ។ ខាងក្រោមនេះជាសេចក្តីសន្យាខ្លះៗ ដែលពួកហោរាទាំងនោះបានកត់ទុកពីបុរាណ៖

*មើល នាងព្រហ្មចារីនឹងមានគភ៌ ប្រសូតបានបុត្រា១...។*
*_ហោរា អេសាយ ៧:១៤*

*"តែឯង ឱបេថ្លេហិម...នឹងមានម្នាក់កើតចេញពីឯងមកឲ្យអញ អ្នកនោះត្រូវឡើងជាអ្នកគ្រប់គ្រង...ដើមកំណើតរបស់អ្នកនោះបានចាប់តាំងពីបុរាណ គឺពីអស់កល្បរៀងមក។"*
*_ហោរា មីកា ៥:១*

*ដ្បិតមានបុត្រ១កើតដល់យើង ព្រះទ្រង់ប្រទានបុត្រា១មកយើង ហើយ...គេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា...នឹងជាម្ចាស់នៃមេត្រីភាព។*
*_ហោរា អេសាយ ៩:៦*

*ព្រះនៃអ្នករាល់គ្នា ទ្រង់នឹងយាងមក...ទ្រង់នឹងយាងមកជួយសង្គ្រោះអ្នករាល់គ្នា។ គ្រានោះ ភ្នែករបស់មនុស្សខ្វាក់ នឹងបានភ្លឺឡើង ហើយត្រចៀករបស់មនុស្សថ្លង់នឹងឮបាន។ គ្រានោះ ពួកមនុស្សខ្វិននឹងលោតដូចជាប្រើស...។*
*_ហោរា អេសាយ ៣៥:៤-៦*

*ទ្រង់...គឺដូចជាកូនចៀមដែលគេដឹកទៅសំឡាប់...។*
*_ហោរា អេសាយ ៥៣:៧*

*"គេបានចាក់ទំលុះដៃជើងនៃទូលបង្គំ។"*
*_ហោរា ដាវីឌ, ទំនុកដំកើង ២២:១៦*

ព្រះសង្គ្រោះដែលត្រូវបានសន្យានឹងយាងមក!
ប៉ុន្តែ តើទ្រង់នឹងយាងមកនៅពេលណា? ហើយ តើទ្រង់ជានរណា?
តើទំនាយទាំងនោះនឹងសម្រេចយ៉ាងដូចម្តេច?



# ផ្នែកទី២

## ព្រះមហាក្សត្រ
## បំពេញផែនការ
## របស់ទ្រង់

— ព្រះគម្ពីរសញ្ញាថ្មី —



## ភាគទី៣៧
# រឿងរបស់ព្រះមហាក្សត្របន្ត

តើអ្នកចូលចិត្តផ្នែកទីមួយនៃសៀវភៅរបស់ព្រះមហាក្សត្រដែរឬទេ? តើអ្នកបានរៀនអ្វីខ្លះពីក្នុងព្រះគម្ពីរសញ្ញាចាស់?

សញ្ញាមានន័យថា *កិច្ចព្រមព្រៀង ឬកិច្ចសន្យា*។ យូរណាស់មកហើយ មុនពេលព្រះជាម្ចាស់បានប្រទានព្រះគម្ពីរសញ្ញាថ្មី នោះទ្រង់មានបន្ទូលថា៖

> “នឹងមានគ្រាមកដល់ ដែលអញនឹងតាំងសញ្ញាថ្មី។” (យេរេមា ៣១:៣១)

ពេលតាំងសញ្ញាដំបូងជាមួយរាស្ត្ររបស់ទ្រង់ នោះព្រះជាម្ចាស់បានប្រទានច្បាប់ជាច្រើន ដើម្បីបង្ហាញពីភាពបរិសុទ្ធរបស់ទ្រង់ និងភាពទុច្ចរិតរបស់ពួកគេ។ ទ្រង់ក៏បានប្រទានរូបភាព និងទំនាយជាច្រើន អំពីព្រះសង្គ្រោះដែលត្រូវយាងមក។ នៅក្នុងសញ្ញាចាស់ ពួកហោរាបានទាយទុកជាមុនថា ព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ*នឹងយាងមក* តែនៅក្នុងសញ្ញាថ្មីវិញ បានចែងថា ព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ*បានយាងមកហើយ*!

ក្នុងព្រះគម្ពីរសញ្ញាថ្មីមានកណ្ឌគម្ពីរ *ដំណឹងល្អ*។ ក្នុងភាសាអារ៉ាប់ គេហៅពាក្យនេះថា *អ៊ិនជីល*។
កណ្ឌគម្ពីរដំណឹងល្អចាប់ផ្តើមយ៉ាងដូច្នេះ៖

> នេះបញ្ជីពង្សាវតារពីព្រះយេស៊ូវគ្រីស្ទ ជាវង្សាហ្លួងដាវីឌ នឹងជាជំនួរវង្សនៃលោកអ័ប្រាហាំដែរ។ អ័ប្រាហាំបង្កើតអ៊ីសាក ឯបង្កើតយ៉ាកុប...។ (ម៉ាថាយ ១:១-២)

ព្រះគម្ពីរបានកត់ត្រាបញ្ជីពង្សាវតារពីឈ្មោះមួយទៅឈ្មោះមួយតៗគ្នា ចាប់តាំងពីលោកអ័ប្រាហាំ រហូតដល់ព្រះយេស៊ូវ។ ព្រះជាម្ចាស់នឹងរក្សាព្រះបន្ទូលរបស់ទ្រង់ ដែលសន្យាថានឹងប្រទានពរដល់គ្រប់ជាតិសាសន៍ ដោយចាត់ព្រះសង្គ្រោះឲ្យយាងមកតាមរយៈពូជរបស់លោក អ័ប្រាហាំ។

ព្រះគម្ពីរសញ្ញាថ្មីមានកណ្ឌគម្ពីរដំណឹងល្អចំនួន៤កណ្ឌ។ ហេតុអ្វីបានជាមានដល់ទៅ៤កណ្ឌ? មិនមានតែ១កណ្ឌ? ក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់មានបន្ទូលប្រាប់លោក ម៉ូសេ ថា៖

> “កាលណាមានសាក្សីពីរ ឬបីនាក់ ទើបសំណុំរឿងនោះអាចយកជាការបាន។” (ចោទិយកថា ១៩:១៥ គខប)

ដើម្បីបញ្ជាក់បង្ហាញពីភាពពិតនៃរឿងរ៉ាវ និងសាររបស់ទ្រង់ នោះព្រះជាម្ចាស់បានជ្រើសរើសមនុស្ស៤នាក់ គឺមិនមែន២ ឬ៣នាក់ ដើម្បីកត់ត្រាអំពីជីវិតរបស់ព្រះមេស្ស៊ីដោយឡែកពីគ្នា។ ឈ្មោះរបស់ពួកគេ គឺម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន។ ដូចអ្នកយកព័ត៌មាន៤នាក់ ដែលចុះផ្សាយពីហេតុការណ៍តែ១ ទាំង៤នាក់បានរៀបរាប់ពីសាច់រឿងតែ១ តែតាមទស្សនៈ៤ខុសៗគ្នា។

ព្រះគម្ពីរសញ្ញាថ្មីមានចំនួន២៧កណ្ឌ។ កណ្ឌគម្ពីរកិច្ចការ ដែលបានកត់ត្រាដោយលោក លូកា ប្រាប់ពីអ្វីៗដែលបានកើតឡើង បន្ទាប់ពីព្រះមេស្ស៊ីបានបញ្ចប់បេសកកម្មរបស់ទ្រង់។ ព្រះជាម្ចាស់បានបណ្តាលឲ្យលោក ប៉ុល (ជាអតីតអ្នកបៀតបៀន) លោក យ៉ាកុប និងលោក យូដាស (ជាបងប្អូនរបស់ព្រះយេស៊ូវ) លោក ពេត្រុស និង លោក យ៉ូហាន (ជាអ្នកនេសាទ) កត់ត្រាព្រះគម្ពីរសញ្ញាថ្មីដែលនៅសល់។ កណ្ឌនីមួយៗបើកសម្តែងឲ្យស្គាល់កាន់តែច្បាស់អំពីព្រះមហាក្សត្រ និងផែនការរបស់ទ្រង់ សម្រាប់អស់អ្នកដែលស្រឡាញ់ទ្រង់។

ឥឡូវនេះ រឿងរបស់ទ្រង់មានដូចតទៅ។





# ភាគទី៣៨
# រឿងរ៉ាវរបស់នាង ម៉ារា

ដល់ពេលហើយ គឺក្រោយពីការរៀបចំអស់រយៈពេលរាប់ពាន់ឆ្នាំ នោះព្រះជាម្ចាស់នឹងចាត់ព្រះសង្គ្រោះដ៏ជាព្រះមេស្ស៊ី និងជាព្រះមហាក្សត្រដែលត្រូវបានសន្យា ឲ្យយាងមកលើផែនដីក្នុងពេលឆាប់ៗនេះ។ ប៉ុន្តែ តើទ្រង់ជានរណា? ហើយ តើទ្រង់នឹងយាងមកដោយរបៀបណា?

> កាលនៅរាជ្យហេរ៉ូឌ ជាស្តេចស្រុកយូដា… ព្រះទ្រង់ចាត់ទេវតាកាព្រីយ៉ែល ឲ្យទៅឯនាងព្រហ្មចារីម្នាក់ ដែលនៅភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ ជាស្ត្រីដែលបានបំរុងទុកឲ្យមនុស្សម្នាក់ឈ្មោះយ៉ូសែប ជាពូជហ្លួងដាវីឌ នាងនោះឈ្មោះម៉ារា។
>
> ទេវតានិយាយថា “កុំខ្លាចអី ម៉ារាអើយ ដ្បិតព្រះបានប្រោសមេត្តាដល់នាងហើយ។ មើល នាងនឹងមានគភ៌ប្រសូតបានបុត្រា១ ដែលនាងត្រូវថ្វាយព្រះនាមថា «យេស៊ូវ»។ បុត្រនោះនឹងបានជាធំឧត្តម ហើយគេនឹងហៅទ្រង់ ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត។ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងប្រទានរាជ្យនៃហ្លួងដាវីឌ ជាឰយុកោទ្រង់ថ្វាយទ្រង់សោយ។ ទ្រង់នឹងសោយរាជ្យ…ហើយរាជ្យទ្រង់នឹងមិនផុតឡើយ”។
>
> តែម៉ារាសួរទេវតាថា “ខ្ញុំមិនស្គាល់ប្រុសណាផង ដូច្នេះ តើធ្វើដូចម្តេចនឹងឲ្យការនេះសម្រេចបាន?”។
>
> ទេវតាក៏ឆ្លើយថា “ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាង ហើយព្រះចេស្តានៃព្រះដ៏ខ្ពស់បំផុត នឹងមកគ្របបាំងនាងដោយស្រមោល ហេតុដូច្នេះ បុត្របរិសុទ្ធដែលនឹងប្រសូតមកនោះ ត្រូវហៅថាជាព្រះរាជបុត្រានៃព្រះ”។ (លូកា១:៥, ២៦-២៧, ៣០-៣៥)

ហេតុអ្វីបានជាទេវតា កាព្រីយ៉ែល ហៅព្រះយេស៊ូវថា “ព្រះរាជបុត្រានៃព្រះ”?

មនុស្សខ្លះគិតថា ការហៅបែបនេះមានន័យថា ព្រះជាម្ចាស់មានប្រពន្ធ ហើយក៏បង្កើតបានបុត្រាមួយ។ នេះ*មិន*មានន័យយ៉ាងដូច្នេះទេ។ បើអ្នកមកពីទ្វីបអាហ្វ្រិក គេអាចហៅអ្នកថា “កូនអាហ្វ្រិក”។ តើនេះមានន័យថា ទ្វីបអាហ្វ្រិកយកប្រពន្ធ ហើយមានកូនដែរឬទេ? ទេ! គឺមានន័យថា អ្នកមកពីទ្វីបអាហ្វ្រិក។

ព្រះមេស្ស៊ីត្រូវបានហៅថា ព្រះរាជបុត្រានៃព្រះ ពីព្រោះទ្រង់បានយាងមកពីព្រះជាម្ចាស់។ ទ្រង់បានយាងមកក្នុងគ្រួសាររបស់លោក អ័ដាម ដែលត្រូវបានបំផ្លាញដោយអំពើបាប ប៉ុន្តែទ្រង់មិនមែនជាពូជរបស់លោក អ័ដាម នោះទេ។ ទ្រង់ជាព្រះបន្ទូល ជាព្រលឹង និងជាព្រះរាជបុត្រានៃព្រះ។

> កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។ ទ្រង់គង់នៅជាមួយនឹងព្រះតាំងអំពីដើមមក។ គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ។
> ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ នឹងសេចក្តីពិត។ (យ៉ូហាន ១:១-៣, ១៤)

តើអ្នកចាំអ្វីដែលព្រះជាម្ចាស់បានសន្យា នៅថ្ងៃដែលលោក អ័ដាម បរិភោគផ្លែដែលទ្រង់បានហាមដែរឬទេ? ព្រះជាម្ចាស់បានប្រកាសថា *ពូជស្ត្រីនឹងកិនក្បាលសត្វពស់*។

ពូជស្ត្រីដែលព្រះជាម្ចាស់បានសន្យានោះ ឥឡូវបានចាប់ទំក្នុងផ្ទៃរបស់នាងព្រហ្មចារីហើយ។ តើទ្រង់នឹងកិនក្បាលសត្វពស់យ៉ាងណានោះ យើងនឹងឃើញនៅពេលខាងមុខ។





# ភាគទី៣៩
# រឿងរ៉ាវរបស់លោក យ៉ូសែប

នាង ម៉ារា បានភ្ជាប់ពាក្យជាមួយនឹងលោក យ៉ូសែប ដែលជាជាងឈើម្នាក់នៅភូមិណាសារ៉ែត ជាស្រុកជាប់ព្រំប្រទល់នៅភាគខាងជើងនៃតំបន់ប៉ាឡេស្ទីន។

ទាំងនាង ម៉ារា និងលោក យ៉ូសែប គឺជាសាសន៍យូដា ជាពូជពង្សស្ដេច ដាវីឌ ហើយក៏ជាពូជរបស់លោក អ័ប្រាហាំ ដែរ។ លោក យ៉ូសែប អាចធ្វើជាព្រះរាជបុត្រស្នងរាជ្យ ប៉ុន្តែប្រទេសគាត់ត្រូវបានត្រួតត្រាដោយចក្រភពរ៉ូម។ ពួកទាហានរ៉ូមបានដើរល្បាតនៅតាមផ្លូវ។ សាសន៍យូដាដែលជាប់សង្ស័យជាអ្នកប្រឆាំងត្រូវបានចាប់ខ្លួន ហើយឆ្កាង។ អ្នកយកពន្ធក៏បានកេងប្រវ័ញ្ចប្រជាជន។ ជីវិតពិតជាជូរចត់។

ប៉ុន្តែ លោក យ៉ូសែប កំពុងតែរំភើបចិត្ត ដោយព្រោះគាត់នឹងយកនាង ម៉ារា ធ្វើជាប្រពន្ធក្នុងពេលឆាប់ៗនេះ។ គាត់បានខំរៀបចំកន្លែងដែលពួកគេត្រូវរស់នៅជាមួយគ្នា ក្រោយពេលរៀបការ។ ថ្ងៃមួយ ស្រាប់តែគាត់បានឮដំណឹងដ៏គួរឲ្យភ្ញាក់ផ្អើល គឺថា នាង ម៉ារា មានទម្ងន់។

តើអ្នកគិតថា លោក យ៉ូសែប មានអារម្មណ៍យ៉ាងណា? មើលទៅហាក់ដូចជានាង ម៉ារា មិនស្មោះត្រង់ចំពោះគាត់។

លោក យ៉ូសែប ខូចចិត្តជាខ្លាំង ប៉ុន្តែគាត់ចង់ធ្វើអ្វីដែលត្រឹមត្រូវ។ ដូច្នេះ គាត់ក៏បានសម្រេចចិត្តនឹងផ្ដាច់ពាក្យដោយស្ងាត់ៗ ពីព្រោះគាត់មិនចង់ឲ្យនាងមានសេចក្ដីអាម៉ាស់ឡើយ។

> កាលដែលគាត់កំពុងតែគិតពីការនោះ ស្រាប់តែមានទេវតានៃព្រះអម្ចាស់លេចមកពន្យល់សប្តិ ប្រាប់គាត់ថា៖
>
> “យ៉ូសែប ពូជហ្លួងដាវីឌអើយ កុំឲ្យខ្លាចនឹងយកនាងម៉ារា ជាប្រពន្ធអ្នកឡើយ ដ្បិតបុត្រដែលមកចាប់ទំផ្ទៃនាង នោះកើតពីព្រះវិញ្ញាណបរិសុទ្ធទេ។ នាងនឹងប្រសូតបុត្រា១ ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ឲ្យរួចពីបាប។”
>
> ការទាំងនោះកើតមក ដើម្បីឲ្យបានសំរេចសេចក្តី ដែលព្រះអម្ចាស់ទ្រង់មានបន្ទូលដោយសារហោរាថា «មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយព្រះនាមបុត្រនោះត្រូវហៅថា អេម៉ាញូអែល» ដែលប្រែថា ព្រះអង្គទ្រង់គង់ជាមួយនឹងយើងខ្ញុំ។ (ម៉ាថាយ ១:២០-២៣)

ទុក្ខសោករបស់លោក យ៉ូសែប បានត្រឡប់ជាអំណរវិញ។ *នេះជាកិត្តិយសដ៏អស្ចារ្យ! នាង ម៉ារា នឹងធ្វើជាម្តាយនៃព្រះមេស្ស៊ីដែលត្រូវបានសន្យា! ហើយលោក យ៉ូសែប នឹងក្លាយជាអាណាព្យាបាលរបស់បុត្រានោះ!*

ព្រះមេស្ស៊ីដ៏បរិសុទ្ធនេះ នឹងមានម្តាយជាមនុស្ស តែគ្មានឪពុកជាមនុស្សទេ។ ព្រះនាមរបស់ទ្រង់ គឺយេស៊ូវ មានន័យថា *ព្រះយេហូវ៉ាសង្គ្រោះ* ឬក៏អាចហៅយ៉ាងខ្លីថា *ព្រះសង្គ្រោះ*។

> លុះយ៉ូសែបភ្ញាក់ពីដេកឡើង នោះគាត់ក៏ធ្វើតាមបង្គាប់របស់ទេវតានៃព្រះអម្ចាស់ គឺគាត់យកប្រពន្ធមកនៅជាមួយ តែមិនបានរួមរស់នឹងនាងសោះ ទាល់តែនាងប្រសូតបុត្រជាចំបងមក រួចគាត់ថ្វាយព្រះនាមថា «យេស៊ូវ»។ (ម៉ាថាយ ១:២៤-២៥)

ព្រះហស្តនៃព្រះជាម្ចាស់បានគ្រប់គ្រងលើការទាំងអស់នេះ។





## ភាគទី៤០

# ការយាងមកដល់

នៅ៧០០ឆ្នាំមុនគ្រានោះ ហោរា មីកា បានទាយថា ព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រនឹងប្រសូតក្នុងភូមិបេថ្លេហិម ជាស្រុកកំណើតរបស់ស្តេច ដាវីឌ ពីបុរាណ។

ប៉ុន្តែ មានបញ្ហាមួយ។ នាង ម៉ារា និងលោក យ៉ូសែប បានរស់នៅក្នុងភូមិណាសារ៉ែត ដែលត្រូវធ្វើដំណើរអស់រយៈពេល៣ថ្ងៃពីខាងជើងទៅទីនោះ។ តើបទគម្ពីរនឹងសម្រេចយ៉ាងដូចម្តេច?

ព្រះជាម្ចាស់បានគ្រប់គ្រងអ្វីៗទាំងអស់។

វេលាដែលនាង ម៉ារា ត្រូវសម្រាលបុត្រក៏ជិតមកដល់ នោះព្រះចៅអធិរាជ សេសារ អូគូស្ទ បានចេញព្រះរាជក្រម១ច្បាប់ ឲ្យមនុស្សទាំងអស់ដែលនៅក្រោមអំណាចនៃចក្រភពរ៉ូម ទៅឯស្រុកកំណើតរៀងៗខ្លួន ដើម្បីចុះបញ្ជីបង់ពន្ធ។ ដូច្នេះ លោក យ៉ូសែប និងនាង ម៉ារា ដែលជិតគ្រប់ខែក៏បានចាកចេញពីភូមិណាសារ៉ែត ទៅកាន់ភូមិបេថ្លេហិម។

> ពេលអ្នកទាំងពីរកំពុងនៅទីនោះ វេលាដែលនាងត្រូវប្រសូតក៏មកដល់។
>
> នាងប្រសូតបានបុត្រាច្បងមក ហើយរុំបុត្រនោះនឹងសំពត់ រួចដាក់ឲ្យផ្ទំក្នុងស្នូកសត្វ ព្រោះក្នុងផ្ទះសំណាក់គ្មានកន្លែងសម្រាប់ពួកគេទេ។ (លូកា ២:៦-៧ គកស១៦)

ភូមិបេថ្លេហិមបានពេញដោយអ្នកធ្វើដំណើរដ៏នឿយហត់ ដែលមកចុះបញ្ជីបង់ពន្ធ។ នៅទីនោះឯង *ព្ទជស្ត្រី* ដែលត្រូវបានសន្យាក៏ប្រសូតមក។ កណ្ឌគម្ពីរដំណឹងល្អបានកត់ត្រាពីព្រឹត្តិការណ៍ទាំងនោះយ៉ាងលម្អិត៖

> នាងប្រសូតបានបុត្រាច្បង។ (លូកា ២:៧ គកស១៦)

ខាងមាតាទ្រង់ ទារកនេះគឺជាកូនប្រុសរបស់នាង ម៉ារា ដែលទើបនឹងកើត តែចំពោះខាងព្រះវរបិតាទ្រង់វិញ ទ្រង់គឺជាព្រះរាជបុត្រានៃព្រះដ៏នៅអស់កល្បជានិច្ច។ ព្រះបន្ទូលដែលបង្កើតរបស់សព្វសារពើ និងសម្លេងដ៏លាន់ឮចេញពីភ្នំស៊ីណាយនោះ ឥឡូវបានឮជាសម្លេងយំយ៉ាងស្រទន់របស់ទារកតូចវិញ។

ប៉ុន្តែ តើទ្រង់បានប្រសូតនៅកន្លែងណា?

មិនមែននៅក្នុងរាជវាំង មិនមែននៅក្នុងមន្ទីរពេទ្យ ហើយក៏មិនមែននៅក្នុងផ្ទះសំណាក់ដែរ។ ព្រះមហាក្សត្រដែលយាងមកពីស្ថានសួគ៌នេះ បានប្រសូតនៅកន្លែងដែលកូនចៀមកើត គឺក្នុងក្រោលសត្វ ដោយយកស្នូកធ្វើជាគ្រែ។

ទាំងនេះសុទ្ធតែជាផែនការរបស់ព្រះជាម្ចាស់។

> ដ្បិតអ្នករាល់គ្នាបានស្គាល់ព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ ថាទោះបើទ្រង់ជាសេដ្ឋីក៏ដោយ គង់តែទ្រង់បានត្រឡប់ជាក្រ ដោយព្រោះអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានមានឡើង ដោយសារសេចក្តីកម្សត់របស់ទ្រង់។ (២កូរិនថូស ៨:៩)

ប៉ុន្តែ តើព្រះជាម្ចាស់មិនបានរៀបចំពិធីណាមួយ ដើម្បីអបអរសាទរការយាងមកដល់នៃព្រះរាជបុត្រារបស់ទ្រង់ទេឬអី?

ទ្រង់ពិតជាបានរៀបចំ។





# ភាគទី៤១
# រឿងរ៉ាវរបស់ពួកអ្នកគង្វាល

តើព្រះជាម្ចាស់បានប្រាប់ដំណឹងអំពីការយាងមកផែនដីរបស់ព្រះមេស្ស៊ីដល់នរណាមុនគេ? ដល់ព្រះចៅអធិរាជ? ដល់អ្នកមាន និងអ្នកល្បីល្បាញ? ឬដល់ពួកអ្នកដឹកនាំសាសនា?

ទេ!

មនុស្សដំបូងដែលបានទទួលដំណឹងដ៏អស្ចារ្យនេះ គឺជាពួកអ្នកគង្វាលចៀមក្រីក្រ ដែលចិញ្ចឹមចៀមសម្រាប់ធ្វើជាយញ្ញបូជានៅលើអាសនាព្រះវិហារក្នុងក្រុងយេរូសាឡិម។

> រីឯនៅស្រុកនោះឯង មានពួកអ្នកគង្វាល ដែលចាំយាម រក្សាហ្វូងចៀមរបស់ខ្លួន នៅឯវាលក្នុងវេលាយប់។ នោះមើល មានទេវតានៃព្រះអម្ចាស់មកឈរជិតគេ ឯសិរីល្អរបស់ទ្រង់ក៏ភ្លឺឆ្វាត់ជុំវិញ ហើយគេមានសេចក្តីភ័យខ្លាចជាខ្លាំង។
>
> តែទេវតាប្រាប់ថា “កុំខ្លាចអី មើល ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្តីអំណរយ៉ាងអស្ចារ្យ ដែលសំរាប់បណ្តាជនទាំងអស់គ្នា។ ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ ១អង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទ[១៣]ដ៏ជាព្រះអម្ចាស់! ហើយនេះជាទីសំគាល់ដល់អ្នករាល់គ្នា គឺអ្នករាល់គ្នានឹងឃើញព្រះឱរស១រុំនឹងសំពត់ផ្តេកនៅក្នុងស្នូក“។
>
> នោះស្រាប់តែមានពួកពលបរិវារកកកុញពីស្ថានសួគ៌ មកនៅជាមួយនឹងទេវតានោះ ក៏ពោលសរសើរដល់ព្រះថា “សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្តីសុខសាន្តនៅផែនដីនៅកណ្តាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់!“។
>
> កាលពួកទេវតាបានឃ្លាតចេញ ហោះទៅស្ថានសួគ៌វិញហើយ នោះពួកអ្នកគង្វាលនិយាយគ្នាថា “ចូរយើងទៅឯបេថ្លេហិម មើលការដែលបានកើតមកនោះ ដែលព្រះអម្ចាស់បានប្រាប់ឲ្យយើងដឹង“។
>
> គេក៏ទៅជាប្រញាប់ ឃើញម៉ារា នឹងយ៉ូសែបនៅទីនោះ ព្រមទាំងព្រះឱរសផ្តេកនៅក្នុងស្នូកផង។
>
> កាលបានឃើញហើយ នោះគេក៏រាយរ៉ាប់រឿង ពីសេចក្តីដែលទេវតាបានប្រាប់ពីព្រះឱរស។ ហើយអស់អ្នកណាដែលឮ ក៏មានសេចក្តីអស្ចារ្យ ពីពាក្យដែលពួកអ្នកគង្វាលបានប្រាប់មក។ (លូកា ២:៨-១៨)

នេះពិតជាដំណឹងដ៏អស្ចារ្យ ដែលពួកគេត្រូវប្រាប់!

*ព្រះសង្គ្រោះបានប្រសូតហើយ! យើងបានឃើញទ្រង់ ហើយក៏បានពាល់ទ្រង់ដែរ! ទេវតាបានប្រាប់យើងថា ទ្រង់គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់! ពួកទេវតាលេចមកពេញផ្ទៃមេឃ! យប់ភ្លឺដូចថ្ងៃ! ព្រះមេស្ស៊ីបានយាងមកហើយ! ទ្រង់គង់នៅទីនេះ! គង់នៅទីនេះ!*

មនុស្សខ្លះបានជឿដំណឹងដែលពួកអ្នកគង្វាលប្រាប់ ប៉ុន្តែភាគច្រើនមិនបានជឿទេ។ ទោះបើជឿ ឬមិនជឿក៏ដោយ ព្រះមហាក្សត្រពិតជាបានចូលមកក្នុងមនុស្សជាតិ ហើយថ្ងៃប្រសូតរបស់ទ្រង់បានបែងចែកប្រវត្តិសាស្ត្រលោកីយ៍ជាពីរ។[១៤]

> លុះដល់គំរប់៨ថ្ងៃ កាលត្រូវកាត់ស្បែកព្រះឱរស នោះគេថ្វាយព្រះនាមថា «យេស៊ូវ» ជានាមដែលទេវតាបានប្រាប់ មុនដែលទ្រង់មកចាប់ទំផ្ទៃ។ (លូកា ២:២១)





# ភាគទី៤២
# រឿងរ៉ាវរបស់ពួកហោរាពីទិសខាងកើត

ក្រោយពីព្រះយេស៊ូវបានប្រសូតក្នុងក្រោលសត្វ នោះលោក យ៉ូសែប បានរៀបចំកន្លែងស្នាក់នៅសម្រាប់គ្រួសារគាត់។

ថ្ងៃមួយ ពួកហោរា (ជាអ្នកប្រាជ្ញខាងផ្កាយ) បានមកដល់ក្រុងយេរូសាឡិម ទាំងរំភើបចិត្ត។ នាំមុខដោយផ្កាយដ៏ពិសេសមួយ ពួកគេបានធ្វើដំណើរយ៉ាងឆ្ងាយពីប្រទេសពើស៊ី ដើម្បីស្វែងរកព្រះមហាក្សត្រទើបនឹងប្រសូតមក។

ហោរាទាំងនេះមានសំណួរមួយ និងគោលបំណងមួយៈ

> “តើព្រះអង្គដែលប្រសូតមក ធ្វើជាស្តេចសាសន៍យូដា ទ្រង់គង់នៅឯណា? ពីព្រោះយើងបានឃើញផ្កាយរបស់ទ្រង់ ពីទិសខាងកើតមក ហើយយើងមកថ្វាយបង្គំទ្រង់។”
>
> កាលស្តេចហេរ៉ូឌបានឮ នោះទ្រង់មានសេចក្តីវិតក្កព្រួយ ព្រមទាំងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នាផង។ កាលបានប្រជុំពួកសង្គ្រាជ នឹងពួកអាចារ្យនៃបណ្តាជនមកសាកសួរពីព្រះគ្រីស្ទ ដែលទ្រង់ត្រូវប្រសូតនៅឯណា នោះគេក៏ទូលទ្រង់ថា “នៅឯភូមិបេថ្លេហិមក្នុងស្រុកយូដា ព្រោះហោរាបានចែងសេចក្តីទុកមកដូច្នេះ...”។
>
> នោះស្តេចហេរ៉ូឌ ក៏ហៅពួកហោរានោះមក ដោយសំងាត់...។ រួចទ្រង់...បង្គាប់ថា “ចូរអ្នករាល់គ្នាទៅស៊ើបដំណឹង ពីកូនតូចនោះឲ្យច្បាស់លាស់ កាលណាបានឃើញហើយ នោះត្រូវមកប្រាប់ដល់យើងវិញ ដើម្បីឲ្យយើងបានទៅថ្វាយបង្គំដែរ”។
>
> កាលគេបានទទួលបង្គាប់នៃស្តេចស្រេចហើយ នោះក៏នាំគ្នាចេញទៅ ឯផ្កាយដែលគេបានឃើញពីទិសខាងកើត នោះក៏នាំមុខគេ ដរាបដល់ចំពីលើកន្លែងដែលបុត្រតូចនៅទើបឈប់។
>
> គេមានសេចក្តីអំណរជាខ្លាំងក្រៃ ដោយឃើញផ្កាយនោះ ហើយក៏ចូលទៅក្នុងផ្ទះ ឃើញបុត្រតូច នៅជាមួយនឹងម៉ារា ជាមាតា រួចក៏ក្រាបថ្វាយបង្គំ ព្រមទាំងបើកយកទ្រព្យដ៏វិសេសរបស់ខ្លួន ថ្វាយដង្វាយជាមាស ជាកំញាន ជាជ័រល្វីងទេស ដល់បុត្រនោះ រួចវិលទៅស្រុកគេវិញ តាមផ្លូវមួយទៀតទៅ ដោយព្រោះព្រះទ្រង់ពន្យល់សប្តិប្រាប់មិនឲ្យត្រឡប់ទៅឯហេរ៉ូឌវិញឡើយ។
>
> កាលគេចេញទៅបាត់ហើយ នោះទេវតានៃព្រះអម្ចាស់ក៏លេចមក ពន្យល់សប្តិប្រាប់យ៉ូសែបថា “ចូរក្រោកឡើងនាំបុត្រតូច នឹងមាតាទ្រង់ រត់ទៅឯស្រុកអេស៊ីព្ទទៅ ឲ្យនៅស្រុកនោះទាល់តែយើងប្រាប់ ដ្បិតហេរ៉ូឌនឹងរកសំឡាប់បុត្រតូច”។
>
> (ម៉ាថាយ ២:២-១៣)

ស្តេច ហេរ៉ូឌ បានព្យាយាមរកសម្លាប់បុត្រតូចនោះ។ ពួកមនុស្សនៅក្រុងយេរូសាឡិមមិនបានខ្វល់ខ្វាយពីទ្រង់ទេ។ ប៉ុន្តែ ពួកហោរាដែលបានធ្វើដំណើរឆ្លងកាត់វាលខ្សាច់ដើម្បីស្វែងរកទ្រង់ បានមកថ្វាយបង្គំទ្រង់ ហើយក៏បានថ្វាយតង្វាយដ៏ស័ក្តិសមជាស្តេចផងដែរ គឺមានមាស កំញាន និងគ្រឿងដ៏មានតម្លៃសម្រាប់អប់សាកសព។ ហេតុអ្វីបានជាពួកគេថ្វាយគ្រឿងអប់សាកសពដូច្នេះ?

តើពួកហោរាទាំងនេះបានដឹងទេថា ព្រះយេស៊ូវបានប្រសូតមកដើម្បីសុគតឬ?





## ភាគទី៤៣

# បុត្រដ៏ល្អឥតខ្ចោះ

ក្រោយពីទេវតាបានព្រមានដល់លោក យ៉ូសែប ឲ្យនាំនាង ម៉ារា និងព្រះយេស៊ូវជាបុត្រតូច ទៅស្រុកអេស៊ីព្ទ នោះពួកគេក៏បានភៀសខ្លួន ហើយរស់នៅទីនោះ រហូតដល់ស្តេច ហេរ៉ូឌ ដ៏ឃោរឃៅបានសុគត។

> លុះហេរ៉ូឌបានសុគតរួចហើយ នោះទេវតានៃព្រះអម្ចាស់លេចមក ពន្យល់សប្តិប្រាប់យ៉ូសែប នៅស្រុកអេស៊ីព្ទថា "ចូរក្រោកឡើងនាំបុត្រតូច នឹងមាតាទ្រង់ ទៅនៅឯស្រុកអ៊ីស្រាអែលវិញទៅ ដ្បិតអស់ពួកអ្នកដែលរកសំឡាប់បុត្រតូច បានស្លាប់អស់ហើយ"។ (ម៉ាថាយ ២:១៩-២០)

ការនេះបានសម្រេចទំនាយពីបុរាណមួយទៀត ដែលព្រះយេហូវ៉ាមានបន្ទូលថា៖

> អញ...ក៏បានហៅកូនអញចេញពីស្រុកអេស៊ីព្ទមក។ (ហូសេ ១១:១)

ដូច្នេះ លោក យ៉ូសែប និងនាង ម៉ារា ក៏នាំព្រះយេស៊ូវទៅភូមិណាសារ៉ែត ជាកន្លែងដែលទ្រង់ធំដឹងក្តីជាមួយនឹងបងប្អូន[១៩]របស់ទ្រង់។

ព្រះយេស៊ូវជាកុមារមានចំណុចជាច្រើន ដែលដូចទៅនឹងក្មេងៗដទៃទៀត គឺទ្រង់បានសោយ ផ្ទំ លេង សិក្សា ហើយរៀនពីមុខរបរ។ ប៉ុន្តែ ព្រះយេស៊ូវក៏មានចំណុចខ្លះ ដែលខុសពីក្មេងៗដទៃទៀតដែរ គឺទ្រង់មិនដែលអាត្មានិយម តែងតែគោរពឪពុកម្តាយ ហើយមិនដែលកុហកឡើយ។ ទ្រង់តែងតែធ្វើអ្វីៗ ដែលផ្គាប់ដល់ព្រះហឫទ័យរបស់ព្រះវរបិតានៅឯស្ថានសួគ៌ជានិច្ច។

> ទ្រង់បរិសុទ្ធ ឥតពុតមាយា ឥតសៅហ្មង ដែលបានញែកចេញពីមនុស្សបាប។ (ហេព្រើរ ៧:២៦)

ព្រះយេស៊ូវ គឺជាកុមារដ៏ល្អឥតខ្ចោះតែមួយគត់ក្នុងប្រវត្តិសាស្ត្រ។ *ល្អឥតខ្ចោះ* មិនមានន័យថា ទ្រង់មិនដែលមានស្នាមរបួស ឬកើតមុននោះទេ។ ប៉ុន្តែ នេះមានន័យថា ទ្រង់មានលក្ខណៈដ៏ល្អឥតខ្ចោះ។ ទ្រង់ គឺបរិសុទ្ធ ហើយល្អយ៉ាងពេញខ្នាត។ ទ្រង់ក៏មានព្រះបេស្កា និងប្រាជ្ញាយ៉ាងពេញលេញផងដែរ ប៉ុន្តែមុនពេលទ្រង់ចាប់ទំក្នុងផ្ទៃរបស់នាង ម៉ារា នោះទ្រង់បានដាក់ភាពកំសោយលើអង្គទ្រង់ផ្ទាល់ ដើម្បីរស់នៅជាមនុស្សក្នុងចំណោមពួកមនុស្ស។

> ព្រះយេស៊ូវក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ នឹងចិត្តមនុស្សផង។ (លូកា ២:៥២)

ពេលព្រះយេស៊ូវមានព្រះជន្ម១២ឆ្នាំ ទ្រង់បានធ្វើដំណើរជាមួយឪពុកម្តាយ ពីភូមិណាសារ៉ែត ទៅក្រុងយេរូសាឡិម ដើម្បីចូលរួមបុណ្យថ្វាយយញ្ញបូជា ដែលហៅថា បុណ្យរំលង[១៦]ដូចរាល់តែឆ្នាំ។ ខណៈដែលមិត្តភក្តិរបស់ទ្រង់ដើរលេងជុំវិញទីក្រុងដ៏ធំនោះ ព្រះយេស៊ូវបានចំណាយពេលពេញមួយសប្តាហ៍នៅទីធ្លាព្រះវិហារ ដោយអង្គុយក្នុងចំណោមពួកគ្រូបង្រៀន ទាំងស្តាប់ ហើយសួរសំណួរដល់ពួកគេ។

> ពួកអស់អ្នកដែលឮទ្រង់ក៏អស្ចារ្យក្នុងចិត្តពីប្រាជ្ញា ហើយនឹងពាក្យចំឡើយរបស់ទ្រង់។ (លូកា ២:៤៧)

ព្រះវិហារ គឺជាកន្លែងដែលកូនចៀមត្រូវបានដុតនៅលើអាសនា សម្រាប់អំពើបាបរបស់មនុស្ស។ ព្រះយេស៊ូវជាកុមារបានជ្រាបអំពីអ្វីដែលពួកគ្រូបង្រៀនទាំងនោះមិនបានដឹង។

ទ្រង់បានយាងមកដើម្បីថ្វាយកូនចៀមចុងក្រោយ។





## ភាគទី៥៤
# កូនចៀមនៃព្រះ

៣០ឆ្នាំបានកន្លងផុតទៅ តាំងពីព្រះយេស៊ូវបានប្រសូតនៅឯភូមិបេថ្លេហិម។ ព្រះចៅអធិរាជ សេសារ អូគូស្ទ ក៏សុគតទៅ នោះបុត្រាចុងរបស់ទ្រង់ សេសារ ទីបេរី បានឡើងសោយរាជ្យនៅចក្រភពរ៉ូម។ ស្ដេច ហេរ៉ូឌ អាន់ទីផាស បានត្រួតត្រានៅស្រុកកាលីឡេ។ រីឯលោក ប៉ុនទាស ពីឡាត់ បានគ្រប់គ្រងនៅស្រុកយូដា។ នោះក៏មានហោរាថ្មីម្នាក់កំពុងប្រកាសព្រះបន្ទូលនៅតំបន់ប៉ាឡេស្ទីន។

> នៅគ្រានោះ យ៉ូហាន-បាទីស្ទ គាត់មកនៅក្នុងទីរហោស្ថានស្រុកយូដា កំពុងតែប្រកាសថា “ចូរឲ្យប្រែចិត្តចុះ ដ្បិតនគរស្ថានសួគ៌ជិតដល់ហើយ”។
>
> ...អ្នកនេះហើយ ដែលហោរាអេសាយបានទាយថា “មានសំឡេងនៃមនុស្សម្នាក់ កំពុងតែស្រែកនៅទីរហោស្ថានថា «ចូររៀបចំផ្លូវទទួលព្រះអម្ចាស់ ចូរដំរង់ផ្លូវតូចថ្វាយទ្រង់ចុះ»”។
>
> ឯយ៉ូហាននេះ គាត់ពាក់អាវរោមអូដ្ឋ ហើយមានខ្សែក្រវាត់ស្បែកនៅចង្កេះ ក៏មានកណ្ដូប នឹងទឹកឃ្មុំព្រៃជាអាហារ។ (ម៉ាថាយ ៣:១-៤)

នៅសម័យនោះ មនុស្សជាច្រើនបានស្លៀកពាក់សំពត់ទេស និងបរិភោគអាហារល្អៗ ប៉ុន្តែលោក យ៉ូហាន បានរស់នៅយ៉ាងសាមញ្ញ។ គាត់ជាអ្នកដែលបានទទួលបេសកកម្មដ៏ពិសេស។

លោក យ៉ូហាន ជាអ្នករៀបចំផ្លូវថ្វាយព្រះមហាក្សត្រ។

រាប់រយឆ្នាំមុន ហោរាពីរនាក់ គឺលោក អេសាយ និងលោក ម៉ាឡាគី បានកត់ត្រាពីហោរាម្នាក់ ដែលត្រូវប្រកាសពីការយាងមកនៃព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ។ ហោរានោះ គឺជាលោក យ៉ូហាន នេះឯង។

ពួកហោរាសម័យមុនៗបានទាយថា៖ *ដល់ពេលកំណត់ នោះព្រះសង្គ្រោះដែលត្រូវបានសន្យា នឹងយាងមកលើផែនដី។* រីឯហោរា យ៉ូហាន បានប្រកាសថា៖ *ពេលវេលានោះបានមកដល់ហើយ។ ព្រះសង្គ្រោះគង់នៅទីនេះ!*

ហ្វូងមនុស្សបាននាំគ្នាមកឯទីរហោស្ថាន ដើម្បីស្ដាប់លោក យ៉ូហាន។ អស់អ្នកដែលទទួលសារភាពថា ខ្លួនជាមនុស្សមានបាបដែលត្រូវការព្រះសង្គ្រោះនោះ បានមកទទួលបុណ្យជ្រមុជទឹកនៅទន្លេយ័រដាន់។ ដោយការធ្វើបែបនេះ ពួកគេបានបង្ហាញពីសេចក្ដីជំនឿលើព្រះមេស្ស៊ី ដែលនឹងលាងបាបដ៏ធំរបស់ពួកគេ ហើយបំពាក់ពួកគេដោយសេចក្ដីសុចរិតរបស់ទ្រង់។

ពីមួយថ្ងៃទៅមួយថ្ងៃ លោក យ៉ូហាន បានប្រាប់ពួកមនុស្សអំពីព្រះសង្គ្រោះយាងមកពីស្ថានសួគ៌ ដែលគេបានរង់ចាំជាយូរមកហើយនោះថា “ខ្ញុំមិនគួរនឹងកាន់សុព័ណ៌បាទទ្រង់ទេ ព្រះអង្គនោះនឹងធ្វើបុណ្យជ្រមុជឲ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ”(ម៉ាថាយ ៣:១១)។

លុះដល់ថ្ងៃមួយ នោះព្រះសង្គ្រោះបានយាងមក ទាំងយាងកាត់ភ្នំ និងហ្វូងមនុស្ស ហើយចុះទៅដល់ត្រង់កន្លែងដែលលោក យ៉ូហាន កំពុងធ្វើបុណ្យជ្រមុជទឹក។

លោក យ៉ូហាន បានចង្អុលទៅព្រះយេស៊ូវ ហើយនិយាយថា៖

> “នុ៎ះន៍ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក!” (យ៉ូហាន ១:២៩)

ហេតុអ្វីបានជាលោក យ៉ូហាន ហៅព្រះយេស៊ូវថា កូនចៀមនៃព្រះ?

បើអ្នកដឹងពីមូលហេតុនោះ អ្នកប្រាកដជាបានដឹងអំពីបេសកកម្មរបស់ព្រះមហាក្សត្រហើយ។





# ភាគទី៤៥
# ព្រះរាជបុត្រាដ៏ល្អឥតខ្ចោះ

ព្រះយេស៊ូវបានបង្គាប់លោក យ៉ូហាន ឲ្យធ្វើបុណ្យជ្រមុជទឹកថ្វាយទ្រង់។ លោក យ៉ូហាន បានប្រកែក ពីព្រោះព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រដែលយាងមកពីស្ថានសួគ៌ មិនត្រូវការប្រែចិត្តឡើយ។

> ព្រះយេស៊ូវមានបន្ទូលថា "ចូរធ្វើម្តងនេះចុះ ដ្បិតគួរឲ្យយើងធ្វើសំរេចតាមគ្រប់ទាំងសេចក្តីសុចរិតយ៉ាងដូច្នេះ"។ (ម៉ាថាយ ៣:១៥)

ដូច្នេះ លោក យ៉ូហាន ក៏ធ្វើបុណ្យជ្រមុជទឹកថ្វាយព្រះយេស៊ូវ។ ដោយការទទួលបុណ្យជ្រមុជទឹក នោះព្រះយេស៊ូវបានបង្ហាញថា ទ្រង់ស្ថិតនៅក្នុងចំណោមមនុស្សជាតិដែលទ្រង់បានយាងមកដើម្បីសង្គ្រោះ។

> កាលព្រះយេស៊ូវបានទទួលបុណ្យជ្រមុជហើយ នោះទ្រង់យាងឡើងពីទឹកភ្លាម ស្រាប់តែមេឃក៏របើកឡើង ឲ្យទ្រង់ឃើញព្រះវិញ្ញាណនៃព្រះ យាងចុះមកដូចជាសត្វព្រាប ក៏សណ្ឋិតលើទ្រង់។ នោះមានឮសំឡេងចេញពីមេឃថា "នេះជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់"។ (ម៉ាថាយ ៣:១៦-១៧)

ដូចនៅថ្ងៃដំបូងនៃការបង្កើត លក្ខណៈដ៏ពិសេសរបស់ព្រះជាម្ចាស់ ត្រូវបានបង្ហាញឲ្យឃើញសាជាថ្មីម្តងទៀត។ ដូចដែលព្រះជាម្ចាស់ ព្រះវិញ្ញាណ និងព្រះបន្ទូលបានរួមគ្នាតែមួយ ដើម្បីបង្កើតលោកីយ៍ ឥឡូវនេះទាំងបីអង្គក៏រួមគ្នាតែមួយ ដើម្បីនឹងសង្គ្រោះលោកីយ៍ផងដែរ។[១៧]

យើងឃើញ *ព្រះវិញ្ញាណនៃព្រះ* (ដែលពីដំបូងឡើយរេរានៅពីលើទឹក) មកសណ្ឋិតលើព្រះយេស៊ូវ។ យើងឃើញ *ព្រះរាជបុត្រានៃព្រះ* (ជាព្រះបន្ទូលដែលបានបង្កើតលោកីយ៍) យាងឡើងពីទឹកមក។ យើងក៏ឮ *ព្រះវរបិតា* មានបន្ទូលចេញពីមេឃ។

អស់ពេលជាង៣០ឆ្នាំ ព្រះយេស៊ូវបានរស់នៅធម្មតា ដោយគ្មានអ្នកណាចាប់អារម្មណ៍ពីទ្រង់ ប៉ុន្តែព្រះវរបិតានៅឯស្ថានសួគ៌បានទតឃើញគ្រប់ទាំងគំនិត ពាក្យសំដី និងទង្វើរបស់ទ្រង់។ តើព្រះជាម្ចាស់បានយល់ឃើញយ៉ាងដូចម្តេច ចំពោះជីវិតនៃព្រះរាជបុត្រារបស់ទ្រង់?

> "ជាទីពេញចិត្តអញណាស់!"

នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ មានតែព្រះយេស៊ូវប៉ុណ្ណោះ ដែលបានធ្វើអ្វីៗទាំងអស់តាមការតម្រូវរបស់ព្រះជាម្ចាស់ គឺក្នុងគ្រប់ការទាំងអស់ គ្រប់ពេលវេលា ហើយយ៉ាងល្អឥតខ្ចោះ។

ព្រះយេស៊ូវបានធ្វើអ្វីដែលលោក អ័ដាម បានបរាជ័យនឹងធ្វើ គឺជាការឆ្លុះបញ្ចាំងពីរូបអង្គនៃព្រះជាម្ចាស់។ ប៉ុន្តែ ព្រះយេស៊ូវបានធ្វើអ្វីដែលលើសពីការឆ្លុះបញ្ចាំងនេះទៅទៀត គឺទ្រង់ផ្ទាល់ជារូបអង្គនៃព្រះជាម្ចាស់។

> ឯព្រះ ដែលពីដើម ទ្រង់មានបន្ទូលនឹងពួកឰយុកោ ដោយពួកហោរា ជាច្រើនដងច្រើនបែប។ នៅជាន់ក្រោយបង្អស់នេះ ទ្រង់បានមានបន្ទូលនឹងយើងរាល់គ្នា ដោយសារព្រះរាជបុត្រាវិញ ដែលទ្រង់បានដំរូវឲ្យបានគ្រងរបស់ទាំងអស់ ទុកជាមរដក ព្រមទាំងបង្កើតលោកីយ ដោយសារព្រះរាជបុត្រានោះដែរ គឺទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ ហើយជារូបភាពនៃអង្គទ្រង់ ទាំងទ្រទ្រង់គ្រប់របស់ទាំងអស់ ដោយសារព្រះបន្ទូលដ៏មានព្រះចេស្តានៃទ្រង់...។ (ហេព្រើរ ១:១-៣)

ដូច្នេះ គ្មានអ្វីចម្លែកនោះទេ ដែលព្រះយេស៊ូវមានបន្ទូលនាពេលក្រោយថា៖

> "ខ្ញុំ ហើយនឹងព្រះវរបិតា គឺតែ១ព្រះអង្គទេ។" (យ៉ូហាន ១០:៣០)

ព្រះយេស៊ូវ គឺជាព្រះរាជបុត្រាដ៏ល្អឥតខ្ចោះ។





# ភាគទី៤៦
# មនុស្សទីពីរ

សាតាំងមិនសប្បាយចិត្តសោះ ដែលមនុស្សដ៏គ្រប់លក្ខណ៍នេះ កំពុងរស់នៅក្នុងនគរ*របស់វា*! ដូច្នេះ វាក៏មានល្បិចមួយ។ ដូចដែលវាបានល្បួងមនុស្សដំបូងបង្អស់ឲ្យធ្វើបាបជាយ៉ាងណា នោះវាក៏នឹងព្យាយាមធ្វើឲ្យព្រះអង្គនេះធ្វើបាបយ៉ាងនោះដែរ។

សាតាំងចង់ឲ្យព្រះយេស៊ូវស្ថិតនៅក្រោមអំណាចរបស់វា ដូចដែលវាបានធ្វើឲ្យលោក អ័ដាម ស្ថិតនៅក្រោមអំណាចរបស់វាដែរ។ បើវាអាចល្បួងព្រះរាជបុត្រានៃព្រះឲ្យធ្លាក់ក្នុងអំពើបាប នោះទ្រង់នឹងគ្មានលក្ខណៈគ្រប់គ្រាន់ ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់ពីអំពើបាបបានឡើយ។

> គ្រានោះ ព្រះវិញ្ញាណក៏នាំព្រះយេស៊ូវ ទៅឯទីរហោស្ថាន ដើម្បីឲ្យត្រូវអារក្សល្បួង។ កាលទ្រង់បានតម៤០ថ្ងៃ៤០យប់ហើយ ក្រោយមកទ្រង់ឃ្លាន រួចមេល្បួងក៏មកទូលទ្រង់ថា “បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរបង្គាប់ឲ្យថ្មទាំងនេះត្រឡប់ជានំបុ័ងទៅ”។ (ម៉ាថាយ ៤:១-៣)

ព្រះយេស៊ូវឃ្លានជាខ្លាំង ប៉ុន្តែទ្រង់មិនបានស្តាប់តាមអារក្សទេ។ ទ្រង់នឹងមិនធ្វើអ្វីដែលព្រះវរបិតាមិនសព្វព្រះហឫទ័យនោះឡើយ។ ទ្រង់ក៏នឹងមិនប្រើអំណាចដ៏គ្មានដែនកំណត់របស់ទ្រង់ ដើម្បីបំពេញចំណង់ខាងសាច់ឈាមរបស់ទ្រង់ដែរ។ ដើម្បីតយុទ្ធនឹងអារក្ស ព្រះយេស៊ូវបានលើកឡើងពីគម្ពីរក្រឹត្យវិន័យរបស់លោក ម៉ូសេ ដោយមានបន្ទូលថា៖

> “មានសេចក្តីចែងទុកមកដូច្នេះ «មនុស្សមិនមែនរស់ ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ»។”
> (ម៉ាថាយ ៤:៤; ចោទិយកថា ៨:៣)

ដោយអំនួតដ៏ឆោតល្ងង់ នោះអារក្សក៏ព្យាយាមល្បួងព្រះយេស៊ូវដ៏បរិសុទ្ធម្តងទៀត។

> អារក្សបាននាំទ្រង់ទៅលើកំពូលភ្នំយ៉ាងខ្ពស់ ក៏បង្ហាញអស់ទាំងនគរក្នុងលោកីយ នឹងសិរីលំអរបស់នគរទាំងនោះថ្វាយទ្រង់ទត រួចទូលថា “បើសិនជាអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះខ្ញុំនឹងឲ្យរបស់ទាំងនេះដល់អ្នក”។ (ម៉ាថាយ ៤:៨-៩)

នៅពេលដែលលោក អ័ដាម បានធ្វើបាប នោះមនុស្សជាតិបានបាត់បង់សិទ្ធិគ្រប់គ្រងផែនដី។ សាតាំងបានលួចយកអំណាចត្រួតត្រាពិភពលោក ដោយតាំងខ្លួនជាស្តេច។ ឥឡូវនេះ មហាក្សត្រដ៏មានសិរីល្អបានគង់នៅលើផែនដី ដើម្បីដណ្តើមយកអំណាចនេះមកវិញ ប៉ុន្តែទ្រង់នឹងមិនសម្រេចការនេះ ដោយចុះចូលនឹងសាតាំងដែលទ្រង់បានយាងមកបំផ្លាញនោះទេ។

> នោះព្រះយេស៊ូវមានបន្ទូលតបថា “នែ សាតាំង ចូរឯងថយចេញពីអញទៅ ដ្បិតមានសេចក្តីចែងទុកមកថា «ឯងត្រូវថ្វាយបង្គំដល់ព្រះអម្ចាស់ ជាព្រះនៃឯង ហើយត្រូវគោរពដល់ទ្រង់តែមួយព្រះអង្គប៉ុណ្ណោះ»”។ (ម៉ាថាយ ៤:១០)

ទីបំផុត អារក្សក៏ចេញពីព្រះយេស៊ូវទៅ។ សាតាំងមិនដែលល្បួងនរណាម្នាក់ដូចទ្រង់សោះឡើយ ដែលគ្មានចិត្តចង់ធ្វើបាប ហើយក៏មិនអាចធ្វើបាបបានដែរ។ ព្រះយេស៊ូវ គឺខុសពីលោក អ័ដាម និងពូជរបស់គាត់។

> មនុស្សទីមួយកើតចេញពីដីមក គឺធ្វើពីធូលីដី រីឯមនុស្សទីពីរវិញ មកពីស្ថានសួគ៌។
> (១កូរិនថូស ១៥:៤៧ គកស១៦)

លោក អ័ដាម គឺជាមនុស្សគ្រប់លក្ខណ៍ទីមួយ។ ព្រះយេស៊ូវ គឺជាមនុស្សគ្រប់លក្ខណ៍ទីពីរ។

ពេលសាតាំងល្បួងលោក អ័ដាម ឲ្យធ្វើបាប នោះលោក អ័ដាម បានចាញ់ តែសាតាំងបានឈ្នះ។
ពេលសាតាំងព្យាយាមល្បួងព្រះយេស៊ូវឲ្យធ្វើបាប នោះសាតាំងបានចាញ់ តែព្រះយេស៊ូវបានឈ្នះ។

មនុស្សទីមួយបាននាំយើងចូលទៅក្នុងនគរនៃអំពើបាប និងសេចក្តីស្លាប់របស់សាតាំង។
មនុស្សទីពីរបានមក ដើម្បីនាំយើងចេញមកវិញ។





# ភាគទី៤៧
# ព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ

ក្រោយពីសាតាំងបានបរាជ័យក្នុងការល្បួងព្រះយេស៊ូវឲ្យធ្វើបាប នោះទ្រង់ក៏យាងត្រឡប់ទៅភូមិណាសារ៉ែតវិញ ជាកន្លែងដែលទ្រង់បានធំដឹងក្តីឡើង ហើយក៏បានធ្វើការជាជាងឈើ។

ទ្រង់...ក៏ចូលទៅក្នុងសាលាប្រជុំ នៅថ្ងៃឈប់សំរាក តាមទំលាប់ទ្រង់។ (លូកា ៤:១៦)

សាលាប្រជុំ គឺជាកន្លែងថ្វាយបង្គំ ដែលមានគេអានព្រះគម្ពីរ ហើយពន្យល់ឲ្យស្តាប់ ជារៀងរាល់ថ្ងៃសៅរ៍។ នៅថ្ងៃសៅរ៍មួយនោះ ព្រះយេស៊ូវក៏មានសេចក្តីប្រកាសមួយ។

ទ្រង់...ឈរឡើង ដើម្បីអានមើលគម្ពីរ។

គេក៏យកគម្ពីរហោរាអេសាយមកថ្វាយទ្រង់ កាលទ្រង់បានបើកគម្ពីរហើយ នោះទ្រង់រកឃើញត្រង់កន្លែងដែលមានសេចក្តីចែងទុកមកថា៖

«ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំ ឲ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំឲ្យមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង ហើយប្រកាសប្រាប់ពីសេចក្តីប្រោសលោះដល់ពួកឈ្លើយ នឹងសេចក្តីភ្លឺឡើងវិញដល់មនុស្សខ្វាក់...»។ (លូកា ៤:១៦-១៨)

បទគម្ពីរដែលព្រះយេស៊ូវបានអាននោះ គឺជាទំនាយពីបុរាណអំពីព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ ដែលនឹងសម្តែងឲ្យលោកីយ៍ឃើញពីលក្ខណៈរបស់ព្រះជាម្ចាស់ ហើយជួយសង្គ្រោះមនុស្សមានបាបឲ្យរួចពីអំណាចរបស់សាតាំង អំពើបាប សេចក្តីស្លាប់ និងស្ថាននរក។

កាលទ្រង់បានបិទគម្ពីរ ប្រគល់ដល់អ្នករក្សាសាលាវិញហើយ  នោះទ្រង់ក៏គង់ចុះ។

ឯពួកអ្នកដែលនៅក្នុងសាលា គេក៏សំឡឹងមើលទ្រង់។ ទ្រង់ចាប់តាំងមានបន្ទូលទៅគេថា “នៅថ្ងៃនេះ បទគម្ពីរនេះបានសំរេចនៅត្រចៀកអ្នករាល់គ្នាហើយ!”។ (លូកា ៤:២០-២១)

តើមនុស្សនៅជុំវិញព្រះយេស៊ូវមានប្រតិកម្មយ៉ាងដូចម្តេច ចំពោះការប្រកាសថាទ្រង់ជាព្រះមេស្ស៊ីដែលយាងមកពីស្ថានសួគ៌ ដើម្បីសម្រេចអ្វីដែលពួកហោរាបានសរសេរនៅក្នុងព្រះគម្ពីរ?

កាលពួកអ្នកនៅក្នុងសាលាប្រជុំ បានឮសេចក្តីទាំងនោះហើយ គេមានពេញដោយសេចក្តីក្រោធ ក៏ក្រោកឡើងដេញទ្រង់ចេញពីភូមិ បណ្តើរទៅដល់ចំរែះនៅលើភ្នំដែលគេបានកធ្វើភូមិ ដើម្បីនឹងច្រានទំលាក់ចុះទៅក្រោម។

ប៉ុន្តែទ្រង់យាងកាត់កណ្តាលពួកគេចេញបាត់ទៅ។ (លូកា ៤:២៨-៣០)

ព្រះយេស៊ូវមានអំណាចគ្រប់គ្រង។ ខុសពីពូជរបស់លោក អ័ដាម ដែលឆ្លងអំពើបាប ហើយត្រូវស្លាប់ ព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ ដែលព្រះជាម្ចាស់បានចាក់ប្រេងតាំងនេះ[១៨] គឺអាចគ្រប់គ្រងអ្វីៗទាំងអស់យ៉ាងពេញលេញ។ គ្មានអ្នកណាអាចប៉ះពាល់ទ្រង់បានឡើយ លុះត្រាតែទ្រង់អនុញ្ញាតឲ្យ។

ប៉ុន្តែ ទ្រង់នឹងប៉ះពាល់ពួកគេវិញ។





## ភាគទី៤៨
# អំណាចលើពួកអារក្ស និងជំងឺ

នៅក្នុងបទគម្ពីររបស់ពួកហោរា ព្រះមេស្ស៊ីមានព្រះនាមមួយ ដែលហៅថា *ព្រះពាហុនៃព្រះយេហូវ៉ា* (អេសាយ ៥៣:១)។ គ្រប់ទាំងការអស្ចារ្យដែលទ្រង់បានធ្វើបង្ហាញថា ទ្រង់ពិតជាព្រះពាហុនៃព្រះជាម្ចាស់នៅលើផែនដីមែន។ តាមរយៈការប៉ះពាល់ដោយព្រះហស្តទ្រង់ ឬព្រះបន្ទូលដែលចេញពីព្រះឱស្ឋទ្រង់មក នោះមនុស្សដែលមានជំងឺ និងមនុស្សដែលជិតស្លាប់ក៏បានជាសះស្បើយភ្លាមៗ។

> នោះមានហ្វូងមនុស្សមកឯទ្រង់កកកុញ នាំទាំងមនុស្សខ្វិន ខ្វាក់ គ ពិការ នឹងមនុស្សឯទៀតជាច្រើន មកដាក់នៅទៀបព្រះបាទទ្រង់ ហើយទ្រង់ក៏ប្រោសឲ្យគេបានជា។ (ម៉ាថាយ ១៥:៣០)

ទំនាយរបស់ពួកហោរាកំពុងតែសម្រេចពិតមែន។

> មនុស្សខ្វាក់បានភ្លឺ មនុស្សខ្វិនបានដើររួច មនុស្សឃ្លង់បានជាស្អាត មនុស្សថ្លង់បានឮ មនុស្សស្លាប់បានរស់ឡើងវិញ ហើយមនុស្សទាល់ក្របានឮដំណឹងល្អផង។ (ម៉ាថាយ ១១:៥ [អេសាយ ៣៥:៤-៦, ៦១:១])

គ្មានជំងឺណាមួយ ដែលព្រះយេស៊ូវមិនអាចប្រោសឲ្យជាបានឡើយ។

> គ្រានោះ មានមនុស្សឃ្លង់ម្នាក់ មកឯព្រះយេស៊ូវ លុតជង្គង់ទូលអង្វរថា "បើទ្រង់សព្វព្រះហឫទ័យ ទ្រង់អាចនឹងប្រោសឲ្យទូលបង្គំជាស្អាតបាន"។
>
> ដូច្នេះ ទ្រង់មានព្រះហឫទ័យក្តួលអាណិត ក៏លូកព្រះហស្តទៅពាល់គាត់ដោយបន្ទូលថា "ខ្ញុំចង់ដែរ ឲ្យជាស្អាតទៅ"។
>
> លុះទ្រង់មានបន្ទូលហើយ ស្រាប់តែរោគឃ្លង់ចេញពីគាត់បាត់ទៅ ហើយគាត់បានជាស្អាត។ (ម៉ាកុស ១:៤០-៤២)
>
> ដល់ពេលថ្ងៃលិច អស់អ្នកដែលមានបងប្អូនឈឺជំងឺផ្សេងៗ គេនាំអ្នកទាំងនោះមកឯទ្រង់ ហើយទ្រង់ប្រោសគេគ្រប់គ្នាឲ្យបានជា ដោយដាក់ព្រះហស្តលើ ក៏មានអារក្សចេញពីមនុស្សជាច្រើនដែរ វាស្រែកឡើងថា "ទ្រង់ជាព្រះរាជបុត្រានៃព្រះ!"។
>
> តែទ្រង់បន្ទោស ហាមមិនឲ្យវានិយាយសោះ ពីព្រោះវាដឹងថា ទ្រង់ជាព្រះគ្រីស្ទពិត។ (លូកា ៤:៤០-៤១)

ព្រះយេស៊ូវមិនចង់ឲ្យពួកអារក្សធ្វើបន្ទាល់អំពីទ្រង់ទេ។ ពួកទេវតាអាក្រក់ទាំងនេះបានឃើញពីអំណាច និងព្រះចេស្តារបស់ទ្រង់ នៅពេលដែលទ្រង់មានបន្ទូលបង្កើតផ្ទៃមេឃ និងផែនដី។ ពួកវាបានភ័យញ័រដោយនឹកដល់ថ្ងៃ ដែលទ្រង់បានបោះទម្លាក់ពួកវាឲ្យចុះពីស្ថានសួគ៌មក។ ប៉ុន្តែ ឥឡូវនេះ ទ្រង់កំពុងគង់នៅលើផែនដីជាមនុស្ស! អំណាចរបស់មេពួកវាកំពុងតែដួលរលំ។ មហាក្សត្រដ៏មានសិរីល្អនេះ បានចូលមកវាយប្រហារតំបន់ត្រួតត្រារបស់ពួកវាហើយ។

ព្រះយេស៊ូវយាងទៅទីណា អំណាចរបស់សាតាំងត្រូវបានចុះខ្សោយនៅទីនោះ។ ព្រះយេស៊ូវយាងទៅទីណា បណ្តាសារបស់អំពើបាបត្រូវបានថយចេញពីទីនោះ។

ទន្ទឹមនឹងការអស្ចារ្យទាំងនេះ ព្រះយេស៊ូវក៏មានបន្ទូលប្រកាសថា៖

> "ពេលវេលាបានសំរេចហើយ នគរព្រះជិតមកដល់
> ដូច្នេះ ចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ!" (ម៉ាកុស ១:១៥)





# ភាគទី៤៩
# អំណាចលើខ្យល់ និងសមុទ្រ

ព្រះយេស៊ូវបានជ្រើសរើសបុរស១២នាក់ ដើម្បីដើរជាមួយទ្រង់ ហើយរៀនពីទ្រង់។ នៅក្នុងចំណោមពួកអ្នកដើរតាមទ្រង់ ក៏មានស្ត្រីជាច្រើនផងដែរ។ ពួកគេបានជួយព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ ដោយផ្គត់ផ្គង់ជាអាហារ និងប្រាក់។

ចំពោះអស់អ្នកណាដែលបានជឿលើព្រះយេស៊ូវ នោះទ្រង់បានត្រាស់ហៅយ៉ាងសាមញ្ញថា៖

> "ចូរមកតាមខ្ញុំ។" (លូកា ៥:២៧)

ប៉ុន្តែ ការត្រាស់ហៅរបស់ទ្រង់ក៏បានទាមទារតម្លៃដ៏ខ្ពស់ផងដែរ៖

> "អ្នកណាដែលស្រឡាញ់ឪពុក ឬម្តាយ ជាជាងខ្ញុំ នោះមិនគួរនឹងខ្ញុំទេ ហើយអ្នកណាដែលស្រឡាញ់កូនប្រុស ឬកូនស្រី ជាជាងខ្ញុំ នោះក៏មិនគួរនឹងខ្ញុំដែរ។" (ម៉ាថាយ ១០:៣៧)

ដោយសារសិស្សរបស់ព្រះយេស៊ូវមួយចំនួនជាអ្នកនេសាទ នោះទ្រង់បានចំណាយពេលនៅជិតមាត់សមុទ្រកាលីឡេជាញឹកញាប់។ ហ្វូងមនុស្សក៏បានមកឯទ្រង់ពីជិតពីឆ្ងាយ។

> ខណៈនោះ ទ្រង់តាំងបង្រៀន នៅត្រង់មាត់សមុទ្រម្តងទៀត ហើយមានមនុស្សទាំងហ្វូងមូលគ្នា មកឯទ្រង់ ដល់ម្ល៉េះបានជាទ្រង់យាងចុះទៅគង់ក្នុងទូក នៅសមុទ្រវិញ ហើយមនុស្សទាំងអស់នៅលើគោក តាមមាត់ច្រាំង។ (ម៉ាកុស ៤:១)

ក្រោយពីបង្រៀនពេញមួយថ្ងៃ នោះព្រះយេស៊ូវមានបន្ទូលទៅពួកសិស្សថា "ចូរយើងឆ្លងទៅត្រើយម្ខាង"។ ទ្រង់បានគង់នៅក្នុងទូកជាមួយពួកសិស្សជាស្រេច ដូច្នេះពួកគេក៏ចាកចេញពីហ្វូងមនុស្សទៅ។

> ភ្លាមនោះ មានខ្យល់ព្យុះកំណាចមួយកើតឡើង ហើយរលកក៏បោកចូលក្នុងទូក ធ្វើឲ្យទឹកចូលទូកស្ទើរពេញ។ តែព្រះអង្គផ្ទំលក់លើខ្នើយ នៅកន្សៃទូក ពួកសិស្សក៏ដាស់ព្រះអង្គ ហើយទូលព្រះអង្គថា "លោកគ្រូ យើងវិនាសឥឡូវហើយ! តើលោកមិនអំពល់ទេឬ?"។
>
> ព្រះអង្គក៏តើនឡើង បន្ទោសខ្យល់ ហើយបង្គាប់ទៅសមុទ្រថា "ចូរស្ងប់ ហើយស្ងៀមទៅ!"។
>
> ពេលនោះ ខ្យល់ក៏ស្ងប់ ហើយស្ងាត់សូន្យឈឹង។
>
> ព្រះអង្គមានព្រះបន្ទូលទៅគេថា "ហេតុអ្វីបានជាអ្នករាល់គ្នាភ័យ? តើអ្នករាល់គ្នានៅតែគ្មានជំនឿទេឬ?"។
>
> ពេលនោះ គេមានសេចក្តីស្ញប់ស្ញែងជាខ្លាំង ហើយសួរគ្នាទៅវិញទៅមកថា "ចុះតើលោកនេះជានរណាដែលសូម្បីតែខ្យល់ និងសមុទ្រក៏ស្តាប់បង្គាប់លោកដូច្នេះ?"។ (ម៉ាកុស ៤:៣៧-៤១ គកស១៦)

*តើលោកនេះជានរណា?* កាលពីមួយពាន់ឆ្នាំមុន ហោរា ដាវីឌ បានឆ្លើយនឹងសំណួរនេះរួចហើយថា៖

> ...គេក៏ទាល់ប្រាជ្ញាទៅ។ គ្រានោះ គេអំពាវនាវដល់ព្រះយេហូវ៉ា ដោយសេចក្តីវេទនារបស់គេ ហើយទ្រង់ក៏ប្រោសឲ្យរួចពីសេចក្តីលំបាកនោះ។ ទ្រង់ធ្វើឲ្យព្យុះសង្ឃរាបានស្ងាត់ឈឹងទៅវិញ ហើយឲ្យរលកស្ងប់ស្ងៀមដែរ។ (ទំនុកដំកើង ១០៧:២៧-២៩)

តើអ្នកណាអាចធ្វើឲ្យខ្យល់ និងសមុទ្រស្ងប់ទៅបាន ដោយគ្រាន់តែបង្គាប់ពួកវានោះ?

គឺព្រះបន្ទូលដដែល ដែលបានបង្កើតពួកវាមក។





## ភាគទី៥០
# អំណាចលើអំពើបាប

នៅថ្ងៃមួយ មានបុរស៤នាក់បានសែងអ្នកស្លាប់ដៃស្លាប់ជើងម្នាក់មកឯផ្ទះ ដែលព្រះយេស៊ូវកំពុងគង់នៅ។

ពួកគេខំព្យាយាមប្រជ្រៀតចូលទៅខាងក្នុង តែចូលមិនបាន ដោយសារមានមនុស្សច្រើនពេក។ ដូច្នេះ ពួកគេក៏ឡើងទៅលើដំបូលផ្ទះ ដើម្បីដកក្បឿងចេញ ហើយសម្រូតគ្រែអ្នកជំងឺនោះចុះទៅត្រង់កន្លែងដែលព្រះយេស៊ូវកំពុងគង់នៅ។

> ព្រះយេស៊ូវឃើញជំនឿរបស់គេ ព្រះអង្គមានព្រះបន្ទូលទៅអ្នកស្លាប់ដៃស្លាប់ជើងថា “កូនអើយ ខ្ញុំអត់ទោសឲ្យអ្នកបានរួចពីបាបហើយ“។ (ម៉ាកុស ២:៥ គកស១៦)

ព្រះយេស៊ូវជ្រាបថា អ្វីដែលបុរសនេះត្រូវការបំផុតនោះ គឺមិនមែនជាការដើរបានវិញនោះទេ ប៉ុន្តែគឺជាការអត់ទោសឲ្យរួចពីបាបវិញ។

> មានអាចារ្យខ្លះអង្គុយនៅទីនោះ រិះគិតក្នុងចិត្តថា “ហេតុអ្វីបានជាអ្នកនេះនិយាយដូច្នេះ? ពាក្យនេះប្រមាថដល់ព្រះទេតើ! ក្រៅពីព្រះមួយអង្គ តើមានអ្នកណាអាចអត់ទោសបាបបាន?“។
>
> ព្រះយេស៊ូវជ្រាបក្នុងវិញ្ញាណព្រះអង្គភ្លាមពីការរិះគិតនៅក្នុងចិត្តរបស់គេ ហើយព្រះអង្គមានព្រះបន្ទូលទៅគេថា “ហេតុអ្វីបានជាអ្នករាល់គ្នារិះគិតនៅក្នុងចិត្តដូច្នេះ? ដ្បិតដែលនិយាយទៅអ្នកស្លាប់ដៃស្លាប់ជើងនេះថា ខ្ញុំអត់ទោសឲ្យអ្នកបានរួចពីបាបហើយ ឬថា ចូរក្រោកឡើង ហើយយកគ្រែស្នែងរបស់អ្នកដើរទៅ តើពាក្យណាងាយថាជាជាង? ប៉ុន្តែ ដើម្បីឲ្យអ្នករាល់គ្នាដឹងថា នៅផែនដីនេះ កូនមនុស្សមានអំណាចនឹងអត់ទោសបាបបាន“។
>
> ព្រះអង្គមានព្រះបន្ទូលទៅអ្នកស្លាប់ដៃស្លាប់ជើងនោះថា “ខ្ញុំនិយាយទៅកាន់អ្នក ចូរក្រោកឡើង យកគ្រែស្នែងរបស់អ្នក ហើយទៅផ្ទះទៅ!“។
>
> គាត់ក៏ក្រោកឡើងភ្លាម យកគ្រែស្នែងដើរចេញទៅនៅមុខមនុស្សទាំងអស់ ធ្វើឲ្យគេគ្រប់គ្នាមានសេចក្តីអស្ចារ្យ ហើយសរសើរតម្កើងដល់ព្រះ ដោយពោលថា “យើងមិនដែលបានឃើញអ្វីដូច្នេះសោះ!“។ (ម៉ាកុស ២:៦-១២ គកស១៦)

ពួកអាចារ្យទាំងនោះងងឹតដោយសាសនា និងអំនួតរបស់ពួកគេ។ ពួកគេបានគិតក្នុងចិត្តយ៉ាងដូច្នេះថា៖ *យេស៊ូវ ឯងប្រមាថដល់ព្រះ! ឯងត្មះតិះដៀលដល់ព្រះ ដ្បិតឯងអះអាងថាអាចអត់ទោសបាបបាន ប៉ុន្តែមានតែព្រះមួយអង្គប៉ុណ្ណោះ ដែលអាចធ្វើបាន!*

ពួកគេគិតត្រូវហើយ គឺមានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចអត់ទោសបាបបាន ប៉ុន្តែពួកគេបានសន្និដ្ឋានខុសថា ព្រះយេស៊ូវជានរណា។

តើ*អ្នក*គិតថា ព្រះយេស៊ូវជានរណា? តើអ្នកនៅចាំអត្ថន័យរបស់ព្រះនាមទ្រង់ដែរឬទេ? គឺមានន័យថា *ព្រះយេហូវ៉ាសង្គ្រោះ*។

នៅស្រុកមួយក្នុងតំបន់ប៉ាឡេស្ទីន ដែលព្រះយេស៊ូវបានយាងទៅបង្រៀន នោះពួកមនុស្សបានសន្និដ្ឋានយ៉ាងដូច្នេះថា៖

> “ឥឡូវនេះ យើងជឿ...ដោយព្រោះបានឮទ្រង់ផ្ទាល់ខ្លួនយើងវិញ ហើយយើងដឹងថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះដ៏ជួយសង្គ្រោះមនុស្សលោកពិតប្រាកដមែន។“ (យ៉ូហាន ៤:៤២)





## ភាគទី៥១
# អំណាចលើសេចក្តីស្លាប់

ព្រះយេស៊ូវមានអំណាចលើគ្រប់ផ្នែកទាំងអស់ ដែលទ្រង់បានបង្កើត។ ប៉ុន្តែ ទ្រង់មិនបានចេញទៅទាំងប្រកាសថា “ចូរថ្វាយបង្គំអញ! អញជាព្រះ! អញជាព្រះ!”។ ទ្រង់គ្រាន់តែបានធ្វើអ្វីៗ ដែលមានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចធ្វើបាន ហើយទុកឲ្យមនុស្សពិចារណាដោយខ្លួនឯងវិញ។

ដោយផ្អែកទៅលើរឿងពីរបន្តទៀត តើអ្នកគិតថា ព្រះយេស៊ូវជានរណា?

> ទ្រង់យាងទៅឯក្រុង១ហៅថា ណាអ៊ីន មានទាំងពួកសិស្ស នឹងមនុស្សសន្ធឹកទៅដែរ។ កាលចូលទៅជិតដល់ទ្វារកំផែងក្រុង នោះឃើញគេសែងខ្មោចចេញមក ជាខ្មោចកូនតែ១ ដែលម្តាយនៅមេម៉ាយ ហើយមានមនុស្សក្រុងនោះជាច្រើនហែមកជាមួយនឹងគាត់។
>
> កាលព្រះអម្ចាស់បានឃើញ នោះទ្រង់មានព្រះហឫទ័យក្តួលអាណិតអាសូរដល់គាត់ណាស់ ក៏មានបន្ទូលថា “កុំយំអី”។
>
> រួចទ្រង់យាងចូលទៅពាល់ក្តារមឈូស ឯពួកអ្នកសែងក៏ឈប់ ហើយទ្រង់មានបន្ទូលថា “អ្នកកំឡោះអើយ ខ្ញុំបង្គាប់អ្នកថា ចូរក្រោកឡើង!”។
>
> អ្នកដែលស្លាប់នោះ ក៏ក្រោកឡើងអង្គុយ ហើយចាប់តាំងនិយាយ រួចទ្រង់ប្រគល់ដល់ម្តាយវិញ។ មនុស្សទាំងអស់គ្នាកើតមានសេចក្តីស្ញែងខ្លាច ក៏សរសើរដំកើងដល់ព្រះ។
> (លូកា ៧:១១-១៦)

នៅថ្ងៃមួយទៀត ព្រះយេស៊ូវបានយាងទៅជួបបងប្អូនស្រីពីរនាក់ គឺម៉ាថា និងម៉ារា ដែលកំពុងកើតទុក្ខ។ កាលពី៤ថ្ងៃមុន ប្អូនប្រុសរបស់ពួកគេឈ្មោះ ឡាសារ បានស្លាប់។

> ម៉ាថាទូលព្រះយេស៊ូវថា “ព្រះអម្ចាស់អើយ បើសិនជាទ្រង់បានគង់នៅទីនេះ នោះប្អូនខ្ញុំម្ចាស់មិនបានស្លាប់ទេ...”។
>
> ព្រះយេស៊ូវមានបន្ទូលទៅនាងថា “ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ។ ឯអ្នកណាដែលរស់នៅ ហើយជឿដល់ខ្ញុំ នោះមិនត្រូវស្លាប់ឡើយ នាងជឿសេចក្តីនេះឬទេ?”។
>
> នាងទូលឆ្លើយថា “ព្រះពរព្រះអម្ចាស់ ខ្ញុំម្ចាស់ជឿហើយថា ទ្រង់ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ដែលត្រូវយាងមកក្នុងលោកីយមែន”។
>
> នោះព្រះយេស៊ូវយាងទៅដល់ផ្នូរ...ឯផ្នូរនោះជារអាងថ្ម ហើយមានថ្ម១បិទសន្ធប់។ ព្រះយេស៊ូវមានបន្ទូលថា “ចូរយកថ្មចេញ”។
>
> តែម៉ាថា ជាបងរបស់រូបបុគ្គលនោះទូលថា “ព្រះអម្ចាស់អើយ ខ្មោចនេះធុំក្លិនហើយ ព្រោះស្លាប់កន្លងមកបាន៤ថ្ងៃ”។
>
> ព្រះយេស៊ូវមានបន្ទូលទៅនាងថា “តើខ្ញុំមិនបានប្រាប់នាងថា បើសិនជានាងជឿ នោះនាងនឹងឃើញសិរីល្អនៃព្រះទេឬអី?”។ ដូច្នេះ គេក៏យកថ្មចេញ...។ កាលទ្រង់មានបន្ទូលដូច្នេះហើយ ក៏បន្លឺវាចាថា “ឡាសារអើយ ចូរចេញមក”។ នោះអ្នកដែលបានស្លាប់ ក៏ចេញមក មានទាំងសំពត់ស្នបរុំជាប់នៅជើងដៃផង ហើយមានកន្សែងគ្របមុខដែរ ព្រះយេស៊ូវមានបន្ទូលទៅគេថា “ចូរស្រាយគាត់ឲ្យទៅចុះ”។ (យ៉ូហាន ១១:២១, ២៥-២៧, ៣៨-៤១, ៤៣-៤៤)

នៅក្នុងប្រវត្តិសាស្ត្រ មានតែព្រះអម្ចាស់យេស៊ូវមួយអង្គប៉ុណ្ណោះ ដែលអាចមានបន្ទូលថា៖

> “ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត។”

កិច្ចការរបស់ទ្រង់បានបញ្ជាក់ថា ព្រះបន្ទូលរបស់ទ្រង់ គឺជាការពិត។





# ភាគទី៥២
# អ្នកផ្គត់ផ្គង់

ហ្វូងមនុស្សដ៏ច្រើនកកកុញបាននាំគ្នាមកតាមព្រះយេស៊ូវ ហើយពេលខ្លះពួកគេនៅជាមួយទ្រង់ជាច្រើនថ្ងៃជាប់គ្នា។ ជាញឹកញាប់ ពួកគេបានរកទ្រង់ឃើញនៅតំបន់ដាច់ស្រយាល ដែលទ្រង់បានយាងទៅដើម្បីចំណាយពេលជាមួយពួកសិស្ស។ មានពេលខ្លះ ហ្វូងមនុស្សបានឃ្លាន។

នេះជាអ្វីដែលបានកើតឡើង នៅពេលរសៀលមួយ ដែលមានមនុស្សជាង៥០០០នាក់មកជួបជុំគ្នានៅលើភ្នំមួយ ត្រង់ភាគខាងកើតនៃសមុទ្រកាលីឡេ។ ពេលនោះ ព្រះយេស៊ូវមានបន្ទូលសួរទៅលោក ភីលីព ជាសិស្សម្នាក់របស់ទ្រង់ថា៖

> “យើងនឹងទិញនំប៉័ងពីណាមក ឲ្យមនុស្សទាំងអស់នេះបានបរិភោគ?” ទ្រង់មានបន្ទូលសួរដូច្នេះ ដើម្បីនឹងល្បងលគាត់ទេ ព្រោះទ្រង់ជ្រាបការ ដែលទ្រង់គិតធ្វើហើយ។
>
> ភីលីពទូលឆ្លើយថា “ទោះបើទិញនំប៉័ងអស់៤០រៀល ក៏មិនគ្រាន់ឲ្យគ្រប់គ្នាសូម្បីតែបន្តិចបន្តួចផង!”។
>
> មានសិស្សទ្រង់ម្នាក់ ឈ្មោះអនទ្រេ ជាប្អូនស៊ីម៉ូន-ពេត្រុស គាត់ទូលទ្រង់ថា “នៅទីនេះមានក្មេងម្នាក់ មាននំប៉័ងម្សៅឱក៥ នឹងត្រីតូច២ ប៉ុន្តែ ដែលមានតែប៉ុណ្ណោះ តើមានប្រយោជន៍អ្វីដល់មនុស្សច្រើនទាំងម្លេះ?”។
>
> ព្រះយេស៊ូវមានបន្ទូលថា “ចូរឲ្យមនុស្សទាំងអស់អង្គុយទៅ”។ រីឯនៅទីនោះមានស្មៅច្រើន ដូច្នេះ គេក៏នាំគ្នាអង្គុយ មានចំនួនប្រហែលជា៥ពាន់នាក់។
>
> រួចព្រះយេស៊ូវទ្រង់យកនំប៉័ងនោះមកអរព្រះគុណ រួចចែកទៅឲ្យពួកសិស្ស គេក៏ចែកដល់ពួកអ្នកដែលអង្គុយ បានចែកទាំងត្រីតូចនោះបែបដូច្នោះដែរ តាមតែគេចង់បាន។
>
> លុះគេបានឆ្អែតគ្រប់គ្នាហើយ នោះទ្រង់មានបន្ទូលទៅពួកសិស្សថា “ចូរប្រមូលចំណិតដែលសល់នៅ ដើម្បីកុំឲ្យបាត់អ្វីឡើយ”។
>
> ក្រោយដែលបរិភោគរួចហើយ នោះគេប្រមូលចំណិតនំប៉័ងម្សៅឱក ដែលសល់ពី៥ដុំនោះដាក់ពេញបាន១២កន្ត្រក! (យ៉ូហាន ៦:៥-១៣)

លុះដល់ថ្ងៃបន្ទាប់ មនុស្សខ្លះក៏បាននាំគ្នាមករកព្រះយេស៊ូវទៀត។ ពួកគេចង់លើកទ្រង់ឡើងជាស្តេច គឺព្រោះតែពួកគេចង់ឲ្យទ្រង់ជួយសង្គ្រោះពួកគេពីការជិះជាន់របស់ពួករ៉ូម ហើយប្រទានអាហារបន្ថែមទៀតដល់ពួកគេ។ ព្រះយេស៊ូវមានបន្ទូលទៅពួកគេថា៖

> “កុំឲ្យខំប្រឹងឲ្យបានតែអាហារ ដែលតែងតែពុករលួយនោះឡើយ ចូរខំឲ្យបានអាហារ ដែលនៅស្ថិតស្ថេរ ដរាបដល់ជីវិតអស់កល្បជានិច្ចវិញ ជាអាហារដែលកូនមនុស្ស[១៩]នឹងឲ្យមកអ្នករាល់គ្នា ដ្បិតគឺកូនមនុស្សនេះហើយ ដែលព្រះវរបិតាដ៏ជាព្រះ ទ្រង់បានដៅចំណាំទុក។”
>
> “ខ្ញុំជានំប៉័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ។” (យ៉ូហាន ៦:២៧, ៣៥)

អាហារអាចជួយរូបកាយរបស់អ្នកឲ្យរស់បានមួយរយៈ ប៉ុន្តែមានតែព្រះអម្ចាស់យេស៊ូវប៉ុណ្ណោះដែលអាចប្រទានជីវិតដ៏ពិតដល់អ្នក គឺសម្រាប់ពេលនេះ និងពេលអនាគតជារៀងរហូត។

មានតែព្រះយេស៊ូវប៉ុណ្ណោះ ដែលអាចមានបន្ទូលថា៖

> “ខ្ញុំជានំប៉័ងជីវិត។”





# ភាគទី៥៣
# គ្រូបង្រៀន

ព្រះយេស៊ូវមិនដូចពួកគ្រូបង្រៀនខាងសាសនានោះទេ ដែលចេះតែបង្គាប់ថា "ចូរធ្វើបែបនេះ! កុំធ្វើបែបនោះ! ចូរធ្វើតាមច្បាប់នេះ! នេះជាវិធីត្រឹមត្រូវ!" គឺមានតែព្រះយេស៊ូវប៉ុណ្ណោះ ដែលអាចមានបន្ទូលថា៖

"ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត។" (យ៉ូហាន ១៤:៦)

ព្រះយេស៊ូវក៏ខុសពីពួកហោរា ដែលបានថ្វាយយញ្ញបូជាសម្រាប់អំពើបាបរបស់ខ្លួន និងកត់ត្រាអំពីការយាងមករបស់ព្រះមេស្ស៊ីដែរ។ ព្រះយេស៊ូវមានបន្ទូលថា៖

"កុំឲ្យគិតស្មានថា ខ្ញុំមកដើម្បីនឹងលើកក្រិត្យវិន័យ ឬទំនាយពួកហោរាចោលឡើយ ខ្ញុំមិនមែនមកនឹងលើកចោលទេ គឺមកនឹងធ្វើឲ្យសំរេចវិញ។" (ម៉ាថាយ ៥:១៧)

ជាញឹកញាប់ ព្រះយេស៊ូវបានបង្រៀនពួកសិស្សអំពីរបៀបរស់នៅជារាស្ត្រនៃនគរស្ថានសួគ៌ ដើម្បីឆ្លុះបញ្ចាំងពីលក្ខណសម្បត្តិ និងសិរីល្អនៃព្រះមហាក្សត្ររបស់ពួកគេ។

"អ្នករាល់គ្នាបានឮសេចក្ដី ដែលថ្លែងទុកមកថា «ចូរស្រឡាញ់អ្នកជិតខាងឯង តែស្អប់ខ្មាំងសត្រូវឯងវិញ»។ ប៉ុន្តែខ្ញុំប្រាប់ថា ត្រូវស្រឡាញ់ពួកខ្មាំងសត្រូវ...ហើយត្រូវអធិស្ឋានឲ្យអ្នកណាដែលធ្វើទុក្ខបៀតបៀនដល់អ្នករាល់គ្នាវិញ។"

"កាលណាអ្នកអធិស្ឋាន កុំឲ្យធ្វើដូចមនុស្សមានពុត ដែលចូលចិត្តឈរអធិស្ឋាន... ឲ្យមនុស្សលោកឃើញនោះឡើយ...។ តែឯអ្នក កាលណាអធិស្ឋាន នោះត្រូវឲ្យចូលទៅក្នុងបន្ទប់ ហើយបិទទ្វារ រួចអធិស្ឋានដល់ព្រះវរបិតានៃអ្នក ដែលទ្រង់គង់នៅទីលាក់កំបាំងចុះ...។ ដូច្នេះ ចូរអធិស្ឋានបែបយ៉ាងនេះវិញថា «ឱព្រះវរបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយ សូមឲ្យព្រះនាមទ្រង់បានបរិសុទ្ធ។ សូមឲ្យរាជ្យទ្រង់បានមកដល់ សូមឲ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី ដូចនៅស្ថានសួគ៌ដែរ។ សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ...»។"

"ដូច្នេះ កុំឲ្យខ្វល់ខ្វាយថា តើត្រូវបរិភោគអ្វី ឬស្លៀកពាក់អ្វីនោះឡើយ។ ដ្បិតគឺជាសាសន៍ដទៃទេតើ ដែលខំស្វែងរករបស់ទាំងនោះវិញ ឯព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយ ថាអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះដែរ។ ចូរស្វែងរកនគរ នឹងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង។"

"ចូរប្រយ័តនឹងពួកគ្រូក្លែងក្លាយ ដែលគេមកឯអ្នករាល់គ្នា ដោយពាក់រោមចៀមបំប្លែងខ្លួន តែខាងក្នុងរបស់គេ ជាឆ្កែចចកដែលឆ្មក់ស៊ីវិញ។"

"ដូច្នេះ អស់អ្នកណាដែលឮពាក្យរបស់ខ្ញុំទាំងនេះ ហើយប្រព្រឹត្តតាម ខ្ញុំនឹងធៀបអ្នកនោះដូចជាមនុស្សប៉ិនប្រយ័ត ដែលសង់ផ្ទះខ្លួននៅលើថ្ម។ រួចភ្លៀងធ្លាក់មក ទឹកក៏ជន់ឡើង ហើយខ្យល់បក់ប៉ះនឹងផ្ទះនោះ តែមិនបានរលំទេ ពីព្រោះបានសង់នៅលើថ្ម។"

"ឯអស់អ្នកណាដែលឮពាក្យរបស់ខ្ញុំទាំងនេះ តែមិនប្រព្រឹត្តតាម អ្នកនោះត្រូវធៀបដូចជាមនុស្សល្ងង់ ដែលសង់ផ្ទះខ្លួននៅលើខ្សាច់វិញ។ រួចភ្លៀងធ្លាក់មក ទឹកក៏ជន់ឡើង ហើយខ្យល់បក់ប៉ះនឹងផ្ទះនោះ ផ្ទះនោះក៏រលំទៅ ហើយមានការខូចខាតជាធំ។" (ម៉ាថាយ ៥:៤៣-៤៤; ៦:៥-៦, ៩-១១, ៣១-៣៣; ៧:១៥, ២៤-២៧)

មិនដែលមានអ្នកណានិយាយដូចគ្រូបង្រៀន ដែលយាងមកពីស្ថានសួគ៌នេះសោះឡើយ។





## ភាគទី៥៤
# ឫទ្ធានុភាពរបស់ព្រះមហាក្សត្រ

ពួកគ្រូបង្រៀន និងពួកសង្ឃនៃសាសន៍យូដា មិនសប្បាយចិត្តនឹងឃើញហ្វូងមនុស្សនាំគ្នាទៅស្តាប់ព្រះយេស៊ូវទេ។ ពួកគេចង់ឲ្យហ្វូងមនុស្សមកស្តាប់ពួកគេវិញ មិនមែនស្តាប់ទ្រង់ទេ!

នៅថ្ងៃមួយ ពួកសង្គ្រាជបានចាត់ពួកកងរក្សាព្រះវិហារឲ្យទៅចាប់ព្រះយេស៊ូវ ប៉ុន្តែពួកគេមិនអាចចាប់ទ្រង់បានឡើយ។ ពេលពួកគេត្រឡប់មកវិញ ពួកសង្គ្រាជបានសួរថា “ហេតុអ្វីបានជាមិនចាប់អ្នកនោះមក?”។ ពួកកងរក្សាព្រះវិហារឆ្លើយថា៖

> “មិនដែលមានអ្នកណានិយាយដូចអ្នកនោះទេ។” (យ៉ូហាន ៧:៤៦ គកស១៦)

សូម្បីតែពួកហោរាក៏មិនបាននិយាយដូចព្រះយេស៊ូវដែរ។ ពួកហោរា គឺអាចប្រៀបដូចជាទៀនដែលបញ្ចេញពន្លឺព្រឹមៗក្នុងលោកីយ៍ដ៏ងងឹត ប៉ុន្តែព្រះមេស្ស៊ីវិញ គឺជា “ព្រះអាទិត្យនៃសេចក្តីសុចរិត” (ម៉ាឡាគី ៤:២)។ តើអ្នកណាត្រូវការទៀនទៀត ខណៈដែលព្រះអាទិត្យបានរះហើយនោះ?

ព្រះយេស៊ូវមានបន្ទូលថា៖

> “ខ្ញុំជាពន្លឺលោកីយ អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្តីងងឹតឡើយ
> គឺនឹងមានពន្លឺនៃជីវិតវិញ។” (យ៉ូហាន ៨:១២)

ព្រះយេស៊ូវ គឺជាព្រះបន្ទូល ដែលកាលដើមដំបូងឡើយបានបង្គាប់ថា “ចូរឲ្យមានពន្លឺឡើង”។ ទ្រង់គឺជាប្រភពនៃពន្លឺតែមួយគត់សម្រាប់រូបកាយ និងវិញ្ញាណ។

ពេលវេលាដែលព្រះមេស្ស៊ីត្រូវបំពេញបេសកកម្មរបស់ទ្រង់ជិតមកដល់ នោះទ្រង់បាននាំសិស្សបីនាក់ គឺពេត្រុស យ៉ាកុប និងយ៉ូហាន ឡើងទៅលើភ្នំខ្ពស់មួយ។

> រួចទ្រង់បានផ្លាស់ប្រែនៅមុខអ្នកទាំងនោះ ព្រះភក្ត្រទ្រង់បានភ្លឺដូចព្រះអាទិត្យ
> ហើយព្រះពស្ត្រទ្រង់ក៏ត្រឡប់ជាសដូចពន្លឺ។
> នោះឃើញលោកម៉ូសេ នឹងលោកអេលីយ៉ា លេចមកឯគេ កំពុងតែទូលនឹងទ្រង់។
> ...នោះមានពពកយ៉ាងភ្លឺបានមកបាំងគេ ហើយមានឮសំឡេងចេញពីពពកនោះថា៖
> “នេះជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់ ចូរស្តាប់តាមចុះ!”។
> កាលបានឮហើយ នោះពួកសិស្សក៏ក្រាបផ្កាប់មុខនឹងដី ទាំងភ័យស្លុតជាខ្លាំង។
> តែព្រះយេស៊ូវទ្រង់យាងទៅពាល់គេ ដោយបន្ទូលថា “ចូរក្រោកឡើង កុំភ័យឡើយ”។
> កាលគេបានងើបឡើង នោះមិនបានឃើញអ្នកណាសោះ ឃើញតែព្រះយេស៊ូវតែប៉ុណ្ណោះ។
> (ម៉ាថាយ ១៧:១-៣, ៥-៨)

ពួកសិស្សមិនអាចភ្លេចអ្វីដែលពួកគេបានឃើញនៅថ្ងៃនោះឡើយ។ ក្រោយមក លោក ពេត្រុសបានសរសេរថា “យើងខ្ញុំជាស្មរបន្ទាល់ ដែលបានឃើញឫទ្ធានុភាពរបស់ទ្រង់ជាក់នឹងភ្នែក!” (២ពេត្រុស ១:១៦)។ ឯលោក យ៉ូហាន បានសរសេរថា “យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ នឹងសេចក្តីពិត” (យ៉ូហាន ១:១៤)។

ប៉ុន្តែ សម្រាប់ពេលនេះ សិរីល្អនៃព្រះរាជបុត្រានៅតែលាក់ទុកក្នុងរូបកាយនៃសាច់ឈាមរបស់ទ្រង់។

ឥឡូវ ដល់ពេលដែលព្រះមហាក្សត្រត្រូវបំពេញបេសកកម្មរបស់ទ្រង់ហើយ។





# ភាគទី៥៥
# បេសកកម្មរបស់ព្រះមហាក្សត្រ

អស់រយៈពេល៣ឆ្នាំ ព្រះអម្ចាស់យេស៊ូវបានធ្វើដំណើរជុំវិញតំបន់ប៉ាឡេស្ទីន ដោយ “ធ្វើការល្អ ព្រមទាំងប្រោសឲ្យអស់អ្នក ដែលត្រូវអារក្សសង្កត់សង្កិនបានជាផង” (កិច្ចការ ១០:៣៨)។ ប្រជាជនធម្មតាបានស្រឡាញ់ទ្រង់ ប៉ុន្តែពួកអ្នកដឹកនាំសាសនានៅក្រុងយេរូសាឡិមវិញ បានរកសម្លាប់ទ្រង់ ហើយព្រះយេស៊ូវក៏បានជ្រាបពីការនេះដែរ។

> កាលជិតដល់កំណត់ ដែលទ្រង់ត្រូវឡើងទៅស្ថានសួគ៌ នោះទ្រង់ដំរង់ព្រះភក្ត្រយាងឆ្ពោះត្រង់ទៅឯក្រុងយេរូសាឡិមតែម្តង។ (លូកា ៩:៥១)

បើអ្នកបានដឹងថា ពួកមនុស្សអាក្រក់នៅទីក្រុងដ៏ឆ្ងាយមួយកំពុងមានគម្រោងចាប់ និងធ្វើទារុណកម្ម ហើយសម្លាប់អ្នក តើអ្នកនឹងទៅទីនោះដែរឬទេ?

នោះហើយជាអ្វីដែលព្រះយេស៊ូវបានធ្វើ។

> តាំងពីគ្រានោះមក ព្រះយេស៊ូវទ្រង់ចាប់ផ្តើមប្រាប់ដល់ពួកសិស្សថា ទ្រង់ត្រូវតែយាងទៅឯក្រុងយេរូសាឡិម ហើយត្រូវរងទុក្ខជាច្រើននៅដៃនៃពួកចាស់ទុំ ពួកសង្គ្រាជ នឹងពួកអាចារ្យ ហើយត្រូវគេធ្វើគុតផង តែក្រោយ៣ថ្ងៃមក ទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ។ (ម៉ាថាយ ១៦:២១)

នេះមិនមែនជាលក្ខណៈនៃព្រះមហាក្សត្រ ដែលពួកសិស្សចង់បាននោះទេ។ *ព្រះមេស្ស៊ីត្រូវជាប់ឆ្កាងមែនឬ? ព្រះជាម្ចាស់ពិតជាមិនអនុញ្ញាតឲ្យអ្នករើសតាំងរបស់ទ្រង់រងទុក្ខ ហើយត្រូវអាម៉ាស់នោះទេ!* ដូច្នេះហើយបានជាលោក ពេត្រុស ទូលទ្រង់ថា៖

> “ឱព្រះអម្ចាស់អើយ! សូមទ្រង់ប្រណីអង្គទ្រង់វិញ ការនោះមិនត្រូវមកដល់ទ្រង់ឡើយ!”
>
> តែទ្រង់បែរទៅមានបន្ទូលនឹងគាត់ថា “សាតាំងអើយ ចូរថយទៅក្រោយអញទៅ! ឯងជាសេចក្តីបង្អាក់ដល់ចិត្តអញ ព្រោះមិនចេះគិតតាមគំនិតនៃព្រះសោះ គឺគិតតាមតែគំនិតរបស់មនុស្សលោកវិញ”។ (ម៉ាថាយ ១៦:២២-២៣)

ពួកសិស្សចង់បានព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ ដែលនឹងបំផ្លាញអំណាចត្រួតត្រារបស់សាសន៍រ៉ូម ហើយបង្កើតរដ្ឋាភិបាលថ្មីនៅក្រុងយេរូសាឡិមវិញ។ សូម្បីតែពេលធ្វើដំណើរ ពួកសិស្សបានប្រកែកគ្នាថា អ្នកណានឹងបានឋានៈធំជាងគេក្នុងនគរនៃព្រះ។ ដូច្នេះ ព្រះយេស៊ូវមានបន្ទូលទៅពួកសិស្សថា៖

> “អ្នកណាក្នុងពួកអ្នករាល់គ្នា ដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នាវិញ...ដូចជាកូនមនុស្សបានមក មិនមែនឲ្យគេបំរើលោកទេ គឺនឹងបំរើគេវិញ ហើយនឹងឲ្យជីវិតខ្លួន ទុកជាថ្លៃលោះមនុស្សជាច្រើនផង។” (ម៉ាថាយ ២០:២៦, ២៨)

ពេលទ្រង់យាងមកផែនដីលើកទីមួយ ព្រះមេស្ស៊ីមិនបានយាងមក ដើម្បីយកឈ្នះលើនគរទាំងប៉ុន្មាន ឬសោយរាជ្យលើបល្ល័ង្កនៅផែនដីនោះទេ តែទ្រង់បានយាងមក ដើម្បីយកឈ្នះលើសាតាំង និងសោយរាជ្យក្នុងចិត្តមនុស្សវិញ។ ដោយហេតុនេះ ព្រះយេស៊ូវបានបង្រៀនថា៖

> “នគរព្រះក៏នៅកណ្តាលអ្នករាល់គ្នាហើយ។” (លូកា ១៧:២១)

ប៉ុន្តែ មុននឹងព្រះមហាក្សត្រដែលយាងមកពីស្ថានសួគ៌ អាចសោយរាជ្យនៅក្នុងចិត្តមនុស្សបាន (ហើយក្រោយមក នៅលើផែនដីទាំងមូល) នោះត្រូវសងថ្លៃលោះអំពើបាបរបស់លោកីយ៍ និងឈ្នះលើសេចក្តីស្លាប់ជាមុនសិន។

*នោះហើយ* គឺជាបេសកកម្មរបស់ទ្រង់។





# ភាគទី៥៦
# ព្រះមហាក្សត្រយាងចូលក្រុងយេរូសាឡិម

អ្វីៗទាំងអស់កំពុងដំណើរការទៅតាមផែនការជាបន្តបន្ទាប់។ កាលព្រះអម្ចាស់យេស៊ូវបានយាងជិតដល់ក្រុងយេរូសាឡិមហើយ នោះទ្រង់បានចាត់សិស្សពីរនាក់ឲ្យធ្វើកិច្ចការមួយដោយមានបន្ទូលថា៖

> “ត្រូវចូលទៅក្នុងភូមិនៅខាងមុខនុ៎ះ កាលណាចូលដល់ហើយ នោះនឹងឃើញកូនលា១ គេចងទុក ដែលមិនទាន់មានអ្នកណាជិះនៅឡើយ ចូរស្រាយវាដឹកនាំមក។ បើអ្នកណាសួរអ្នកថា «ស្រាយវាធ្វើអី» នោះត្រូវឆ្លើយថា «ពីព្រោះព្រះអម្ចាស់ទ្រង់ត្រូវការនឹងវា»។”
>
> ពួកអ្នកដែលទ្រង់បានចាត់នោះ ក៏ទៅឃើញមានដូចជាទ្រង់ប្រាប់។ កំពុងដែលគេស្រាយកូនលា ម្ចាស់វាក៏សួរថា “អ្នកស្រាយវាធ្វើអី?”។
>
> គេឆ្លើយថា “ព្រះអម្ចាស់ទ្រង់ត្រូវការនឹងវា”។ រួចគេដឹកវាទៅថ្វាយព្រះយេស៊ូវ ក៏ក្រាលអាវគេលើខ្នង ហើយថ្វាយទ្រង់គង់។
>
> កំពុងដែលទ្រង់យាងទៅ គេក៏នាំគ្នាយកអាវរបស់ខ្លួនក្រាលតាមផ្លូវ។ លុះទ្រង់យាងជិតដល់ហើយ គឺត្រង់ផ្លូវចុះពីភ្នំដើមអូលីវមក នោះពួកសិស្សទ្រង់ទាំងហ្វូងចាប់តាំងមានសេចក្ដីរីករាយ ក៏ពោលសរសើរដល់ព្រះ ដោយសំឡេងយ៉ាងខ្លាំង ដោយព្រោះអស់ទាំងការឫទ្ធិបារមី ដែលគេបានឃើញនោះ គឺពោលថា “ស្តេចដែលយាងមក ដោយនូវព្រះនាមព្រះអម្ចាស់ ទ្រង់ប្រកបដោយព្រះពរ! សូមឲ្យបានសេចក្ដីក្សេមក្សាន្តនៅស្ថានសួគ៌ នឹងសិរីល្អនៅស្ថានដ៏ខ្ពស់បំផុត!”។
>
> នោះពួកផារិស៊ីខ្លះ[២០]ដែលនៅក្នុងបណ្ដាមនុស្ស គេទូលទ្រង់ថា “លោកគ្រូ ត្រូវស្តីបន្ទោសដល់ពួកសិស្សលោកផង!”។ តែទ្រង់មានបន្ទូលទៅគេថា “ខ្ញុំប្រាប់អ្នករាល់គ្នាថា បើអ្នកទាំងនេះនៅស្ងៀម នោះថ្មនឹងស្រែកឡើងវិញ!”។ (លូកា ១៩:៣០-៤០)

ព្រះមហាក្សត្រនេះ ពិតជាខុសពីស្តេចដទៃទៀតមែន!

ព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ មិនបានវាយសង្គ្រុបទីក្រុង ទាំងមានសម្លេងត្រែអឺងកង ឬកងទ័ពដ៏ខ្លាំងក្លានោះទេ។ ទ្រង់ក៏មិនបានយាងចូលមក ដោយគង់លើសេះសង្គ្រាមដ៏ក្លាហាននោះដែរ។

ទ្រង់បានគង់លើសត្វលាដ៏ស្លូតមួយ គឺជាលាជំទង់ ដែលមិនធ្លាប់មានគេជិះ (តាមធម្មតាលោតកញ្ឆ្រោល) ក៏ជាសត្វដែលមានសញ្ញាឈើឆ្កាងនៅលើខ្នង និងស្មា ហើយអ្វីដែលសំខាន់បំផុតនោះគឺថា វាជាសត្វតែមួយគត់ ដែលអាចសម្រេចទំនាយរបស់ហោរា សាការី ដែលបានកត់ត្រាពី៥០០ឆ្នាំមុនថា៖

> ចូររីករាយជាខ្លាំងឡើង ឱកូនស្រីយេរូសាឡិមអើយ ចូរស្រែកហ៊ោចុះ! មើល ស្តេចរបស់នាងទ្រង់យាងមកឯនាង ទ្រង់ជាអ្នកសុចរិត ហើយមានជ័យជំនះ ទ្រង់ក៏សុភាព ទ្រង់គង់លើសត្វលា គឺជាលាជំទង់ ជាកូនរបស់មេលា។ (សាការី ៩:៩)

ហេតុអ្វីបានជាព្រះមេស្ស៊ីដ៏ជាព្រះមហាក្សត្រ មិនជិះសេះសង្គ្រាមដ៏ខ្លាំងក្លា ដើម្បីយាងចូលទៅក្នុងក្រុងយេរូសាឡិមយ៉ាងដូច្នេះ? ពីព្រោះទ្រង់មិនបានយាងមក ដើម្បីសង្គ្រោះមនុស្សពីការជិះជាន់របស់ពួករ៉ូមនោះទេ។

ទ្រង់បានយាងមក ដើម្បីសង្គ្រោះមនុស្សពីអំពើបាបរបស់ពួកគេវិញ។





# ភាគទី៥៧
# ព្រះមហាក្សត្រត្រូវបានចោទសួរ

ក្នុងរយៈពេលពីរបីថ្ងៃជាប់គ្នា ព្រះយេស៊ូវបានបង្រៀននៅក្នុងព្រះវិហារជាកន្លែងដែលទ្រង់ធ្លាប់ទៅកាលពីនៅជាកុមារ ហើយបានធ្វើឲ្យពួកគ្រូបង្រៀនមានការអស្ចារ្យក្នុងចិត្ត ដោយសំណួរដ៏ស៊ីជម្រៅ និងចម្លើយដ៏មានប្រាជ្ញារបស់ទ្រង់។ ប៉ុន្តែ នៅពេលនេះ ពួកអ្នកដឹកនាំក្នុងព្រះវិហារមានអាកប្បកិរិយាខុសពីមុនៈ

“យើងរាល់គ្នាមិនចង់ឲ្យមនុស្សនេះសោយរាជ្យលើយើងទេ!” (លូកា ១៩:១៤)

ដូច្នេះ ពួកគេបានវាយប្រហារព្រះយេស៊ូវ ដោយសួរសំណួរដែលអាចបង្កឲ្យមានបញ្ហាធំៗ ទាំងសង្ឃឹមនឹងបាននាំប្រជាជនឲ្យប្រឆាំងនឹងទ្រង់វិញ។

> គេឃ្លាំមើលទ្រង់ ហើយក៏ចាត់ពួកសំងាត់ខ្លះទៅដែលធ្វើឫកជាត្រឹមត្រូវ ដើម្បីនឹងចាប់ទ្រង់ដោយនូវព្រះបន្ទូល ប្រយោជន៍នឹងបញ្ជូនទ្រង់ទៅក្នុងកំឡាំង នឹងអំណាចនៃចៅហ្វាយខេត្ត។
>
> អ្នកទាំងនោះទូលសួរទ្រង់ថា “លោកគ្រូ យើងខ្ញុំដឹងថា លោកមានប្រសាសន៍ ហើយបង្រៀនសុទ្ធតែដោយត្រឹមត្រូវទាំងអស់ ហើយលោកមិនយល់មុខអ្នកណាសោះ លោកបង្រៀនពីផ្លូវព្រះ តាមតែសេចក្តីពិត។ ដូច្នេះ តើបើកឲ្យយើងខ្ញុំបង់ពន្ធថ្វាយសេសារឬទេ?”។
> (លូកា ២០:២០-២២)

តើព្រះយេស៊ូវនឹងឆ្លើយយ៉ាងដូចម្តេច? ប្រសិនបើទ្រង់ឆ្លើយថា “ត្រូវបង់ពន្ធឲ្យព្រះចៅអធិរាជ” នោះពួកសាសន៍យូដានឹងចោទប្រកាន់ទ្រង់ថាជាអ្នកក្បត់ជាតិ។ ផ្ទុយទៅវិញ ប្រសិនបើទ្រង់ឆ្លើយថា “មិនចាំបាច់បង់ពន្ធទេ” នោះចៅហ្វាយសាសន៍រ៉ូមនឹងឮពាក្យនេះ ហើយកាត់ទោសទ្រង់ថាជាអ្នកប្រឆាំង។

> តែទ្រង់ជ្រាបឧបាយកលរបស់គេ ក៏មានបន្ទូលថា...“ចូរបង្ហាញកាក់ធំ១មកឲ្យខ្ញុំមើល។ តើមានរូប នឹងឈ្មោះនេះជារបស់អ្នកណា?”។
>
> គេទូលឆ្លើយថា “ជារបស់សេសារ”។
>
> នោះទ្រង់មានបន្ទូលថា “បើដូច្នេះ ចូរថ្វាយរបស់សេសារទៅសេសារទៅ ហើយរបស់ព្រះទៅព្រះវិញ”។
>
> ខណៈនោះ គេចាប់ព្រះបន្ទូលទ្រង់នៅមុខជនទាំងឡាយមិនបាន ហើយក៏ស្ងៀមនៅដោយអស្ចារ្យពីចំឡើយរបស់ទ្រង់។ (លូកា ២០:២៣-២៦)

ពួកគ្រូបង្រៀនសាសនានៃនិកាយផ្សេងៗគ្នា បានព្យាយាមចាប់កំហុសព្រះយេស៊ូវម្តងហើយម្តងទៀត ប៉ុន្តែរាល់តែដង ទ្រង់បានឆ្លើយដោយប្រាជ្ញាដ៏ពោរពេញ។

> រួចតាំងពីថ្ងៃនោះមក គ្មានអ្នកណាហ៊ានទូលសួរទ្រង់ទៀតឡើយ។ (ម៉ាថាយ ២២:៤៦)

ដោយភាពអាម៉ាស់ ពួកគេក៏ដើរចេញពីទ្រង់ទៅឃុបឃិតជាមួយពួកសង្គ្រាជ ដើម្បីចាប់ ហើយធ្វើគុតព្រះយេស៊ូវ។ ពួកគេពិតជាមនុស្សខ្វាក់មែន! ពួកសង្ឃទាំងនេះ មានតួនាទីជាអ្នកថ្វាយយញ្ញបូជានៅលើអាសនានៃព្រះវិហារ ប៉ុន្តែពួកគេមិនបានដឹងថា អ្នកដែលពួកគេរកសម្លាប់នេះ គឺជាព្រះអង្គដែលយញ្ញបូជាទាំងនោះបានចង្អុលបង្ហាញនោះទេ!

ផែនការដ៏អាថ៌កំបាំងរបស់ព្រះជាម្ចាស់ គឺជិតបានសម្រេចហើយ។





## ភាគទី៥៨
# ព្រះមហាក្សត្រត្រូវបានចាប់ខ្លួន

នេះគឺជាយប់មុនថ្ងៃបុណ្យថ្វាយយញ្ញបូជាប្រចាំឆ្នាំ ដែលហៅថា បុណ្យរំលង។[១៦] នៅថ្ងៃបុណ្យរំលងនោះ សត្វចៀមរាប់ពាន់ក្បាលត្រូវបានសម្លាប់។

ព្រះយេស៊ូវបានជ្រាបថា ទ្រង់ក៏ត្រូវគេធ្វើគុតនៅថ្ងៃនោះដែរ ប៉ុន្តែទ្រង់បានចំណាយពេលជាមួយពួកសិស្ស ដើម្បីបរិភោគអាហារពេលល្ងាចចុងក្រោយ។ កាលកំពុងបរិភោគ នោះទ្រង់យកនំបុ័ងមក ហើយប្រទានពរ រួចកាច់ហុចទៅឲ្យពួកសិស្សបរិភោគ។ ទ្រង់ក៏បានយកពែងហុចទៅឲ្យពួកគេផងដែរ។ ទ្រង់មានបន្ទូលថា នំបុ័ងដែលកាច់ចេញនេះ នឹងជួយរំឭកពួកគេពីរូបកាយរបស់ទ្រង់ ហើយទឹកទំពាំងបាយជូរនេះនឹងជួយរំឭកពីព្រះលោហិតរបស់ទ្រង់ ដែលត្រូវបង្ហូរចេញ ដើម្បីតាំងសញ្ញាថ្មីសម្រាប់ការអត់ទោសបាប។

នៅកណ្តាលអធ្រាត្រ ព្រះយេស៊ូវបាននាំពួកសិស្សទៅសួនច្បារមួយហៅថា គេតសេម៉ានី។ នៅទីនោះ ទ្រង់បានអធិស្ឋានដល់ព្រះវរបិតា ដោយជ្រាបពីការអាក្រក់ដែលជិតនឹងកើតឡើងចំពោះទ្រង់។

ពេលនោះ ពួកអ្នកដឹកនាំសាសនាក៏បានមកដល់ ជាមួយនឹងពួកមនុស្សកាន់ដាវកាន់ដំបងដូចជាតាមគេឲ្យសញ្ញា។ ព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកគេថា៖

> "តើអ្នករាល់គ្នាបានចេញមកចាប់ខ្ញុំ ដោយកាន់ដាវ កាន់ដំបង ដូចជាមកចាប់ចោរឬអី? ខ្ញុំបានអង្គុយជាមួយនឹងអ្នករាល់គ្នា ហើយបង្រៀនក្នុងព្រះវិហាររាល់តែថ្ងៃ តែអ្នករាល់គ្នាមិនបានចាប់ខ្ញុំទេ។ ប៉ុន្តែ ការទាំងនេះបានកើតមក ដើម្បីឲ្យបានសំរេចតាមទំនាយពួកហោរាវិញ។"
>
> នោះពួកសិស្សទាំងអស់ក៏រត់ចោលទ្រង់ទៅ។ (ម៉ាថាយ ២៦:៥៥-៥៦)

ព្រះយេស៊ូវអនុញ្ញាតឲ្យគេចងទ្រង់ រួចនាំទ្រង់ទៅផ្ទះសម្តេចសង្ឃ ដែលជាកន្លែងពួកអ្នកដឹកនាំសាសន៍យូដាបានជួបជុំគ្នា។ នៅទីនោះ មនុស្សជាច្រើនបានធ្វើបន្ទាល់ក្លែងក្លាយពីព្រះយេស៊ូវ។

> ឯសំដេចសង្ឃ ក៏ឈរឡើងនៅកណ្តាលជំនុំ ដណ្តឹងសួរព្រះយេស៊ូវថា "តើឯងមិនព្រមឆ្លើយសោះឬអី? សេចក្តីដែលគេចោទប្រកាន់ឯងទាំងប៉ុន្មាននេះ តើយ៉ាងដូចម្តេច?"។ តែទ្រង់នៅតែស្ងៀម មិនបានឆ្លើយអ្វីសោះ។ រួចសំដេចសង្ឃពិចារណាសួរទ្រង់ទៀតថា "តើឯងជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានពរឬអី?"។
>
> ព្រះយេស៊ូវមានបន្ទូលថា "គឺខ្ញុំនេះហើយ មួយទៀត អ្នករាល់គ្នានឹងឃើញកូនមនុស្សអង្គុយនៅខាងស្តាំនៃព្រះចេស្តា ហើយទាំងមកក្នុងពពកនៅលើមេឃផង"។
>
> នោះសំដេចសង្ឃក៏ហែកព្រះពស្ត្រលោក ដោយពាក្យថា "តើយើងចាំបាច់ត្រូវការនឹងទីបន្ទាល់ណាទៀត? អ្នករាល់គ្នាបានឮពាក្យប្រមាថនេះហើយ ចុះតើគិតដូចម្តេច?"។
>
> អ្នកទាំងអស់គ្នាក៏កាត់ទោសទ្រង់ថា គួរស្លាប់ហើយ។
>
> អ្នកខ្លះចាប់តាំងស្តោះដាក់ទ្រង់ ក៏ខ្ទប់ព្រះភក្ត្រ ហើយវាយទ្រង់ រួចទូលប្រាប់ថា "ចូរទាយចុះ!" ឯពួកអាជ្ញា ក៏ទះទ្រង់ដែរ។ (ម៉ាកុស ១៤:៦០-៦៥)

តុលាការនៃសាសន៍យូដាបានកាត់ទោសសម្លាប់ទ្រង់ ប៉ុន្តែពួកគេគ្មានអំណាចនឹងអនុវត្តឡើយ គឺមានតែតុលាការនៃសាសន៍រ៉ូមប៉ុណ្ណោះ ដែលអាចធ្វើបាន។





# ភាគទី៥៩
# ព្រះមហាក្សត្រត្រូវបានកាត់ទោស

លុះព្រលឹមឡើង ពួកអ្នកដឹកនាំសាសនា និងហ្វូងមនុស្សដែលកាន់តែច្រើនឡើងៗបានបណ្តើរព្រះយេស៊ូវចេញពីផ្ទះសម្តេចសង្ឃ ឆ្លងកាត់តាមផ្លូវក្រុងយេរូសាឡិម ដើម្បីទៅឯសាលាជំនុំរបស់លោក ប៉ុនទាស-ពីឡាត់ ជាចៅហ្វាយសាសន៍រ៉ូម។

ពួកអ្នកដឹកនាំសាសនាទាំងនោះចង់ឲ្យលោក ពីឡាត់ កាត់ទោសសម្លាប់ព្រះយេស៊ូវ ដោយចោទប្រកាន់ទ្រង់ថា៖

“យើងខ្ញុំបានឃើញមនុស្សនេះ នាំបំភាន់សាសន៍យើងឲ្យវង្វេងចេញ ក៏ហាមមិនឲ្យបង់ពន្ធថ្វាយសេសារផង ដោយលើកខ្លួនថាជាព្រះគ្រីស្ទ គឺជាស្តេចដែរ។”

[បន្ទាប់ពីចោទសួរទ្រង់រួចហើយ] នោះលោកពីឡាត់មានប្រសាសន៍ដល់ពួកសង្គ្រាជ នឹងបណ្តាមនុស្សថា “ខ្ញុំមិនឃើញជាមនុស្សនេះមានទោសអ្វីសោះ!”។ (លូកា ២៣:២, ៤)

គេឆ្លើយទៅលោកថា “បើវាមិនមែនជាមនុស្សអាក្រក់ នោះយើងខ្ញុំមិនបានបញ្ជូនវាមកទេ”។...

នោះលោកពីឡាត់ក៏ចូលទៅក្នុងសាលាជំនុំវិញ រួចហៅព្រះយេស៊ូវមកដណ្តឹងសួរថា “តើអ្នកជាស្តេចសាសន៍យូដាឬអី?...ចុះអ្នកបានធ្វើអ្វី?”។

ព្រះយេស៊ូវមានបន្ទូលថា “នគរខ្ញុំមិនមែនត្រូវខាងលោកីយនេះទេ បើសិនជានគរខ្ញុំត្រូវខាងលោកីយនេះ នោះពួកអ្នកបំរើខ្ញុំ គេនឹងបានតយុទ្ធហើយ ដើម្បីមិនឲ្យខ្ញុំត្រូវបញ្ជូនទៅសាសន៍យូដាឡើយ តែឥឡូវនេះ នគរខ្ញុំមិនមែនត្រូវខាងស្ថាននេះទេ”។

លោកពីឡាត់ក៏សួរទ្រង់ថា “ដូច្នេះ អ្នកជាស្តេចមែនឬ?”។

ព្រះយេស៊ូវមានបន្ទូលឆ្លើយថា “លោកមានប្រសាសន៍ថា ខ្ញុំជាស្តេច នោះត្រូវហើយ ខ្ញុំបានកើតមក ហើយក៏ចូលក្នុងលោកីយនេះសំរាប់តែការនោះឯង ដើម្បីឲ្យខ្ញុំបានធ្វើបន្ទាល់ពីសេចក្តីពិត អស់អ្នកណាដែលកើតពីសេចក្តីពិត នោះក៏ឮសំឡេងខ្ញុំ”។

លោកពីឡាត់ទូលសួរទ្រង់ថា “តើយ៉ាងណាដែលហៅថាសេចក្តីពិតនោះ?”។

កាលបានទូលដូច្នោះរួចហើយ នោះលោកចេញទៅឯពួកសាសន៍យូដាម្តងទៀត ក៏មានប្រសាសន៍ថា “ខ្ញុំមិនឃើញជាអ្នកនោះមានទោសខុសអ្វីសោះ”។ (យ៉ូហាន ១៨:៣០, ៣៣, ៣៥-៣៨)

ប៉ុន្តែ ហ្វូងមនុស្សបន្តស្រែកឡើងថា៖

“ឲ្យឆ្កាងវាៗទៅ!”

លោកមានប្រសាសន៍ទៅគេជាគំរប់៣ដងថា “តើមនុស្សនេះបានធ្វើអាក្រក់អ្វី? ខ្ញុំមិនឃើញជាមានហេតុអ្វីគួរឲ្យស្លាប់ទេ ដូច្នេះ ខ្ញុំនឹងវាយប្រដៅ រួចលែងវាទៅ”។

តែគេស្រែកទទូចជាខ្លាំង ទាំងសូមឲ្យឆ្កាងទ្រង់វិញ ហើយសំរែករបស់ជនទាំងនោះ នឹងពួកសង្គ្រាជ ក៏បានឈ្នះ។ (លូកា ២៣:២១-២៣)

លោក ពីឡាត់ បានដឹងថា ព្រះយេស៊ូវគ្មានទោសសោះ ប៉ុន្តែដោយសារគាត់ខ្លាចពួកអ្នកដឹកនាំសាសនា និងហ្វូងមនុស្ស នោះគាត់ក៏បានកាត់ទោសសម្លាប់ព្រះយេស៊ូវទៅ។





## ភាគទី៦០
# ព្រះមហាក្សត្រត្រូវបានបំពាក់ភួងបន្លា

លោក ពីឡាត់ បានកាត់ក្ដីព្រះយេស៊ូវឲ្យទទួលទោសដ៏ធ្ងន់បំផុតតាមច្បាប់នៃចក្រភពរ៉ូម គឺជាការវាយដំដ៏សាហាវ ដែលបន្តដោយការឆ្កាង។ អ្នកទោសត្រូវបានវាយនឹងខ្សែតីម៉្យាង ដែលមានបង្កប់ដែកស្រួចតាមខ្សែ។

នៅ៧០០ឆ្នាំមុន ព្រះអម្ចាស់បានបង្គាប់ឲ្យហោរា អេសាយ សរសេរថា៖

> “ខ្ញុំបានប្រគល់ខ្នងទៅឲ្យពួកអ្នកដែលវាយ ហើយថ្ពាល់ខ្ញុំទៅឲ្យពួកដែលបោចពុកចង្កា ខ្ញុំមិនបានគេចមុខពីសេចក្ដីអាម៉ាស់ខ្មាស ឬពីការស្តោះទឹកមាត់ទេ។“ (អេសាយ ៥០:៦)

កណ្ឌគម្ពីរដំណឹងល្អប្រាប់ពីអ្វីដែលបានកើតឡើង ក្រោយពីព្រះអម្ចាស់យេស៊ូវត្រូវបានគេវាយ៖

> នោះពួកទាហានរបស់លោកចៅហ្វាយ គេក៏នាំព្រះយេស៊ូវទៅក្នុងសាលា រួចប្រមូលក្រុមទាហានទាំងអស់មកទាស់នឹងទ្រង់។
>
> គេដោះព្រះពស្ត្រទ្រង់ចេញ ហើយយកអាវក្រហមមកបំពាក់វិញ ក៏ក្រងភួងបន្លាបំពាក់លើព្រះសិរទ្រង់ ហើយយកដើមត្រែងដាក់នៅព្រះហស្តស្តាំ រួចគេលុតជង្គង់នៅចំពោះទ្រង់ទាំងពោលចំអកថា “ថ្វាយបង្គំស្តេចសាសន៍យូដា!“។ គេស្តោះដាក់ទ្រង់ ក៏យកដើមត្រែងនោះវាយព្រះសិរផង។ (ម៉ាថាយ ២៧:២៧-៣០)

ពួកទាហានទាំងនោះមិនបានយល់ពីអត្ថន័យនៃភួងបន្លា ដែលពួកគេបំពាក់នៅលើព្រះសិរទ្រង់នោះទេ។ បន្លាគឺជាផ្នែកមួយនៃបណ្តាសាដែលធ្លាក់មកលើផែនដី ដោយសារអំពើបាបរបស់លោក អ័ដាម។ ព្រះមហាក្សត្រដ៏មានសិរីល្អដែលបរិសុទ្ធនេះ បានយាងមកដើម្បីទទួលយកបណ្តាសានៃអំពើបាបជំនួសយើង។

> កាលគេបានចំអកមើលងាយទ្រង់ស្រេចហើយ ក៏ដោះអាវនោះចេញ ហើយបំពាក់ព្រះពស្ត្រទ្រង់ទៅវិញ រួចនាំចេញទៅឆ្កាង។ (ម៉ាថាយ ២៧:៣១)

អ្នកទោសពីរនាក់ទៀត ក៏ត្រូវបាននាំទៅឆ្កាងជាមួយនឹងព្រះយេស៊ូវដែរ។ ម្នាក់ៗត្រូវលីឈើឆ្កាងរបស់ខ្លួន ទៅកាន់កន្លែងដែលត្រូវស្លាប់។

ពេលកំពុងដើរតាមក្បួនដង្ហែដ៏គួរឲ្យរន្ធត់នេះ ពួកទាហានរ៉ូមបានចាប់បង្ខំបុរសម្នាក់មកពីអាហ្វ្រិកខាងជើងឲ្យលីឈើឆ្កាងជំនួសព្រះយេស៊ូវ។ បន្ទាប់មក ពួកគេបានបន្តធ្វើដំណើរទាំងកាត់តាមផ្លូវតូចចង្អៀតក្នុងក្រុងយេរូសាឡិម ចេញទៅខាងក្រៅកំផែងក្រុង ហើយឡើងទៅទីទួលមួយឈ្មោះថា គាល់កូថា នៅប៉ែកខាងជើងនៃភ្នំម៉ូរីយ៉ា ដែលជាកន្លែងហោរា អ័ប្រាហាំ បាននិយាយ តាំងពី១៩០០ឆ្នាំមុនថា៖

> “កូនអើយ កូនចៀមដែលសំរាប់ជាដង្វាយដុត នោះព្រះទ្រង់នឹងផ្គត់ផ្គង់ឲ្យ។“ (លោកុប្បត្តិ ២២:៨)

ឥឡូវ ដល់ពេលដែលកូនចៀមនោះត្រូវស្លាប់ហើយ។





# ភាគទី៦១
# ព្រះមហាក្សត្រត្រូវបានឆ្កាង

ការឆ្កាង គឺជាវិធីសាស្ត្រប្រហារជីវិតដ៏សាហាវបំផុតមិនធ្លាប់មាន ដែលអនុវត្តដោយរដ្ឋ។ ដើម្បីបន្ថែមភាពអាម៉ាស់ពីលើការឈឺចាប់ដ៏ធ្ងន់ធ្ងរបំផុត នោះពួកទាហានរ៉ូមបានដោះខោអាវរបស់អ្នកទោសចេញឲ្យនៅជាអាក្រាត មុននឹងដំដែកគោលនៅលើដៃជើងរបស់អ្នកទោសឲ្យជាប់ទៅនឹងឈើឆ្កាង។

> កាលមកដល់កន្លែងដែលហៅថា ភ្នំរលាក្បាលហើយ គេឆ្កាងទ្រង់នៅទីនោះ ព្រមទាំងចោរកំណាចផង ម្នាក់ខាងស្តាំ ម្នាក់ខាងឆ្វេងទ្រង់។ ឯព្រះយេស៊ូវ ទ្រង់មានបន្ទូលថា "ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ"។
>
> គេក៏នាំគ្នាធ្វើឆ្នោតចាប់ព្រះពស្ត្រទ្រង់ចែកគ្នា។ ឯបណ្តាជនដែលឈរមើល នឹងពួកនាម៉ឺនដែលឈរជាមួយ ក៏បន្តុះទ្រង់ថា "វាបានជួយសង្គ្រោះមនុស្សឯទៀត បើវាជាព្រះគ្រីស្ទ ជាអ្នករើសតាំងរបស់ព្រះមែន នោះឲ្យវាជួយសង្គ្រោះខ្លួនវាទៅ"។ (លូកា ២៣:៣៣-៣៥)

បើព្រះយេស៊ូវបានជួយសង្គ្រោះអង្គទ្រង់វិញ នោះទ្រង់មិនអាចជួយសង្គ្រោះយើងបានឡើយ។ ហ្វូងមនុស្សមិនបានដឹងថា ពួកគេកំពុងតែសម្រេចអ្វីដែលព្រះអម្ចាស់បានមានបន្ទូលទៅកាន់ហោរា ដាវីឌ ថា៖

> "គេបានចាក់ទំលុះដៃជើងនៃទូលបង្គំ។ ...គេគន់មើល ហើយសំឡឹងមកទូលបង្គំ។ គេយកសំលៀកបំពាក់ទូលបង្គំចែកគ្នា ឯអាវវែងរបស់ទូលបង្គំ គេក៏ធ្វើឆ្នោតចាប់យក។ ...អស់អ្នកដែលឃើញទូលបង្គំក៏ឡកឡឺយឲ្យ គេបូញមាត់ ហើយគ្រវីក្បាល ដោយថា «...ចូរឲ្យទ្រង់ជួយសង្គ្រោះវាចុះ ដ្បិតវាបានយកទ្រង់ជាទីគាប់ចិត្តហើយ!»។"
> (ទំនុកដំកើង ២២:១៦-១៨, ៧-៨)

ផែនការសង្គ្រោះរបស់ព្រះជាម្ចាស់កំពុងសម្រេចក្នុងគ្រប់ផ្នែកទាំងអស់។

នៅលើភ្នំដដែល[១១]ដែលហោរា អ័ប្រាហាំ បាននិយាយថា "កូនចៀមដែលសំរាប់ជាដង្វាយដុត នោះព្រះទ្រង់នឹងផ្គត់ផ្គង់ឲ្យ" និង "ព្រះយេហូវ៉ានឹងផ្គត់ផ្គង់" (លោកុប្បត្តិ ២២:៨, ១៤) ឥឡូវនេះព្រះជាម្ចាស់បានប្រទានកូនចៀមរបស់ទ្រង់ផ្ទាល់ គឺព្រះយេស៊ូវ។

តើអ្នកចាំពីការដែលចៀមឈ្មោលគ្មានទោស ត្រូវបានថ្វាយជាយញ្ញបូជានៅលើអាសនា ដើម្បីលោះកូនប្រុសរបស់លោក អ័ប្រាហាំ ដែលត្រូវស្លាប់នោះដែរឬទេ? នៅពេលនេះ ព្រះរាជបុត្រានៃព្រះដែលគ្មានបាប ក៏ត្រូវបានថ្វាយជាយញ្ញបូជានៅលើឈើឆ្កាង ដើម្បីលោះពូជរបស់លោក អ័ដាម ដែលត្រូវស្លាប់យ៉ាងនោះដែរ។ ព្រះជាម្ចាស់បានសំចៃទុកកូនប្រុសរបស់លោក អ័ប្រាហាំ ប៉ុន្តែទ្រង់ "មិនបានសំចៃទុកនូវព្រះរាជបុត្រាទ្រង់បង្កើត គឺបានបញ្ជូនទ្រង់ទៅជំនួសយើងរាល់គ្នា" (រ៉ូម ៨:៣២)។

> ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។ (យ៉ូហាន ៣:១៦)
>
> ទ្រង់បានលោះអ្នករាល់គ្នា ឲ្យរួចពីកិរិយាឥតប្រយោជន៍ ដែលបានតពីពួកឰយុកោមក នោះមិនមែនដោយរបស់ពុករលួយ ដូចជាប្រាក់ឬមាសនោះទេ គឺបានលោះដោយសារព្រះលោហិតដ៏វិសេសរបស់ព្រះគ្រីស្ទវិញ ទុកដូចជាឈាមនៃកូនចៀមឥតខ្ចោះ ឥតស្លាកស្នាម។ (១ពេត្រុស ១:១៨-១៩)

អ្នកពិតជាមានតម្លៃណាស់ចំពោះព្រះជាម្ចាស់។





# ភាគទី៦២
# ព្រះសង្គ្រោះដ៏ជាព្រះមហាក្សត្រ

ដើម្បីបំពេញផែនការសង្គ្រោះរបស់ព្រះជាម្ចាស់ នោះព្រះអម្ចាស់យេស៊ូវបានទទួលភាពអាម៉ាស់ ដែលអំពើបាបនាំមកជាមួយ។ ទ្រង់ត្រូវបណ្តាសាជំនួសយើង គឺទ្រង់បានទទួលទណ្ឌកម្ម ដែលយើងសមនឹងទទួល។

ក្នុងថ្ងៃដែលលោក អ័ដាម បានរំលងបញ្ញត្តិរបស់ព្រះជាម្ចាស់ នោះទ្រង់ប្រកាសថា នៅថ្ងៃមួយ ព្រះមេស្ស៊ីនឹងកិនក្បាលសត្វពស់។ ព្រះជាម្ចាស់បានមានបន្ទូលទៅសាតាំងថា៖

> “ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ។” (លោកុប្បត្តិ ៣:១៥)

ទំនាយដ៏អាថ៌កំបាំងពីបុរាណ អំពីការដែលសាតាំងចឹកកែងជើងរបស់ព្រះសង្គ្រោះនេះ បានទាយទុកជាមុនអំពីភាពអាម៉ាស់ និងការឈឺចាប់ ដែលកូនចៀមនៃព្រះត្រូវទទួលនៅលើឈើឆ្កាង ខណៈដែល “ទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង” (អេសាយ ៥៣:៥)។

ពួកមនុស្សដែលបញ្ជូនព្រះយេស៊ូវទៅឆ្កាង មិនបានដឹងអំពីផែនការដ៏អាថ៌កំបាំងរបស់ព្រះជាម្ចាស់នោះទេ។

> គ្មានចៅហ្វាយណាក្នុងលោកីយនេះ បានស្គាល់សេចក្តីអាថ៌កំបាំងនោះឡើយ បើបានស្គាល់ នោះគេមិនបានឆ្កាងព្រះអម្ចាស់ដ៏មានសិរីទេ។
>
> ដ្បិតដំណឹងពីឈើឆ្កាង នោះជាសេចក្តីចំកួត ដល់អស់អ្នកដែលកំពុងតែវិនាស តែជាព្រះចេស្តានៃព្រះ ដល់យើងរាល់គ្នាដែលកំពុងតែបានសង្គ្រោះវិញ។ (១កូរិនថូស ២:៨; ១:១៨)

ឈើឆ្កាងរបស់ព្រះយេស៊ូវ គឺត្រូវបានដាក់នៅចន្លោះចោរកំណាចពីរនាក់។

> រីឯចោរកំណាចម្នាក់ដែលជាប់ព្យួរ វាប្រមាថមើលងាយដល់ទ្រង់ថា “បើឯងជាព្រះគ្រីស្ទពិត នោះចូរជួយសង្គ្រោះខ្លួនឯង ហើយនឹងយើងផង!”។
>
> ប៉ុន្តែម្នាក់ទៀតឆ្លើយបន្ទោសវាថា “តើឯងមិនខ្លាចព្រះទេឬអី? ដ្បិតឯងក៏ជាប់ទោសដូចគ្នា។ គេធ្វើទោសយើងត្រូវហើយ ដ្បិតយើងត្រូវទោសចំពោះការដែលយើងបានប្រព្រឹត្ត ប៉ុន្តែព្រះអង្គនេះមិនបានធ្វើខុសអ្វីសោះ”។ រួចអ្នកនោះទូលព្រះយេស៊ូវថា “ព្រះអម្ចាស់អើយ កាលណាចូលទៅក្នុងនគរទ្រង់ សូមនឹកចាំពីទូលបង្គំផង”។
>
> ព្រះយេស៊ូវមានបន្ទូលទៅថា “ខ្ញុំប្រាប់អ្នកជាប្រាកដថា ថ្ងៃនេះ អ្នកនឹងនៅក្នុងស្ថានបរមសុខជាមួយនឹងខ្ញុំដែរ”។ (លូកា ២៣:៣៩-៤៣)

ចោរទី១គ្រាន់តែចង់រួចពីការរងទុក្ខខាងឯរូបកាយប៉ុណ្ណោះ។ គាត់មិនបានគិតថា ខ្លួនត្រូវការព្រះសង្គ្រោះដើម្បីសុគតជំនួសគាត់នោះទេ។

ចំណែកឯចោរទី២ គាត់ក៏ធ្លាប់ប្រមាថដល់ព្រះយេស៊ូវដែរ ប៉ុន្តែខណៈដែលគាត់កំពុងប្រឈមមុខនឹងសេចក្តីស្លាប់ នោះគាត់បានប្រែចិត្តវិញ។ គាត់ចង់ឲ្យព្រះអម្ចាស់ជួយសង្គ្រោះគាត់ឲ្យរួចពីនគររបស់សាតាំង។ គាត់ចង់ក្លាយជារាស្ត្រនៃនគររបស់ព្រះជាម្ចាស់ ប្រសិនបើព្រះមហាក្សត្រនឹងទទួលយកគាត់។ ចម្លើយរបស់ព្រះយេស៊ូវ គឺច្បាស់លាស់ណាស់៖

> “ថ្ងៃនេះ អ្នកនឹងនៅក្នុងស្ថានបរមសុខជាមួយនឹងខ្ញុំដែរ។” (លូកា ២៣:៤៣)

លុះដល់ល្ងាចថ្ងៃនោះ ចោរទាំងពីរនាក់ក៏បានស្លាប់។ ម្នាក់បានទៅស្ថាននរក ប៉ុន្តែម្នាក់ទៀតបានទៅស្ថានបរមសុខវិញ។ តើអ្វីទៅដែលបានធ្វើឲ្យមានភាពខុសគ្នាយ៉ាងដូច្នេះ?

ម្នាក់មិនបានទុកចិត្តលើព្រះសង្គ្រោះដ៏ជាព្រះមហាក្សត្រទេ។
ប៉ុន្តែ ម្នាក់ទៀតបានទុកចិត្តលើទ្រង់វិញ។





# ភាគទី៦៣
# យញ្ញបូជាចុងក្រោយបង្អស់

លុះដល់ពេលថ្ងៃត្រង់ នោះព្រះយេស៊ូវបានជាប់នៅលើឈើឆ្កាងអស់រយៈពេលបីម៉ោងមកហើយ ក៏មានពពកខ្មៅពាសពេញ ថ្ងៃប្រែទៅដូចជាយប់។ មនុស្សឈរមើលក៏ភ័យខ្លាច រួចបំបែកគ្នាទៅ។ ភាពស្ងប់ស្ងាត់ដ៏ព្រឺព្រួចបានគ្របដណ្ដប់លើភ្នំនោះ។ បីម៉ោងក្រោយមក ព្រះយេស៊ូវបានស្រែកឡើងយ៉ាងខ្លាំងថា៖

“ឱព្រះអង្គៗនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ?” (ម៉ាថាយ ២៧:៤៦)

នៅលើអាសនានៃឈើឆ្កាងនោះ ព្រះរាជបុត្រាដ៏អស់កល្បរបស់ព្រះ មានព្រះហឫទ័យរន្ធត់ដោយដាច់ចេញពីព្រះវរបិតានៅឯស្ថានសួគ៌។ ក្នុងរយៈពេលប៉ុន្មានម៉ោងដ៏ងងឹតនោះ ដោយលាក់កំបាំងពីភ្នែកមនុស្ស ព្រះជាម្ចាស់ក៏បានដកយកអំពើបាបរបស់យើងទាំងអស់ ទៅផ្ទុកលើព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ទ្រង់។ ព្រះយេស៊ូវបានក្លាយជាតង្វាយលោះបាបចុងក្រោយបង្អស់។

ខណៈដែលអំពើបាបនៃលោកីយ៍ពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ត្រូវបានផ្ទុកលើព្រះយេស៊ូវ នោះព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌ត្រូវបែរព្រះភក្ត្រចេញ ពីព្រោះ “ទ្រង់មានព្រះនេត្របរិសុទ្ធក្រៃលែង នឹងទតមើលការអាក្រក់មិនបាន”(ហាបាគុក ១:១៣)។ អស់រយៈពេលបីម៉ោងដ៏យូរ សេចក្ដីក្រោធរបស់ព្រះជាម្ចាស់ទាស់នឹងអំពើបាប បានបញ្ឆេះឡើងនៅលើតង្វាយដុតរបស់ទ្រង់ផ្ទាល់។ ដូចកូនចៀមដែលត្រូវបានថ្វាយជាយញ្ញបូជានៅលើអាសនា នោះព្រះយេស៊ូវដ៏ជាកូនចៀមនៃព្រះក៏ត្រូវបានព្យួរនៅលើឈើឆ្កាងរវាងស្ថានសួគ៌និងផែនដី គឺរវាងព្រះជាម្ចាស់និងមនុស្ស។ ក្នុងពេលវេលានោះ ព្រះអង្គដ៏គ្មានដែនកំណត់បានរងទុក្ខវេទនា ដែលយើងត្រូវទទួលនៅក្នុងស្ថាននរក ដើម្បីកុំឲ្យយើងរងទុក្ខវេទនានៅទីនោះអស់កល្បជានិច្ច។

ឥឡូវ ការនេះបានសម្រេចហើយ។

ដោយព្រះយេស៊ូវជ្រាបថា ទ្រង់បានទទួលទណ្ឌកម្មដែលមនុស្សមានបាបសមនឹងទទួល ហើយក៏បានសម្រេចទំនាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់រួចរាល់ នោះទ្រង់មានបន្ទូលថា៖

“ការស្រេចហើយ!”

នោះទ្រង់ឱនព្រះសិរប្រគល់វិញ្ញាណទ្រង់ទៅ។ (យ៉ូហាន ១៩:៣០)

គ្រានោះ វាំងននក្នុងព្រះវិហារក៏រហែកជា២ភាគ ចាប់តាំងពីលើចុះទៅដល់ក្រោម ក៏មានកក្រើកដី ហើយថ្មប្រេះដាច់ពីគ្នា។ (ម៉ាថាយ ២៧:៥១)

ជាច្រើនសតវត្សរ៍កន្លងមក កូនចៀមត្រូវបានសម្លាប់ ហើយដុតនៅលើអាសនាព្រះវិហារ។ ខណៈដែលព្រះយេស៊ូវបានសុគត នោះព្រះជាម្ចាស់បានហែកវាំងននដែលឃាំងបន្ទប់ដ៏ពិសេសមួយ ជាកន្លែងសម្រាប់ប្រោះឈាមជារៀងរាល់ឆ្នាំ ដើម្បីបិទបាំងអំពើបាប។ ដោយការហែកវាំងននោះ ព្រះជាម្ចាស់បានប្រកាសថា៖ *ការស្រេចហើយ! ថ្លៃលោះបាបត្រូវបានសងយ៉ាងពេញលេញ! កូនចៀមអញបានបង្ហូរឈាមដ៏បរិសុទ្ធ សម្រាប់អំពើបាបរបស់លោកីយ៍ហើយ។ អញនឹងលែងទទួលយកឈាមសត្វសម្រាប់អំពើបាបទៀតហើយ។ កូនស្ងួនភ្ងារបស់អញ គឺជាយញ្ញបូជាចុងក្រោយបង្អស់។ ចំពោះអស់អ្នកណាដែលជឿដល់ទ្រង់ នោះទ្វារស្ថានសួគ៌បានបើកចំហហើយ!* (សូមអានកណ្ឌគម្ពីរហេព្រើរ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី។)

៧០០ឆ្នាំមុន ហោរា អេសាយ បានចែងថា៖

ទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់។ ...យើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ហើយព្រះយេហូវ៉ាបានទំលាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់។ (អេសាយ ៥៣:៥-៦)

ការស្រេចហើយ។





# ភាគទី៦៤
# ព្រះមហាក្សត្រត្រូវបានបញ្ចុះក្នុងផ្នូរ

ព្រះយេស៊ូវពីភូមិណាសារ៉ែតបានសុគតហើយ។ ដើម្បីប្រាកដថាទ្រង់បានសុគតមែន នោះទាហានម្នាក់បានយកលំពែងចាក់ត្រង់ចំហៀងទ្រង់។ ឈាម និងទឹកក៏បានហូរចេញមក។

ពួកសិស្សលែងមានសង្ឃឹមទៀតហើយ។ ដោយគិតថា ព្រះយេស៊ូវគួរតែបានកម្ទេចពួករ៉ូមចោល ហើយចាប់ផ្តើមនគររបស់ទ្រង់នៅលើផែនដី នោះពួកសិស្សមិនទាន់បានយល់ពីការសន្យារបស់ទ្រង់ថា ទ្រង់នឹងមានព្រះជន្មរស់ពីសុគតឡើងវិញនៅថ្ងៃទី៣។

ជាធម្មតា សាកសពរបស់មនុស្សដែលគេបានសម្លាប់នៅលើឈើឆ្កាង ត្រូវបានបោះទៅកន្លែងចោលសំរាមនៅក្រៅទីក្រុង ឬក៏នៅក្នុងរណ្តៅធំមួយ។ ចំពោះព្រះសពរបស់ព្រះយេស៊ូវវិញ មិនបានធ្វើយ៉ាងដូច្នេះទេ។ ៧០០ឆ្នាំមុន ហោរា អេសាយ បានថែងថាៈ

> “ក្នុងកាលដែលទ្រង់សុគត នោះគេក៏បញ្ចុះសពទ្រង់នៅជាមួយនឹងពួកអាក្រក់ ហើយនៅក្នុងផ្នូររបស់អ្នកមានម្នាក់...។”(អេសាយ ៥៣:៩)

ព្រះជាម្ចាស់មានផែនការនឹងបញ្ចុះព្រះសពរបស់ព្រះរាជបុត្រាទ្រង់ នៅក្នុងផ្នូរដ៏ឧត្តម។

> ដល់ល្ងាច មាននមនុស្សអ្នកមានម្នាក់ ជាសិស្សព្រះយេស៊ូវ ឈ្មោះយ៉ូសែប ដែលនៅភូមិអើរីម៉ាថេ គាត់មកដល់ បានទៅឯលោកពីឡាត់ សូមព្រះសពព្រះយេស៊ូវ លោកពីឡាត់ក៏បង្គាប់ឲ្យប្រគល់ព្រះសពដល់គាត់។ (ម៉ាថាយ ២៧:៥៧-៥៨)

មុនព្រះយេស៊ូវបានសុគត លោក យ៉ូសែប ពីភូមិអើរីម៉ាថេ និងសម្លាញ់គាត់ឈ្មោះ នីកូដេម បានដើរតាមព្រះយេស៊ូវដ៏ជាព្រះមេស្ស៊ីដោយសម្ងាត់។ ពួកគេធ្លាប់ខ្លាចពួកអ្នកដឹកនាំសាសនា ប៉ុន្តែ ក្រោយពីបានឃើញព្រះយេស៊ូវរងទុក្ខនៅលើឈើឆ្កាង នោះពួកគេក៏ឈប់ខ្លាចតទៅទៀត។ ដូច្នេះ ពួកគេបានយកព្រះសពរបស់ព្រះយេស៊ូវមកលាងជម្រះ ហើយក៏រុំនឹងសំពត់ទេសឯកដ៏ស្អាតជាមួយនឹងជ័រល្វីងទេសប្រមាណជា៣៥គីឡូ គឺដូចទៅនឹងគ្រឿងអប់សាកសពដ៏មានតម្លៃ ដែលពួកហោរាពីទិសខាងកើតធ្លាប់ថ្វាយដល់ព្រះយេស៊ូវជាបុត្រតូច។ បន្ទាប់មក ពួកគេបានដាក់ព្រះសពទ្រង់នៅក្នុងផ្នូរថ្មីរបស់លោក យ៉ូសែប។ ក្រោយពីពួកគេបានប្រមៀលថ្មធំបិទមាត់ផ្នូរហើយ នោះក៏ត្រឡប់ទៅផ្ទះវិញ។

ការបញ្ចុះព្រះសពបែបនេះ គឺស័ក្តិសមនឹងព្រះមហាក្សត្រពិតមែន។

នៅព្រឹកថ្ងៃបន្ទាប់ នោះពួកអ្នកដឹកនាំសាសនាបាននាំគ្នាទៅឯលោក ពីឡាត់ រួចជម្រាបថាៈ

> “លោក យើងខ្ញុំនឹកចាំពីពាក្យដែលអាកំភូតនោះបាននិយាយ ពីកាលនៅរស់នៅឡើយថា «ក្រោយមក៣ថ្ងៃ ខ្ញុំនឹងរស់ឡើងវិញ»។ ដូច្នេះ សូមលោកបង្គាប់ឲ្យគេប្រុងប្រយ័តផ្នូរនោះ ដរាបដល់គំរប់៣ថ្ងៃ ក្រែងពួកសិស្សរបស់វាមកលួចយកខ្មោចវាទាំងយប់ទៅ រួចប្រាប់ដល់បណ្តាជនថា វាបានរស់ពីស្លាប់ឡើងវិញហើយ បើយ៉ាងនោះ សេចក្តីកំភូតជាន់ក្រោយនេះនឹងបានអាក្រក់ជាងជាន់មុនទៅទៀត។”
>
> លោកពីឡាត់មានប្រសាសន៍ទៅគេថា “អ្នករាល់គ្នាមានអ្នកយាមល្បាតស្រាប់ហើយ ដូច្នេះ ចូរទៅរក្សាឲ្យមាំមួនតាមចិត្តចុះ”។ រួចគេក៏ទៅបិទចំណាំធ្វើឲ្យមាំមួន ហើយដាក់គ្នាឲ្យចាំយាមផង។ (ម៉ាថាយ ២៧:៦៣-៦៦)

ទន្ទឹមនឹងនេះ នៅខាងក្នុងផ្នូរវិញ តើមានអ្វីកំពុងកើតឡើងចំពោះព្រះសពរបស់ព្រះយេស៊ូវ?

គឺគ្មានទេ។





# ភាគទី៦៥
# ផ្នូរនៅទទេ

តាំងពីថ្ងៃដែលលោក អ័ដាម បានធ្វើបាបមក នោះសេចក្តីស្លាប់បានសោយរាជ្យនៅលើមនុស្សលោក ដូចស្តេចដ៏កាចសាហាវ។ ប្រសិនបើព្រះយេស៊ូវធ្លាប់ធ្វើបាប នោះសេចក្តីស្លាប់ក៏ត្រូវបណ្តាលឲ្យរូបកាយរបស់ទ្រង់ពុករលួយ មានក្លិនស្អុយ ហើយត្រឡប់ទៅជាធូលីដីជាមិនខាន។ ប៉ុន្តែ ១០០០ឆ្នាំមុន ហោរា ដាវីឌ បានសរសេរថា៖

“ទ្រង់មិនទុកឲ្យ...អ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្តីពុករលួយដែរ។” (ទំនុកដំកើង ១៦:១០)

សេចក្តីស្លាប់ និងផ្នូរគ្មានអំណាចលើព្រះយេស៊ូវ ដែលមិនធ្លាប់ធ្វើបាបសោះឡើយ។

លុះដល់ថ្ងៃទី៣ ក្រោយពីព្រះយេស៊ូវបានសុគត ហើយបញ្ចុះនៅក្នុងផ្នូរ គឺត្រូវនឹងព្រឹកព្រលឹមថ្ងៃអាទិត្យ នោះស្ត្រីប៉ុន្មាននាក់ក៏បាននាំគ្នាមកឯផ្នូរ ដើម្បីបង្ហាញការគោរព។ រំពេចនោះ មានកក្រើកដីជាខ្លាំង ខណៈដែលទេវតាចុះពីលើមេឃមកប្រមៀលថ្មចេញពីផ្នូរ ហើយអង្គុយលើថ្មនោះ។ ឯពួកយាមល្បាតក៏ញ័ររន្ធត់ នោះទេវតានិយាយទៅកាន់ពួកស្ត្រីថា៖

“កុំឲ្យភ័យអី! ដ្បិតខ្ញុំដឹងហើយថា នាងរកព្រះយេស៊ូវដែលត្រូវឆ្កាង។ តែទ្រង់មិនគង់នៅទីនេះទេ! ដ្បិតទ្រង់មានព្រះជន្មរស់ឡើងវិញហើយ ដូចជាទ្រង់បានមានបន្ទូលទុក ចូរមកមើលកន្លែងដែលទ្រង់បានផ្ទំចុះ។ រួចទៅឲ្យឆាប់ ប្រាប់ដល់ពួកសិស្សទ្រង់ថា ទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញហើយ...។”

ស្ត្រី២នាក់នោះក៏ដើរចេញពីផ្នូរជាប្រញាប់ទាំងភ័យ ហើយមានសេចក្តីអំណរជាខ្លាំងផង ក៏រត់ទៅប្រាប់ដល់ពួកសិស្សទ្រង់។

តែកាលនាងកំពុងតែទៅ នោះព្រះយេស៊ូវទ្រង់យាងមកជួបនឹងនាង មានបន្ទូលថា “ជំរាបសួរ!” រួចអ្នកទាំង២ក៏ចូលទៅឱបព្រះបាទថ្វាយបង្គំទ្រង់។ (ម៉ាថាយ ២៨:៥-៩)

ទន្ទឹមនឹងនេះ ពួកយាមល្បាតក៏បានចូលទៅក្នុងទីក្រុង រួចជម្រាបពួកអ្នកដឹកនាំសាសនាអំពីអ្វីដែលបានកើតឡើង។ ដូច្នេះ ពួកអ្នកដឹកនាំទាំងនោះ បានយកប្រាក់ជាច្រើនសូកដល់ពួកយាមល្បាត ដោយប្រាប់ថា៖

“អ្នករាល់គ្នាត្រូវនិយាយថា «ពេលយើងខ្ញុំកំពុងដេកលក់ ពួកសិស្សរបស់វាបានចូលមកលួចយកសពទៅទាំងយប់»។“ (ម៉ាថាយ ២៨:១៣ គកស១៦)

ប៉ុន្តែ ការភូតភររបស់ពួកគេមិនអាចលាក់បាំងការពិតបានឡើយ។ *ផ្នូរនោះនៅទទេ!*

ដោយការសុគត នោះព្រះយេស៊ូវបានសងថ្លៃលោះបាបរបស់យើង។
ដោយការបញ្ចុះក្នុងផ្នូរ នោះព្រះយេស៊ូវបានយាងចុះទៅកន្លែងនៃសេចក្តីស្លាប់ និងពុករលួយ។
ដោយការរស់ឡើងវិញ នោះព្រះយេស៊ូវបានឈ្នះលើសេចក្តីស្លាប់ ហើយឥឡូវនេះ
ទ្រង់មានបន្ទូលថា៖

“កុំខ្លាចអ្វីឡើយ! អញជាដើម ហើយជាចុង ជាព្រះដ៏រស់នៅ អញបានស្លាប់ តែមើលអញរស់នៅអស់កល្បជានិច្ចរៀងរាបតទៅវិញ! អញក៏មានកូនសោនៃសេចក្តីស្លាប់នឹងស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ។” (វិវរណៈ ១:១៧-១៨)

ចំពោះអស់អ្នកណាដែលជឿដំណឹងល្អនេះ សេចក្តីស្លាប់ គឺគ្រាន់តែជាទ្វារបើកចូលទៅក្នុងព្រះវត្តមានរបស់ព្រះមហាក្សត្រ ដែលមានបន្ទូលថា៖

“ដោយព្រោះខ្ញុំរស់ នោះអ្នករាល់គ្នានឹងរស់ដែរ។” (យ៉ូហាន ១៤:១៩)





# ភាគទី៦៦
# សាររបស់ពួកហោរា

នៅថ្ងៃដែលព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ទ្រង់បានលេចមកឲ្យពួកសិស្សជាច្រើនឃើញ គឺមុនដំបូងពួកស្រីៗ រួចលោក ពេត្រុស បន្ទាប់មកអ្នកដំណើរ២នាក់...។

> នៅថ្ងៃនោះឯង មានពួកសិស្ស២នាក់កំពុងតែដើរទៅឯភូមិអេម៉ោស ចំងាយ១១គីឡូម៉ែត្រ ពីក្រុងយេរូសាឡិមទៅ។
>
> នោះព្រះយេស៊ូវក៏ចូលមក យាងជាមួយនឹងគេដែរ។ តែភ្នែកគេត្រូវបិទ្ទិន មិនឲ្យស្គាល់ទ្រង់ទេ។ ព្រះយេស៊ូវមានបន្ទូលសួរគេថា "អ្នករាល់គ្នាដើរបណ្តើរ ជជែកគ្នាបណ្តើរ តើនិយាយគ្នាអំពីរឿងអ្វីហ្នឹង?"។
>
> គេក៏ឈប់ដើរ ឈរស្ងៀម មានទឹកមុខស្រងូត។ ឯម្នាក់ដែលឈ្មោះក្លេវប៉ាស គាត់ឆ្លើយថា "តើអ្នកស្នាក់នៅក្នុងក្រុងយេរូសាឡិមតែម្នាក់ឯងទេឬអី បានជាមិនដឹងការដែលកើតមកនៅគ្រានេះ?"។
>
> ទ្រង់មានបន្ទូលថា "តើការអ្វីហ្នឹង?"។ (លូកា ២៤:១៣, ១៥-១៦, ខ១៧ គខប, ១៨-១៩)

អ្នកដំណើរ២នាក់នេះប្រាប់ថា ពួកគេបានសង្ឃឹមលើព្រះយេស៊ូវពីភូមិណាសារ៉ែតធ្វើជាព្រះមេស្ស៊ី ដែលយកឈ្នះលើពួកខ្មាំងសត្រូវ។ ប៉ុន្តែ ទ្រង់ត្រូវបានឆ្កាងវិញ! ហើយឥឡូវនេះ ផ្នូរក៏នៅទទេ។ *មិនយល់ទាល់តែសោះ!*

> នោះទ្រង់មានបន្ទូលទៅគេថា "ឱមនុស្សឥតពិចារណា ហើយក្រនឹងជឿអស់ទាំងសេចក្តីដែលពួកហោរាបានទាយទុកមកអើយ! តើមិនគួរឲ្យព្រះគ្រីស្ទរងទុក្ខទាំងនោះ ហើយចូលទៅក្នុងសិរីល្អនៃទ្រង់វិញទេឬអី?"។
>
> រួចទ្រង់ក៏ស្រាយន័យសេចក្តី ដែលតំរូវដល់ទ្រង់ ពីក្នុងគម្ពីរទាំងឡាយ ឲ្យគេស្តាប់ ចាប់តាំងពីគម្ពីរលោកម៉ូសេ នឹងគម្ពីរពួកហោរារៀងមក។
>
> នោះក៏ជិតដល់ភូមិដែលគេគិតទៅ ហើយទ្រង់ធ្វើដូចជាចង់យាងបង្ហួស។ តែគេឃាត់ទ្រង់ដោយពាក្យថា "សូមនៅជាមួយនឹងយើងខ្ញុំសិន ពីព្រោះល្ងាច ថ្ងៃទាបណាស់ហើយ"។ ដូច្នេះ ទ្រង់ក៏យាងចូលទៅគង់ជាមួយនឹងគេ។
>
> កាលគង់នៅតុជាមួយគ្នា នោះទ្រង់យកនំបុ័ងមកប្រទានពរ រួចកាច់ប្រទានទៅឲ្យគេ។ នោះភ្នែកគេបានបើកភ្លឺឡើង ហើយគេបានស្គាល់ទ្រង់ តែទ្រង់បាត់ពីមុខគេទៅភ្លាម!
>
> នោះគេនិយាយគ្នាថា "តើយើងមិនមានសេចក្តីខ្នួលខ្នាញ់នៅក្នុងចិត្ត ក្នុងពេលដែលទ្រង់កំពុងតែមានបន្ទូលនឹងយើង ហើយសំដែងពីគម្ពីរ តាមផ្លូវនោះទេឬអី?"។ (លូកា ២៤:២៥-៣២)

គេក៏ប្រញាប់ទៅក្រុងយេរូសាឡិមវិញ ដើម្បីប្រាប់ពួកសិស្សថា៖
*ព្រះអម្ចាស់មានព្រះជន្មរស់! ទ្រង់ជាព្រះសង្គ្រោះដែលត្រូវបានសន្យានៅក្នុងព្រះគម្ពីរ!*
*ទ្រង់ជាកូនចៀមនៃព្រះ ដែលត្រូវបានបង្ហាញនៅពេលថ្វាយយញ្ញបូជា! ទ្រង់ជាព្រះជាម្ចាស់!*

ទីបំផុត ពួកគេក៏បានយល់ពីសាររបស់ពួកហោរា...

គឺយល់ទាំងស្រុង។





# ភាគទី៦៧
# រូបកាយដែលបានផ្លាស់ប្រែ

លុះដល់ព្រលប់ថ្ងៃអាទិត្យ នោះពួកសិស្សបានជួបជុំគ្នា ទាំងទ្វារនៅខ្ទាស់ជាប់។ រំពេចនោះ ព្រះយេស៊ូវបានលេចមកក្នុងបន្ទប់ ហើយមានបន្ទូលថា៖

> “សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខចុះ!”
>
> កាលទ្រង់មានបន្ទូលដូច្នោះហើយ នោះក៏បង្ហាញព្រះហស្ត នឹងចំហៀងទ្រង់ឲ្យគេមើល ដូច្នេះពួកសិស្សមានចិត្តត្រេកអរ ដោយបានឃើញព្រះអម្ចាស់។ (យ៉ូហាន ២០:១៩-២០)

លោក ថូម៉ាស ជាម្នាក់ក្នុងពួកសិស្សទាំង១២ មិនបាននៅជាមួយនៅល្ងាចថ្ងៃនោះទេ។ ក្រោយមក ពួកសិស្សឯទៀតបានប្រាប់គាត់ថា “យើងបានឃើញព្រះអម្ចាស់!”។

> តែគាត់ឆ្លើយថា “បើខ្ញុំមិនឃើញស្នាមដែកគោលនៅព្រះហស្តទ្រង់ ទាំងលូកម្រាមទៅក្នុងស្នាមដែកគោលនោះ ហើយលូកដៃខ្ញុំទៅក្នុងចំហៀងទ្រង់ នោះខ្ញុំមិនព្រមជឿទេ”។
>
> ដល់៨ថ្ងៃក្រោយមក ពួកសិស្សទ្រង់នៅក្នុងផ្ទះម្តងទៀត ហើយថូម៉ាសក៏នៅជាមួយដែរ នោះព្រះយេស៊ូវទ្រង់យាងមក ឈរកណ្តាលពួកគេ ទាំងទ្វារនៅបិទ ហើយមានបន្ទូលថា “សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត!”។
>
> រួចទ្រង់មានបន្ទូលទៅថូម៉ាសថា “ចូរលូកម្រាមដៃអ្នកមក ស្ទាបមើលដៃខ្ញុំឯណេះ ហើយលូកដៃមកក្នុងចំហៀងខ្ញុំផង កុំឲ្យមានចិត្តមិនជឿឡើយ ត្រូវឲ្យជឿចុះ”។
>
> នោះថូម៉ាសទូលឆ្លើយថា “ឱព្រះអម្ចាស់ទូលបង្គំ ឱព្រះនៃទូលបង្គំអើយ!”។
>
> ព្រះយេស៊ូវមានបន្ទូលទៅគាត់ថា “ថូម៉ាសអើយ អ្នកជឿដោយព្រោះបានឃើញខ្ញុំទេតើ មានពរហើយ អ្នកណាដែលជឿឥតឃើញសោះ”។ (យ៉ូហាន ២០:២៤-២៩)

ក្នុងរយៈពេល៤០ថ្ងៃបន្តបន្ទាប់ ព្រះអម្ចាស់បានលេចមកឯពួកអ្នកដើរតាមទ្រង់ ហើយក៏មានបន្ទូលជាមួយពួកគេ រួចបាត់ទៅវិញ។ រូបកាយរបស់ព្រះយេស៊ូវ ដែលមានព្រះជន្មរស់ពីសុគតឡើងវិញ អាចយាងកាត់ជញ្ជាំងបាន ហើយក៏អាចយាងទៅកន្លែងណាមួយក្នុងមួយរំពេច។ ទ្រង់ជាមនុស្សដំបូងបង្អស់ ដែលមានរូបកាយបែបនេះ ប៉ុន្តែទ្រង់ក៏មិនមែនជាមនុស្សចុងក្រោយដែលមានរូបកាយបែបនេះដែរ។

> យើងក៏នឹងមានរូបរាងរបស់ព្រះអម្ចាស់ពីស្ថានសួគ៌ ដូចជាយើងមានរូបរាងរបស់មនុស្សដែលធ្វើពីធូលីមកដែរ។
>
> សេចក្តីស្លាប់បានមកដោយសារមនុស្ស នោះសេចក្តីដែលមនុស្សស្លាប់បានរស់ឡើងវិញក៏មកដោយសារមនុស្សដែរ។ ព្រោះដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នាក៏នឹងបានប្រោសឲ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ។ (១កូរិនថូស ១៥:៤៩, ២១-២២)

តើអ្នកដឹងថា ខ្លួនអ្នកជាមនុស្សមានបាប ដែលគ្មានសង្ឃឹម ហើយគ្មានផ្លូវដើម្បីទទួលសិទ្ធិរស់នៅក្នុងនគររបស់ព្រះជាម្ចាស់ដែរឬទេ? តើអ្នកជឿថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានសុគតជំនួស*អ្នក* ដោយសារអំពើបាបរបស់*អ្នក* ហើយក៏បានរស់ឡើងវិញ ទាំងយកឈ្នះលើសេចក្តីស្លាប់សម្រាប់*អ្នក*ដែរឬទេ? បើអ្នកជឿពិតមែន នោះព្រះជាម្ចាស់មានបន្ទូលថា អ្នកមិននៅ*ក្នុងលោកអ័ដាម*ទៀតទេ។ ព្រះជាម្ចាស់ទតឃើញថា អ្នកជាមនុស្សសុចរិត *ក្នុងព្រះគ្រីស្ទ*វិញ។ នៅថ្ងៃមួយ អ្នកក៏នឹងទទួលរូបកាយដែលបានផ្លាស់ប្រែ ដូចជាព្រះយេស៊ូវផងដែរ។

ប៉ុន្តែ គឺជារូបកាយដែលគ្មានស្នាមដែកគោល។





# ភាគទី៦៨
# ការយាងចាកចេញ

អំណាចគ្រប់គ្រងរបស់លោក អ័ដាម ដែលសាតាំងបានដណ្តើមយក នោះព្រះយេស៊ូវបានយកមកវិញ។ ដោយគ្រប់ទាំងអំណាចលើសាតាំងនិងពួកអារក្ស ខ្យល់និងសមុទ្រ ជំងឺនិងការស្រេកឃ្លាន អំពើបាបនិងសេចក្តីស្លាប់ នោះព្រះយេស៊ូវបានសម្តែងឲ្យឃើញថា ទ្រង់គ្រប់គ្រងលើអ្វីៗទាំងអស់។ សូម្បីតែពេលពួកអ្នកដឹកនាំសាសនា និងពួកទាហានបានចាប់ទ្រង់រួចធ្វើទារុណកម្ម ហើយឆ្កាងទ្រង់ ទ្រង់បានអនុញ្ញាតឲ្យពួកគេធ្វើការទាំងនោះ។

ដូច្នេះ មុនពេលទ្រង់យាងឡើងទៅដំណាក់របស់ព្រះវរបិតាវិញ នោះព្រះអម្ចាស់យេស៊ូវមានបន្ទូលទៅកាន់ពួកសិស្សថា៖

> "គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង។ ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ[២១] ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា នឹងព្រះវិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀន ឲ្យគេកាន់តាមគ្រប់ទាំងសេចក្តី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។" (ម៉ាថាយ ២៨:១៨-២០)

ព្រះយេស៊ូវក៏មានបន្ទូលប្រាប់អស់អ្នកដែលដើរតាមទ្រង់ថា៖

> "ខ្ញុំឲ្យសេចក្តីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្តីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្តីស្រឡាញ់ដល់គ្នាទៅវិញទៅមក។" (យ៉ូហាន ១៣:៣៤-៣៥)

៤០ថ្ងៃក្រោយពីទ្រង់មានព្រះជន្មរស់ឡើងវិញ នោះព្រះយេស៊ូវបានប្រមូលផ្តុំពួកសិស្ស នៅលើភ្នំដើមអូលីវក្រៅក្រុងយេរូសាឡិម។ ពួកសិស្សចង់ដឹងពីពេលវេលា ដែលទ្រង់នឹងយាងត្រឡប់មកវិញ។

ព្រះយេស៊ូវមានបន្ទូលឆ្លើយថា៖

> "មិនត្រូវឲ្យអ្នករាល់គ្នាដឹងពេល ដឹងកំណត់ ដែលព្រះវរបិតាបានទុកនៅក្នុងអំណាចរបស់ទ្រង់នោះឡើយ។ ប៉ុន្តែ កាលណាព្រះវិញ្ញាណបរិសុទ្ធ[២២]បានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនឹងធ្វើជាទីបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា នឹងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង។"
>
> កាលទ្រង់បានមានបន្ទូលសេចក្តីទាំងនោះរួចជាស្រេច ហើយពួកសាវកកំពុងតែមើល នោះព្រះបានលើកទ្រង់ឡើងទៅ រួចមានពពកមកបំបាំងទ្រង់ពីភ្នែកគេ។ កំពុងដែលគេងើយសំឡឹងមើលទៅលើមេឃ ក្នុងកាលដែលទ្រង់យាងទៅ នោះឃើញមាន២នាក់ស្លៀកពាក់ស ឈរនៅជិត និយាយថា៖
>
> "ពួកអ្នកស្រុកកាលីឡេអើយ ហេតុអ្វីបានជាឈរងើយមើលទៅលើមេឃដូច្នេះ? ព្រះយេស៊ូវនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នាឡើងទៅលើស្ថានសួគ៌ ទ្រង់នឹងយាងមកវិញ តាមបែបដដែល ដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ។"
>
> ពួកអ្នកទាំងនោះក៏វិល...ត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ...។ (កិច្ចការ ១:៧-១២)

ទន្ទឹមនឹងនេះដែរ នៅឯស្ថានសួគ៌ ក៏ដល់ពេលដែលព្រះមហាក្សត្រនេះត្រូវបាន "បំពាក់សិរីល្អ នឹងកេរ្តិ៍ឈ្មោះឲ្យ ទុកជាមកុដ" (ទំនុកដំកើង ៨:៥; ហេព្រើរ ២:៩)។





# ភាគទី៦៩
# ការអបអរសាទរជ័យជម្នះ

ចូរស្រមៃមើលពីភាពរុងរឿង គ្រប់ទាំងពណ៌ តន្ត្រី និងភាពរំភើប។ ពួកទេវតារាប់រយលាននកំពុងនិយាយគ្នាថា៖ *ព្រះមហាក្សត្រនឹងយាងមកវិញ! តែទ្រង់នឹងយាងមក ទាំងមានរូបភាពខុសពីមុន! ព្រះអង្គដែលបានបង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ នឹងមានរូបភាពជាមនុស្សអស់កល្បជាដរាបទៅ!*

ទីក្រុងនៃស្ថានសួគ៌ក៏គ្របដណ្តប់ដោយភាពស្ងប់ស្ងាត់ទៅវិញ។

ភ្លាមនោះ សម្លេងត្រែបានបន្លឺឡើងព្រមគ្នាយ៉ាងអស្ចារ្យ រួចក៏មានការប្រកាសដោយសូរលាន់ឮរំពងថា៖

ឱទ្វារទាំងឡាយអើយ ចូរងើបក្បាលឡើង! ឱទ្វារដ៏នៅអស់កល្បជានិច្ចអើយ
ចូរនៅជាចំហចុះ នោះមហាក្សត្រដ៏មានសិរីល្អ ទ្រង់នឹងយាងចូលមក។
តើមហាក្សត្រដ៏មានសិរីល្អនេះជាអ្នកណា?
គឺព្រះយេហូវ៉ាដ៏មានព្រះចេស្តា នឹងឥទ្ធិឫទ្ធិ ជាព្រះយេហូវ៉ាដ៏មានឥទ្ធិឫទ្ធិក្នុងចំបាំង!
តើមហាក្សត្រដ៏មានសិរីល្អនេះជាអ្នកណា?
គឺព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់ជាមហាក្សត្រដ៏មានសិរីល្អនោះឯង!
(ទំនុកដំកើង ២៤:៧-៨,១០)

ទ្វារនៃស្ថានសួគ៌បើកចំហឡើង ដោយមានសម្លេងសាទរយ៉ាងខ្ញៀវខ្ញារ នោះព្រះអង្គដ៏មានជ័យជម្នះ ដ៏ជាកូនចៀមនៃព្រះ និងដ៏ជាកូនមនុស្សដែលមានស្នាមជាប់ពីការច្បាំង ក៏បានមកដល់ គឺ*ព្រះយេស៊ូវ!* ដោយយាងកាត់បណ្តារាស្ត្រដ៏សន្ធឹក ដែលកំពុងសរសើរតម្កើង នោះទ្រង់បានយាងឆ្ពោះទៅកាន់បល្ល័ង្កនៃព្រះវរបិតា។ បន្ទាប់មក ទ្រង់បែរទតទៅពូជរបស់លោក អ័ដាម ដែលទ្រង់បានប្រោសលោះ រួចទ្រង់ក៏ប្រថាប់ចុះ។

បេសកកម្មរបស់ទ្រង់បានសម្រេចហើយ។

ក្រោយមក រាស្ត្រនៃស្ថានសួគ៌ច្រៀងទំនុកថ្មីមួយនេះ ថ្វាយព្រះមហាក្សត្រថា៖

"ទ្រង់គួរនឹងយកក្រាំងនេះ…ដ្បិតទ្រង់បានត្រូវគេធ្វើគុត ហើយទ្រង់បានលោះយើងរាល់គ្នាដោយព្រះលោហិតទ្រង់ ចេញពីគ្រប់ទាំងពូជមនុស្ស គ្រប់ភាសា គ្រប់នគរ ហើយពីគ្រប់ទាំងសាសន៍ ថ្វាយដល់ព្រះ។" (វិវរណៈ ៥:៩)

បន្ទាប់មក ពួកទេវតាដែលនៅជុំវិញបល្ល័ង្កក៏ច្រៀងសរសើរដល់ព្រះជាម្ចាស់ថា៖

"កូនចៀមដែលគេបានសំឡាប់ នោះគួរនឹងបានព្រះចេស្តា…កិត្តិនាម សិរីល្អ នឹងព្រះពរ!" (វិវរណៈ ៥:១២)

នៅលើផែនដីនាសព្វថ្ងៃនេះ ពូជរបស់លោក អ័ដាម ភាគច្រើននៅតែជាប់ខ្លួនជាឈ្លើយនៅក្នុងនគរនៃអំពើបាប និងសេចក្តីស្លាប់របស់សាតាំង គឺជានគរដែលត្រូវវិនាស។ ប៉ុន្តែ ពួកគេអាចទទួលសេរីភាពបាន។ ដោយការសុគត ការបញ្ចុះក្នុងផ្នូរ និងការរស់ឡើងវិញរបស់ទ្រង់ ព្រះអម្ចាស់យេស៊ូវបានឈ្នះចម្បាំងដ៏សំខាន់បំផុតជាស្ថាពរ។ ចំពោះអស់អ្នកដែលទុកចិត្តលើទ្រង់ នោះទ្រង់មានបន្ទូលថា៖

"កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ អ្នករាល់គ្នាជឿដល់ព្រះហើយ ចូរជឿដល់ខ្ញុំដែរ។ នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន…។ បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ។"

"ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ។" (យ៉ូហាន ១៤:១-៣, ៦)





# ភាគទី៧០
# ព្រះមហាក្សត្រនឹងយាងមកវិញ

នៅថ្ងៃមួយក្នុងពេលឆាប់ៗនេះ ខណៈដែលលោកីយ៍កំពុងតែវល់នឹងការឥតប្រយោជន៍ និងសាសនាក្លែងក្លាយ នោះមហាក្សត្រដ៏មានសិរីល្អនឹងយាងមកផែនដីវិញ តែមិនមែនដោយគង់លើលាជំទង់ ហើយក៏មិនមែនដើម្បីទទួលការចំអក ឬពាក់ត្បូងបន្លានោះដែរ។

ព្រះមហាក្សត្រដែលមានព្រះជន្មរស់ឡើងវិញនេះ បានសម្ដែងឲ្យលោក យ៉ូហាន ឃើញទិដ្ឋភាពខ្លះៗពីថ្ងៃនោះទុកជាមុន៖

> ខ្ញុំក៏ឃើញមេឃបើកចំហឡើង នោះឃើញមានសេះស១ នឹងព្រះអង្គដែលគង់លើវា ទ្រង់មានព្រះនាមថា «ស្មោះត្រង់ ហើយពិតប្រាកដ»។ ទ្រង់ជំនុំជំរះ ហើយច្បាំងដោយសុចរិត។ ព្រះនេត្រទ្រង់ដូចជាអណ្ដាតភ្លើង ហើយនៅលើព្រះសិរសា មានមកុដជាច្រើន...។ ...ព្រះនាមទ្រង់ហៅថា «ព្រះបន្ទូលនៃព្រះ»។ អស់ទាំងពលបរិវារនៅស្ថានសួគ៌ ក៏ជិះសេះសដង្ហែទ្រង់ ទាំងស្លៀកពាក់សំពត់ទេស ហើយស្អាតផង។ ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឧរូទ្រង់ថា «ស្ដេចលើអស់ទាំងស្ដេច ជា**ព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់**»។ (វិវរណៈ ១៩:១១-១៤, ១៦)

ខណៈដែលព្រះមហាក្សត្រយាងត្រឡប់មកវិញ នោះនឹងមានសម្លេងដូចផ្គរលាន់ពីលើមេឃថា៖

> "នគរទាំងប៉ុន្មាននៅលោកីយ បានត្រឡប់ជានគររបស់ព្រះអម្ចាស់នៃយើងរាល់គ្នា នឹងជារបស់ផងព្រះគ្រីស្ទនៃទ្រង់ហើយ ទ្រង់នឹងសោយរាជ្យនៅអស់កល្បជានិច្ចរៀងរាបតទៅ!"
> (វិវរណៈ ១១:១៥)

ពួកខ្មាំងសត្រូវរបស់ព្រះមហាក្សត្រនឹងរលាយនៅចំពោះទ្រង់។ បន្ទាប់មក ទ្រង់នឹងចាប់សាតាំងមកចងទុក ហើយសម្ដែងឲ្យលោកីយ៍ដ៏នឿយព្រួយបានឃើញពីការសោយរាជ្យដ៏សុចរិត។ នៅពេលនោះផែនដីនឹងពោរពេញដោយសេចក្ដីសុខសាន្តដ៏អស្ចារ្យបំផុត។

> ព្រះយេហូវ៉ានឹងធ្វើជាមហាក្សត្រលើផែនដីទាំងមូល។ នៅថ្ងៃនោះ នឹងមានតែព្រះយេហូវ៉ាជាព្រះមួយព្រះអង្គ ហើយព្រះនាមព្រះអង្គនឹងមានតែមួយដែរ។ (ហោរា សាការី ១៤:៩ គកស១៦)

នៅថ្ងៃជំនុំជម្រះ ព្រះអម្ចាស់យេស៊ូវនឹងធ្វើជាចៅក្រម។

> ព្រះដ៏មានព្រះជន្មពីចាស់បុរាណគង់លើបល្ល័ង្ករបស់ព្រះអង្គ...ឯបល្ល័ង្កព្រះអង្គសុទ្ធតែជាអណ្ដាតភ្លើង ហើយកង់នៃបល្ល័ង្កនោះ ជាភ្លើងដែលកំពុងឆេះ។ មានទន្លេជាភ្លើងហូរចេញពីចំពោះព្រះអង្គ មានមនុស្សរាប់ពាន់រាប់ម៉ឺនគោរពបម្រើព្រះអង្គ ហើយរាប់លានរាប់កោដិឈរនៅចំពោះព្រះអង្គ។ ការវិនិច្ឆ័យបានរៀបចំជាស្រេច ហើយបញ្ជីទាំងប៉ុន្មានក៏បើកឡើងដែរ។
> (ហោរា ដានីយ៉ែល ៧:៩-១០ គកស១៦)

សាតាំង និងនគរនៃសេចក្ដីងងឹតរបស់វានឹង "ត្រូវបោះទៅក្នុងបឹង ដែលឆេះជាភ្លើង នឹងស្ពាន់ធ័រ" (វិវរណៈ ២០:១០)។ ទីបំផុត ក្បាលរបស់សត្វពស់នឹងត្រូវបានកិនកម្ទេចចោលជារៀងដរាបទៅ។ សម្រាប់រាស្ត្រនៅក្នុងនគរនៃពន្លឺវិញ ព្រះជាម្ចាស់នឹងបង្កើត "ផ្ទៃមេឃថ្មី នឹងផែនដីថ្មី...។ ...ទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹងធ្វើជាព្រះដល់គេ។ ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ នឹងគ្មានសេចក្ដីស្លាប់ ឬសេចក្ដីសោកសង្រេង ឬសេចក្ដីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ" (វិវរណៈ ២១:១, ៣-៤)។

ទីបំផុត សេចក្ដីអធិស្ឋានរបស់អស់អ្នកដែលស្រឡាញ់ព្រះមហាក្សត្ររបស់ខ្លួន នោះនឹងបានសម្រេចជារៀងដរាប៖

> "សូមឲ្យរាជ្យទ្រង់បានមកដល់ សូមឲ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី
> ដូចនៅស្ថានសួគ៌ដែរ!" (ម៉ាថាយ ៦:១០)

តើនេះជាសេចក្ដីអធិស្ឋានរបស់អ្នកមែនឬ? តើអ្នកបានក្រាបថ្វាយបង្គំចុះចូលចំពោះមហាក្សត្រដ៏មានសិរីល្អហើយឬនៅ?

តើទ្រង់ជាព្រះមហាក្សត្រ*របស់អ្នក*ដែរឬទេ?



# សេចក្ដីបញ្ចប់

**ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
អ្នកណាដែលស្ដាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គ
ដែលចាត់ឲ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច
ហើយមិនដែលត្រូវជំនុំជំរះឡើយ
គឺបានកន្លងហួសពីសេចក្ដីស្លាប់ ទៅដល់ជីវិតវិញ។**

— ព្រះយេស៊ូវជាមហាក្សត្រដ៏មានសិរីល្អ (យ៉ូហាន ៥:២៤)

**ទ្រង់បានគង់ក្នុងលោកីយ ហើយលោកីយក៏កើតមកដោយសារទ្រង់
តែមិនស្គាល់ទ្រង់ទេ។ ...ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់
គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់
នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ។**

— កណ្ឌគម្ពីរដំណឹងល្អ (យ៉ូហាន ១:១០, ១២)

## ខ្លឹមសារសំខាន់ៗនៃរឿង • ១

# រស់នៅដោយសុភមង្គលជារៀងរហូត ឬយ៉ាងណា?

មនុស្សគ្រប់វ័យចូលចិត្តរឿងប្រឌិត ដែលចេញពីការស្រមៃ ដូចជារឿងស្នេហា និងការជួយរំដោះ ដែលមានចុងបញ្ចប់ដ៏ល្អ។ មនុស្សនិយមនិទានរឿងបែបនេះ ដោយសារព្រះជាម្ចាស់ដ៏ជាព្រះពិតតែមួយ បានដាក់សេចក្តីប្រាថ្នាក្នុងចិត្តមនុស្ស ឲ្យចង់រួចផុតពីសេចក្តីអាក្រក់ ហើយរស់នៅដោយសុភមង្គល ជារៀងរហូត។ ប៉ុន្តែ រឿងមហាក្សត្រដ៏មានសិរីល្អនេះ គឺមិនមែនជារឿងប្រឌិត ដែលបង្កើតដោយការស្រមៃនោះទេ។



ខុសពីរឿងប្រឌិត សៀវភៅរបស់ព្រះជាម្ចាស់ត្រូវបានសរសេរដោយពួកហោរា៤០នាក់ ក្នុងរយៈពេលជាង១៥សតវត្សរ៍។ ខុសពីរឿងប្រឌិត រឿងរបស់ព្រះជាម្ចាស់ក៏ត្រូវបាន បញ្ជាក់បង្ហាញពីភាពពិតដោយទំនាយរបស់ពួកហោរារាប់រយដង និងការរកឃើញខាង បុរាណវត្ថុផងដែរ។



ខុសពីវីរបុរសក្នុងរឿងប្រឌិត ព្រះយេស៊ូវជាចំណុចដែលបែងចែកប្រវត្តិសាស្ត្រ ពិភពលោកជាពីរ។ ព្រះយេស៊ូវក៏អាចជួយលុបលាងអំពើបាប និងភាពអាម៉ាស់របស់ យើង ហើយនាំយើងទៅឯព្រះជាម្ចាស់ ព្រមទាំងប្រទានឲ្យយើងមានចិត្តថ្មី ដែលពេញ ទៅដោយសេចក្តីស្រឡាញ់ អំណរ និងសេចក្តីសុខសាន្តរបស់ទ្រង់ តែរឿងស្រមើស្រមៃ មិនអាចធ្វើបានយ៉ាងដូច្នោះឡើយ។

ដោយការសម្រេចតាមបទគម្ពីរនៃពួកហោរា នោះព្រះយេស៊ូវដ៏ជាព្រះមេស្ស៊ីបាននាំឲ្យពូជរបស់លោក អ័ដាម អាចរស់នៅអស់កល្បជានិច្ច ជាមួយព្រះអាទិករដ៏ជាព្រះមហាក្សត្រ។ ប៉ុន្តែ មិនមែនមនុស្ស ទាំងអស់នឹងបានរស់នៅក្នុងនគររបស់ទ្រង់នោះទេ។



ដូចដែលព្រះជាម្ចាស់បានបង្កើតច្បាប់១យ៉ាងច្បាស់លាស់សម្រាប់លោក អ័ដាម អំពីការរស់នៅក្នុងសួនច្បារនៅផែនដីជាយ៉ាងណា នោះព្រះជាម្ចាស់ក៏បានបង្កើត ច្បាប់១យ៉ាងច្បាស់លាស់ សម្រាប់ពូជរបស់លោក អ័ដាម អំពីការរស់នៅក្នុងទីក្រុង នៃស្ថានសួគ៌យ៉ាងនោះដែរ គឺ៖

> គ្មានអ្វីដែលស្មោកគ្រោក ឬអ្នកណាដែលប្រព្រឹត្តបែបគួរខ្ពើម ឬសេចក្តីកំភូតណាចូលទៅក្នុងទីក្រុង នោះបានឡើយ ចូលបានតែអ្នកណា ដែលមានឈ្មោះកត់ទុក ក្នុងបញ្ជីជីវិតរបស់កូនចៀមប៉ុណ្ណោះ។ (វិវរណៈ ២១:២៧)



បញ្ជីជីវិតរបស់កូនចៀម គឺជាបញ្ជីនៃស្ថានសួគ៌សម្រាប់កត់ឈ្មោះរបស់មនុស្សគ្រប់រូប ដែលបានទុកចិត្តលើផ្លូវនៃសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ តាំងពីសម័យលោក អ័ដាម មកម្ល៉េះ។ មហាក្សត្រដ៏មានសិរីល្អនឹងមិនបង្ខំអ្នក ឬគ្រួសារអ្នកឲ្យជឿលើទ្រង់ និងអ្វីៗ ដែលទ្រង់បានធ្វើ ដើម្បីសង្គ្រោះអ្នកពីសាតាំង អំពើបាប សេចក្តីស្លាប់ និងស្ថាននរក នោះឡើយ។

នៅក្នុងនគររបស់ទ្រង់នឹងគ្មានរាស្ត្រណា ដែលមិនចុះចូលចំពោះទ្រង់សោះឡើយ។ ប៉ុន្តែ ដោយសារ ព្រះមហាក្សត្រមិនចង់ឲ្យមាននរណាម្នាក់ត្រូវវិនាស ទើបទ្រង់បញ្ចប់សៀវភៅរបស់ទ្រង់ ដោយការ អញ្ជើញ ការព្រមាន និងការសន្យា ដូចខាងក្រោម៖

> "អ្នកណាដែលស្រេក នោះមានតែមក ហើយអ្នកណាដែលចង់បាន មានតែយកទឹកជីវិតនោះចុះ ឥតចេញថ្លៃទេ។ ខ្ញុំធ្វើបន្ទាល់ដល់អស់អ្នកណា ដែលឮសេចក្តីទំនាយក្នុងគម្ពីរនេះថា បើអ្នកណា បញ្ចូលអ្វីក្នុងសេចក្តីទាំងនេះ នោះព្រះទ្រង់នឹងបន្ថែមអស់ទាំងសេចក្តីវេទនា ដែលកត់ទុកក្នុងគម្ពីរ នេះ ដល់អ្នកនោះផង។ ...ព្រះអង្គដែលធ្វើបន្ទាល់ពីសេចក្តីទាំងនេះ ទ្រង់មានបន្ទូលថា «អើ អញមកជាឆាប់»។"
>
> "អាម៉ែន ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក!" (វិវរណៈ ២២:១៧-២០)

ក្រោយពីលោក អ័ដាម បានធ្វើបាបហើយ តើគាត់បាននិយាយទៅកាន់ព្រះជាម្ចាស់យ៉ាងដូចម្ដេច នៅពេលដែលទ្រង់បានយាងមកក្នុងសួនច្បារ ហើយហៅរកគាត់? លោក អ័ដាម បានឆ្លើយតបដោយសេចក្ដីអាម៉ាស់ថា៖

"ទូលបង្គំបានឮសំឡេងទ្រង់នៅក្នុងសួនច្បារ ក៏រត់ទៅពួន ដោយនឹកភ័យខ្លាច។" (លោកុប្បត្តិ ៣:១០)

ប៉ុន្តែ ឥឡូវនេះ តើពូជរបស់លោក អ័ដាម មួយចំនួនឆ្លើយតបយ៉ាងដូចម្ដេចវិញចំពោះការសន្យាថា ព្រះអម្ចាស់នឹងយាងមកលើផែនដីសម្រាប់ពួកគេ? ពួកគេឆ្លើយតបដោយសេចក្ដីអំណរថា៖

"អាម៉ែន ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក។" (វិវរណៈ ២២:២០)

តើអ្វីទៅដែលបាននាំឲ្យមានការផ្លាស់ប្ដូរបែបនេះ? ហេតុអ្វីបានជាមនុស្សខ្លះ លែងមានសេចក្ដីភ័យខ្លាចនឹងឈរនៅចំពោះព្រះដ៏ជាចៅក្រមនៃផែនដី? ហេតុអ្វីបានជាពួកគេមានចិត្តរំភើបនឹងឃើញព្រះភក្ត្ររបស់ព្រះមហាក្សត្រដោយផ្ទាល់?

ពីព្រោះ ពួកគេបានជឿលើរឿង និងសាររបស់ព្រះមហាក្សត្រ។

ហោរា អេសាយ បានសរសេរថា៖

> តើមានអ្នកណាបានជឿដំណឹង ដែលយើងប្រាប់?...។ យើងទាំងអស់គ្នាបានទាសចេញដូចជាចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ហើយព្រះយេហូវ៉ាបានទំលាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់។ (អេសាយ ៥៣:១, ៦)

ហោរា អេសាយ បានសង្ខេបរឿង និងសាររបស់ព្រះមហាក្សត្រជា៣ចំណុច ដូចខាងក្រោម៖



**១. យើងមានបញ្ហា។**

"យើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន។"



**២. ព្រះជាម្ចាស់មានដំណោះស្រាយ។**

"ព្រះយេហូវ៉ាបានទំលាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់(ព្រះរាជបុត្រា)។"



**៣. យើងមានជម្រើស។**

"តើមានអ្នកណាបានជឿដំណឹង ដែលយើងប្រាប់?"

តើអ្នកជឿលើព្រះមហាក្សត្រនេះដែរឬទេ?

> បើសិនជាយើងបានទទួលសេចក្ដីបន្ទាល់របស់មនុស្សទៅហើយ នោះសេចក្ដីបន្ទាល់របស់ព្រះក៏ប្រសើរជាងទៅទៀត ដ្បិតសេចក្ដីបន្ទាល់របស់ព្រះ គឺជាសេចក្ដីដែលទ្រង់ថ្លែងប្រាប់ពីព្រះរាជបុត្រានៃទ្រង់។...
>
> អ្នកណាដែលមិនជឿដល់ព្រះសោះ នោះឈ្មោះថា បានធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ពីព្រោះមិនបានជឿដល់សេចក្ដីបន្ទាល់ ដែលទ្រង់បានធ្វើពីដំណើរព្រះរាជបុត្រានៃទ្រង់។ នេះហើយជាសេចក្ដីបន្ទាល់នោះ គឺថា ព្រះទ្រង់បានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចមកយើងរាល់គ្នា ហើយជីវិតនោះ គឺនៅក្នុងព្រះរាជបុត្រានៃទ្រង់។ ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ។
>
> ខ្ញុំបានសរសេរសេចក្ដីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ។ (១យ៉ូហាន ៥:៩-១៣)

ពិតណាស់ អ្នកអាច*ដឹង* ។ ព្រះមហាក្សត្រមិនទុកឲ្យអ្នកនៅស្រពេចស្រពិលឡើយ។

តើអ្នកបានបែរចេញពីសាសនារបស់មនុស្ស ហើយជឿលើសេចក្ដីបន្ទាល់របស់ព្រះជាម្ចាស់ហើយឬនៅ? បើអ្នកបានធ្វើយ៉ាងដូច្នេះមែន នោះអ្នកនឹងបាននៅជាមួយព្រះមហាក្សត្រអស់កល្បជានិច្ច គឺ...

...រស់នៅដោយសុភមង្គលជារៀងរហូត។

# ខ្លឹមសារសំខាន់ៗនៃរឿង • ២
## ដំណឹងអាក្រក់

ដូចដែលយើងបានអាននៅខាងដើមនៃសៀវភៅរបស់ទ្រង់ ព្រះមហាក្សត្រនៃសកលលោក បានបង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺឲ្យចំនឹងរូបអង្គទ្រង់។ ទ្រង់បានបង្កើតមនុស្សសម្រាប់សិរីល្អរបស់ទ្រង់។ មនុស្សនឹងត្រូវបានធ្វើជាសម្បត្តិដ៏ពិសេស ជាមិត្តសម្លាញ់ និងជារាស្ត្រដ៏បរិសុទ្ធក្នុងនគរនៃពន្លឺរបស់ទ្រង់។ ប៉ុន្តែ ជាដំបូង ត្រូវមានពេលវេលានៃការល្បងលជាមុនសិន។

ព្រះយេហូវ៉ាដ៏ជាព្រះបានប្រទានដល់លោក អ័ដាម នូវការល្បងលដ៏តូចមួយ ដែលអាចនាំឲ្យមានផលវិបាកដ៏ធំ។ ព្រះជាម្ចាស់មានបន្ទូលទៅគាត់ថា គាត់អាចបរិភោគផ្លែឈើទាំងអស់ក្នុងសួនច្បារបានតាមចិត្ត លើកលែងតែមួយប៉ុណ្ណោះ។ តើព្រះជាម្ចាស់មានបន្ទូលថានឹងមានអ្វីកើតឡើងចំពោះលោក អ័ដាម ប្រសិនបើគាត់មិនគោរពតាមច្បាប់មួយនេះ?



តើព្រះជាម្ចាស់មានបន្ទូលទៅលោក អ័ដាម ថា គាត់ត្រូវចាប់ផ្តើមសូត្រធម៌ ធ្វើបុណ្យ ហើយព្យាយាមធ្វើល្អ ដើម្បីសងនឹងអំពើអាក្រក់របស់គាត់ដែរឬទេ? *ទេ!* ព្រះជាម្ចាស់មានបន្ទូលថា “ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះ*នឹងត្រូវស្លាប់ជាមិនខាន*“ (លោកុប្បត្តិ ២:១៧)។



យើងដឹងអំពីអ្វីដែលបានកើតឡើង។ មនុស្សបានជ្រើសរើសយកការមិនស្តាប់បង្គាប់តាមព្រះអាទិករដែលជាព្រះមហាក្សត្ររបស់ខ្លួន។ លោក អ័ដាម និងនាង អេវ៉ា បានធ្វើបាប។ ប៉ុន្តែ តើពួកគេបានស្លាប់ភ្លាមៗនៅថ្ងៃដដែលនោះដែរឬទេ? ទេ! ដូច្នេះ តើព្រះជាម្ចាស់មានន័យយ៉ាងដូចម្តេច នៅពេលដែលទ្រង់មានបន្ទូលថា “ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន“?

តាមព្រះគម្ពីរ តើសេចក្តីស្លាប់មានអត្ថន័យយ៉ាងដូចម្តេច?



សូមលោកអ្នកមើលមករូបភាពនេះ។ តើមានអ្វីកំពុងកើតឡើងចំពោះមែកឈើ? តើមែកឈើនេះនឹងទៅជាយ៉ាងណា ក្រោយពីវាត្រូវបានបាក់ពីដើម? តើវានឹងនៅរស់ ឬក៏ងាប់? មែកឈើនេះមើលទៅហាក់ដូចជានៅរស់ ប៉ុន្តែវាគង់តែនឹងងាប់ ពីព្រោះវាបានដាច់ចេញពីប្រភពនៃជីវិតហើយ។

សេចក្តីស្លាប់មានន័យថា *ការដាច់ចេញ*។ នេះគឺជាដំណឹងអាក្រក់។

ពេលលោក អ័ដាម និងនាង អេវ៉ា បានជ្រើសរើសទៅតាមផ្លូវរបស់ពួកគេ ជាជាងផ្លូវរបស់ព្រះជាម្ចាស់ នោះពួកគេបានបាត់បង់ទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ ដូចជាមែកឈើដែលបានដាច់ចេញពីដើមផងដែរ។ ទំនាក់ទំនងរបស់ពួកគេជាមួយព្រះជាម្ចាស់ត្រូវបានដាច់ចេញ។ ពួកគេមិនចង់នៅជាមួយទ្រង់ទៀតទេ ដូច្នេះពួកគេបានព្យាយាមពួនពីទ្រង់វិញ។ លោក អ័ដាម និងនាង អេវ៉ា បានស្លាប់ខាងឯវិញ្ញាណហើយ។

> អំពើទុច្ចរិតរបស់អ្នករាល់គ្នា...បានខណ្ឌកណ្តាលអ្នក និងព្រះ ហើយអំពើបាបរបស់អ្នករាល់គ្នាបានបាំងព្រះភក្ត្រព្រះអង្គមិនឲ្យអ្នកឃើញ ហេតុនោះហើយបានជាព្រះអង្គមិនព្រមស្តាប់។
> (អេសាយ ៥៩:២ គកស១៦)

លោក អ័ដាម និងនាង អេវ៉ា ក៏ចាប់ផ្តើមស្លាប់ខាងឯរូបកាយផងដែរ។ ដូចដែលស្លឹកឈើនៅលើមែក



ដែលបាក់ពីដើមមិនក្រៀមស្វិតភ្លាមៗជាយ៉ាងណា នោះរូបកាយរបស់ពួកគេក៏មិនបានត្រឡប់ទៅជាធូលីដី នៅថ្ងៃដែលពួកគេបានធ្វើបាបយ៉ាងនោះដែរ ប៉ុន្តែពួកគេបានចាប់ផ្តើមចាស់ទៅៗ។ សេចក្តីស្លាប់ គឺជាខ្មាំងសត្រូវដែលពួកគេនឹងមិនអាចគេចផុតបានឡើយ។

លើសពីនេះទៅទៀត ដំណឹងអាក្រក់នេះកាន់តែធ្ងន់ទៅៗ។ ប្រសិនបើព្រះជាម្ចាស់មិនបានជួយសង្គ្រោះទេ នោះលោក អ័ដាម និងនាង អេវ៉ា ត្រូវប្រឈមមុខនឹងការដាច់ចេញពីព្រះជាម្ចាស់អស់កល្បជានិច្ច នៅក្នុង "ភ្លើងដែលឆេះអស់កល្បជានិច្ច ដែលបានរៀបចំទុកសំរាប់អារក្ស ហើយនឹងពួកទេវតារបស់វា" (ម៉ាថាយ ២៥:៤១)។

មនុស្សខ្លះសើចចំអកនៅពេលដែលពួកគេឮអំពីស្ថាននរក ដែលជាបឹងភ្លើងសម្រាប់ឃុំព្រលឹងរបស់មនុស្សមានបាបអស់កល្បជានិច្ច។ ប៉ុន្តែ តើការសើចចំអកអំពីរឿងដែលយើងមិនយល់នោះជាការមានប្រាជ្ញាដែរឬទេ? ក្នុងនាមជាមនុស្ស យើងមិនអាចយល់អំពីភាពអស់កល្បជានិច្ចបានឡើយ។ វាគឺជារឿងមួយ ដែលមានលក្ខណៈហួសពីការយល់ដឹងរបស់មនុស្ស។[៤] ពួកមនុស្សពីសម័យដើមក៏បានសើចចំអកឲ្យហោរាណូអេ នៅពេលដែលគាត់កំពុងធ្វើទូកធំ ទាំងព្រមានពួកគេអំពីទឹកជំនន់ជិតមកដល់ ប៉ុន្តែខណៈដែលទ្វារនៃទូកធំត្រូវបានបិទ ហើយទឹកជំនន់បានចាប់ផ្តើម ទើបពួកគេបានយល់ពីសេចក្តីពិត ដែលពួកគេបានសើចចំអកនោះ។ ក្នុងរបៀបស្រដៀងគ្នានេះដែរ ខណៈដែលមនុស្សចូលទៅក្នុងស្ថាននរកភ្លាម ទើបពួកគេនឹងយល់ពីភាពធ្ងន់ធ្ងរនៃកន្លែងនោះ។



> គេនឹងរងទុក្ខទោស ជាសេចក្តីហិនវិនាសអស់កល្បជានិច្ច ឃ្លាតពីព្រះភក្ត្រនៃព្រះអម្ចាស់ ហើយពីសិរីល្អនៃព្រះចេស្តាទ្រង់។ (២ថែស្សាឡូនីច ១:៩)

ព្រះមហាក្សត្រនឹងមិនទុកឲ្យអំពើបាបបំផ្លាញសកលលោករបស់ទ្រង់ជារៀងរហូតទេ។

អំពើបាបមានអំណាចបំផ្លាញ ហើយក៏ជាគ្រោះមហន្តរាយដ៏មានឥទ្ធិពលធំបំផុត នៅលើភពផែនដីរបស់យើង។ អំពើបាប គឺជាមូលហេតុដែលបណ្តាលឲ្យមានសេចក្តីអាក្រក់គ្រប់បែបយ៉ាង។



ដូចជាជំងឺឆ្លង អំពើបាបរបស់លោក អ័ដាម បានឆ្លងមកយើងទាំងអស់គ្នា។ ដូចដែលមែកតូចៗ និងស្លឹកជាប់នឹងមែកដែលបាក់ពីដើមត្រូវងាប់ជាយ៉ាងណា នោះយើងម្នាក់ៗក៏បានរងឥទ្ធិពល ដោយអំពើបាបរបស់លោក អ័ដាម យ៉ាងនោះដែរ។ យើងទាំងអស់គ្នាសុទ្ធតែជាអ្នកដែលជាប់នឹងមែករបស់លោក អ័ដាម។



> តាមរយៈមនុស្សតែម្នាក់ បាបបានចូលមកក្នុងពិភពលោក ហើយតាមរយៈបាប សេចក្តីស្លាប់ក៏ចូលមកដែរ។ ហេតុនេះហើយបានជាសេចក្តីស្លាប់រាលដាលដល់មនុស្សគ្រប់ៗរូប ព្រោះគ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប។ (រ៉ូម ៥:១២ គខប)



មនុស្សនៅសម័យរបស់លោក ម៉ូសេ ក៏មានគំនិតខុសឆ្គង ដូចមនុស្សនៅសម័យនេះដែរ។ ពួកគេបានសង្ឃឹមថា ប្រសិនបើពួកគេធ្វើល្អបានច្រើនជាងអាក្រក់ នោះព្រះជាម្ចាស់នឹងអាណិតមេត្តាដល់ពួកគេនៅថ្ងៃជំនុំជម្រះ។ ដើម្បីកែតម្រូវគំនិតខុសឆ្គងរបស់ពួកគេ នោះព្រះជាម្ចាស់បានយាងចុះមកលើភ្នំស៊ីណាយនៅក្នុងភ្លើងឆេះ ហើយបានប្រទានក្រឹត្យវិន័យទាំង១០ប្រការដល់ពួកគេឲ្យគោរពតាម។ អស់អ្នកណាដែលមិនបានគោរពតាមច្បាប់ទាំង១០ប្រការយ៉ាងល្អឥតខ្ចោះ នោះត្រូវបានរាប់ជាមានទោស ដែលសមនឹងស្លាប់។






ក្រឹត្យវិន័យទាំង១០ប្រការ គឺអាចប្រៀបដូចជាកញ្ចក់។ ប្រសិនបើមុខរបស់អ្នកកខ្វក់ កញ្ចក់នឹងជួយអ្នកឲ្យមើលឃើញភាពកខ្វក់នោះ ប៉ុន្តែវាមិនអាចជួយលុបលាងភាពកខ្វក់នោះបានទេ។ យ៉ាងនោះដែរ ក្រឹត្យវិន័យក៏មិនត្រូវបានប្រទានមកយើង ដើម្បីឲ្យយើងមានភាពសុចរិតនៅចំពោះព្រះជាម្ចាស់នោះទេ។ ផ្ទុយទៅវិញ ក្រឹត្យវិន័យជួយបង្ហាញយើងឲ្យដឹងថា យើងជាមនុស្សមានបាប ដែលជាប់ទោសនៅចំពោះព្រះជាម្ចាស់ដ៏បរិសុទ្ធ។ យើងជាមនុស្សមិនសមនឹងរស់នៅក្នុងនគរដ៏សុចរិតរបស់ទ្រង់ឡើយ។ យើងជាមនុស្សមានបាបគ្មានសង្ឃឹម ដែលត្រូវការព្រះសង្គ្រោះដ៏ល្អឥតខ្ចោះ។

> ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ។ (រ៉ូម ៣:២៣)

ដំណឹងអាក្រក់ គឺថា យើងមិនអាចបំពេញតាមខ្នាតដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់បានទេ។ ដំណឹងល្អ គឺថា មានម្នាក់នៅក្នុងប្រវត្តិសាស្ត្រ ដែលបានបំពេញតាមខ្នាតនោះយ៉ាងល្អឥតខ្ចោះ។

ព្រះនាមរបស់ទ្រង់ គឺព្រះយេស៊ូវ។

## ខ្លឹមសារសំខាន់ៗនៃរឿង • ៣

# ដំណឹងល្អ

ព្រះយេហូវ៉ាទ្រង់ប្រកបដោយសេចក្ដីយុត្តិធម៌ និងសេចក្ដីមេត្តាករុណាដ៏ល្អឥតខ្ចោះ។ សេចក្ដីយុត្តិធម៌មានន័យថា ទ្រង់ត្រូវដាក់ទោសយ៉ាងពេញលេញចំពោះអំពើបាបរបស់ខ្ញុំទៅតាមច្បាប់។ សេចក្ដីមេត្តាករុណាមានន័យថា ទ្រង់មិនដាក់ទោសចំពោះខ្ញុំទៅតាមច្បាប់នោះទេ។ តើព្រះជាម្ចាស់អាចដាក់ទោសចំពោះអំពើបាបរបស់យើង ដោយមិនដាក់ទោសចំពោះយើងយ៉ាងដូចម្ដេច?



ចម្លើយនោះ គឺអាចរកឃើញនៅក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលបានយាងមកដើម្បីជួយសង្គ្រោះយើង។

នៅក្នុងសម័យនៃព្រះគម្ពីរសញ្ញាចាស់ គឺមុនពេលព្រះយេស៊ូវបានយាងមក ព្រះជាម្ចាស់បានរៀបចំ *ច្បាប់នៃតង្វាយលោះបាប* ដើម្បីជួយសង្គ្រោះមនុស្សមានបាបឲ្យរួចពី*ច្បាប់នៃអំពើបាប និងសេចក្ដីស្លាប់*។ ព្រះជាម្ចាស់បានទទួលឈាមនៃសត្វដែលគ្មានទោសជាថ្លៃលោះបាប។ នេះគឺជារបៀបដែលទ្រង់បានដាក់ទោសចំពោះអំពើបាប ដោយមិនដាក់ទោសចំពោះមនុស្សមានបាប។

ប៉ុន្តែ តើកូនចៀមមានតម្លៃស្មើនឹងមនុស្សដែរឬទេ? ទេ! ឈាមនៃសត្វគ្រាន់តែបានបង្ហាញពីអ្វីដែលសេចក្ដីយុត្តិធម៌ពិតជាបានទាមទារប៉ុណ្ណោះ។

តើឈាមប្រភេទណាដែលអាចសងថ្លៃលោះបាបរបស់លោកីយ៍បាន? គឺមានតែឈាមនៃមនុស្សដែលល្អឥតខ្ចោះ និងមានជីវិតគ្មានដែនកំណត់ប៉ុណ្ណោះ។ ព្រះអាទិករដ៏ជាព្រះបន្ទូលបានយាងមកដោយអង្គទ្រង់ផ្ទាល់ ដើម្បីធ្វើជាមនុស្សនោះឯង។



“កាលដើមដំបូងមានព្រះបន្ទូល...។ ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាមហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា។ យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ នឹងសេចក្ដីពិត។“ (យ៉ូហាន ១:១, ១៤)





ឈាមរបស់កូនចៀមគ្រាន់តែបានជួយ*បិទបាំង* អំពើបាបប៉ុណ្ណោះ។ ព្រះយេស៊ូវ គឺជា “កូនចៀមនៃព្រះ ដែល*ដោះ*បាបមនុស្សលោក!“ (យ៉ូហាន ១:២៩)។





តើអ្នកនឹកចាំពីអេបិលដែរឬទេ? ព្រះជាម្ចាស់បានផ្ទុកអំពើបាបរបស់អេបិលទៅលើកូនចៀម។ កូនចៀម គឺជាអ្នកផ្ទុកអំពើបាបរបស់អេបិលជាបណ្ដោះអាសន្ន។ រីឯព្រះយេស៊ូវវិញ គឺជាអ្នកផ្ទុកអំពើបាបរបស់យើងជាអចិន្ត្រៃយ៍។ ព្រះជាម្ចាស់បានផ្ទុកអំពើបាបរបស់យើងទាំងអស់ទៅលើព្រះយេស៊ូវ។







សត្វចៀមដែលត្រូវបានសម្លាប់ ហើយដុតក្លាយជាផេះជំនួសអេបិល គឺជារូបភាពតំណាងឲ្យព្រះយេស៊ូវ ដែលបានសងថ្លៃលោះបាបរបស់យើងយ៉ាងពេញលេញ។ ដោយហេតុនេះ មុននឹងទ្រង់ផុតដង្ហើមទៅ នោះព្រះយេស៊ូវបានបន្លឺសម្លេងនៃជ័យជម្នះថា “ការស្រេចហើយ“ (យ៉ូហាន ១៩:៣០)។

សេចក្ដីយុត្តិធម៌ គឺត្រូវបានបំពេញតាមការទាមទារយ៉ាងសព្វគ្រប់។ សេចក្ដីមេត្តាករុណា គឺត្រូវបានត្រៀមទុកជាស្រេច។

> អ្នករាល់គ្នាកំពុងតែបានសង្គ្រោះ ដោយសារដំណឹងល្អនោះផង គឺបើសិនជាកាន់ខ្ជាប់តាមព្រះបន្ទូល...។ ...ព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ។ ...ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្មរស់ឡើងវិញ ក៏តាមបទគម្ពីរ។ (១កូរិនថូស ១៥:២-៤)

    

ចូរគិតពិចារណាមើលអំពីលោក អ័ប្រាហាំ និងកូនប្រុសរបស់គាត់។ ហេតុអ្វីបានជាព្រះជាម្ចាស់បានបង្គាប់ឲ្យពួកគេទៅថ្វាយយញ្ញបូជា នៅត្រង់ភ្នំដ៏ជាក់លាក់មួយ ដែលនៅឆ្ងាយដល់ម្ល៉េះ?





ព្រះជាម្ចាស់កំពុងប្រទានទីសម្គាល់នៅត្រង់កន្លែង ដែលព្រះរាជបុត្រារបស់ទ្រង់នឹងយាងទៅ ដើម្បីសុគតសម្រាប់អំពើបាបរបស់លោកីយ៍។





ហេតុអ្វីបានជាលោក អ័ប្រាហាំ ដាក់ឈ្មោះភ្នំនោះថា “ព្រះយេហូវ៉ានឹងផ្គត់ផ្គង់“? គឺដោយព្រោះនៅលើភ្នំនោះឯង ដែលព្រះជាម្ចាស់បានផ្គត់ផ្គង់យញ្ញបូជាដ៏ពេញលេញជាចុងក្រោយបង្អស់។





តើព្រះជាម្ចាស់បានផ្គត់ផ្គង់អ្វីសម្រាប់កូនប្រុសរបស់លោក អ័ប្រាហាំ? គឺចៀមឈ្មោលមួយ។ តើព្រះជាម្ចាស់បានផ្គត់ផ្គង់អ្វី ដើម្បីសង្គ្រោះអ្នកពីការជំនុំជម្រះ? គឺព្រះយេស៊ូវដ៏ជាកូនចៀមនៃព្រះ។

តើអ្នកខ្លាចសេចក្ដីស្លាប់ និងការជំនុំជម្រះដែរឬទេ? ប្រសិនបើអ្នកជឿទុកចិត្តទាំងស្រុងលើព្រះយេស៊ូវជាព្រះសង្គ្រោះរបស់អ្នក នោះអ្នកមិនចាំបាច់ភ័យខ្លាចឡើយ ព្រោះព្រះជាម្ចាស់បានទទួលការសងថ្លៃលោះដ៏ពេញលេញពីព្រះយេស៊ូវសម្រាប់អំពើបាបរបស់អ្នក ហើយក៏បានលើកទ្រង់ឡើងឲ្យរស់ពីសុគតឡើងវិញ។

ឥឡូវ ចូរឲ្យយើងគិតត្រឡប់ទៅកាន់លោក អ័ដាម និងនាង អេវ៉ា វិញ។ អំពើបាប និងសេចក្ដីអាម៉ាស់បាននាំឲ្យពួកគេបិទបាំងខ្លួនដោយស្លឹកល្វា ហើយធ្វើឲ្យពួកគេចង់ពួនពីព្រះជាម្ចាស់។ ដោយសេចក្ដីយុត្តិធម៌ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ ព្រះជាម្ចាស់បានបើកចំហឲ្យឃើញនូវអំពើបាបរបស់ពួកគេ ហើយក៏បានបិទបាំងខ្លួនពួកគេ ដោយធ្វើអាវពីស្បែករបស់សត្វ ដែលត្រូវបានថ្វាយជាយញ្ញបូជា។ ឈាមរបស់សត្វដែលត្រូវបង្ហូរចេញ គឺបង្ហាញពីអ្វីដែលត្រូវការជាចាំបាច់ ដើម្បីបិទបាំងអំពើបាបរបស់ពួកគេ រីឯស្បែករបស់សត្វវិញ គឺបង្ហាញពីអ្វីដែលត្រូវការជាចាំបាច់ ដើម្បីបិទបាំងភាពអាម៉ាស់របស់ពួកគេ។

យើងទាំងអស់គ្នាក៏មានចំណែកក្នុងអំពើបាប និងសេចក្ដីអាម៉ាស់របស់ដូនតាយើងផងដែរ។ យើងខ្វះមិនដល់សេចក្ដីសុចរិតរបស់ព្រះជាម្ចាស់។ យើងមិនសមនឹងរស់នៅជាមួយទ្រង់ឡើយ។ ដំណឹងល្អសម្រាប់យើង គឺថា ព្រះយេស៊ូវគ្រីស្ទបានទទួលអំពើបាប និងសេចក្ដីអាម៉ាស់របស់យើងនៅលើឈើឆ្កាងរួចហើយ។ ក្នុងរយៈពេលប៉ុន្មានម៉ោងដ៏ងងឹតនោះ ទ្រង់បានឆ្លងកាត់នូវការដាច់ចេញពីព្រះជាម្ចាស់ដែលយើងសមនឹងទទួល។ បន្ទាប់មក ទ្រង់ក៏បានសុគត ប៉ុន្តែដោយសារទ្រង់គ្មានអំពើបាបរបស់ទ្រង់ផ្ទាល់ នោះផ្នូរមិនអាចឃុំទ្រង់បានឡើយ។

ដោយការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ នោះព្រះជាម្ចាស់បានបើកផ្លូវឲ្យអ្នកអាចទទួលការសម្អាត និងការបិទបាំងខ្លួនរបស់អ្នក គឺដោះដូរអំពើបាបរបស់ អ្នកជាមួយនឹងសេចក្ដីសុចរិតរបស់ទ្រង់។









> ដ្បិតយើងខ្ញុំទាំងអស់គ្នាបានត្រឡប់ទៅដូចជាមនុស្សដែលមិនស្អាត ហើយអស់ទាំងអំពើសុចរិតរបស់យើងខ្ញុំ ក៏ដូចជាអាវកខ្វក់ហើយ...។ (អេសាយ ៦៤:៦)
>
> ខ្ញុំនឹងអរសប្បាយចំពោះព្រះយេហូវ៉ា ព្រលឹងខ្ញុំនឹងរីករាយចំពោះព្រះនៃខ្ញុំ ពីព្រោះទ្រង់បានប្រដាប់ខ្លួនខ្ញុំដោយសំលៀកបំពាក់នៃសេចក្ដីសង្គ្រោះ ទ្រង់បានគ្រលុំខ្ញុំដោយអាវជាសេចក្ដីសុចរិត...។ (អេសាយ ៦១:១០)
>
> ដ្បិតឯព្រះអង្គ ដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្ដីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង។ (២កូរិនថូស ៥:២១)

នៅថ្ងៃជំនុំជម្រះ តើអ្នកនឹងឈរនៅចំពោះព្រះជាម្ចាស់ ដោយពាក់អាវកខ្វក់នៃការខិតខំប្រឹងប្រែងតាមសាសនារបស់អ្នកផ្ទាល់ឬ?

ឬក៏ឈរនៅចំពោះទ្រង់ ដោយពាក់អាវនៃសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទវិញ?

## ខ្លឹមសារសំខាន់ៗនៃរឿង • ៤

# ការឆ្លើយតបរបស់អ្នកចំពោះព្រះមហាក្សត្រ

ចូរស្រមៃមើលថា អ្នកកំពុងដើរកាត់ព្រៃដ៏ស្ងាត់តែម្នាក់ឯង។ តើអ្នកចង់ជួបសត្វមួយណា? កូនចៀម ឬក៏សិង្ហ?



នៅពេលដែលមហាក្សត្រដ៏មានសិរីល្អបានយាងមកជាលើកទីមួយ ទ្រង់ត្រូវបានហៅថា *កូនចៀម*។ ទ្រង់បានយាងមកដោយបន្ទាបអង្គ ទ្រង់ដើម្បីសង្គ្រោះមនុស្សមានបាប។ នៅពេលដែលព្រះមហាក្សត្រយាងត្រឡប់មកវិញ នោះទ្រង់នឹងត្រូវបានហៅថា *សិង្ហ*។ ទ្រង់នឹងយាងមកដោយឫទ្ធានុភាព ដើម្បីជំនុំជម្រះមនុស្សមានបាប ដែលមិនបានប្រែចិត្ត។



នៅពេលដែលព្រះយេស៊ូវយាងមកវិញ តើអ្នកនឹងអរសប្បាយនៅក្នុងវត្តមានរបស់ព្រះសង្គ្រោះដ៏ជាព្រះមហាក្សត្រ ឬក៏ញាប់ញ័រនៅចំពោះមុខចៅក្រមដ៏ជាព្រះមហាក្សត្រវិញ? ទាំងអស់នេះ គឺអាស្រ័យទៅលើការឆ្លើយតបរបស់អ្នកចំពោះព្រះបន្ទូលនៃព្រះជាម្ចាស់។

នៅពេលដែលព្រះយេស៊ូវបានចាប់ផ្តើមចេញទៅបង្រៀន នោះព្រះបន្ទូលដំបូងរបស់ទ្រង់ គឺ៖

> "ចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ!" (ម៉ាកុស ១:១៥)

"ប្រែចិត្ត" មានន័យថា *ផ្លាស់ប្តូរចិត្តគំនិតរបស់អ្នក* អំពីអ្វីដែលអ្នកកំពុងតែជឿទុកចិត្ត ដើម្បីទទួលសិទ្ធិនឹងរស់នៅក្នុងនគររបស់ព្រះជាម្ចាស់។ នេះមានន័យថា អ្នកឈប់ជឿទុកចិត្តលើផ្លូវរបស់អ្នក ហើយចាប់ផ្តើមជឿទុកចិត្តលើផ្លូវរបស់ព្រះជាម្ចាស់ រួចដើរតាមផ្លូវរបស់ទ្រង់វិញ។

"ជឿដំណឹងល្អ" មានន័យថា *ដាក់ជំនឿរបស់អ្នកទៅលើព្រះសង្គ្រោះ* ដែលបានសុគតសម្រាប់អំពើបាបរបស់អ្នក ហើយមានព្រះជន្មរស់ឡើងវិញ ដើម្បីប្រទានជីវិតថ្មីដល់អ្នក។ ប៉ុន្តែ តើការដាក់ជំនឿរបស់អ្នកទៅលើនរណាម្នាក់ នោះមានន័យយ៉ាងដូចម្តេច?

ខ្ញុំសូមពន្យល់ដោយលើកឡើងនូវរឿងពិតមួយ ដែលបានកើតឡើងនៅអាហ្វ្រិកខាងលិច។ រឿងនេះ គឺអំពីស្ត្រីពីរនាក់ឈ្មោះ ហ្វាទូ និងប៊ិនទូ។

ទាំងពីរនាក់បានឆ្លងមេរោគម៉្យាង ដែលបណ្តាលឲ្យមានបញ្ហាក្នុងភ្នែក។ ហ្វាទូបានទៅមន្ទីរពេទ្យ ហើយគ្រូពេទ្យក៏បានឲ្យនាងប្រើថ្នាំបន្តក់ភ្នែកសម្លាប់មេរោគ នោះភ្នែករបស់នាងបានជាសះស្បើយ។ រីឯប៊ិនទូវិញ នាងបានទៅជួបគ្រូបុរាណ ហើយគ្រូនោះក៏បានយកអ្វីដែលគាត់បានផ្សំមកញីលើភ្នែករបស់នាង។ ភ្នែករបស់នាងទៅជាឡើងស ហើយនាងត្រូវបានខ្វាក់ភ្នែកវិញ។

ស្ត្រីទាំងពីរនាក់ឈ្មោះ ហ្វាទូ និងប៊ិនទូមានជំនឿដូចគ្នា។ ទាំងពីរនាក់បានធ្វើតាមជំនឿរបស់ពួកគេរៀងៗខ្លួន ដោយទៅជួបអ្នកព្យាបាលដែលពួកគេបានជឿទុកចិត្ត ក៏ប៉ុន្តែលទ្ធផលដែលពួកគេបានទទួលនោះ គឺខុសគ្នាឆ្ងាយណាស់។

ទាក់ទងនឹងភាពអស់កល្ប មនុស្សម្នាក់ៗមានជំនឿលើអ្វីមួយ ឬក៏នរណាម្នាក់។ មនុស្សជាច្រើនជឿតាមសាសនារបស់ឪពុកម្តាយពួកគេ។ អ្នកខ្លះគាំទ្រពួកមនុស្សដែលអះអាងថា ជីវិតរបស់មនុស្សបញ្ចប់នៅត្រឹមផ្នូរ។ មនុស្សផ្សេងទៀតមានគំនិតផ្ទាល់ខ្លួនអំពីជីវិត សេចក្តីស្លាប់ និងភាពអស់កល្ប។ ទីបំផុត មានសំណួរតែមួយគត់ដែលសំខាន់បំផុត គឺថា តើអ្នកបានជ្រើសរើសយកសេចក្តីពិតដែរឬទេ?

សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំបានសម្រេចចិត្តរួចហើយ គឺខ្ញុំជឿទុកចិត្តលើព្រះមហាក្សត្រ ដែលមានបន្ទូលថា៖

> "អស់អ្នកណាដែលកើតពីសេចក្តីពិត នោះក៏ឮសំឡេងខ្ញុំ។" (យ៉ូហាន ១៨:៣៧)

ព្រះអង្គនោះហើយ គឺជាអ្នកដែលខ្ញុំចង់រស់នៅជាមួយជារៀងរហូត។ ទ្រង់នោះហើយ គឺជាអ្នកដែល "ស្រឡាញ់ខ្ញុំ ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំ" (កាឡាទី ២:២០)។

ទ្រង់មិនមែនគ្រាន់តែជាស្តេចមួយអង្គប៉ុណ្ណោះទេ។ ទ្រង់ គឺជាព្រះមហាក្សត្រ*របស់ខ្ញុំ*!



មនុស្សដំបូងបង្អស់ត្រូវបានបង្កើតមកឲ្យឆ្លុះបញ្ចាំងពីរូបអង្គទ្រង់។ ភាពដូចរូបអង្គទ្រង់នោះត្រូវបានខូចដោយអំពើបាប។ ព្រះយេស៊ូវគ្រីស្ទដែលជា "រូបអង្គនៃព្រះដ៏មើលមិនឃើញ" (កូឡុស ១:១៥) បានយាងមកដើម្បីប្រទានជីវិតថ្មីដល់អ្នក ហើយស្តារនូវភាពដូចរូបអង្គទ្រង់នៅក្នុងអ្នកឡើងវិញ។



បើសិនជាអ្នកបានដាក់ជំនឿរបស់អ្នកទៅលើព្រះយេស៊ូវគ្រីស្ទ ដែលជាមហាក្សត្រដ៏មានសិរីល្អ នោះនៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់ អ្នកមិននៅ *ក្នុងអ័ដាម* ទៀតទេ តែអ្នកបាននៅ *ក្នុងព្រះគ្រីស្ទ* វិញ។ អ្នកគឺជារាស្ត្រនៃនគរស្ថានសួគ៌ ដែលជាទីគាប់ព្រះហឫទ័យ និងជាកូនជាទីស្រឡាញ់របស់ព្រះជាម្ចាស់។ អ្នកគឺជាសម្បត្តិដ៏ពិសេសរបស់ព្រះជាម្ចាស់ផ្ទាល់ ដែលទ្រង់បានសងថ្លៃលោះ ដោយព្រះលោហិតនៃព្រះរាជបុត្រារបស់ទ្រង់។

ក្នុងនាមជាសមាជិកថ្មី ដែលកើតនៅក្នុងគ្រួសាររបស់ព្រះជាម្ចាស់ នោះអ្នកអាចហៅព្រះជាម្ចាស់ថា *ព្រះវរបិតា*។ ប៉ុន្តែ ឯកសិទ្ធិដ៏អស្ចារ្យនេះ ក៏នាំមកនូវទំនួលខុសត្រូវដ៏ធំផងដែរ។

> ចូរធ្វើដូចជាកូនដែលស្តាប់បង្គាប់ គឺមិនត្រូវត្រាប់តាមសេចក្តីប៉ងប្រាថ្នា ដែលពីដើមអ្នករាល់គ្នានៅល្ងង់នោះឡើយ។ ផ្ទុយទៅវិញ ដូចព្រះអង្គដែលបានត្រាស់ហៅអ្នករាល់គ្នា ទ្រង់បរិសុទ្ធយ៉ាងណា ចូរឲ្យអ្នករាល់គ្នាបានបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់យ៉ាងនោះដែរ។
> (១ពេត្រុស ១:១៤-១៥ គកស១៦)

ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវ នោះអ្នកត្រូវបានបង្គាប់ឲ្យចេះអត់ទោស ស្រឡាញ់ និងអធិស្ឋានសម្រាប់មនុស្សទាំងអស់ សូម្បីតែខ្មាំងសត្រូវរបស់អ្នកក៏ដោយ។ ព្រះយេស៊ូវមានបន្ទូលថា៖

> "គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្តីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្តីស្រឡាញ់ដល់គ្នាទៅវិញទៅមក។" (យ៉ូហាន ១៣:៣៥)

កាលណាអ្នកចុះចូលនឹងព្រះអម្ចាស់យេស៊ូវ នោះព្រះវិញ្ញាណរបស់ទ្រង់ (ដែលបានមកសណ្ឋិតក្នុងចិត្តរបស់អ្នក ខណៈដែលអ្នកបានជឿលើដំណឹងល្អ) នឹងជួយអ្នកឲ្យឈ្នះលើអំពើបាប ហើយឆ្លុះបញ្ចាំងពីលក្ខណៈដ៏បរិសុទ្ធរបស់ទ្រង់ផងដែរ។

> ផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត...។ (កាឡាទី ៥:២២-២៣)

ក្នុងនាមជាកូនរបស់ព្រះមហាក្សត្រ អ្នកមានគោលបំណងថ្មីក្នុងជីវិត គឺជាការលើកតម្កើងទ្រង់។ អ្នកគឺជាឯកអគ្គរាជទូតដែលតំណាងទ្រង់ នៅចំពោះលោកីយ៍ដែលបាត់បង់ ដូច្នេះចូរតំណាងទ្រង់ឲ្យបានល្អ។ នៅថ្ងៃមួយ អ្នកនឹងឃើញទ្រង់មុខទល់នឹងមុខ ហើយអ្នក "នឹងបានដូចជាទ្រង់" (១យ៉ូហាន ៣:២)។ រហូតដល់ពេលនោះ ចូរនិយាយទៅកាន់ទ្រង់គ្រប់ពេលវេលា។ ចូរសរសើរតម្កើងទ្រង់ក្នុងគ្រប់ស្ថានភាព។ ចូរថ្វាយបង្គំ ហើយបម្រើទ្រង់ជាមួយនឹងបងប្អូនឯទៀត ដែលស្រឡាញ់ទ្រង់ និងព្រះបន្ទូលរបស់ទ្រង់។ ចូរសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ (ចាប់ផ្តើមពី *កណ្ឌគម្ពីរលូកា យ៉ូហាន កិច្ចការ* និង *រ៉ូម*)។ ព្រះវិញ្ញាណបរិសុទ្ធ គឺជាគ្រូបង្រៀនរបស់អ្នក។ ព្រះគម្ពីរគឺជាអាហារខាងព្រលឹងវិញ្ញាណរបស់អ្នក ហើយក៏ជាអាវុធសម្រាប់តយុទ្ធនឹងសាតាំង ដែលមិនចង់ឲ្យអ្នកគិត និយាយ ឬប្រព្រឹត្តដូចព្រះយេស៊ូវ។ កាលណាអ្នកសញ្ជឹងគិតពីព្រះបន្ទូលនៅក្នុងព្រះគម្ពីរកាន់តែច្រើន នោះអ្នកនឹងកាន់តែរឹងមាំខាងឯវិញ្ញាណ។



ខ្ញុំស្រឡាញ់រូបភាពនេះ ដែលរកឃើញនៅក្នុងខគម្ពីរមួយពីកណ្ឌទំនុកដំកើងដូចខាងក្រោម៖

> ឱព្រះអង្គអើយ ព្រលឹងទូលបង្គំដង្ហក់រកទ្រង់ ដូចជាក្តាន់ញីដង្ហក់រកជ្រោះទឹក។
> (ទំនុកតម្កើង ៤២:១)

តើអ្នកអាចនិយាយយ៉ាងដូច្នេះបានដែរឬទេ?

ជម្រើស គឺជារបស់អ្នក។

*ប៉ុល ប្រាមសិន (Paul D. Bramsen)*
resources@rockintl.org

# សេចក្ដីបន្ថែមពិសេស

ដ្បិតដោយសារព្រះគុណ អ្នករាល់គ្នាបានសង្គ្រោះ
តាមរយៈជំនឿ ហើយសេចក្ដីនេះមិនមែនមកពី
អ្នករាល់គ្នាទេ គឺជាអំណោយទានរបស់ព្រះវិញ
ក៏មិនមែនដោយការប្រព្រឹត្តដែរ ដើម្បីកុំឲ្យអ្នកណាម្នាក់
អួតខ្លួន ដ្បិតយើងជាស្នាព្រះហស្ត ដែលព្រះអង្គបាន
បង្កើតមកក្នុងព្រះគ្រីស្ទយេស៊ូវសម្រាប់ការល្អ ដែលព្រះ
បានរៀបចំទុកជាមុន ដើម្បីឲ្យយើងប្រព្រឹត្តតាម។

ដូច្នេះ ដោយព្រះរាប់យើងជាសុចរិត ដោយសារជំនឿ
នោះយើងមានសន្តិភាពជាមួយព្រះ
តាមរយៈព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង។
តាមរយៈព្រះអង្គ និងដោយសារជំនឿ យើងមានផ្លូវចូល
ទៅក្នុងព្រះគុណនេះ ដែលយើងកំពុងឈរ ហើយយើង
អួតដោយសង្ឃឹមថានឹងមានសិរីល្អរបស់ព្រះ។

— ពីព្រះគម្ពីរសញ្ញាថ្មី

(អេភេសូរ ២:៨-១០; រ៉ូម ៥:១-២ គកស១៦)

# មហាក្សត្រដ៏មានសិរីល្អ
## សំណួររំឭក • ផ្នែកទី១ • ព្រះគម្ពីរសញ្ញាចាស់

នៅក្នុងផ្នែកនេះ មានសំណួរ១ឬ២ សម្រាប់គ្រប់៧០ភាគ។ ចម្លើយសម្រាប់សំណួរទាំងនេះ គឺមាននៅក្នុងអត្ថបទនៃភាគនីមួយៗ។ លោកអ្នកអាចថតចម្លងទំព័រទាំងអស់នេះ យកទៅប្រើប្រាស់សម្រាប់ការសិក្សាជាក្រុម។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ **www.one-god-one-message.com**

*លេខភាគ • សំណួរ*

១ • មហាក្សត្រដ៏មានសិរីល្អត្រូវចំណាយពេលរាប់ពាន់ឆ្នាំ ដើម្បីសម្រេចផែនការរបស់ទ្រង់។ តើការនេះប្រាប់អ្នកឲ្យដឹងថា ព្រះមហាក្សត្រមានលក្ខណៈយ៉ាងដូចម្ដេច?

២ • ព្រះគម្ពីរមាន២ផ្នែកសំខាន់ៗ។ តើផ្នែកទាំង២នោះមានឈ្មោះអ្វីខ្លះ? តើផ្នែកទាំង២នោះខុសគ្នាយ៉ាងដូចម្ដេច?

៣ • តើអ្នកជឿលើខដំបូងនៃព្រះគម្ពីរ (លោកុប្បត្តិ ១:១) ដែរឬទេ? ហេតុអ្វីបានជាអ្នកជឿ ឬមិនជឿ?

៤ • ព្រះជាម្ចាស់មិនដែលគង់នៅឯកានោះទេ សូម្បីតែពេលទ្រង់គង់នៅតែអង្គឯងក៏ដោយ។ តើអ្នកយល់យ៉ាងដូចម្ដេចចំពោះសេចក្ដីថ្លែងការណ៍នេះ?

៥ • តើយើងអាចរៀនពីលក្ខណៈរបស់ព្រះជាម្ចាស់អ្វីខ្លះ កាលណាយើងឃើញរបស់ទាំងប៉ុន្មានដែលទ្រង់បានបង្កើតមក?

៦ • ព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យមានលក្ខណៈខុសពីពពួកសត្វ។ ចូររៀបរាប់អំពីភាពខុសគ្នានោះ។

៧ • ហេតុអ្វីបានជាព្រះជាម្ចាស់មិនបានសួរលោក អ័ដាម ថា តើគាត់ចង់រស់នៅក្នុងសួនច្បារអេដែនដែរឬទេ?

៨ • តើអំពើបាបគឺជាអ្វី? តើព្រះជាម្ចាស់មានបន្ទូលថានឹងមានអ្វីកើតឡើងចំពោះលោក អ័ដាម ប្រសិនបើគាត់មិនស្ដាប់តាមសេចក្ដីបង្គាប់របស់ព្រះជាម្ចាស់នោះ? តើយើងអាចហៅសេចក្ដីស្លាប់បានម្យ៉ាងទៀតថាជាអ្វី?

៩ • ព្រះជាម្ចាស់បានបង្កើតនាង អេវ៉ា ឲ្យចំនឹងរូបអង្គទ្រង់ ដូចទៅនឹងលោក អ័ដាម ផងដែរ។ តើការនេះមានន័យយ៉ាងដូចម្ដេច?

១០ • តើអ្វីជាចំណុចដ៏គួរឲ្យចាប់អារម្មណ៍បំផុតនៅឯស្ថានសួគ៌?

១១ • តើអំពើបាបបានចូលមកក្នុងសកលលោកយ៉ាងដូចម្ដេច?

១២ • តើព្រះយេហូវ៉ាមានបន្ទូលថានឹងមានអ្វីកើតឡើង ប្រសិនបើមនុស្សបរិភោគផ្លែនៃដើមដឹងខុសត្រូវ? រីឯសាតាំងវិញ តើវាបាននិយាយថានឹងមានអ្វីកើតឡើង?

១៣ • តើអំពើបាបបានចូលមកក្នុងមនុស្សជាតិយ៉ាងដូចម្ដេច?

១៤ • តើលទ្ធផលដំបូងនៃអំពើបាបគឺជាអ្វី? តើអំពើបាបរបស់លោក អ័ដាម និងនាង អេវ៉ា បាននាំឲ្យភាពអាម៉ាស់មកជំនួសកិត្តិយសយ៉ាងដូចម្ដេច?

១៥ • នៅត្រង់ថ្ងៃដែលលោក អ័ដាម និងនាង អេវ៉ា បានធ្វើបាប តើពួកគេបានស្លាប់ក្នុងលក្ខណៈបែបណា? តើពួកគេដូចទៅនឹងមែកឈើដែលបាក់ពីដើមយ៉ាងដូចម្ដេច? (សូមអានទំព័រ១៦០បន្ថែមទៀត)

១៦ • ចូររៀបរាប់អំពីរបៀបដែលបណ្ដាសានៃអំពើបាបបានបង្ខូចអ្វីៗ ដែលព្រះជាម្ចាស់បង្កើតពីដើមមក។

១៧ • ហេតុអ្វីបានជាអ្នកគិតថា ផែនការដ៏អាថ៌កំបាំងរបស់ព្រះជាម្ចាស់ តម្រូវឲ្យមានព្រះសង្គ្រោះដែលជាពូជរបស់ស្ត្រី (ដែលមានម្ដាយជាមនុស្ស តែគ្មានឪពុកជាមនុស្ស)?

១៨ • តើព្រះជាម្ចាស់បានធ្វើអ្វី ដើម្បីបិទបាំងអំពើបាប និងភាពអាម៉ាស់របស់លោក អ័ដាម និងនាង អេវ៉ា? តើព្រះជាម្ចាស់បានបង្ហាញឲ្យពួកគេដឹងថា ទ្រង់ជាព្រះដ៏មានសេចក្តីយុត្តិធម៌ សេចក្តីមេត្តាករុណា និងព្រះគុណយ៉ាងដូចម្តេច?

១៩ • ហេតុអ្វីបានជាព្រះជាម្ចាស់បណ្តេញលោក អ័ដាម និងនាង អេវ៉ា ឲ្យចេញពីសួនច្បារអេដែន?

២០ • តើអំពើបាបរបស់លោក អ័ដាម និងនាង អេវ៉ា បានជះឥទ្ធិពលចំពោះកូនៗរបស់ពួកគេយ៉ាងដូចម្តេច? តើវាមានឥទ្ធិពលចំពោះយើង និងគ្រួសាររបស់យើងយ៉ាងដូចម្តេច? (សូមអានទំព័រ១៦១បន្ថែមទៀត)

២១ • តើព្រះជាម្ចាស់ទទួលយកកូនចៀមប្រភេទណាឲ្យងាប់ជំនួសមនុស្សមានបាប?

២២ • តើពាក្យថា *ជួន* មានន័យយ៉ាងដូចម្តេច? ហេតុអ្វីបានជារបៀបនៃការអត់ទោសរបស់ព្រះជាម្ចាស់ ទាមទារឲ្យមានការសងថ្លៃលោះដោយសេចក្តីស្លាប់?

២៣ • តើព្រះជាម្ចាស់បានធ្វើយ៉ាងដូចម្តេច ចំពោះអំពើបាបរបស់អេបិល? តើតង្វាយរបស់កាអ៊ីនមានបញ្ហាអ្វី?

២៤ • តើការប្រែចិត្តមានន័យយ៉ាងដូចម្តេច? តើព្រះជាម្ចាស់ចង់ឲ្យកាអ៊ីនធ្វើអ្វី?
តើកាអ៊ីនបានធ្វើយ៉ាងដូចម្តេចវិញ?

២៥ • តើទឹកជំនន់ទូទាំងពិភពលោកនៅសម័យលោក ណូអេ បង្រៀនដល់យើងអ្វីខ្លះ ស្តីអំពីការអត់ធ្មត់ និងការជំនុំជម្រះរបស់ព្រះជាម្ចាស់?

២៦ • តើលោក ណូអេ និងគ្រួសាររបស់គាត់បានធ្វើអ្វីមុនគេ ក្រោយពីពួកគេបានចេញពីទូកធំនោះមក?

២៧ • តើរឿងប៉មបាបិលបង្ហាញពីលក្ខណៈរបស់មនុស្សកាន់តាមសាសនាក្លែងក្លាយយ៉ាងដូចម្តេច?

២៨ • តើព្រះយេហូវ៉ាបានសន្យានឹងធ្វើការដ៏អស្ចារ្យ២យ៉ាងអ្វីខ្លះ ប្រសិនបើលោក អ័ប្រាហាំ ទុកចិត្ត និងធ្វើតាមទ្រង់?

២៩ • ហេតុអ្វីបានជាព្រះជាម្ចាស់អត់ទោសបាបរបស់លោក អ័ប្រាហាំ និងនាង សារ៉ា
ហើយរាប់ពួកគេជាសុចរិត?

៣០ • តើកូនប្រុសរបស់លោក អ័ប្រាហាំ បានសួរឪពុកពីរឿងអ្វី ខណៈដែលពួកគេកំពុងឡើងលើភ្នំមួយ ដើម្បីថ្វាយយញ្ញបូជា?

៣១ • ព្រះជាម្ចាស់បានសន្យាថា ទ្រង់នឹងធ្វើឲ្យអ៊ីសាកក្លាយជាឪពុកនៃសាសន៍មួយថ្មី។ លោក អ័ប្រាហាំ បានដឹងថា ព្រះជាម្ចាស់មិនអាចកុហកបានទេ បើដូច្នេះ តើគាត់បានគិតថា ព្រះជាម្ចាស់នឹងធ្វើអ្វី ក្រោយពីគាត់បានថ្វាយអ៊ីសាកជាយញ្ញបូជានៅលើអាសនា?

៣២ • ហេតុអ្វីបានជាលោក អ័ប្រាហាំ ដាក់ឈ្មោះភ្នំនោះថា *ព្រះយេហូវ៉ា**នឹង**ផ្គត់ផ្គង់*? នៅថ្ងៃនោះ តើ *កូនចៀម* ដែលលោក អ័ប្រាហាំ បានលើកឡើងនោះបានងាប់ជំនួសកូនរបស់គាត់ដែរឬទេ?

៣៣ • តើព្រះយេហូវ៉ាបំពេញតាមសេចក្តីសន្យាធំៗទាំងពីរចំពោះលោក អ័ប្រាហាំ យ៉ាងដូចម្តេច?

៣៤ • ប្រសិនបើយើងព្យាយាមធ្វើតាមបញ្ញត្តិរបស់ព្រះជាម្ចាស់ តើយើងអាចល្អគ្រប់គ្រាន់ ដើម្បីរស់នៅជាមួយព្រះជាម្ចាស់នៅស្ថានសួគ៌ដែរឬទេ? តើក្រឹត្យវិន័យទាំង១០ប្រការអាចប្រៀបដូចជាកញ្ចក់យ៉ាងដូចម្តេច?
តើក្រឹត្យវិន័យទាំងនោះបង្ហាញថា យើងត្រូវការព្រះសង្គ្រោះយ៉ាងដូចម្តេច?

៣៥ • ហេតុអ្វីបានជាការថ្វាយយញ្ញបូជាសត្វ មិនអាចដោះបាបរបស់លោកីយ៍បាន?

៣៦ • ចូរជ្រើសរើសទំនាយមួយនៅក្នុងរូបភាពក្រាំង ហើយពន្យល់អំពីរបៀបដែលទំនាយនោះចង្អុលបង្ហាញពីព្រះសង្គ្រោះដែលត្រូវយាងមក។

# សំណួររំឭក • ផ្នែកទី២ • ព្រះគម្ពីរសញ្ញាថ្មី

៣៧ • ហេតុអ្វីបានជាព្រះជាម្ចាស់ប្រើមនុស្ស៤នាក់ (ជាជាងមនុស្សតែម្នាក់) ដើម្បីសរសេរដំណឹងល្អអំពីព្រះយេស៊ូវ?

៣៨ • ហេតុអ្វីបានជាទេវតា កាព្រីយ៉ែល ហៅព្រះយេស៊ូវថា *ព្រះរាជបុត្រានៃព្រះ?*

៣៩ • តើព្រះនាមថា *យេស៊ូវ* មានន័យយ៉ាងដូចម្តេច?

៤០ • តើអ្នកចូលចិត្តចំណុចមួយណាជាងគេ នៅក្នុងរឿងប្រសូតរបស់ព្រះយេស៊ូវ?

៤១ • ទេវតាបានប្រាប់ដល់ពួកអ្នកគង្វាលថា "មានព្រះសង្គ្រោះ១អង្គ ប្រសូតដល់អ្នករាល់គ្នា...គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់"។ ហេតុអ្វីបានជាពួកអ្នកគង្វាលមានចិត្តរំភើប នៅពេលដែលពួកគេបានឮដំណឹងនេះ?

៤២ • ពួកហោរាបានថ្វាយបង្គំដល់ព្រះយេស៊ូវជាបុត្រតូច។ តើនេះជាការត្រឹមត្រូវដែរឬទេ? ហេតុអ្វី?

៤៣ • តើព្រះយេស៊ូវជាកុមារមានលក្ខណៈខុសពីក្មេងៗដទៃទៀតយ៉ាងដូចម្តេច?

៤៤ • តើសារដែលហោរា យ៉ូហាន បានប្រកាសនោះ មានលក្ខណៈខុសពីសាររបស់ពួកហោរាសម័យមុនៗយ៉ាងដូចម្តេច? ហេតុអ្វីបានជាអ្នកគិតថា លោក យ៉ូហាន បានចង្អុលទៅព្រះយេស៊ូវ ហើយនិយាយថា "នុ៎ះន៏ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក"?

៤៥ • ចូរអានភាគនេះម្តងទៀត ហើយរៀបរាប់ពីអ្វីដែលអ្នកបានរកឃើញតាមរយៈព្រះគម្ពីរ ទាក់ទងនឹងព្រះវិញ្ញាណនៃព្រះ ព្រះរាជបុត្រានៃព្រះ និងព្រះវរបិតានៅឯស្ថានសួគ៌។

៤៦ • ហេតុអ្វីបានជាសាតាំងព្យាយាមល្បួងព្រះយេស៊ូវឲ្យធ្វើបាប?

៤៧ • ក្រោយពីព្រះយេស៊ូវបានអានពីគម្ពីរហោរា អេសាយ នោះទ្រង់មានបន្ទូលថា "នៅថ្ងៃនេះ បទគម្ពីរនេះបានសំរេចនៅត្រចៀកអ្នករាល់គ្នាហើយ!"។ ហេតុអ្វីបានជាអ្នកគិតថា ពាក្យនេះបានធ្វើឲ្យមនុស្សនៅជុំវិញទ្រង់ខឹងខ្លាំងដល់ម្ល៉េះ?

៤៨ • តើព្រះយេស៊ូវបានធ្វើជា *ព្រះពាហុនៃព្រះជាម្ចាស់* នៅលើផែនដីយ៉ាងដូចម្តេច? ហេតុអ្វីបានជាពួកអារក្សខ្លាចព្រះយេស៊ូវ?

៤៩ • ក្រោយពេលព្រះយេស៊ូវបានបង្គាប់ទៅខ្យល់ថា "ចូរស្ងប់ ហើយស្ងៀមទៅ!" នោះពួកសិស្សបាននិយាយថា "ចុះតើលោកនេះជានរណាដែលសូម្បីតែខ្យល់ និងសមុទ្រក៏ស្តាប់បង្គាប់លោកដូច្នេះ?"។ តើ*អ្នក*គិតថា ព្រះយេស៊ូវជានរណា?

៥០ • ហេតុអ្វីបានជាពួកអ្នកដឹកនាំសាសនាចោទប្រកាន់ព្រះយេស៊ូវថា ទ្រង់បានពោលពាក្យប្រមាថដល់ព្រះ?

៥១ • ព្រះយេស៊ូវមានបន្ទូលថា "ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ"។ តើយើងដឹងថា ព្រះបន្ទូលរបស់ទ្រង់ជាការពិតដោយសារអ្វី?

៥២ • តើព្រះយេស៊ូវមានបន្ទូលយ៉ាងដូចម្តេច ទៅកាន់ពួកមនុស្សដែលបានឃើញការអស្ចារ្យ ហើយត្រឡប់មកវិញនៅថ្ងៃបន្ទាប់ ដោយចង់បានអាហារបន្ថែមទៀត?

៥៣ • ចូរអានភាគនេះម្តងទៀត ហើយរៀបរាប់ពីចំណុចមួយនៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូវ ដែលបានធ្វើឲ្យអ្នកមានការអស្ចារ្យក្នុងចិត្ត។

៥៤ • ពួកហោរាបានហៅព្រះមេស្ស៊ីថា "ព្រះអាទិត្យនៃសេចក្តីសុចរិត"។ ព្រះយេស៊ូវក៏បានហៅអង្គទ្រង់ថា "ពន្លឺលោកីយ"។ តើព្រះយេស៊ូវដ៏ជាព្រះមេស្ស៊ីខុសពីពួកហោរាយ៉ាងដូចម្តេច?

៥៥ • តើពួកសិស្សបានគិតថា ព្រះមេស្ស៊ីគួរតែធ្វើអ្វី? តើព្រះមេស្ស៊ីបានយាងមកដើម្បីធ្វើអ្វី?

៥៦ • ហេតុអ្វីបានជាព្រះអម្ចាស់យេស៊ូវយាងចូលក្រុងយេរូសាឡិម ដោយគង់លើសត្វលាដ៏ស្លូតមួយ ជំនួសសេះសង្គ្រាមដ៏ខ្លាំងក្លា?

៥៧ • ហេតុអ្វីបានជាពួកអ្នកដឹកនាំសាសនា មិនអាចបញ្ឆោតព្រះយេស៊ូវឲ្យមានបន្ទូលខុសបាន?

៥៨ • ហេតុអ្វីបានជាសម្តេចសង្ឃ និងពួកអ្នកដឹកនាំសាសន៍យូដានិយាយថា ព្រះយេស៊ូវគួរតែស្លាប់?

៥៩ • ហេតុអ្វីបានជាលោក ពីឡាត់ កាត់ទោសសម្លាប់ព្រះយេស៊ូវ?

៦០ • ពួកទាហានបានយកភួងបន្លាមកបំពាក់លើព្រះសិររបស់ព្រះយេស៊ូវ។ តើបន្លារំឭកយើងអំពីអ្វី?

៦១ • តើទំនាយរបស់លោក អ័ប្រាហាំ បានសម្រេចតាមរយៈព្រះយេស៊ូវយ៉ាងដូចម្តេច? តើអ្នកមានតម្លៃប៉ុណ្ណាចំពោះព្រះជាម្ចាស់?

៦២ • ចោរពីរនាក់បានជាប់ឆ្កាងនៅសងខាងព្រះយេស៊ូវ។ ឥឡូវនេះ ចោរម្នាក់នៅក្នុងស្ថាននរក (ដាច់ចេញពីព្រះអម្ចាស់អស់កល្បជានិច្ច) ហើយម្នាក់ទៀតនៅក្នុងស្ថានសួគ៌វិញ (ជាមួយព្រះអម្ចាស់អស់កល្បជានិច្ច)។ តើអ្វីទៅដែលបានធ្វើឲ្យមានភាពខុសគ្នាយ៉ាងដូច្នេះ?

៦៣ • ខណៈដែលព្រះអម្ចាស់យេស៊ូវជាប់នៅលើឈើឆ្កាងក្នុងភាពងងឹត តើព្រះវរបិតាដែលគង់នៅស្ថានសួគ៌បានផ្ទុកអ្វីនៅលើទ្រង់? ហេតុអ្វីបានជាព្រះយេស៊ូវមានបន្ទូលថា "ការស្រេចហើយ"? ហេតុអ្វីបានជាព្រះជាម្ចាស់ហែកវាំងននក្នុងព្រះវិហារជាពីរ?

៦៤ • តើពួកសិស្សបានចងចាំការសន្យារបស់ព្រះយេស៊ូវថា ទ្រង់នឹងមានព្រះជន្មរស់ឡើងវិញដែរឬទេ? ចំណែកឯពួកអ្នកដឹកនាំសាសនាដ៏អាក្រក់វិញ តើពួកគេបានចងចាំការសន្យារបស់ទ្រង់ដែរឬទេ?

៦៥ • តើពួកស្ត្រីបានឃើញអ្វី កាលពួកគេបានទៅដល់ផ្នូរនៅព្រឹកថ្ងៃអាទិត្យ? តើពួកអ្នកដឹកនាំសាសនាបានធ្វើអ្វី កាលពួកគេបានដឹងថាផ្នូរនៅទទេ? ហេតុអ្វីបានជាអ្នកមិនចាំបាច់ភ័យខ្លាចចំពោះសេចក្តីស្លាប់ ប្រសិនបើអ្នកទុកចិត្តទាំងស្រុងលើព្រះយេស៊ូវដ៏ជាកូនចៀមនៃព្រះ ដែលបានសុគតសម្រាប់អំពើបាបរបស់អ្នក ហើយក៏មានព្រះជន្មរស់ឡើងវិញ?

៦៦ • ហេតុអ្វីបានជាព្រះអម្ចាស់យេស៊ូវហៅអ្នកដំណើរពីរនាក់ នៅតាមផ្លូវទៅកាន់ភូមិអេម៉ោសថា ពួកគេជាមនុស្សឥតពិចារណា?

៦៧ • កាលព្រះសង្គ្រោះមានព្រះជន្មរស់ឡើងវិញ ទ្រង់បានលេចមកនៅក្នុងបន្ទប់ នោះលោក ថូម៉ាស បានទូលទ្រង់ថា "ឱព្រះអម្ចាស់ទូលបង្គំ ឱព្រះនៃទូលបង្គំអើយ!"។ តើលោក ថូម៉ាស បាននិយាយត្រូវឬខុស ដែលគាត់ហៅព្រះយេស៊ូវថាជាព្រះអម្ចាស់ និងជាព្រះរបស់គាត់? ហេតុអ្វី?

៦៨ • មុនពេលព្រះយេស៊ូវយាងត្រឡប់ទៅឯស្ថានសួគ៌វិញ តើព្រះយេស៊ូវមានបន្ទូលប្រាប់ពួកសិស្សឲ្យធ្វើអ្វីបន្តទៀត?

៦៩ • តើមហាក្សត្រដ៏មានសិរីល្អជាអ្នកណា? តើអ្នកគិតយ៉ាងដូចម្តេចអំពីទ្រង់?

៧០ • នៅពេលដែលព្រះមហាក្សត្រនេះយាងត្រឡប់មកវិញ តើអ្នកនឹងមានចិត្តអរសប្បាយ ឬក៏ភ័យខ្លាច? ហេតុអ្វី?

# មហាក្សត្រដ៏មានសិរីល្អ

# កំណត់យោង

**បុព្វកថារបស់អ្នកនិពន្ធ៖** [១]សៀវភៅ *ដំណើរផ្សងព្រេងរបស់អាលីសនៅទឹកដីដ៏អស្ចារ្យ* ត្រូវបានបកប្រែជិត២០០ភាសា ប៉ុន្តែ *ព្រះគម្ពីរបរិសុទ្ធ* ទាំងមូល ឬដោយផ្នែក ត្រូវបានបកប្រែជាង២៥០០ភាសា។

[២]ព្រះគម្ពីរត្រូវបានបញ្ជាក់បង្ហាញពីភាពពិត តាមរយៈបុរាណវត្ថុវិទ្យា ប្រវត្តិសាស្ត្រពិភពលោក ទំនាយដែលបានសម្រេច និងភាពស៊ីសង្វាក់គ្នាយ៉ាងល្អឥតខ្ចោះនៃសាច់រឿងដ៏ស្មុគស្មាញ ដែលត្រូវបានកត់ត្រាក្នុងរយៈពេលជិត២០០០ឆ្នាំ។

**ភាគទី២៖** [៣]ព្រះមហាក្សត្រមិនត្រឹមតែជាព្រះអាទិករ និងជាអ្នកទ្រទ្រង់សកលលោកទាំងមូលប៉ុណ្ណោះទេ ទ្រង់ក៏ជាអ្នកនិពន្ធ និងជាអ្នកការពារសៀវភៅរបស់ទ្រង់ផងដែរ។ ក្រាំងនៃសមុទ្រស្លាប់បានបញ្ជាក់បង្ហាញថា ព្រះគម្ពីរសញ្ញាចាស់ដែលយើងប្រើប្រាស់នៅសព្វថ្ងៃនេះ គឺដូចទៅនឹងព្រះគម្ពីរដែលមានតាំងពីមុនសម័យព្រះគ្រីស្ទមកម្ល៉េះ។ ព្រះគម្ពីរសញ្ញាថ្មីក៏ត្រូវបានបញ្ជាក់បង្ហាញពីភាពពិតដោយឯកសារពីបុរាណរាប់ពាន់ច្បាប់ ដែលភាគច្រើនមានតាំងពីដើមសតវត្សរ៍ ក្រោយពីព្រះគ្រីស្ទបានប្រសូតមក។ ការអះអាងដ៏ពេញនិយមដែលថា អត្ថបទដើមត្រូវបានកែប្រែ ហើយបំផ្លាញដោយមនុស្ស នោះគ្មានមូលដ្ឋានពិតទេ។ សម្រាប់ពត៌មានបន្ថែម សូមអានជំពូកទី៣នៃសៀវភៅ *One God One Message* (www.one-god-one-message.com)។

**ភាគទី៥៖** [៤]សម្រាប់ការពន្យល់ដ៏លម្អិតអំពីលក្ខណៈសម្បត្តិនៃព្រះជាម្ចាស់ ដែលយើងអាចរកឃើញតាមរយៈការបង្កើតក្នុងពេល៦ថ្ងៃនោះ សូមអានជំពូកទី៨នៃសៀវភៅ *One God One Message*។

**ភាគទី៦៖** [៥]ប្រសិនបើព្រះជាម្ចាស់ គឺជាព្រះតែមួយ នោះហេតុអ្វីបានជាទ្រង់មានបន្ទូលថា “ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង...“? ចម្លើយនោះ គឺមានបង្កប់នៅក្នុងការរួបរួមដ៏ស្មុគស្មាញរបស់ទ្រង់។ នៅក្នុងព្រះគម្ពីរ ពាក្យថា “ព្រះជាម្ចាស់“ ក្នុងភាសាហេព្រើរ គឺ អេឡូហ៊ីម *(Elohim)* ដែលជានាមសំដៅទៅលើចំនួនលើសពីមួយ។ សម្រាប់ពាក្យថា “មួយ“ នៅក្នុងឃ្លា “ទ្រង់ជាព្រះតែ១“ គឺ *អេឆាត (echad)* ដែលបង្ហាញពីការរួបរួមនៃសមាសភាព។ នៅក្នុងភាពអស់កល្ប មុនពេលទ្រង់បានបង្កើតពួកទេវតា ឬមនុស្ស នោះព្រះជាម្ចាស់មានអំណរនឹងប្រកបនៅក្នុងអង្គទ្រង់ គឺជាមួយព្រះរាជបុត្រាដ៏ជាព្រះបន្ទូលរបស់ទ្រង់ និងព្រះវិញ្ញាណបរិសុទ្ធ។ "ព្រះជាម្ចាស់ជាព្រះដ៏ឧត្តម ដែលយើងពុំអាចស្វែងយល់បានឡើយ" (ហោរា យ៉ូប ៣៦:២៦)។

**ភាគទី៦ និង៧៖** [៦]ធាតុគីមីដែលផ្សំឡើងជារាងកាយរបស់មនុស្ស គឺរកឃើញមានទាំងអស់ នៅក្នុងធូលីដីរបស់ផែនដី។ ការពិតនេះមិនត្រូវបានទទួលស្គាល់ដោយវិទ្យាសាស្ត្រនោះទេ ប៉ុន្តែមកដល់ពេលថ្មីៗនេះ ទើបគេទទួលស្គាល់។ អ្នកវិទ្យាសាស្ត្រភាគច្រើនទទួលបានចំណេះដឹង ដោយពឹងផ្អែកទៅលើការសង្កេត និង*ទ្រឹស្តី* (ជាគំនិតរបស់មនុស្ស) ប៉ុន្តែអ្នកជឿលើព្រះគម្ពីរវិញ គឺពឹងផ្អែកទៅលើការសង្កេត និង*ការបើកសម្តែង* (ជាព្រះបន្ទូលរបស់ព្រះ)។

**ភាគទី១១៖** [៧]សម្រាប់ពត៌មានបន្ថែមអំពីប្រភពដើមរបស់សាតាំង សូមអានជំពូកទី១១នៃសៀវភៅ *One God One Message*។

**ភាគទី១៦៖** [៨]ប្រសិនបើបឹងភ្លើងដែលជាកន្លែងដាក់ទណ្ឌកម្មអស់កល្បជានិច្ចនោះ មើលទៅដូចជាអយុត្តិធម៌ ឬមិនសមហេតុផលនោះប្រហែលជាអ្នកមិនទាន់បានយល់ច្បាស់ អំពីភាពបរិសុទ្ធដែលមិនផ្លាស់ប្រែរបស់ព្រះជាម្ចាស់ លក្ខណៈដ៏នៅអស់កល្បរបស់មនុស្ស ភាពធ្ងន់ធ្ងរនៃអំពើបាប និងភាពអស់កល្បនៅឡើយទេ។ ពាក្យថា *ភាពអស់កល្ប* គឺជារឿងដែលហួសពីគំនិតរបស់យើងដោយសារការយល់ដឹងរបស់យើងកំណត់ដោយពេលវេលា។ ភាពអស់កល្ប គឺជាភាពអចិន្ត្រៃយ៍។ ព្រះជាម្ចាស់ដែលជាអ្នកបង្កើតពេលវេលាមកមិនកំណត់ដោយពេលវេលាទេ (២ពេត្រុស ៣:៨-៩)។ ភាពអស់កល្ប គឺមិនអាចរាប់ជាឆ្នាំបានទេ។ សូមគិតយ៉ាងដូច្នេះវិញថា ភាពអស់កល្បគឺជា *ពេលវេលាឥឡូវនេះ ដែលគ្មានទីបញ្ចប់*។ ខណៈដែលមនុស្សមានបាបចូលទៅក្នុងកន្លែង ដែលគេមិនអាចគេចផុតបាននោះ ទើបពួកគេនឹងយល់ពីភាពធ្ងន់ធ្ងររបស់វា។

**ភាគទី១៧៖** [៩]ការលោះ(ឬ ប្រោសលោះ)មានន័យថា *ទិញមកវិញដោយការបង់ថ្លៃដែលត្រូវបានទាមទារ*។ នៅក្នុងជំពូកទី១៨នៃសៀវភៅ *One God One Message* អ្នកនិពន្ធបានបកស្រាយពីចំណុចនេះ ដោយលើកឡើងពីរឿងរបស់គាត់ផ្ទាល់ ដែលបានកើតឡើង កាលពីគាត់នៅតូច៖

ពេលខ្ញុំនៅក្មេង ខ្ញុំបានរស់នៅរដ្ឋកាលីហ្វ័រញ៉ា ហើយក៏បានចិញ្ចឹមឆ្កែតូចមួយ។ ខ្ញុំបានឲ្យចំណីវា ថែទាំវា ហើយលេងជាមួយវា។ វាបានទៅតាមខ្ញុំគ្រប់ទីកន្លែង ហើយក៏បានបង្ហាញអារម្មណ៍រំភើប ពេលខ្ញុំមកពីសាលាវិញ។ ប៉ុន្តែ វាមានបញ្ហាមួយ គឺពេលខ្លះ វាបានរត់ទៅក្រៅផ្ទះបាត់ៗ។ ទោះជាយ៉ាងណា វាតែងតែត្រឡប់មកផ្ទះវិញ។

ប៉ុន្តែ នៅថ្ងៃមួយ ពេលខ្ញុំចេញពីសាលាមកផ្ទះវិញ នោះឆ្កែរបស់ខ្ញុំមិនបានចេញមកទទួលខ្ញុំទេ។ ដល់ម៉ោងចូលគេងហើយ ខ្ញុំនៅតែរកវាមិនឃើញសោះ។ នៅថ្ងៃបន្ទាប់ ឪពុករបស់ខ្ញុំបានឲ្យខ្ញុំទាក់ទងទៅមណ្ឌលឃុំឃាំងសត្វនៅតំបន់នោះ ដែលជាកន្លែងមើលថែសត្វ ដូចជាឆ្មា និងឆ្កែដែលវង្វេងជាបណ្តោះអាសន្ន។ សត្វដែលគ្មានម្ចាស់ត្រូវបានគេសម្លាប់ចោល។

ខ្ញុំបានទាក់ទងទៅកន្លែងនោះ ហើយគេពិតជាមានឆ្កែតូចមួយ ដែលដូចទៅនឹងការពិពណ៌នារបស់ខ្ញុំមែន។ អ្នកដើរចាប់ឆ្កែនៅទីក្រុងនោះបានចាប់វាយកទៅ។ ឆ្កែរបស់ខ្ញុំបានស្ថិតនៅក្នុងស្ថានភាព ដែលជួយខ្លួនឯងមិនបាន។ បើសិនជាគ្មានអ្នកណាមកជួយវាទេ នោះវានឹងត្រូវគេចាក់ថ្នាំសម្លាប់។

ខ្ញុំបានទៅកន្លែងដែលវាត្រូវបានឃុំឃាំងនោះ ហើយបានសុំយកឆ្កែរបស់ខ្ញុំមកវិញ! ប៉ុន្តែ បុគ្គលិកដែលធ្វើការនៅទីនោះបានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំចង់យកវាទៅវិញ ខ្ញុំត្រូវបង់ពិន័យជាមុនសិន។ ការបណ្តោយឲ្យសត្វឆ្កែរត់ពេញផ្លូវតាមតែចិត្ត គឺខុសច្បាប់។

ខ្ញុំបានបង់ថ្លៃដែលគេទាមទារ ហើយទីបំផុត ឆ្កែរបស់ខ្ញុំត្រូវបានដោះលែង។ វាពិតជាអរណាស់ ដែលបានចេញពីទ្រុងដ៏តូចចង្អៀតនោះ ហើយត្រឡប់មកផ្ទះវិញជាមួយនឹងអ្នកជួយមើលថែវា! វាត្រូវបានលោះ។

បទពិសោធន៍របស់ខ្ញុំពីតូចក្នុងការបង់ថ្លៃលោះសម្រាប់ឆ្កែដែលបាត់ដើម្បីយកវាមកវិញនេះ ក៏អាចជួយយើងឲ្យយល់ខ្លះៗអំពីស្ថានភាពរបស់យើងផងដែរ។ ក្នុងនាមជាមនុស្សដែលបានបះបោរ ហើយជាប់ទោស យើងមិនអាចជួយសង្គ្រោះខ្លួនយើងឲ្យរួចពីទោសនៃអំពើបាប ព្រមទាំងអំណាចរបស់អំពើបាប និងសេចក្តីស្លាប់បានឡើយ។

យើងត្រូវការព្រះសង្គ្រោះដែលអាចបង់ថ្លៃលោះ។

**ភាគទី២៣៖** [១០]អ្វីដែលអាចកើតឡើងនោះ គឺព្រះជាម្ចាស់បង្ហាញការសព្វព្រះហឫទ័យចំពោះតង្វាយរបស់អេបិល ដូចដែលទ្រង់បានធ្វើនៅសម័យហោរា ម៉ូសេ សាឡូម៉ូន និងអេលីយ៉ា៖ “មានភ្លើងចេញពីចំពោះព្រះយេហូវ៉ា មកបញ្ឆេះដង្វាយដុត នឹងខ្លាញ់នៅលើអាសនា“ (លេវីវិន័យ ៩:២៤; ២របាក្សត្រ ៧:១; ១ពង្សាវតារក្សត្រ ១៨:៣៨)។

**ភាគទី៣០ និង៦១៖** [១១]ម៉ូរីយ៉ា មានន័យថា *ព្រះជាម្ចាស់បានជ្រើសរើស*។ នេះជាតំបន់ដែលក្រុងយេរូសាឡិមត្រូវបានសាងសង់ឡើងនៅពេលក្រោយ។ នៅសព្វថ្ងៃនេះ ភ្នំម៉ូរីយ៉ា គឺជាកន្លែងដែលធ្លាប់មានព្រះវិហាររបស់ស្តេច សាឡូម៉ូន (២របាក្សត្រ ៣:១)។ នៅជួរភ្នំដដែលមិនឆ្ងាយពីទីនោះ គឺជា“កន្លែងដែលហៅថា ភ្នំលលាដ៏ក្បាល“ (លូកា ២៣:៣៣ គកស១៦)។

**ភាគទី៣៦៖** [១២]ទំនាយទាំងប៉ុន្មានដែលបានសម្រេចហើយនោះ ធ្វើឲ្យព្រះគម្ពីរមានលក្ខណៈខុសគ្នាដាច់ពីអស់ទាំងសៀវភៅដទៃទៀតនៅក្នុងពិភពលោក។ ទំនាយរបស់ពួកហោរាអំពីព្រឹត្តិការណ៍នាពេលអនាគត ហើយការសម្រេចនៃទំនាយទាំងនោះនៅក្នុងប្រវត្តិសាស្ត្រ គឺជាវិធីសាស្ត្រមួយ ដែលព្រះជាម្ចាស់បានបញ្ជាក់បង្ហាញពីភាពពិតនៃព្រះបន្ទូលរបស់ទ្រង់។ មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលអាចមានបន្ទូលថា “យើងបានប្រាប់ទុកជាមុន តាំងពីគ្រាដំបូងនូវហេតុការណ៍ដែលនឹងកើតមានតាមក្រោយ យើងប្រាប់ទុកជាមុនតាំងពីយូរលង់នូវហេតុការណ៍ដែលពុំទាន់កើតមាននៅឡើយ“ (អេសាយ ៤៦:១០ គខប)។ ព្រះយេស៊ូវដ៏ជាព្រះមេស្ស៊ីបានមានបន្ទូលថា "ខ្ញុំប្រាប់អ្នករាល់គ្នាតាំងពីឥឡូវនេះ មុនដែលការនោះកើតមក ដើម្បីកាលណាបានកើតមកដល់ នោះឲ្យអ្នករាល់គ្នាបានជឿថា គឺខ្ញុំនេះហើយ" (យ៉ូហាន ១៣:១៩)។ សូមអានជំពូកទី៥នៃសៀវភៅ *One God One Message*។

**ភាគទី៤១៖** [១៣]“ព្រះគ្រីស្ទ“ ជាពាក្យភាសាក្រិក ដែលបកប្រែពីពាក្យភាសាហេព្រើរ *"ព្រះមេស្ស៊ី"* គឺមានន័យថា *អ្នកដែលព្រះជាម្ចាស់រើសតាំង*។

[១៤]របៀបដាក់កាលបរិច្ឆេទនៃព្រឹត្តិការណ៍នៅក្នុងប្រវត្តិសាស្ត្រ គឺផ្អែកទៅលើឆ្នាំ ដែលព្រះយេស៊ូវគ្រីស្ទបានប្រសូត។ ឧទាហរណ៍ ហោរា អ័ប្រាហាំ បានកើតនៅខ្ទង់ឆ្នាំ២០០០ មុនគ.ស. (២០០០ឆ្នាំ *មុនព្រះគ្រីស្ទ* បានប្រសូត)។ សៀវភៅនេះ(*មហាក្សត្រដ៏មានសិរីល្អ*) ត្រូវបាននិពន្ធឡើងនៅគ.ស. ២០១១ (ជាង២០០០ឆ្នាំ *ក្រោយព្រះគ្រីស្ទ* បានប្រសូត)។ អក្សរឡាតាំងសម្រាប់ “គ.ស.“ គឺ AD ជាអក្សរកាត់នៃពាក្យ *Anno Domini* ដែលមានន័យថា “*នៅក្នុងឆ្នាំនៃព្រះអម្ចាស់របស់យើង*“។ សព្វថ្ងៃនេះ មនុស្សជាច្រើនប្រើ BCE (Before Common Era គឺមុនសម័យទូទៅ) និង CE (Common Era គឺសម័យទូទៅ) ដើម្បីដកពាក្យ “គ្រីស្ទ“ ចេញពីអក្សរកាត់នោះ ប៉ុន្តែចំណុចបែងចែកនៃប្រវត្តិសាស្ត្រ គឺនៅតែជាឆ្នាំដែលព្រះយេស៊ូវគ្រីស្ទបានប្រសូតដដែល។

**ភាគទី៤៣៖** [១៥]“«តើគាត់មិនមែនជាជាងឈើ ជាកូននៃនាងម៉ារា ហើយជាបងយ៉ាកុប យ៉ូសែប យូដាស នឹងស៊ីម៉ូនទេឬអី ហើយប្អូនស្រីគាត់ តើមិននៅជាមួយនឹងយើងនៅទីនេះទេឬអី?» អ្នកទាំងនោះក៏អាក់អន់ចិត្តនឹងទ្រង់“ (ម៉ាកុស ៦:៣)។ ដោយសារលោក យ៉ូសែប មិនមែនជាឪពុកបង្កើតរបស់ព្រះយេស៊ូវ ដូច្នេះព្រះយេស៊ូវជាប់សាច់ឈាមនឹងបងប្អូនរបស់ទ្រង់តែនៅខាងមាតាទ្រង់ប៉ុណ្ណោះ។ ព្រះយេស៊ូវ គឺជាព្រះរាជបុត្រានៃព្រះ ហើយក៏ជាកូនមនុស្សផងដែរ។ សូមអានកំណត់យោងទី១៩ (ភាគទី៥២)។

**ភាគទី៤៣ និង៥៨៖** [១៦]នៅក្នុងពិធីបុណ្យរំលងជារៀងរាល់ឆ្នាំ សាសន៍យូដាបាននឹកចាំពីព្រឹត្តិការណ៍មួយ ដែលបានកើតឡើងនៅសម័យលោក ម៉ូសេ ជាពេលដែលពួកគេបានធ្វើជាទាសករនៅក្នុងប្រទេសអេស៊ីព្ទ។ ពួកឰយុកោរបស់ពួកគេបានសម្លាប់កូនចៀម ហើយយកឈាមនោះមកលាបនៅក្របទ្វារផ្ទះរបស់ពួកគេ ពីព្រោះព្រះជាម្ចាស់បានមានបន្ទូលថា “កាលផ្ទះណាអញឃើញឈាមនោះអញនឹងរំលងផុតពីឯងរាល់គ្នាទៅ“ (និក្ខមនំ ១២:១៣)។ នៅពាក់កណ្តាលអធ្រាត្រ ព្រះជាម្ចាស់បានសម្លាប់កូនច្បងនៅគ្រប់ផ្ទះ ដែលគ្មានឈាមកូនចៀមនៅក្របទ្វារ។ ព្រះជាម្ចាស់បានប្រើព្រឹត្តិការណ៍នេះ ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់ ពីការជាប់ខ្លួនជាទាសករអស់រយៈពេល៤០០ឆ្នាំ។

**ភាគទី៤៥៖** [១៧]នៅក្នុងលោកីយ៍នេះ យើងមិនអាចយល់អំពីព្រះត្រៃឯកយ៉ាងពេញលេញបានឡើយ។ ព្រះជាម្ចាស់ទ្រង់ធំអស្ចារ្យលើសពីការយល់ដឹងរបស់យើង។ ប៉ុន្តែ រឿងមួយដែលយើងទាំងអស់គ្នាអាចយល់បាននោះ គឺថា អ្វីដែលមានបីរួមមកតែមួយ។ ពិភពលោករបស់យើងពោរពេញទៅដោយរបស់ដែលមានបីរួមមកតែមួយ ដូចជា៖ ក. **ពេលវេលា** មានអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។ ខ. **ទំហំ** មានប្រវែង ទទឹង និងកម្ពស់។ គ. **មនុស្ស** មានវិញ្ញាណ ព្រលឹង  និងរូបកាយ។ ឃ. **អាតូម** មានអេឡិចត្រុង ប្រូតុង និងនឺត្រុង។ ង. **ព្រះអាទិត្យ** របស់យើងក៏មានបីផ្នែកដែរ គឺយើងហៅភពរបស់វាថា *ព្រះអាទិត្យ* ពន្លឺរបស់វាថា *ព្រះអាទិត្យ* ហើយកំដៅរបស់វាថា *ព្រះអាទិត្យ*  ប៉ុន្តែព្រះអាទិត្យមានតែ*មួយ*។ ព្រះជាម្ចាស់ក៏យ៉ាងដូច្នោះដែរ គឺទ្រង់ជា**ព្រះវរបិតា**ដ៏អស់កល្ប **ព្រះរាជបុត្រា**ដ៏អស់កល្ប និង**ព្រះវិញ្ញាណបរិសុទ្ធ**ដ៏អស់កល្ប។ ដូចដែលពន្លឺ និងកំដៅចេញមកពីព្រះអាទិត្យជាយ៉ាងណា ព្រះរាជបុត្រា(ព្រះបន្ទូល)នៃព្រះ និងព្រះវិញ្ញាណបរិសុទ្ធនៃព្រះយាងចេញពីព្រះជាម្ចាស់យ៉ាងនោះដែរ តែទ្រង់គឺជា "ព្រះយេហូវ៉ាតែមួយអង្គគត់" (ចោទិយកថា ៦:៤ គកស១៦)។ សូមអានភាគទី៤ និងកំណត់យោងទី៥ (ភាគទី៦) ឡើងវិញ។ សម្រាប់ការស្វែងយល់បន្ថែមទៀត អំពីការរួមតែមួយដ៏ស្មុគស្មាញរបស់ព្រះជាម្ចាស់ និងអំពីព្រះយេស៊ូវដែលមាននិស្ស័យជាមនុស្សផង និងព្រះផង សូមអានជំពូកទី៩ និង១៧ ក្នុងសៀវភៅ *One God One Message* ។ ប៉ុន្តែ ដើម្បីយល់កាន់តែច្បាស់ សូមអានកណ្ឌដំណឹងល្អតាមលោក យ៉ូហាន។

# មហាក្សត្រដ៏មានសិរីល្អ
# កំណត់យោង

**ភាគទី៤៧៖** [១៨]"ព្រះមេស្ស៊ី" មានន័យថា *អ្នកដែលព្រះជាម្ចាស់រើសតាំង* ឬ តាមន័យចំ ពាក្យនេះមានន័យថា *អ្នកដែលព្រះជាម្ចាស់ចាក់ប្រេងតាំង*។ នៅតំបន់មជ្ឈិមបូព៌ានាសម័យបុរាណ នៅពេលដែលស្ដេចថ្មីត្រូវបានឡើងគ្រងរាជ្យ នោះសង្ឃ ឬហោរាបានចាក់ប្រេងពិសេសលើព្រះសិររបស់ស្ដេច ដើម្បីបង្ហាញថា ទ្រង់គឺជាអ្នកគ្រប់គ្រងថ្មីនៃនគរនោះ។ ព្រះយេស៊ូវមិនត្រូវបានចាក់ប្រេងតាំងដោយមនុស្សទេ តែដោយព្រះវិញ្ញាណបរិសុទ្ធវិញ (សូមអានភាគទី៤៥)។

**ភាគទី៥២៖** [១៩]ព្រះយេស៊ូវតែងតែហៅអង្គទ្រង់ថាជាកូនមនុស្ស។ ទ្រង់ជាព្រះរាជបុត្រានៃព្រះតាំងពីអស់កល្បមក ប៉ុន្តែទ្រង់បានក្លាយជាកូនមនុស្ស។ ក្នុងនាមជាព្រះរាជបុត្រានៃព្រះ ទ្រង់គឺជាព្រះបន្ទូលដែលគង់នៅជាមួយព្រះជាម្ចាស់ តាំងពីដើមដំបូងមក (យ៉ូហាន ១:២ និងលោកុប្បត្តិ ១:៣) ប៉ុន្តែក្នុងនាមជាកូនមនុស្ស ទ្រង់គឺជាព្រះបន្ទូលដែលបានត្រឡប់ជាសាច់ឈាម។ ព្រះអង្គនេះហើយ គឺជាអ្នកដែលព្រះជាម្ចាស់បានរើសតាំងឲ្យធ្វើជាព្រះសង្គ្រោះ ជាចៅក្រម និងជាព្រះមហាក្សត្រនៃពិភពលោក (យ៉ូហាន ១:១៤ និងដានីយ៉ែល ៧:១៣-១៤)។

**ភាគទី៥៦៖** [២០]ពួកផារិស៊ី គឺជាសមាជិកនៃនិកាយសាសនារបស់សាសន៍យូដាមួយ ដែលមានភាពខ្នះខ្នែង។ ពួកផារិស៊ីខ្លះបានអធិស្ឋាន៦ដងក្នុង១ថ្ងៃ តមអាហារ៣ខែក្នុង១ឆ្នាំ ហើយបានយក១ភាគក្នុង១០នៃប្រាក់ចំណូលទៅជួយដល់អ្នកក្រីក្រ (លូកា ១៨:៩-១៤) ប៉ុន្តែទាំងអស់នោះគ្រាន់តែជាទម្លាប់ដែលគ្មានន័យសោះឡើយ។ ពួកគេបានខិតខំប្រឹងប្រែងធ្វើតាមសាសនា តែពួកគេមិនបានស្គាល់ព្រះជាម្ចាស់ទេ ហើយក៏មិនបានស្រឡាញ់ទ្រង់ផងដែរ។

**ភាគទី៦៨៖** [២១]សម្រាប់អ្នកជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ បុណ្យជ្រមុជទឹក គឺជាការប្រកាសថា ខ្លួនបានសម្រេចចិត្តនឹងដើរតាមទ្រង់។ ការជ្រមុជក្នុងទឹកមិនមែនជាពិធីសម្រាប់លាងបាបចេញនោះទេ តែវាជារូបភាពដែលបង្ហាញថា ខ្លួនបានរួបរួមជាមួយនឹងព្រះយេស៊ូវនៅក្នុងការសុគត ការបញ្ចុះក្នុងផ្នូរ និងការរស់ឡើងវិញរបស់ទ្រង់។ បុណ្យជ្រមុជទឹកក៏បង្ហាញពីការបញ្ចប់នៃជីវិតចាស់ និងការចាប់ផ្តើមនៃជីវិតថ្មីនៅក្នុងព្រះគ្រីស្ទ។

[២២]មិនយូរប៉ុន្មានក្រោយពីព្រះរាជបុត្រានៃព្រះបានយាងឡើងទៅស្ថានសួគ៌វិញ នោះព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតក្នុងចិត្តរបស់មនុស្សប្រុសស្រី និងក្មេងគ្រប់ៗគ្នាដែលបានជឿដំណឹងល្អ។ កណ្ឌគម្ពីរកិច្ចការនៅក្នុងព្រះគម្ពីរសញ្ញាថ្មី កត់ត្រាអំពីដំណើររឿងដ៏គួរឲ្យចាប់អារម្មណ៍ ទាក់ទងនឹងការដែលព្រះវិញ្ញាណបរិសុទ្ធបានប្រទានអំណាចដល់ពួកសិស្ស ដើម្បីឲ្យពួកគេឆ្លុះបញ្ចាំងពីលក្ខណៈសម្បត្តិរបស់ព្រះយេស៊ូវគ្រីស្ទ ហើយប្រកាសព្រះបន្ទូលរបស់ទ្រង់ឲ្យបានឮសុសសាយដល់គ្រប់ជាតិសាសន៍។ ផ្លូវនៃសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ គឺមិនបានផ្លាស់ប្តូរឡើយ។ អ្នកក៏អាចទទួលព្រះវិញ្ញាណបរិសុទ្ធជាអំណោយផងដែរ ប្រសិនបើអ្នកសម្រេចចិត្តជឿព្រះបន្ទូលរបស់ទ្រង់ គឺថា អ្នកជាមនុស្សមានបាបដែលបានដាច់ចេញពីព្រះដ៏បរិសុទ្ធ និងគ្មានសង្ឃឹមនឹងជួយសង្គ្រោះខ្លួនឯងពីទោសនៃអំពើបាប ហើយជឿថា ព្រះយេស៊ូវគ្រីស្ទបានទទួលទណ្ឌកម្មជំនួសអ្នកនៅលើឈើឆ្កាង រួចត្រូវបានបញ្ចុះក្នុងផ្នូរ ហើយមានព្រះជន្មរស់ពីសុគតឡើងវិញ។ នេះមានន័យថា ព្រះមហាក្សត្រនៃសកលលោកផ្ទាល់ នឹងយាងមកគង់នៅក្នុងចិត្តរបស់អ្នក។ ទ្រង់នឹងក្លាយជាព្រះអម្ចាស់ ព្រះវរបិតា និងមិត្តសម្លាញ់ថ្មីរបស់អ្នក។ ព្រះគម្ពីរចែងថា “នៅក្នុងព្រះអង្គ អ្នករាល់គ្នាក៏បានឮព្រះបន្ទូលនៃសេចក្តីពិត ជាដំណឹងល្អពីការសង្គ្រោះរបស់អ្នករាល់គ្នា ហើយអ្នករាល់គ្នាបានជឿដល់ព្រះអង្គ បានទទួលការដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ តាមសេចក្តីសន្យា គឺព្រះវិញ្ញាណនេះហើយជាទីបញ្ចាំចិត្ត សម្រាប់មត៌ករបស់យើង រហូតទាល់តែយើងបានរបស់នោះពេញលេញជាកម្មសិទ្ធិ សម្រាប់ជាការសរសើរដល់សិរីល្អរបស់ព្រះអង្គ“ (អេភេសូរ ១:១៣-១៤ គកស១៦)។ ព្រះជាម្ចាស់ គឺជាព្រះមហាក្សត្រដ៏ធំអស្ចារ្យ ហើយទ្រង់នឹងមានគ្រួសារដ៏ធំអស្ចារ្យ ដែលរស់នៅជាមួយទ្រង់អស់កល្បជានិច្ច។ តើអ្នកនឹងបាននៅជាមួយទ្រង់ដែរឬទេ?

# ធនធានផ្សេងៗទៀត

## អង្គការអេម៉ោស កម្ពុជា

EMMAUS CAMBODIA
www.iemmaus.com

### ម៉ោងសិក្សាព្រះគម្ពីរ BIBLETIME

***ម៉ោងសិក្សាព្រះគម្ពីរ*** គឺជាកម្មវិធីសិក្សាព្រះគម្ពីរសម្រាប់កុមារ ដែលត្រូវបានរៀបចំឡើង ដើម្បីយកទៅសិក្សាដោយខ្លួនឯង ឬជាក្រុមនៅតាមផ្ទះ សាលារៀន ឬសាលាថ្ងៃអាទិត្យ។

***ម៉ោងសិក្សាព្រះគម្ពីរ*** ផ្តល់មេរៀនខ្លីៗដ៏ងាយស្រួលយល់ ព្រមទាំងសកម្មភាពដ៏គួរឲ្យចាប់អារម្មណ៍ ដែលអាចជួយពង្រឹងការយល់ដឹងរបស់អ្នកសិក្សអំពីព្រះជាម្ចាស់ និងព្រះបន្ទូល។



វគ្គសិក្សាមួយមានមេរៀនចំនួន៤សម្រាប់សិក្សាក្នុងរយៈពេលមួយខែ ហើយមានប្រធានបទ ឬតួអង្គខុសៗគ្នា ដែលដកស្រង់ចេញពីព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី។

កម្មវិធីសិក្សាទាំងមូលមានចំនួន ៣ កម្រិត ហើយកម្រិតនីមួយៗ មានមេរៀនគ្រប់គ្រាន់ ដើម្បីសិក្សាក្នុងរយៈពេល៣ឆ្នាំ៖

**មត្តេយ្យសិក្សា**
**បឋមសិក្សាកម្រិតទាប**
**បឋមសិក្សាកម្រិតខ្ពស់**

សូមប្រើប្រាស់ធនធានដ៏មានតម្លៃនេះ ដើម្បីជួយកូនៗ និងសិស្សានុសិស្សរបស់អ្នកឲ្យស្វែងយល់អំពីព្រះជាម្ចាស់ និងព្រះបន្ទូលនៅថ្ងៃនេះ!

### វគ្គសិក្សាព្រះគម្ពីរ BIBLE STUDY COURSES



Remember the Creator (ចូរនឹកចាំពីព្រះដ៏បង្កើតខ្លួន)
Lessons for Christian Living (មេរៀនសម្រាប់ជីវិតគ្រីស្ទបរិស័ទ)
Men Who Met the King (អ្នកដែលបានជួបព្រះអម្ចាស់)
What the Bible Teaches (សេចក្តីបង្រៀននៃព្រះគម្ពីរ)
Summary of the Bible (សេចក្តីសង្ខេបព្រះគម្ពីរ)
Christ Loved the Church (ព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ)
**www.iemmaus.com/resources**

អង្គការ ROCK International សូមជូនរឿង

# មហាក្សត្រដ៏មានសិរីល្អ

## ជាខ្សែភាពយន្ត

សូមអញ្ជើញទស្សនារូបភាពដ៏ស្រស់ស្អាត ដែលអមដោយការបញ្ចូលសម្លេងដ៏គួរឲ្យចាប់អារម្មណ៍
តាមសៀវភៅ *មហាក្សត្រដ៏មានសិរីល្អ*

**សាច់រឿង១ មាន២ផ្នែក៖ ទាំងអស់មាន៧០ភាគ ដែលបែងចែកជា១៥វគ្គ**

| ផ្នែកទី១ ព្រះគម្ពីរសញ្ញាចាស់៖ ព្រះមហាក្សត្រមានបន្ទូលទុកជាមុនអំពីផែនការរបស់ទ្រង់ | | ១ម៉ោង ៤៧នាទី |
|---|---|---|
| ១. សេចក្ដីផ្ដើម | *ភាគទី១-៣* | ~ ១០:៤០ |
| ២. ព្រះអាទិករ និងការបង្កើតរបស់ទ្រង់ | *ភាគទី៤-៩* | ~ ១៩:០៤ |
| ៣. ការចូលមកនៃសេចក្ដីអាក្រក់ | *ភាគទី១០-១៥* | ~ ១៥:១០ |
| ៤. បណ្ដាសានៃអំពើបាប និងសេចក្ដីសន្យារបស់ព្រះ | *ភាគទី១៦-១៩* | ~ ១១:៥៧ |
| ៥. របៀបថ្វាយយញ្ញបូជា | *ភាគទី២០-២៤* | ~ ១៤:៥៨ |
| ៦. ការបះបោររបស់មនុស្ស និងសេចក្ដីស្មោះត្រង់របស់ព្រះ | *ភាគទី២៥-២៧* | ~ ៩:០៥ |
| ៧. ផែនការរបស់ព្រះបន្តឈានទៅមុខ | *ភាគទី២៨-៣២* | ~ ១៤:០៤ |
| ៨. ក្រឹត្យវិន័យ និងទំនាយរបស់ពួកហោរា | *ភាគទី៣៣-៣៦* | ~ ១២:២០ |

| ផ្នែកទី២ ព្រះគម្ពីរសញ្ញាថ្មី៖ ព្រះមហាក្សត្របំពេញផែនការរបស់ទ្រង់ | | ១ម៉ោង ៥៥នាទី |
|---|---|---|
| ៩. ការយាងមករបស់ព្រះមហាក្សត្រ | *ភាគទី៣៧-៤២* | ~ ២០:១៦ |
| ១០. លក្ខណៈរបស់ព្រះមហាក្សត្រ | *ភាគទី៤៣-៤៧* | ~ ១៥:៣២ |
| ១១. អំណាចរបស់ព្រះមហាក្សត្រ | *ភាគទី៤៨-៥១* | ~ ១៤:០២ |
| ១២. បេសកកម្មរបស់ព្រះមហាក្សត្រ | *ភាគទី៥២-៥៦* | ~ ១៥:២៤ |
| ១៣. ការចុះចូលរបស់ព្រះមហាក្សត្រ | *ភាគទី៥៧-៦១* | ~ ១៤:៥០ |
| ១៤. ការសុគត និងជ័យជម្នះរបស់ព្រះមហាក្សត្រ | *ភាគទី៦២-៦៥* | ~ ១៣:៥៣ |
| ១៥. ដំណឹងល្អ និងសិរីល្អរបស់ព្រះមហាក្សត្រ | *ភាគទី៦៦-៧០* | ~ ១៨:២៦ |
| *ព្រះយើងធំមហិមា* (ច្រៀងជាភាសាអារ៉ាប់) | *ឈ្មោះអ្នករួមចំណែក* | ~ ២:៤៥ |

*"ភាពយន្តនេះបានពន្យល់ឲ្យខ្ញុំងាយស្រួលយល់។" - ប្អូនប្រុស អេលី អាយុ៧ឆ្នាំ*
*"ខ្ញុំមានអារម្មណ៍ដូចជាខ្ញុំបាននៅទីនោះក្នុងសាច់រឿងទាំងមូល។" - ប្អូនស្រី លីឌា អាយុ២១ឆ្នាំ*
*"ភាពយន្តនេះបានពន្យល់អំពីការបើកសម្ដែងដ៏ជ្រៅបំផុត ក្នុងលក្ខណៈដ៏សាមញ្ញ តែមានអំណាច!" - លោក ឌីក អាយុ៧៤ឆ្នាំ*

**ចូរទស្សនា**
**ខ្សែភាពយន្តតាមវគ្គ**

១ ២ ៣ ៤ ៥

៦ ៧ ៨ ៩ ១០

១១ ១២ ១៣ ១៤ ១៥

**www.ikingofglory.com**